**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ចៅ.ស (អ.ប.ជ ៦១) |
| ភាគីដាក់ឯកសារ៖ | មេធាវីការពារក្តីរបស់ យឹម ទិត្យ |
| ដាក់ជូន៖ | អង្គបុរេជំនុំជម្រះ |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ |

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 17-Feb-2020, 15:49
CMS/CFO: Sann Rada

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ចៅ.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយ**

**របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤**

---

**<u>ដាក់ដោយ៖</u>**

**សហមេធាវី៖**

សូ មូស្សេទ្ធី

Suzana TOMANOVIĆ

**<u>ផ្ញើជូន៖</u>**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

ចៅក្រមបម្រុង Steven J. BWANA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

# មាតិការឿង

**សេចក្ដីផ្ដើម** ........................................ 6

**ប្រវត្តិនីតិវិធី** ........................................ 6

**ច្បាប់ជាធរមាន** ........................................ 8

**ភាពអាចទទួលយកបាន** ........................................ 9

**បទដ្ឋាននៃការពិនិត្យលើបណ្ដឹងឧទ្ធរណ៍** ........................................11

**មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍** ........................................13

I. មូលដ្ឋានទី ១៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយរំលោភសិទ្ធិជាសារវ័ន្តរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយបើកកិច្ចស៊ើបសួរ និងចេញដីកាបញ្ជូនទៅជំនុំជម្រះ ក្នុងកាលៈទេសៈដែលពុំអាចមានការជំនុំជម្រះដោយយុត្តិធម៌ ........................................ 13

ក. មូលដ្ឋានរង ១.១៖ ស.ច.ស.អ មិនបានពិចារណាទៅលើសុពលភាពនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ........................................ 14

ខ. មូលដ្ឋានរង ១.២៖ មិនអាចមានការជំនុំជម្រះដោយយុត្តិធម៌ ........................................ 17

(i) ការជ្រៀតជ្រែកយ៉ាងមានប្រសិទ្ធភាពទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ........................................ 18

(ii) ការពន្យារពេលមិនត្រឹមត្រូវ ........................................ 32

គ. សេចក្ដីសន្និដ្ឋាន ........................................ 43

II. មូលដ្ឋានទី ២៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ក្នុងការចេញដីកាដំណោះស្រាយ ដែលត្រូវចាត់ទុកជាមោឃៈ ដោយមានកំហុសនីតិវិធី ដោយសារខកខានមិនបានកំណត់ច្បាប់ឱ្យបានត្រឹមត្រូវ និងមិនបានយោងទៅលើការវិភាគលើភ័ស្ដុតាងក្នុងការសម្រេចរបស់ខ្លួនទៅលើយុត្តាធិការបុគ្គល ........................................ 45

ក. លក្ខខណ្ឌតម្រូវតាមវិធាន ៦៧ (២) សម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនៅ អ.វ.ត.ក ........................................ 46

ខ. មូលដ្ឋានរងទី ២.១៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយខកខានមិនបានរៀបរាប់ពីការពិចារណាដែលពាក់ព័ន្ធ ដែលត្រូវប្រើប្រាស់ ដើម្បីវាយតម្លៃលើតួនាទីរបស់លោក យឹម ទិត្យ ជាបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" ........................................ 48

គ. មូលដ្ឋានរងទី ២.២៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនកំណត់ឱ្យបានត្រឹមត្រូវពីធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងខកខានមិនយោងទៅលើការវិភាគលើភ័ស្ដុតាងនៅក្នុងសំអាងច្បាប់របស់ខ្លួនស្ដីពីយុត្តាធិការបុគ្គល ........................................ 49

(i) ស.ច.ស.អ ខកខានមិនបានអនុវត្តតាមវិធាន ៦៧ (២) ក្នុងការយល់ឃើញថា ខ្មែរក្រោម គឺជា "ក្រុមពិសេស" មួយ ស្ថិតក្នុងអត្ថន័យនៃធាតុផ្សំសត្យានុម័តនៃអំពើប្រល័យពូជសាសន៍ ........................................ 51

(ii) ស.ច.ស.អ ខកខានមិនបានកំណត់ពីអង្គហេតុ និងបទចោទ ដើម្បីបញ្ជាក់ពីធាតុផ្សំនៃចេតនាជាក់លាក់ ........ 56

ឃ. មូលដ្ឋានរងទី ២.៣៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនបានកំណត់ឲ្យបានត្រឹមត្រូវពីធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ និងខកខានមិនបានយោងទៅលើការវិភាគភ័ស្តុតាងនៅក្នុងសំអាងច្បាប់ស្តីពីយុត្តាធិការបុគ្គល ........ 61

(i) ស.ច.ស.អ ខកខានមិនលើកឡើងពីតម្រុយផ្សេងៗដែលជាលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងដោយប្រសិទ្ធភាព ........ 62

(ii) ស.ច.ស.អ ខកខានមិនបានលើកឡើងអំពីលក្ខខណ្ឌតម្រូវនៃភ័ស្តុតាងបង្ហាញពីទំនាក់ទំនងហេតុ និងបច្ច័យរវាងការខកខានរបស់ថ្នាក់លើក្នុងការគ្រប់គ្រងលើអ្នកនៅក្រោមបង្គាប់ និងការកើតឡើងនៃឧក្រិដ្ឋកម្ម ........ 69

ង. សេចក្តីសន្និដ្ឋាន ........ 72

III. មូលដ្ឋានទី ៣៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារបានពង្រីកវិសាលភាពអង្គហេតុនៅក្នុងកិច្ចស៊ើបសួរ ........ 72

ក. វិធាន ៥៥(២) កម្រិតវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ........ 72

ខ. ដីកាដំណោះស្រាយរបស់ ស.ច.ស.អ ពង្រីកហួសវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលច្បាប់អនុញ្ញាត ........ 74

(i) ក្រោយ "ដើមឆ្នាំ១៩៧៨" នៅក្នុងភូមិភាគនិរតី ........ 75

(ii) មុនបំណាច់ឆ្នាំ១៩៧៥ នៅមន្ទីរសន្តិសុខវត្តព្រះធាតុក្នុងភូមិភាគនិរតី ........ 76

(iii) នៅមុន "ពាក់កណ្តាលឆ្នាំ១៩៧៧" នៅក្នុងភូមិភាគពាយ័ព្យ ........ 76

គ. សេចក្តីសន្និដ្ឋាន ........ 77

IV. មូលដ្ឋានទី ៤៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារបានប្រើប្រាស់ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ជាមូលដ្ឋានសម្រាប់កត្តាពាក់ព័ន្ធ ដើម្បីវាយតម្លៃលើយុត្តាធិការបុគ្គល ........ 78

ក. ភាពអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) និងវិធាន ២១ ........ 78

ខ. ស.ច.ស.អ មានកំហុស ដោយបានប្រើប្រាស់សហឧក្រិដ្ឋកម្មរួម យកមកបង្ហាញពីយុត្តាធិការបុគ្គល 80

គ. សេចក្តីសន្និដ្ឋាន ........ 87

V. មូលដ្ឋានទី ៥ ៖ ស.ច.ស.អ មានកំហុសអង្គហេតុ និងអង្គច្បាប់ ចំពោះការសម្រេចថា លោក យឹម ទិត្យ គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" និងស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ........ 88

ក. មូលដ្ឋានរងទី ៥.១៖ ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា ទំនាក់ទំនងសាច់ញាតិរបស់ លោក យឹម ទិត្យ ជាមួយនឹង តាម៉ុក មានន័យស្មើនឹងការសន្និដ្ឋានអំពីសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ និងថា លោក យឹម ទិត្យ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ........ 89

ខ. មូលដ្ឋានរងទី ៥.២៖ ស.ច.ស.អ មានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសន្និដ្ឋានថា លោក យឹម ទិត្យ មានមុខតំណែងផ្លូវការ ឬមានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងថា គាត់គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម.......................... 101

(i) ស.ច.ស.អ មានកំហុសឆ្គងដែលសន្និដ្ឋានថា លោក យឹម ទិត្យ គឺជា "មេដឹកនាំស្រុកគិរីវង់"............ ........................................................................................................ 101

(ii) ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ មាន "សិទ្ធិអំណាចជាក់ស្ដែងច្រើន" ទូទាំងតំបន់១៣ ........................................................................................ 105

(iii) ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ ជាលេខាតំបន់១...................... 112

(iv) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាលេខាតំបន់៣ ........................................................................................ 127

(v) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាលេខាតំបន់៤ ........................................................................................ 133

(vi) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ........................................................................ 136

គ. មូលដ្ឋានរង ៥.៣៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសម្រេចថា លោក យឹម ទិត្យ បានរួមចំណែកចំពោះសហឧក្រិដ្ឋកម្មរួម........................................ 145

(i) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ក........................................................................ 146

(ii) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ខ ........................................................................ 163

(iii) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម គ........................................................................ 167

ឃ. ការសន្និដ្ឋាន ........................................................................................ 181

**សេចក្ដីសន្និដ្ឋាន........................................................................................ 182**

**ដំណោះស្រាយ ........................................................................................ 183**

## សេចក្ដីផ្ដើម

១. អនុលោមតាមវិធាន ២១, ៦៧(៥) និង ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង ("វិធាន") លោក យឹម ទិត្យ តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្ដី") សូមដាក់ *បណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤* ("បណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយរបស់ ស.ច.ស.អ") ដោយស្នើសុំអង្គបុរេជំនុំជម្រះ ("អ.ប.ជ") បដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះជាស្ថាពរ និងលើកលែងចោទប្រកាន់ប្រឆាំងនឹង លោក យឹម ទិត្យ។ បណ្ដឹងឧទ្ធរណ៍នេះចាំបាច់ត្រូវធ្វើឡើង ដោយសារតែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ("ស.ច.ស.អ") មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ ជា "បុគ្គលទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ។ ជាពិសេស ស.ច. ស.អ (១) មានកំហុសអង្គច្បាប់ដោយរំលោភទៅលើសិទ្ធិជាសារវ័ន្តរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយបើកកិច្ចស៊ើបសួរ និងចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងកាលៈទេសៈដែលមិនអាចមានការជំនុំជម្រះដោយយុត្តិធម៌បាន (២) មានកំហុសអង្គច្បាប់ដោយចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលគ្មានសុពលភាពចំពោះកំហុសផ្នែកនីតិវិធី ដោយសារតែគាត់ពុំបានកំណត់ពីអង្គច្បាប់ឲ្យបានត្រឹមត្រូវ និងយោងទៅការវិភាគលើភ័ស្តុតាងនៅក្នុងការយល់ឃើញរបស់ខ្លួនស្ដីពីយុត្តាធិការបុគ្គល (៣) មានកំហុសអង្គច្បាប់ដោយប្រព្រឹត្តហួសពីវិសាលភាពនៃការស៊ើបអង្កេតជាក់ស្ដែង (៤) មានកំហុសអង្គច្បាប់ដោយប្រើប្រាស់ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមថាជាកត្តាពាក់ព័ន្ធ ដើម្បីវាយតម្លៃអំពីយុត្តាធិការបុគ្គល និង (៥) មានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការយល់ឃើញថា លោក យឹម ទិត្យ គឺជា "បុគ្គលទទួលខុសត្រូវខ្ពស់បំផុត" ហេតុនេះ គាត់ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក។

## ប្រវត្តិនីតិវិធី

២. មេធាវីការពារក្ដីសូមដាក់បញ្ចូលដោយយោងទៅប្រវត្តិនីតិវិធីដែលមាននៅក្នុង *ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* ("ចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ")[1]។

---

[1] ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5 កថាខណ្ឌ ១៤ ដល់ ១០៥។

៣. នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ សហចៅក្រមស៊ើបអង្កេតជាតិ ("ស.ច.ស.ជ") បានចេញ *ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ* ("ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ") ជាភាសាខ្មែរ[2] ហើយ ស.ច.ស.អ បានចេញ*ដីកាដំណោះស្រាយ* របស់ខ្លួន ("ដីកាដំណោះស្រាយរបស់ ស.ច.ស.អ") ជាភាសាអង់គ្លេស[3]។

៤. ការបកប្រែជាភាសាអង់គ្លេសនៃដីកាដំណោះស្រាយរបស់ ស.ច.ស.ជ ត្រូវបានចេញនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៩។ ដោយសារមានភាព "ខុសឆ្គងដែលអាចមើលឃើញយ៉ាងងាយ" ក្នុងការបកប្រែ សំណៅកែប្រែមួយត្រូវបានជូនដំណឹងនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៩[4]។

៥. អនុលោមតាមការពន្យារពេលវេលានៃសេចក្ដីជូនដំណឹងដែល អ.ប.ជ បានអនុញ្ញាត[5] មេធាវីការពារក្ដីបានដាក់ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងដីកាដំណោះស្រាយ នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩[6]។

៦. នៅថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ មេធាវីការពារក្ដីបានដាក់ *សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួន*

---

[2] ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381 ("ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ")។

[3] ដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382 ("ដីកាដំណោះស្រាយរបស់ ស.ច.ស.អ")។

[4] សេចក្ដីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំឱ្យអង្គបុរេជំនុំជម្រះបង្គាប់បញ្ជាបន្ទាន់ឱ្យផ្ដល់នូវការបកប្រែដោយត្រឹមត្រូវជាភាសាអង់គ្លេស នូវដីកាសម្រេចលើកលែងចោទប្រកាន់ចំពោះ យឹម ទិត្យ និងផ្អាកកាលបរិច្ឆេទកំណត់នៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយ ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/12 និង D382/13 កថាខណ្ឌ ៨។ សូមមើលផងដែរ៖សេចក្ដីសម្រេចលើសំណើរបស់យឹម ទិត្យ សុំបន្ថែមចំនួនទំព័រនិងពេលវេលាកំណត់សម្រាប់បណ្ដឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និង D382/19 ទំព័រ ៤-៥។

[5] សេចក្ដីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំពន្យារកាលបរិច្ឆេទសម្រាប់ការជូនដំណឹងអំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៩ ឯកសារ D381/3 និង D382/3។

[6] ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ដោយបានជូនដំណឹងជា៖ ការជូនដំណឹងពីបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់របស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/7 និង ការជូនដំណឹងរបស់ យឹម ទិត្យ អំពីបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D382/9។

*ទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*[7]។

៧. នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ស.ព.អ បានដាក់ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*[8]។

៨. នៅថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់ *ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ*[9]។

៩. នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ អ.ប.ជ បានចេញ *សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤* របស់ខ្លួន ដែលអង្គជំនុំជម្រះបានផ្តល់រយៈពេល ៤៥ ថ្ងៃ ចាប់គិតពីការជូនដំណឹងពីសំណៅបកប្រែជាភាសាអង់គ្លេសដែលបានកែតម្រូវ នៃដីកាដំណោះស្រាយរបស់ ស.ច.ស.ជ ដល់ភាគីក្នុងការដាក់បណ្តឹងឧទ្ធរណ៍របស់ខ្លួន និងបានបង្គាប់ឲ្យភាគីដាក់បណ្តឹងឧទ្ធរណ៍ដោយឡែកពីគ្នាជំទាស់ទៅនឹងដីកាដំណោះស្រាយ ជាឯកសារពីរដាក់ដោយឡែកពីគ្នា[10]។

## ច្បាប់ជាធរមាន

១០. ច្បាប់ជាធរមានចំពោះមូលដ្ឋាននីមួយៗនៃបណ្តឹងត្រូវបានបង្ហាញដូចខាងក្រោម។

---

[7] សំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/8។

[8] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ ឯកសារ D381/13។

[9] ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់ សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/15។

[10] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និង D382/19 ទំព័រ ៤-៥។

## ភាពអាចទទួលយកបាន

១១. បណ្តឹងឧទ្ធរណ៍អាចទទួលយកបានទៅតាមវិធាន ២១ វិធាន ៦៧(៥) និង វិធាន ៧៤។

១២. វិធាន ៦៧(៥) ចែងថា ដីកាដំណោះស្រាយបើកផ្លូវប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤។ វិធាន ៧៤(៣) រៀបរាប់នូវដីកា និងសេចក្តីសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេត ("ស.ច.ស") ដែលមេធាវីការពារក្តីអាចប្តឹងឧទ្ធរណ៍បាន។ ជាពិសេស វិធាន ៧៤(៣)(ក) អនុញ្ញាតឱ្យមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងដីកា "បញ្ជាក់ពីយុត្តាធិការរបស់ អ.វ.ត.ក"។ ចំណុចនេះពង្រីកវិសាលភាពដល់សេចក្តីសម្រេចទាំងអស់ដែលពាក់ព័ន្ធនឹង យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការលើរឿងក្តី។

១៣. វិធាន ២១ ចែងអំពីលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះដោយយុត្តិធម៌ដែល អ.វ.ត.ក មានកាតព្វកិច្ចត្រូវអនុវត្តតាមមាត្រា ១៣(១) នៃ *កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ* ("កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក")[11]។ ទោះបី វិធាន ២១ មិនបានចែងច្បាស់ពីមូលដ្ឋានសម្រាប់បណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏ អ.ប.ជ បានសម្រេចថា អង្គជំនុំជម្រះមាន "សមត្ថកិច្ចធ្វើការពិចារណាលើមូលដ្ឋាននានាដែលបានលើកឡើងដោយម្ចាស់បណ្តឹងឧទ្ធរណ៍ ដែលមិនត្រូវបានរៀបរាប់ច្បាស់លាស់ក្រោមវិធាន ៧៤(៣) នៃវិធានផ្ទៃក្នុង តាមរយៈការបកស្រាយដោយសេរីអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង" ដើម្បីធានាថា កិច្ចដំណើរការនីតិវិធីដោយយុត្តិធម៌ និងចំពោះមុខ[12]។ អ.ប.ជ បានសន្និដ្ឋានថា វិធាន ២១ អាចពង្រីកវិសាលភាពនៃវិធាន ៧៤ ទៅតាមករណីជាក់ស្តែងនីមួយៗ នៅពេលដែល (១) ស្ថានភាពដែលកំពុងពិភាក្សាពុំមានចែងក្នុងវិធាន (២) បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹង

---

[11] សូមមើលឧទាហរណ៍៖ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៧។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាសម្រេចបដិសេធសំណើរបស់គាត់សុំការបំភ្លឺ ចុះថ្ងៃទី ១៣ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារD205/1/1/2 កថាខណ្ឌ ៧។

[12] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ៧១។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/15 កថាខណ្ឌ ១៨។

ដីកាបញ្ជូនទៅជំនុំជម្រះលើកឡើងនូវបញ្ហានានាដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចកែប្រែបាន និង (៣) កាលៈទេសៈពិសេសនៃរឿងក្តីតម្រូវឱ្យមានអន្តរាគមន៍ពី អ.ប.ជ ដើម្បីបញ្ចៀសកុំឱ្យមានព្យសនកម្មដែលមិនអាចជួសជុលបាន ចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ជនត្រូវចោទ[13]។ មេធាវីការពារក្តីសូមបញ្ចូលសារណារបស់ខ្លួនស្តីពីការបំពានលើមាត្រា ២១ ទៅក្នុងមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធខាងក្រោម។

១៤. មេធាវីការពារក្តីសូមដាក់ *បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយរបស់ ស.ច.ស.អ* ដោយឡែកនេះ ដើម្បីលើកឡើងពីមូលដ្ឋានទាំងអស់នៃបណ្តឹងឧទ្ធរណ៍ដែលដាច់ពីគ្នាទាំងផ្លូវច្បាប់ និងនីតិវិធីពីដីកាដំណោះស្រាយរបស់ ស.ច.ស.ជ តាមការណែនាំរបស់ អ.ប.ជ[14]។ ដោយគិតទៅដល់ការព្រួយបារម្ភរបស់ អ.ប.ជ អំពីប្រសិទ្ធភាពតាមផ្លូវតុលាការ និងនីតិវិធី ជាពិសេស គឺថា សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយផ្សេងពីគ្នាអាចតម្រូវឱ្យមានជំហានខុសគ្នាផ្នែកនីតិវិធីនោះ មេធាវីការពារក្តីសូមដាក់ *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ* របស់ខ្លួន ដោយមានមូលដ្ឋានបណ្តឹងឧទ្ធរណ៍តែមួយដែលពាក់ព័ន្ធនឹងដីកាដំណោះស្រាយទាំងពីរ[15]។ កំហុសអង្គច្បាប់នៅក្នុង *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ* កើតមានដូចគ្នាពីដីកាដំណោះស្រាយទាំងពីរ ជំនួសឱ្យការបំបែកនៃកិច្ចដំណើរការនីតិវិធីដោយការចេញដីកាដំណោះស្រាយទាំងពីរ ហើយតម្រូវឱ្យមានការដោះស្រាយរួមគ្នាដោយច្រានចោលដីកាដំណោះស្រាយទាំងពីរដែលមានកំហុសឆ្គង។

---

[13] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៨។ សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ ឯកសារ D427/4/15 កថាខណ្ឌ ១៨។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៧។

[14] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និង D382/19 ទំព័រ ៥។

[15] សេចក្តីសម្រេចលើសំណើរបស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ខ្លួនប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ឯកសារ D381/16 និង D382/19 កថាខណ្ឌ ១២។

## បទដ្ឋាននៃការពិនិត្យលើបណ្តឹងឧទ្ធរណ៍

១៥. អ.ប.ជ យល់ឃើញថា អង្គជំនុំជម្រះអាចបដិសេធសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិរបស់ ស.ច.ស ដែល (១) ផ្អែកលើការបកស្រាយច្បាប់ជាមូលដ្ឋានមិនត្រឹមត្រូវ ដែលជាកំហុសអង្គច្បាប់ ដែលនាំឱ្យសេចក្តីសម្រេចនោះគ្មានសុពលភាព (២) ផ្អែកលើការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវច្បាស់ក្រឡែត ដែលជាកំហុសអង្គហេតុ ដែលបណ្តាលឱ្យមានភាពមិនយុត្តិធម៌ ឬ (៣) មានភាពអយុត្តិធម៌ ឬមិនសមហេតុសមផល ដែលជាការបំពានឆន្ទានុសិទ្ធិរបស់ ស.ច.ស និងបង្ខំឱ្យធ្វើការសន្និដ្ឋាន ដោយពួកគាត់មិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឱ្យបានប្រយ័ត្នប្រយែង[16]។ ហេតុនេះ អ.ប.ជ បានយល់ឃើញថា "ត្រូវបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេតមានកំហុស ឬមានការបំពារបំពាន ដែលមានអានុភាពទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន"[17]។

១៦. ស្របទៅនឹងយុត្តិសាស្ត្រអន្តរជាតិដែលបានបង្កើតឡើង អ.ប.ជ យល់ឃើញថា "ការភ័ន្តច្រឡំអង្គច្បាប់ដែលបានលើកឡើងត្រូវបានពិនិត្យមើល *ជាថ្មី* ដើម្បីសម្រេចថាតើសេចក្តីសម្រេចផ្លូវច្បាប់មានលក្ខណៈត្រឹមត្រូវដែរឬទេ" និង "ការភ័ន្តច្រឡំអង្គហេតុត្រូវបានពិនិត្យមើល ស្របតាមបទដ្ឋានស្តីពីភាពសមស្រប ដើម្បីសម្រេចថា តើពុំមានអ្នកវិនិច្ឆ័យសេចក្តីអង្គហេតុដែលសមស្របបានធ្វើសំអាងផ្អែកអង្គហេតុដែលបានលើកឡើងដែរឬទេ"[18]។ ចំណុចនេះរួមមាន ការវាយតម្លៃថាតើចៅក្រមបានផ្តល់ទម្ងន់ដល់សេចក្តីកត្តាដែលគ្មានទំនាក់ទំនង ឬមិនពាក់ព័ន្ធ ឬ មិនបានផ្តល់ទម្ងន់ឱ្យបានគ្រប់គ្រាន់ដល់កត្តាដែលពាក់ព័ន្ធ[19]។

១៧. នៅពេលធ្វើការវាយតម្លៃលើអង្គហេតុថាតើ លោក យឹម ទិត្យ គឺជាបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត" នៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ឬយ៉ាងណានោះ ស.ច.ស.អ ត្រូវធ្វើការសន្និដ្ឋានបែប

---

[16] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២១។

[17] ដូចយោងខាងលើកថាខណ្ឌ ២០ ដល់ ២២៖ បទដ្ឋានទាំងនេះអនុវត្តចំពោះសេចក្តីសម្រេចឆន្ទានុសិទ្ធិទាំងអស់របស់ ស.ច.ស។

[18] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ១១៣។

[19] សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំស្វែងរកភ័ស្តុតាងដោះបន្ទុក នៅក្នុងឃ្លាំងផ្ទុកឯកសាររួម ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០០៩ ឯកសារ D164/3/6 កថាខណ្ឌ ២៥។

នេះផ្អែកតាមបទដ្ឋាននៃភ័ស្តុតាងពី *"ភវនីយភាព"*[20]។ បទដ្ឋាននៃភវនីយភាពកំណត់ថា សម្ភារៈជាភ័ស្តុតាងនៅក្នុងសំណុំរឿង ត្រូវតែមានភាពខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភ័ស្តុតាងបន្ទាល់[21]។ ហេតុនេះ អ.ប.ជ ត្រូវពិនិត្យថាតើ ស.ច.ស បានអនុវត្តបទដ្ឋាននៃភ័ស្តុតាងត្រឹមត្រូវឬយ៉ាងណា[22]។

១៨. នៅពេលដែលការយល់ឃើញលើអង្គហេតុសំខាន់ផ្អែកលើការសន្និដ្ឋានចេញពីភ័ស្តុតាងប្រយោល ឬនៅពេលមានភ័ស្តុតាងផ្ទុយ ការយល់ឃើញនោះត្រូវតែជាការសន្និដ្ឋានសមហេតុសមផលតែមួយគត់ដែលអាចទាញចេញពីភ័ស្តុតាង។ ស.ច.ស.អ មិនអាចសំអាងការយល់ឃើញរបស់ខ្លួនដោយពឹងផ្អែកទៅលើសេចក្តីសន្និដ្ឋានសមហេតុសមផល *មួយ* ដែលកើតចេញពីភ័ស្តុតាងនោះទេ។ ផ្ទុយទៅវិញ សេចក្តីសន្និដ្ឋាននានាដែលពាក់ព័ន្ធនឹងការវាយតម្លៃរបស់ ស.ច.ស.អ អំពីឋានៈរបស់លោក យឹម ទិត្យ ថាជាបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត" និងនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវតែជាសេចក្តីសន្និដ្ឋានសមហេតុសមផល *តែមួយគត់* ដែលមាន ដោយផ្អែកលើភ័ស្តុតាងនៅចំពោះមុខ ស.ច.ស.អ[23]។ ប្រសិនបើមានសេចក្តីសន្និដ្ឋានមួយផ្សេងទៀតដែលអាចធ្វើឡើងដោយសមហេតុសមផលពីភ័ស្តុតាង ហើយផ្តល់ជាយោបល់ថា លោក យឹម ទិត្យ មិនមែនជាបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត" នោះ ត្រូវអនុវត្តគោលការណ៍ *វិមតិសង្ស័យបានជាប្រយោជន៍ជនជាប់ចោទ*[24] ហើយត្រូវលើកលែងការចោទប្រកាន់លោក យឹម ទិត្យ។

១៩. ការវិភាគរបស់ អ.ប.ជ ពីភាពសមហេតុសមផលនៃការយល់ឃើញលើអង្គច្បាប់របស់ ស.ច.

---

[20] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ២៥។

[21] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ៦១។

[22] ដូចយោងខាងលើ កថាខណ្ឌ ៦៣។

[23] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តីរដ្ឋអាជ្ញា ទល់នឹង Stakić (សំណុំរឿងលេខ IT-97-24-A) សាលដីកា ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២១៩។

[24] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ២៦ ដល់ ៣៨។ សូមមើលផងដែរ៖ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១ និង ៣០១៤។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២២។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១។

ស.អ[25] ត្រូវពិចារណាមិនត្រឹមតែទៅលើភស្តុតាងដែលយកមកសំអាងប៉ុណ្ណោះទេ តែក៏ពិចារណាទៅលើការផ្តល់សំអាងហេតុ ដើម្បីពន្យល់ពីការវិភាគលើភស្តុតាងផងដែរ[26]។ នៅពេលដែលភស្តុតាងគាំទ្រមានភាពទន់ខ្សោយ ឬមានភស្តុតាងផ្ទុយផ្សេងទៀត ស.ច.ស.អ ត្រូវផ្តល់ការពន្យល់ពេញលេញ និងសមហេតុផល ពាក់ព័ន្ធនឹងរបៀប និងមូលហេតុ ដែលគាត់យល់ថាភស្តុតាងនោះអាចជឿជាក់បានគ្រប់គ្រាន់ ដែលបំពេញទៅតាម "បទដ្ឋាននៃភវនីយភាព"។ ភាពខ្វះចន្លោះ ឬការដែលពុំមានការពន្យល់បែបនេះ តម្រូវឲ្យមានការសន្និដ្ឋានថា អ្នកវិនិច្ឆ័យលើអង្គហេតុដែលមិនលម្អៀង មិនអាចយល់ឃើញដូច ស.ច.ស.អ ឡើយ។ អ.ប.ជ ត្រូវជឿជាក់ថា ការយល់ឃើញលើអង្គហេតុដែលផ្អែកលើបទដ្ឋាននៃ "ភវនីយភាព" ត្រូវមានភាពច្បាស់លាស់ និងមានមូលដ្ឋានត្រឹមត្រូវ ទាំងភស្តុតាង និងសនិទានភាព[27]។

## មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍

### I. មូលដ្ឋានទី ១៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយរំលោភសិទ្ធិជាសារវ័ន្តរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយបើកកិច្ចស៊ើបសួរ និងចេញដីកាបញ្ជូនទៅជំនុំជម្រះ ក្នុងកាលៈទេសៈដែលពុំអាចមានការជំនុំជម្រះដោយយុត្តិធម៌

២០. ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយមិនពិចារណាទៅលើសុពលភាពនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ដែលធ្វើឲ្យលោក យឹម ទិត្យ មិនអាចទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយសារមានការជ្រៀតជ្រែកទៅលើរដ្ឋបាលតុលាការ និងការពន្យារពេលនីតិវិធីដោយឥតចាំបាច់។ មូលដ្ឋានបណ្តឹងឧទ្ធរណ៍នេះលើកឡើងពីបញ្ហានានា ដែលអង្គជំនុំជម្រះសាលាដំបូងមិនអាចកែតម្រូវបាន និងកាលៈទេសៈពិសេសៗនៃសំណុំរឿង ០០៤ ដែលតម្រូវឲ្យ អ.ប.ជ ធ្វើអន្តរាគមន៍ ដើម្បីបញ្ចៀសព្យសនកម្មដែលមិនអាចជួសជុលបាន ដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក យឹម ទិត្យ។ មាត្រា ១២ និង ១៣ នៃកិច្ចព្រមព្រៀង

---

[25] ខាងលើ កថាខណ្ឌ ១៦។

[26] វិធាន ៦៧(៤)។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ៦៣។

[27] ដូចយោងខាងលើ។

រវាង អ.ស.ប និង រ.រ.ក និងមាត្រា ៣៣ថ្មី និង ៣៥ថ្មី នៃ*ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើង នៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* ("ច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក") តម្រូវឱ្យ អ.វ.ត.ក ត្រូវប្រកាន់ខ្ជាប់ទៅនឹងសិទ្ធិនានាដែលមានចែងក្នុងមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ('ICCPR') ដែលកម្ពុជាជាភាគី។ សិទ្ធិទាំងនេះរួមមាន ការជំនុំជម្រះដោយ "ឱ្យសាលាក្ដីមានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង" ដោយមិនពន្យារពេល។ វិធាន ២១ ឆ្លុះបញ្ចាំងពីវិធានជាសារវន្តនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាអន្តរជាតិ និងតម្រូវថា "ដំណើរការនីតិវិធីនៅ អ.វ.ត.ក ត្រូវតែមានយុត្តិធម៌" និង "ការសម្រេចសេចក្ដីលើការចោទប្រកាន់ក្នុងរយៈពេលមួយសមស្រប"។ លើសពី នេះទៀត ដោយមិនបានពិចារណាទៅលើទឡ្ហីករណ៍របស់លោក យឹម ទិត្យ ក្នុងចំណុចនេះ ដែល ត្រូវបានលើកឡើងនៅក្នុងចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ[28] ស.ច.ស.អ ក៏បានរំលោភបំពានទៅលើសិទ្ធិរបស់គាត់ក្នុងការឆ្លើយតបនៅក្នុងដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី ដូច ដែល អ.ប.ជ ធ្លាប់បានទទួលស្គាល់ពីមុនមក[29]។ ដោយសារការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក យឹម ទិត្យ មូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍នេះអាចទទួលបាន អនុលោមតាមវិធាន ២១[30]។

## ក. មូលដ្ឋានទី ១.១៖ ស.ច.ស.អ មិនបានពិចារណាទៅលើសុពលភាពនៃការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤

២១. នៅក្នុងចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ មេធាវីការពារក្ដីជំទាស់ថា ស.ច.ស មានកាតព្វកិច្ចកំណត់អំពីសុពលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ហើយថា ដោយសារដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ និង ការស៊ើបអង្កេតនា

---

[28] ចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ៤២៩។

[29] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងទៅនឹងសេចក្ដីសម្រេចរបស់ ស.ច.ស បដិសេធមិនទទួលយកការដាក់ឯកសារចម្លើយតបរបស់លោក អៀង សារី ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ និងសេចក្ដីសង្កេតបន្ថែម និងសំណើសុំផ្អាកដំណើរការនីតិវិធី ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D390/1/2/4 កថាខណ្ឌ ១៦ និង ១៨។

[30] ខាងលើ កថាខណ្ឌ ១៣។

ពេលបន្ទាប់ ពុំមានសុពលភាពនោះ សំណុំរឿង 00៤ ត្រូវលើកលែងចោទប្រកាន់[31]។ ស.ច.ស.អ ផ្ទាល់បានកត់សម្គាល់ថា "ការចោទប្រកាន់ថាមិនមានដីកាសន្និដ្ឋានដែលបានដាក់ត្រឹមត្រូវទេ នៅតែជាបញ្ហាមួយ ដែលចៅក្រមទាំងអស់ត្រូវតែដោះស្រាយជាភារកិច្ចរបស់ខ្លួន និងនៅដំណាក់កាលណាក៏ដោយនៃកិច្ចដំណើរការនីតិវិធី"[32]។ ស្រដៀងគ្នាដែរ ចៅក្រមភាគច្រើននៅ អ.ប.ជ បានសម្រេចថា "ផលវិបាកនៃការរំលោភខាងលើ [ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក កិច្ចព្រមព្រៀង និងវិធានផ្ទៃក្នុង តាមរយៈការបើកកិច្ចស៊ើបសួរបឋមជាឯកតោភាគី] អាចមាននៅក្នុងដំណើរការនីតិវិធីនៅដំណាក់កាលក្រោយមកទៀត"[33]។ ផ្ទុយពីការយល់ឃើញរបស់គាត់ផ្ទាល់ និងការយល់ឃើញរបស់ អ.ប.ជ ស.ច.ស.អ មិនបានលើកឡើងពីបញ្ហាថាតើ ស.ច.ស បានទទួលការស៊ើបអង្កេតស្របច្បាប់ទៅក្នុងសំណុំរឿង 00៤ ឬយ៉ាងណា ហើយពេលនេះ អ.ប.ជ ត្រូវពិចារណាទៅលើផលវិបាកផ្លូវច្បាប់នៃការស៊ើបអង្កេតនោះ។

២២. មាត្រា ១ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក ទាមទារឱ្យមាន "កិច្ចសហការ" រវាងភាគីជាតិ និងភាគីអន្តរជាតិ ចំណែកឯមាត្រា ៦ ចែងឱ្យមានកិច្ចសហការរវាងសហព្រះរាជអាជ្ញា។ ហេតុនេះ កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក ចែងឱ្យមានកិច្ចដំណើរការនីតិវិធីដឹកនាំដោយមន្ត្រីពីររូប តែមិនមែនដាច់ពីគ្នា ដែលសហព្រះរាជអាជ្ញាត្រូវសហការគ្នា[34]។

២៣. ស.ព.អ បានបំពេញការងារជាឯកតោភាគីក្នុងការបើកការស៊ើបអង្កេតបឋម និងដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់ ស.ព.អ[35]។ ការបញ្ចៀសនីតិវិធីសម្រាប់ការដោះស្រាយ

---

[31] ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5 កថាខណ្ឌ ២៤០ ដល់ ២៥៨។

[32] សំណុំរឿង 00៤/២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ ឯកសារ D360 កថាខណ្ឌ ៤១។

[33] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣(ចុះថ្ងៃទី0៧ ខែកញ្ញា ឆ្នាំ២00៩ ឯកសារ D1/1)។ ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានការកោសលុប៖ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២00៩ ឯកសារ D1/1.3 "យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ផុល និងចៅក្រម ហួត វុទ្ធី" កថាខណ្ឌ ១៩។

[34] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ៦(៣) និង (៤)។

[35] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣(ចុះថ្ងៃទី0៧ ខែកញ្ញា ឆ្នាំ២00៩ ឯកសារ D1/1)។ ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានការកោសលុប៖ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ

ករណីខ្វែងយោបល់ គាត់មិនបានទាំងស្នើសុំការអនុញ្ញាតលើដំណើរការជាឯកតោភាគីផងទេ[36]។ ចៅក្រមភាគច្រើននៅ អ.ប.ជ បានសម្រេចថា ការផ្តួចផ្តើមស៊ើបអង្កេតបឋមជាឯកតោភាគីរបស់ ស.ព.អ ជាការអនុវត្តខុសច្បាប់[37]។ ដោយមិនបញ្ចូល ស.ព.ជ ដែលជាដៃគូផ្ទាល់ និងដែលមានសិទ្ធិអំណាចស្មើគ្នានោះ[38] ស.ព.អ បានរារាំងកិច្ចសហការ និងរារាំងលទ្ធភាពនៃវិធីសាស្ត្រសហការក្នុងការចោទប្រកាន់ដែលត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក និង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[39]។ ក្នុងការធ្វើបែបនេះ ស.ព.អ បានរំលោភទៅលើកម្មវត្ថុ និងគោលបំណង លក្ខខណ្ឌ និងស្មារតីនៃកិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និង វិធាន។

២៤. ការគ្មានសុពលភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់ ស.ព.អ មិនត្រូវបានដោះស្រាយដោយការបង្កើននីតិវិធីដោះស្រាយករណីខ្វែងយោបល់យឺតយ៉ាវ ឬដោយការចេញដីកាដំណោះស្រាយនោះឡើយ[40]។ លើសពីនេះទៀត ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី

---

ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៩ ឯកសារ D1/1.3 សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ១៦។

[36] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ៦(៤)។ បទប្បញ្ញត្តិនេះមានឧត្តមភាពទៅលើវិធាន ១(២)។

[37] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ (ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1)។ ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានការកោសលុប៖ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 "យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហ្វូត វុទ្ធី" កថាខណ្ឌ ១៨ និង ១៩។

[38] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ៦(១), (៤) និង ២(១)។

[39] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី៣ (ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1)។ ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានការកោសលុប៖ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៤៥។

[40] ស.ច.ស.អ យល់ឃើញជាឯកត្តោភាគីថា ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមជាឯកត្តោភាគីគ្មានសុពលភាពច្បាស់ណាស់ ដោយសារ ស.ព.អ មិនបានអនុវត្តតាមវិធាន ៧១៖ សេចក្តីសម្រេចស្តីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D27/3 កថាខណ្ឌ ៥៖ "នៅក្នុងករណីនេះ គ្មានការព្រមព្រៀងត្រូវបានសម្រេចឡើងដោយសហព្រះរាជអាជ្ញា គ្មាននីតិវិធីដោះស្រាយការខ្វែងយោបល់គ្នាត្រូវបានបញ្ចប់ និងក៏គ្មានរយៈពេល ៣០ (សាមសិប) ថ្ងៃត្រូវបានកន្លងផុតនោះទេ។ ដូច្នេះ

របស់ ស.ព.អ ត្រូវបានចុះហត្ថលេខាដោយ ស.ព.អ ស្តីទីតែម្នាក់គត់ ដែលធ្វើឲ្យដីកានេះត្រូវទុកជាមោឃៈផ្នែកនីតិវិធីថែមទៀត អនុលោមតាមវិធាន ៥៣(៣)[41]។

*សេចក្តីសន្និដ្ឋាន*

២៥. មូលដ្ឋានគតិយុត្តិសម្រាប់ការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ និងសមត្ថកិច្ចបន្ទាប់របស់ អ.វ.ត.ក ក្នុងការជំនុំជម្រះលោក យឹម ទិត្យ ទទួលរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ[42]។ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយដំណើរការស៊ើបអង្កេតដោយផ្អែកលើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ។ សំណុំរឿង ០០៤ ត្រូវបានបង្កើតឡើងដោយខុសច្បាប់ ហើយពេលនេះត្រូវតែលើកលែងចោទប្រកាន់។

## ខ. មូលដ្ឋានរង ១.២÷ មិនអាចមានការជំនុំជម្រះដោយយុត្តិធម៌

២៦. ស.ច.ស ធ្លាប់បានកត់សម្គាល់ថា វាជាកំហុសផ្នែកសីលធម៌ និងមិនអាចទទួលយកបានតាមផ្លូវច្បាប់ដែលដំណើរការជំនុំជម្រះ នៅក្នុងកាលៈទេសៈដែលជនជាប់ចោទមិនអាចទទួលបានការធានាពីការជំនុំជម្រះដោយយុត្តិធម៌នោះឡើយ[43]។ នៅក្នុងចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ មេធាវីការពារក្តីបានរៀបរាប់យ៉ាងលម្អិតពីវិធីជាច្រើនដែលសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក យឹម ទិត្យ ត្រូវរងការរំលោភបំពានដោយមិនអាចជួសជុលបាន[44]។ ស.ច.ស.អ បានច្រានចោល ឬមិនអើពើចំពោះការរំលោភបំពានទាំងនេះ[45]។ ដោយចេញដីកាបញ្ជូនទៅជំនុំ

ស.ព.អ មិនមានសិទ្ធិយកដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមមកអនុវត្តដោយដាក់ស្នើសុំដីកានេះឡើយ។ ដោយហេតុថា ស.ព.អ [...] ប្រាកដណាស់បានរំលោភវិធាន ៧១(៣) ដោយមិនអើពើអំពីរយៈពេលដោះស្រាយខ្វែងយោបល់គ្នានោះ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលបានដាក់ស្នើសុំដោយ ស.ព.អ មិនអាចចាត់ទុកថាមានសុពលភាពនោះទេ”។

[41] វិធាន ៥៣(១)(ង) តម្រូវឲ្យ “កាលបរិច្ឆេទ និងហត្ថលេខារបស់សហព្រះរាជអាជ្ញាទាំងពីរ”។

[42] កិច្ចព្រមព្រៀងរវាង អ.ស.ប និង រ.រ.ក មាត្រា ១, ៦ និង ៧។ វិធាន ៥៣។ ICCPR មាត្រា ១៤(១)។ យោបល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស អ.ស.ប លេខ ៣២។ ដីកាសម្រេចលើញត្តិរបស់ជនសង្ស័យស្នើសុំឲ្យមានការស្រាយបំភ្លឺទាក់ទិននឹងការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៤ ឯកសារ D204/2 កថាខណ្ឌ ១១។

[43] សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ៥៤។

[44] ចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ២៥៩ ដល់ ៤២៩។

[45] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ២៤។

ជម្រះដោយមិនបានបង្ហាញ ឬមិនទាំងពិចារណាទៅលើលទ្ធផលយូរអង្វែងនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះពេញលេញ និងដោយយុត្តិធម៌នោះ ស.ច.ស.អ មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាសារវ័ន្តតាមផ្លូវតុលាការទេ។ វាពុំមែនជារឿងសមហេតុសមផល និងមិនយុត្តិធម៌ទេដែលបំពានទៅលើឆន្ទានុសិទ្ធិរបស់ខ្លួននោះ។ នាពេលនេះ អ.ប.ជ ត្រូវពិចារណាដល់ផលប៉ះពាល់នៃការធ្វើឱ្យប៉ះពាល់ដល់ភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីប្រឆាំងលោក យឹម ទិត្យ តាមរយៈ (១) ការជ្រៀតជ្រែកយ៉ាងមានប្រសិទ្ធភាពទៅក្នុងកិច្ចការរដ្ឋបាលតុលាការ និង (២) ការពន្យារពេលដោយមិនត្រឹមត្រូវ។

### (i) ការជ្រៀតជ្រែកយ៉ាងមានប្រសិទ្ធភាពទៅក្នុងកិច្ចការរដ្ឋបាលតុលាការ

#### *ក. ការបែកធ្លាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់ ស.ព.អ*

២៧. មកត្រឹមថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ត្រូវបានផ្សព្វផ្សាយជាសាធារណៈដោយខុសច្បាប់[46]។ ឯកសារដែលមានភាពរើសអើង

---

[46] ឯកសារ D72/1.1.11 កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១៖ រាយការណ៍ថា អ្នកស្រី Yuko Maeda ជាអ្នកនាំពាក្យនៅ អ.វ.ត.ក បានរម្លឹកឡើងវិញថា "នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ មានអ្នកកាសែតក្រៅម៉ោងម្នាក់បានចុះផ្សាយជាលើកដំបូងនៅក្នុងកាសែត Jurist Newspaper អំពីឯកសារសម្ងាត់មួយពីតុលាការ ហើយបន្ទាប់មកចុះផ្សាយលើកទីពីរនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ នៅក្នុងទស្សនាវដ្ដី Christian Science Monitor"។ Ferrie, J. "ឯកសារបែកធ្លាយបន្ថែមទៀតបានធ្វើឱ្យសាលាក្ដីខ្មែរក្រហមទទួលរងការរិះគន់នៅកម្ពុជា" The Christian Science Monitor ចុះផ្សាយថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១។ នៅក្នុងសំណុំរឿង ០០៤៖ ឯកសារ D72/1.1.3 ការរាយការណ៍ជាបន្តបន្ទាប់នៅលើសារព័ត៌មានបានដកស្រង់ពីឯកសារចោទប្រកាន់តាមសំណើដើម និងដាក់បង្ហាញឯកសារសម្ងាត់នៅ អ.វ.ត.ក។ សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១។ Manning, S. និង Thompson, A., "ឯកសារដែលបែកធ្លាយផ្ដល់យោបល់ថា អ.ស.ប គួរតែដកថយពីសាលាក្ដីខ្មែរក្រហម" Scoop Independent News ចុះផ្សាយថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់ ស.ព.អ អាចរកបាន ជាមួយនឹងតំណភ្ជាប់នានានៅលើគេហទំព័រ៖ http៖//www.scoop.co.nz/stories/print.html?path=HL1106/S00165/leaked-documents-suggest-un-backing-off-khmer-rouge-trials.htm។ នៅក្នុងសំណុំរឿង ០០៤ ដែរ៖ ឯកសារ D72/1.1.5. Sok, K., "អតីតកម្មាភិបាលខ្មែរក្រហមមិនភ័យខ្លាចសាលាក្ដី និងយមរាជទេ" ចុះផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១។ នៅក្នុងសំណុំរឿង ០០៤៖ ឯកសារ D72/1.1.2. កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១។ ឯកសារ D72/1.1.13។ Sok, K., "ទីតាំងឧក្រិដ្ឋកម្ម ព័ត៌មានអំពីជនរងគ្រោះត្រូវបានផ្សព្វផ្សាយនៅក្នុងសំណុំរឿងដែលកំពុងរង់ចាំការសម្រេចនៅសាលាក្ដី" វិទ្យុសម្លេងអាមេរិក ចុះផ្សាយថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ អាចរកបាននៅលើគេហទំព័រ៖ https៖//www.voacambodia.com/

និងប្រកាន់និន្នាការខ្ពស់នេះបានចោទប្រកាន់លោក យឹម ទិត្យ ពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរ។ ការផ្សព្វផ្សាយឯកសារនេះជាសាធារណៈគឺជាការរំលោភបំពានជាក់ស្តែងទៅលើសច្ចាធារណ៍នៃនិរទោស។ ការធ្វើបែបនេះជាការជ្រៀតជ្រែកយ៉ាងច្បាស់ទៅក្នុងកិច្ចការរដ្ឋបាលតុលាការ[47]។ បន្ទាប់ពីការផ្សាយដោយខុសច្បាប់នេះមក លោក យឹម ទិត្យ ត្រូវបានសារព័ត៌មានបញ្ចេញឈ្មោះម្តងហើយម្តងទៀត[48] ត្រូវគេភ្ជាប់ទៅនឹងទីតាំងឧក្រិដ្ឋកម្មជាក់លាក់ដែលត្រូវបានចោទប្រកាន់ និងមានការថ្លែងថា គាត់ "ទទួលខុសត្រូវភូមិភាគនានាក្នុងសម័យខ្មែរក្រហម ដែលមានប្រជាជនរាប់សែននាក់ត្រូវគេគិតថាបានស្លាប់ ដោយសារការងារហួសកម្លាំង អត់ឃ្លាន និងការសម្លាប់"[49]។

២៨. សុចរិតភាពនៃការស៊ើបអង្កេតពឹងផ្អែកទាំងស្រុងទៅលើភាពសម្ងាត់[50]។ ស.ច.ស បានសម្រេចថាការបែកធ្លាយ "យ៉ាងច្រើន" និង "គួរឲ្យអាម៉ាស់" នូវព័ត៌មានសម្ងាត់នៅក្នុងសំណុំរឿង ០០៤ បាន

---

a/crime-sites-victim-information-released-in-pending-tribunal-case/1568123.html (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩)។

47 សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍សាធារណៈរបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១។

48 Manning, S. និង Thompson, A., "ឯកសារដែលបែកធ្លាយផ្តល់យោបល់ថា អ.ស.ប គួរតែដកថយពីសាលាក្តីខ្មែរក្រហម" Scoop Independent News ចុះផ្សាយថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់ ស.ព.អ អាចរកបាន ជាមួយនឹងតំណភ្ជាប់នានានៅលើគេហទំព័រ៖ http://www.scoop.co.nz/stories/print.html?path=HL1106/S00165/leaked-documents-suggest-un-backing-off-khmer-rouge-trials.htm (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩) ឯកសារ D72/1.1.5។ Sok, K., "អតីតកម្មាភិបាលខ្មែរក្រហមមិនភ័យខ្លាចសាលាក្តី និងយមរាជទេ" ចុះផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ២០១១ នៅក្នុងសំណុំរឿង ០០៤៖ ឯកសារ D72/1.1.2។ កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ D72/1.1.13។

49 Sok, K., "ទីតាំងឧក្រិដ្ឋកម្ម ព័ត៌មានអំពីជនរងគ្រោះត្រូវបានផ្សព្វផ្សាយនៅក្នុងសំណុំរឿងដែលកំពុងរង់ចាំការសម្រេចនៅសាលាក្តី" វិទ្យុសម្លេងអាមេរិក ចុះផ្សាយថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១២ អាចរកបាននៅលើគេហទំព័រ៖ https://www.voacambodia.com/a/crime-sites-victim-information-released-in-pending-tribunal-case/1568123.html (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩)។

50 វិធាន ៥៤ និង ៥៦។

គំរាមកំហែងដល់ "សុចរិតភាពនៃកិច្ចដំណើរការនីតិវិធី"[51]។ ជាមួយនឹងការរំលោភបំពានជាក់ស្តែងទៅលើសច្ចាធារណ៍នៃនិរទោស ការផ្សាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សុចរិតភាពនៃកិច្ចស៊ើបសួរ ដោយអាចធ្វើឱ្យខូចដល់សក្ខីកម្មសាក្សីទាំងអស់នាពេលក្រោយៗ។ ហេតុនេះ ការផ្តល់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ទៅឱ្យសារព័ត៌មាន គឺជាការជ្រៀតជ្រែកដោយចេតនាទៅក្នុងកិច្ចការរដ្ឋបាលតុលាការ ដូចដែល ស.ច.ស បានគូសបញ្ជាក់រួចមកហើយ[52]។

២៩. លទ្ធភាពដែលអាចធ្វើឱ្យខូចដល់សក្ខីកម្ម ធ្វើឱ្យការស៊ើបអង្កេតគ្មានមូលដ្ឋានត្រឹមត្រូវ[53]។ វិធាននីតិវិធីដែលគ្រប់គ្រងលើសុចរិតភាពនៃភ័ស្តុតាងដាច់ចេញពីការវាយតម្លៃទៅលើតម្លៃជាភ័ស្តុតាងរបស់ ស.ច.ស។ នៅពេលវិធាននីតិវិធីទាំងនេះត្រូវបានបំពាន ហើយសុចរិតភាពនៃភ័ស្តុតាងទទួលរងការប៉ះពាល់នោះ ការប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅលើកិច្ចដំណើរការនីតិវិធីជារឿងចៀសមិនរួចឡើយ។ មេធាវីការពារក្តីមិនត្រូវរំពឹងថាអាចស្មានដឹងថាតើ ភ័ស្តុតាងដែលរងការប៉ះពាល់អាចខុសពីភ័ស្តុតាងដែលមិនរងការប៉ះពាល់របៀបណាទេ។ ការបាត់បង់សុចរិតភាពនៃសក្ខីកម្មរបស់សាក្សីជាបញ្ហាចុងក្រោយ និងមិនអាចដោះស្រាយបានឡើយ ដោយយើងមិនអាចដឹងពីការពិតដដែល។

*ខ. ការប៉ះពាល់ដល់ការស៊ើបអង្កេត តាមរយៈភាគីខាងក្រៅ*

៣០. ការបែកធ្លាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ទៅដល់សាធារណជន ធ្វើឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ('DC-Cam') ក៏អាចទទួលបានដែរ ដោយមជ្ឈមណ្ឌលនេះបានធ្វើការស៊ើបអង្កេតដោយខ្លួនឯងហួសពីព្រំដែន និងពីការទទួលខុសត្រូវរបស់ អ.វ.ត.ក ទៅទៀត។

---

[51] ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D355/9 កថាខណ្ឌ ១៣។ អ.វ.ត.ក សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៩។

[52] ត្រូវបានហាមឃាត់ដោយវិធាន ៣៥(១)។ ឯកសារ D72/1.1.11 កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ D72/1.1.3។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីថ្លែងការណ៍សាធារណៈរបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១១។ សេចក្តីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១។

[53] តុលាការ ECtHR រឿងក្តី Jaloud ទល់នឹង ប្រទេសហូឡង់ ពាក្យសុំលេខ 47708/08 សាលក្រម ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ ២២៨។

ហេតុនេះ DC-Cam បានចូលរួមក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង ០០៤ ជាមួយនឹងការបែកធ្លាយដោយខុសច្បាប់នូវដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ហើយ ស.ច.ស.អ បានដំណើរការដោយពឹងផ្អែកជាខ្លាំងទៅលើការងាររបស់មជ្ឈមណ្ឌលនេះ[54]។

៣១. គោលដៅចម្បងនៃគម្រោងគណនីយភាពរបស់ DC-Cam គឺដើម្បី "ជួយនាំយកមេដឹកនាំឱ្យទទួលខុសត្រូវ" នៅចំពោះមុខ អ.វ.ត.ក[55]។ DC-Cam បានទទួលស្គាល់ជាចំហថា បានស៊ើបអង្កេតសំណុំរឿងរបស់ អ.វ.ត.ក ដោយចុះទៅដល់ទីតាំងឧក្រិដ្ឋកម្ម និងសម្ភាសប្រជាជន[56]។

៣២. នៅពេលទទួលអនុវត្តដំណើរការកិច្ចស៊ើបសួរនៅ អ.វ.ត.ក ទោះបីមាន ឬមិនមានសុពលភាពក៏ដោយ ស.ច.ស ជាអ្នកទទួលខុសត្រូវតែឯងចំពោះកិច្ចស៊ើបសួរ និងភាពសម្ងាត់នៃកិច្ចស៊ើបសួរ[57]។ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ស.ព.អ ស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ជូន ស.ច.ស ដោយស្នើសុំឱ្យបើកការស៊ើបអង្កេតទៅលើបុគ្គលនានារួមទាំងលោក យឹម ទិត្យ[58]។ ត្រឹមថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១០ DC-Cam បានដំណើរការបំពេញ

---

[54] សូមមើលឧទាហរណ៍ ឯកសារ D3/8 កំណត់ហេតុស្តាប់ចម្លើយសាក្សី ទន់ ស៊ុន EN 00622285។

[55] មជ្ឈមណ្ឌលឯកសារកម្ពុជា "បេសកកម្មរបស់យើង" អាចរកបាននៅលើគេហទំព័រ៖ http://www.d.dccam.org/Abouts/History/Histories.htm (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩) និង "ការលើកកម្ពស់គណនេយ្យភាព៖ ឆ្នាំ២០០០-បច្ចុប្បន្ន" អាចរកបាននៅលើគេហទំព័រ http://www.d.dccam.org/Projects/Promoting/Promoting_Accountability.htm (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩)។

[56] Crothers, L. "អ្នកស្រាវជ្រាវស៊ើបអង្កេតទៅលើការសម្លាប់រង្គាលដែលត្រូវបានចោទប្រកាន់នៅលើកោះក្នុងសម័យខ្មែរក្រហម" កាសែត ឌឹ កម្ពុជាដេលី ចុះផ្សាយថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៤៖ "ព័ត៌មាននេះមានសារសំខាន់ណាស់ ជាពិសេសសម្រាប់ការស៊ើបអង្កេតទៅលើរឿងក្តីរបស់ មាស មុត ក្នុងសំណុំរឿង ០០៣។ យើងនឹងធ្វើដំណើរទៅលើកោះ និងស្រាវជ្រាវរកទីតាំងឧក្រិដ្ឋកម្ម និងជនអ្នកដែលបានរស់នៅទីនោះតាំងពីដើមទសវត្សរ៍១៩៨០ មក" [អ្នកស៊ើបអង្កេតម្នាក់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា] បាននិយាយ។ ការចោទប្រកាន់ពីដំបូងដែលចងក្រងដោយព្រះរាជអាជ្ញាប្រឆាំង មាស មុត មិនបានលើកឡើងពីការសម្លាប់រង្គាលនៅលើកោះទេ។ ការចោទប្រកាន់បានបញ្ជូនទៅចៅក្រមស៊ើបអង្កេតនៅឆ្នាំ២០០៩ និងការស៊ើបអង្កេតកំពុងបន្ត"។

[57] វិធាន ៥៥, ៥៦ និង ៦០(២)។

[58] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ (ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1)។ ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានការកោសលុប៖ សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ឯកសារ D1/1.3 សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ កថាខណ្ឌ ៤៧។

បេសកកម្មចុះដល់ទីកន្លែង និងចាប់ផ្ដើមស៊ើបអង្កេតនៅស្រុកគិរីវង់ (នៅតំបន់ ១៣ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ)[59]។ ផែនការរបស់ DC-Cam ក្នុងការសម្ភាសប្រជាជនបានបង្ហាញយ៉ាងច្បាស់ក្នុងការការពារ "អ្នកផ្ដល់ព័ត៌មាន" ដោយរក្សាសិទ្ធិរបស់ខ្លួនមិនផ្ដល់ "សក្ខីកម្មប្រឆាំងខ្លួនឯង"[60] ដែលបង្ហាញពីមហិច្ឆតារបស់ខ្លួនក្នុងការស៊ើបអង្កេតទៅតាមគោលដៅ ជាជាងការកត់ត្រារឿងរ៉ាវពេញលេញ ពិតប្រាកដក្នុងគោលបំណងប្រវត្តិសាស្ត្រ ដូចបានលើកឡើងនៅក្នុងផែនការបេសកកម្មរបស់ខ្លួនទេ[61]។ កិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ជាការសម្ងាត់ ហើយក្នុងកាលៈទេសៈណាក៏ដោយ ក៏មិនបានផ្ដោតទៅលើស្រុកគិរីវង់ដែរ[62]។ ទោះបីឈ្មោះ "ទិត្យ" មិនត្រូវបានលើកឡើងក្នុងសេចក្ដីប្រកាសព័ត៌មាន ឬសេចក្ដីថ្លែងការណ៍ជាសាធារណៈនាពេលនោះ ពាក់ព័ន្ធនឹងកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ឬនៅក្នុងបរិបទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ក៏ដោយ តែ DC-Cam កំពុងស្វែងរកលោក យឹម ទិត្យ យ៉ាងសកម្មនៅក្នុងស្រុកគិរីវង់[63]។

៣៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ត្រូវបានបែកធ្លាយដោយខុសច្បាប់ក្រោយពេល ស.ច.ស ចេញសេចក្ដីថ្លែងការណ៍មួយរយៈខ្លី ដែលក្នុងនោះ ពួកគាត់បានពន្យល់ថា ពុំមានការចុះស៊ើបអង្កេតដល់ទីកន្លែងក្នុងសំណុំរឿង ០០៣ និង ០០៤ ទេ[64]។ ទោះជាយ៉ាងណាក្ដី គោលដៅនៃ "ការស៊ើបអង្កេត" ឡើងវិញរបស់ DC-Cam បង្ហាញច្បាស់ថា DC-Cam កំពុងស៊ើបអង្កេត ដោយផ្អែកលើព័ត៌មានសម្ងាត់ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ ដែលមជ្ឈមណ្ឌលនេះអាចទទួលបានពីបុគ្គលិកនៅ អ.វ.ត.ក មុនពេល

[59] ឯកសារ D65.1.2 មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងលើកកម្ពស់គណនេយ្យភាព៖ ទស្សនកិច្ចនៅក្នុងស្រុក ១០៩ ភូមិភាគនិរតី ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១០។

[60] ឯកសារ D65.1.2 មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងលើកកម្ពស់គណនេយ្យភាព៖ ទស្សនកិច្ចនៅក្នុងស្រុក ១០៩ ភូមិភាគនិរតី ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១០។

[61] មជ្ឈមណ្ឌលឯកសារកម្ពុជា "បេសកកម្មរបស់យើង" អាចរកបាននៅលើគេហទំព័រ៖ http៖//www.d.dccam.org/Abouts/History/Histories.htm (ចូលមើលចុងក្រោយ ថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩)។

[62] សំណុំរឿង ០០២ ដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427។

[63] ឯកសារ D65.1.2 មជ្ឈមណ្ឌលឯកសារកម្ពុជា គម្រោងលើកកម្ពស់គណនេយ្យភាព៖ ទស្សនកិច្ចនៅក្នុងស្រុក ១០៩ ភូមិភាគនិរតី ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១០។

[64] សេចក្ដីប្រកាសព័ត៌មានរបស់ អ.វ.ត.ក "សេចក្ដីថ្លែងការណ៍ពីសហចៅក្រមស៊ើបអង្កេត" ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១។

បែកធ្លាយ។ ដោយសារ DC-Cam និងបុគ្គលិករបស់ខ្លួន ពុំមែនជាបុគ្គលិករបស់ អ.វ.ត.ក ឬជាភាគីក្នុងសំណុំរឿង ០០៤ នោះ ពួកគេពុំមានកាតព្វកិច្ចរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរទេ[65]។ កំណត់ហេតុសម្ភាសន៍សាក្សីចំនួន ៥០ របស់ DC-Cam ត្រូវបានបញ្ចូលក្នុងសំណុំរឿង ០០៤ នៅចន្លោះពីពេលបិទការស៊ើបអង្កេតក្នុងសំណុំរឿង ០០២ និងការចុះផ្សាយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់ ស.ព.អ[66]។ កំណត់ហេតុទាំងនេះជាច្រើនត្រូវបានប្រើប្រាស់ធ្វើជា

[65] វិធាន ៥៦(១)។

[66] ឯកសារ D123/2/1.18 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អួង ផង ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D123/2/1.20a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កែវ អ៊ួច ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D123/2/1.19a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អំ គុណ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D123/2/1.21a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ៅ ឆោម ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D65.1.2 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ៅ ឆោម ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D123/2/1.23a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កម ញ៉ោម ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D123/2/1.22a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទឹម ភី ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១០។ ឯកសារ D123/1/2.37 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ លឹម ហុង ហៅ មាស សម្បត្តិ ហៅ អួន ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.27 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ុយ សុត ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.31 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ក្រូច ទឹម ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.29 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយបទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ង៉ែត ចាន់ថូ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.28 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សៅ ហ៊ីយ ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.32a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស គុណ ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.30 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ង៉ែត សារឿន ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០១០។ ឯកសារ D123/1/2.33 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ នេត ឆួង ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១០។ ឯកសារ D123/1/2.34 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ សុខ គា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១០។ ឯកសារ D123/1/2.36 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស រឿន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០។ ឯកសារ D123/1/2.35 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ មាស រឿន ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១០។ ឯកសារ D123/2/1.24a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ងឹម នឿន ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១១។ ឯកសារ D123/2/1.25a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ឡេង អឿក ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។ ឯកសារ D123/2/1.26a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប មុំ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១។ ឯកសារ D123/2/1.27a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ទឹម ពួន ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១១។ ឯកសារ D123/2/1.24 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ជូ យ៉ន ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១១។ ឯកសារ D123/2/1.21 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កៅ សុន ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១១។ ឯកសារ D123/2/1.23 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ម៉ក់ សារិន ចុះថ្ងៃទី១៩ ខែ

មូលដ្ឋានសម្រាប់ឲ្យអ្នកស៊ើបអង្កេតតាមផ្លូវតុលាការតាំងជាសំណួរដល់សាក្សី[67]។ ក្រោយពេល

---

៥២. កិច្ចស៊ើបសួរទៅលើសកម្មភាពឧក្រិដ្ឋរបស់លោក យឹម ទិត្យ ដែលបានចោទប្រកាន់បានធ្វើឡើងរវាងពី ៣៤ ទៅ ៤៤ ឆ្នាំ ក្រោយពេលចាប់ផ្តើមពេលវេលាដែលពាក់ព័ន្ធ[124]។ ការចោទប្រកាន់របស់ ស.ច.ស.អ ពឹងផ្អែកទាំងស្រុងទៅលើសក្ខីកម្មរបស់សាក្សី[125]។ ការថមថយនៃភ័ស្តុតាងដែលមិនអាចជៀជាក់បាន ជារឿងមិនអាចចៀសបានឡើយ។ ការពន្យារពេលថែមទៀតចន្លោះពីការបើកសង្កេតបឋមទៅលើឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ទាំងនេះ និងការជំនុំជម្រះដែលអាចមាន មានឥទ្ធិពលថែមទៀតទៅលើលទ្ធភាពរកសាក្សី និងភាពច្បាស់លាស់ និងភាពត្រឹមត្រូវនៃការចងចាំរបស់ពួកគេ។ ចំណុចនេះត្រូវបានបន្ថែមដោយសារការប្រឡាក់ប្រឡូសនៃបរិយាកាសនយោបាយក្នុងប្រទេស និងអន្តរជាតិ ជុំវិញឧក្រិដ្ឋកម្មរបស់ពួកខ្មែរក្រហម ព្រមទាំងដំណើរការក្តីជាសាធារណៈនៃសំណុំរឿង ០០១ និង ០០២។ ទោះបីវាជារឿងគួរឱ្យសោកស្តាយដល់ភាគីពាក់ព័ន្ធទាំងអស់ក៏ដោយ តែការស្វែងរកការពិតរបស់ អ.វ.ត.ក ជារឿងអកុសល ហើយមិនស្របទៅនឹងភាពយុត្តិធម៌ទេ[126]។

---

[123] ក្រុមប្រឹក្សាអឺរ៉ុប តុលាការជាតិ និងអន្តរជាតិដែលប្រឈមនឹងការរំលោភសិទ្ធិមនុស្សជាទ្រង់ទ្រាយធំ៖ អំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ឆ្នាំ២០១៦ ទំព័រ ៦។

[124] សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ឯកសារ D1/1។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់ ស.ព.អ ឯកសារ D1។ សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរលើ យឹម ទិត្យ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៧ ឯកសារ D368។

[125] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩។

[126] សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ៤។

៥៣. បញ្ហាភស្តុតាងដែលកើតចេញពីព្រឹត្តិការណ៍ពី ៤០ ឆ្នាំមកនេះ ពិតជាមិនអាច "ទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តី" ហើយពេលវេលាកន្លងទៅ មិនបានចាត់ទុកថាជាយុត្តិកម្មសម្រាប់មិនអើពើដល់បញ្ហាសំខាន់ៗនៃភាពជឿជាក់បាននៃភស្តុតាង[127]។ សក្ខីកម្មសាក្សីដែលស្រពិចស្រពិលជាការលំបាកខ្លាំងក្នុងការជំទាស់ ទោះបីជាអាចធ្វើបានក៏ដោយ[128]។ ពេលវេលាកន្លងផុតទៅក៏រារាំងយ៉ាងខ្លាំងដល់លទ្ធភាពរបស់ជនជាប់ចោទក្នុងការផ្តល់ការណែនាំលម្អិតជាក់លាក់ដើម្បីតតាំងនឹងភស្តុតាងរបស់សាក្សីដែរ (ឧទាហរណ៍ ពាក់ព័ន្ធនឹងវត្តមាននៅឯការប្រជុំ ឬទីតាំងឧក្រិដ្ឋកម្មជាក់លាក់)។

## គ. សេចក្តីសន្និដ្ឋាន

៥៤. អ.វ.ត.ក មានភារកិច្ចជាសារវន្តក្នុងការធានាឱ្យមានការជំនុំជម្រះដោយយុត្តិធម៌[129]។ ចំណុចនេះមិនអាចធ្វើបានទេ។ សំណុំរឿង ០០៤ បានទទួលរងព្យសនកម្មផ្នែកនីតិវិធីដែលមិនអាចជួសជុលបាន ដែលមិនអាចមានការជំនុំជម្រះដោយយុត្តិធម៌នាពេលនេះបាន ហើយការបន្តកិច្ចដំណើរការនីតិវិធីគឺជាការបំពានដំណើរការនេះ។ សុចរិតភាពនៃសំណុំរឿង ០០៤ ត្រូវបានរងព្យសនកម្មមិន

[127] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៣៦។ "ក្រោយរយៈពេលកន្លងហួសយូរមក ភស្តុតាងសំខាន់ខ្លះតាមរយៈសាក្សី ឬប្រភពផ្សេងទៀត អាចបាត់បង់ ដល់កម្រិតមួយដែលពិបាករកព័ត៌មានលម្អិតអាចទុកចិត្តបាន ហើយតាមពិតសាក្សីអាចពិបាកនឹងមកផ្តល់សក្ខីកម្ម។ ករណីនេះគឺពុំមែនការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬនាំឱ្យក្លាយជាបទដ្ឋាននៃការបង្ហាញភស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬការផ្តន្ទាទោសនោះឡើយ។ មេធាវីការពារក្តីមានសិទ្ធិទទួលបាននូវការវាយតម្លៃឱ្យសមហេតុផលលើភស្តុតាង និងការបកស្រាយច្បាប់នៅក្នុងច្បាប់នៅក្នុងឋានានុក្រមតុលាការនៃ អ.វ.ត.ក គ្រប់ជាន់ថ្នាក់ ដោយគិតចាប់ផ្តើមពី ក.ស.ច.ស"។

[128] Combs, N. A. ការស្វែងរកការពិតដោយគ្មានការពិត៖ មូលដ្ឋានគ្រឹះនៃភស្តុតាងមិនច្បាស់លាស់ក្នុងការផ្តន្ទាទោសព្រហ្មទណ្ឌជាអន្តរជាតិ Cambridge University Press ឆ្នាំ២០១០ ទំព័រ ៤៤ ត្រូវបានដកស្រង់នៅក្នុង "ការស្ថាបនាឡើងវិញនូវការប្រឈមដែលរីកសាយចំពោះការកាត់សេចក្តីនៃអំពើឃោរឃៅជាទ្រង់ទ្រាយធំ" Washington and Lee Law Review 75 (ឆ្នាំ២០១៨) 223-300 ទំព័រ ២៤២ ដល់ ២៤៣។

[129] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១។ ICCPR មាត្រា ១៤។ សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ៤ និង ៣៥។

អាចជួសជុលបាន ដោយសារការបំពានលើភាពសម្ងាត់[130]។ ក្នុងកាលៈទេសៈទាំងនេះ ការជំនុំជម្រះលោក យឹម ទិត្យ ជាការវាយប្រហារទៅលើសញ្ញាណនៃយុត្តិធម៌ និងភាពសមហេតុផល[131] និង "គួរឱ្យស្អប់ខ្ពើម" ឬ "មិនអាចទទួលយកបាន" ទៅលើកិច្ចការរដ្ឋបាលរបស់តុលាការ ប្រសិនបើអនុញ្ញាតឱ្យបន្តកិច្ចដំណើរការនីតិវិធីទៅមុខ[132]។ គោលការណ៍ដែលថា តុលាការមានកាតព្វកិច្ចមិនបន្តកិច្ចដំណើរការនីតិវិធីដែលមានព្យសនកម្មមិនអាចជួសជុលបាន មុនពេលសម្រេចចុងក្រោយទៅលើរឿងក្តីណាមួយ ត្រូវបានប្រកាន់យកយ៉ាងទូលំទូលាយដោយសាលាក្តីអន្តរជាតិ រួមទាំង អ.វ.ត.ក និងច្បាប់កម្ពុជាផងដែរ[133]។

---

[130] សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ៨០៖ "យើងជ្រើសរើសប្រើពាក្យ "ផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍ទាំងស្រុង" ជាជាងពាក្យ "លើកលែងចោទប្រកាន់" ពីព្រោះថា ច្បាប់ជាធរមាននៅចំពោះមុខ អ.វ.ត.ក ជាពិសេស វិធានផ្ទៃក្នុង ៦៧(៣) ប្រើពាក្យ "លើកលែងការចោទប្រកាន់" សម្រាប់សេណារីយ៉ូពីរផ្សេងគ្នា។ ប៉ុន្តែការប្រើប្រាស់ពាក្យផ្សេងគ្នានេះគ្រាន់តែជាបញ្ហាពាក្យពេចន៍តែប៉ុណ្ណោះ"។

[131] សំណើសុំមតិយោបល់ អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ ឯកសារ D355 កថាខណ្ឌ ៣៩។ ចក្រភពអង់គ្លេស រឿងក្តី R ទល់នឹង Horseferry Road Magistrates' Court [ឆ្នាំ១៩៩៤] 1 A.C. 42 H.L.(E) 74G។ សូមមើលផងដែរ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្តី Barayagwiza ទល់នឹង រដ្ឋអាជ្ញា (ICTR-97-19-AR72) "សេចក្តីសម្រេច" ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៤-៧៥, ៧៧។

[132] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga "សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ សំណុំរឿងលេខ ICC-01/04-01/06-772 កថាខណ្ឌ ២០, ៣០ និង ៣៧។

[133] ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និង សំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារក្តី យឹម ទិត្យ ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ ឯកសារ D355/9 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ឯកសារ E284/4/8 កថាខណ្ឌ ៧៥។ សូមមើលជាឧទាហរណ៍អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Lubanga "សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦" ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ សំណុំរឿងលេខ ICC-01/04-01/06-772 កថាខណ្ឌ ២៦-៣៩។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Tadić (IT-94-1-A) "សាលដីកាលើការចោទប្រកាន់ពីការប្រមាថតុលាការរបស់មេធាវី Milan

៥៥. អនុលោមទៅតាមសំអាងហេតុនានាដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមលើកឡើងថា នាពេលនេះ ការជំនុំជម្រះដោយយុត្តិធម៌មិនអាចកើតមានបានទេ ហើយ អ.ប.ជ ត្រូវតែកែប្រែកំហុសលើអង្គច្បាប់យ៉ាងធ្ងន់ធ្ងររបស់ ស.ច.ស.អ ដែលបានចេញដីកាបញ្ជូនទៅជំនុំជម្រះដោយរំលោភដល់សិទ្ធិជាសារវ័ន្តរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ហេតុនេះសូមបដិសេធសំណុំរឿង ០០៤ ដើម្បីបញ្ចៀសកុំឱ្យភាពអយុត្តិធម៌ធ្ងន់ធ្ងរ។

**II. មូលដ្ឋានទី ២៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ក្នុងការចេញដីកាដំណោះស្រាយ ដែលត្រូវចាត់ទុកជាមោឃៈ ដោយមានកំហុសនីតិវិធី ដោយសារខកខានមិនបានកំណត់ច្បាប់ឱ្យបានត្រឹមត្រូវ និងមិនបានយោងទៅលើការវិភាគលើភ័ស្តុតាងក្នុងការសម្រេចរបស់ខ្លួនទៅលើយុត្តាធិការបុគ្គល**

៥៦. ស.ច.ស.អ បានបកស្រាយច្បាប់មិនត្រឹមត្រូវទាល់តែសោះ ដោយចេញដីកាដំណោះស្រាយដែលមិនមានខ្លឹមសារ និងទម្រង់ ដែលខកខានមិនបានបំពេញលក្ខខណ្ឌជាមូលដ្ឋានសម្រាប់ដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដែលតម្រូវឱ្យបញ្ជាក់អំពីការកំណត់បទចោទប្រឆាំងនឹងជនដែលត្រូវបានចោទប្រកាន់ អង្គហេតុសំខាន់ៗដែលត្រូវសំអាង និងផ្នែកជាក់លាក់នៃភ័ស្តុតាងដែលជាមូលដ្ឋានសម្រាប់សំអាងហេតុ។ ស.ច.ស.អ បានរំលោភបំពានលើវិធាន ៦៧ (២) និងមានកំហុសអង្គច្បាប់ដោយខកខានមិនបាន (១) លើកឡើងឱ្យបានសមស្របពីការពិចារណាដែលពាក់ព័ន្ធដែលត្រូវបានប្រើប្រាស់ ដើម្បីវាយតម្លៃពីតួនាទីរបស់លោក យឹម ទិត្យ ជាបុគ្គល "ទទួលខុសត្រូវខ្ពស់បំផុត" (២) កំណត់ឱ្យបានត្រឹមត្រូវអំពីធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ អង្គហេតុ

---

Vujin" ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៣។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Stanišić និង Župljanin (IT-08-91-A) "សេចក្តីសម្រេចលើសំណើរបស់ Mićo Stanišić សុំការប្រកាសពីការជម្រះក្តីមិនត្រឹមត្រូវ ដើម្បីទុកសាលក្រមសាលាដំបូងជាមោឃៈ" ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៤ កថាខណ្ឌ ៣៥។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Karadžić (IT-95-5/18-AR-73-4) "សេចក្តីសម្រេចលើបណ្តឹងសាទុក្ខរបស់ Karadžić ប្រឆាំងនឹងសេចក្តីសម្រេចរបស់សាលាដំបូងទៅលើកិច្ចព្រមព្រៀង Holbrooke ដែលបានចោទប្រកាន់" ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០០៩ កថាខណ្ឌ ៤៥។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី រដ្ឋអាជ្ញា ទល់នឹង Bobetko (IT-02-62-AR54bis) "សេចក្តីសម្រេចលើការជំទាស់ដោយប្រទេសក្រូអាត ទៅនឹងសេចក្តីសម្រេច និងដីការបស់ចៅក្រមបញ្ជាក់" ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១៥។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្តី Barayagwiza ទល់នឹង រដ្ឋអាជ្ញា (ICTR-97-19-AR72) "សេចក្តីសម្រេច" ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៣ ដល់ ៧៧។

និងភ័ស្តុតាងជាមូលដ្ឋាន ទាក់ទងនឹងការយល់ឃើញរបស់ខ្លួនដែលថា ខ្មែរក្រោម ជា "ក្រុមពិសេស" មួយ ស្ថិតក្នុងអត្ថន័យនៃ *ធាតុផ្សំសត្យានុម័ត* នៃអំពើប្រល័យពូជសាសន៍ និងការយល់ឃើញថា លោក យឹម ទិត្យ មានចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់អំពើប្រល័យពូជសាសន៍ (៣) កំណត់ឲ្យមានត្រឹមត្រូវនូវធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ អង្គហេតុ និងភ័ស្តុតាងជាមូលដ្ឋាន ទាក់ទងនឹងតម្រុយផ្សេងៗដែលបង្ហាញអំពីការគ្រប់គ្រងដោយប្រសិទ្ធភាព និងទំនាក់ទំនងហេតុ និងបច្ច័យទៅតាមលក្ខខណ្ឌតម្រូវ រវាងការខកខានរបស់ថ្នាក់លើដោយមិនបានគ្រប់គ្រងទៅលើអ្នកនៅក្រោមបង្គាប់ និងការកើតឡើងនៃឧក្រិដ្ឋកម្ម។ អ.ប.ជ ត្រូវបដិសេធចោលការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយមិនត្រឹមត្រូវរបស់ ស.ច.ស.អ ដែលបានតាក់តែងឡើងដោយមិនសមស្រប រំលោភបំពានលើសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់លោក យឹម ទិត្យ។

**ក. លក្ខខណ្ឌតម្រូវតាមវិធាន ៦៧ (២) សម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពនៅ អ.វ.ត.ក**

៥៧. វិធាន ៦៧ (២) ដាក់លក្ខខណ្ឌតឹងរឹងសម្រាប់សុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.អ ដែលស្ថិតក្រោមការពិនិត្យរបស់ អ.ប.ជ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវមានការបង្ហាញអង្គហេតុ និងការកំណត់ប្រភេទបទល្មើស រួមទាំង មានបទប្បញ្ញត្តិស្តីពីបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ[134] បើពុំនោះទេ ដីកានេះត្រូវចាត់ទុកជាមោឃៈដោយមានកំហុសនីតិវិធី។ បុរេលក្ខខណ្ឌទាំងនេះត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិជាសារវន្តរបស់ជនជាប់ចោទ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មានសិទ្ធិដឹងអំពីប្រភេទនៃបទល្មើស និងមានឱកាសគ្រប់គ្រាន់ដើម្បីរៀបចំសម្រាប់ការការពារក្តី[135]។ បទល្មើសនីមួយៗ ត្រូវ

[134] នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ដីកាដំណោះស្រាយមិនបាន "រៀបរាប់អំពីអង្គហេតុពាក់ព័ន្ធសំខាន់ៗ ដែលនាំទៅដល់ការចោទប្រកាន់ទាំងអស់នោះឡើយ ហើយក៏មិនបានបង្ហាញអំពីប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទដែលត្រូវបានចោទប្រកាន់ពាក់ព័ន្ធនឹងបទឧក្រិដ្ឋទាំងអស់នោះដែរ" មានន័យថា អង្គជំនុំជម្រះមិនអាចកំណត់អំពីប្រភេទពិតប្រាកដនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ ឬទម្រង់នៃការទទួលខុសត្រូវដែលអនុវត្តចំពោះជនជាប់ចោទឡើយ ហេតុដូច្នេះ ត្រូវបដិសេធចោលបទចោទទាំងនោះ។ សំណុំរឿង ០០២ សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ) ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១ ឯកសារ E122 ("សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់អង្គជំនុំជម្រះសាលាដំបូង) កថាខណ្ឌ ១៤ ដល់កថាខណ្ឌ ២៣។

[135] ដូចយោងខាងលើ កថាខណ្ឌ ១៦។

(១) បញ្ជាក់ឱ្យច្បាស់លាស់ពីអង្គច្បាប់ (២) បញ្ជាក់អំពីធាតុផ្សំនៃបទឧក្រិដ្ឋដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ (៣) បញ្ជាក់អំពីមូលដ្ឋានអង្គហេតុនៃការចោទប្រកាន់ និង (៤) យោងដោយផ្ទាល់ទៅលើផ្នែកផ្សេងៗនៃការវិភាគភ័ស្តុតាងដែលមានរៀបរាប់អំពីអង្គហេតុ[136]។

៥៨. វិធាន ៧៤ (៣)(ក) មិនមានចែងអំពីបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដីទៅលើសុពលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយអនុលោមតាមវិធាន៦៧ (២) ហើយបញ្ហានេះមិនមានលក្ខណៈជាយុត្តាធិការទេ[137]។ ទោះជាយ៉ាងនេះក្ដី ដូចបានកត់សម្គាល់ខាងលើ ការបកស្រាយទូលាយរបស់ អ.ប.ជ លើវិធាន ២១ ពង្រីកសិទ្ធិប្ដឹងឧទ្ធរណ៍[138]។ ការរំលោភបំពានទៅលើវិធាន៦៧ (២) មានចែងនៅក្នុងវិធាន ៧៤(៣)(ក) ដែលត្រូវបានគិតពិចារណាផ្អែកលើវិធាន ២១(១) (ឃ) ដោយហេតុថា វាប៉ះពាល់ទៅលើសិទ្ធិរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដោយមានសិទ្ធិដឹងអំពីមូលដ្ឋានដែលបញ្ជាក់អំពីតួនាទីរបស់គាត់ថាជាបុគ្គលដែល “ទទួលខុសត្រូវខ្ពស់បំផុត” និងទទួលបានឱកាសគ្រប់គ្រាន់ ដើម្បីរៀបចំសម្រាប់ការការពារក្ដី[139]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលខកខានមិនបានរៀបរាប់អំពីមូលដ្ឋាននៃយុត្តាធិការ អ.វ.ត.ក នោះគឺមានកំហុស។ វាជាកំហុសដ៏សំខាន់មួយដែលតម្រូវឱ្យ អ.ប.ជ ប្រកាសមោឃៈភាព[140] ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ មិនមែនអង្គជំនុំជម្រះសាលាដំបូងឡើយ។

---

[136] ដូចយោងខាងលើ កថាខណ្ឌ ១៤ ដល់កថាខណ្ឌ ២៣។

[137] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៤៧។

[138] សូមមើលខាងលើ កថាខណ្ឌ ១៣។ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៧។

[139] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧ ដល់កថាខណ្ឌ ២០។

[140] សំណុំរឿង ០០២ សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១០ ឯកសារ D97/14/15 កថាខណ្ឌ ៣៥៖ អង្គបុរេជំនុំជម្រះបានសម្រេចកាលពីមុនថា ដើម្បីឱ្យមានភាពយុត្តិធម៌ អង្គបុរេជំនុំជម្រះប្រកាសទទួលយកមូលដ្ឋាននៃបណ្ដឹងឧទ្ធរណ៍ ដែលបានលើកឡើងអំពីបញ្ហានៃការជូនដំណឹងអំពីបទចោទ។

**ខ. មូលដ្ឋានទី ២.១÷ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយខកខានមិនបានរៀបរាប់ពីការពិចារណាដែលពាក់ព័ន្ធ ដែលត្រូវប្រើប្រាស់ ដើម្បីវាយតម្លៃលើតួនាទីរបស់លោក យឹម ទិត្យ ជាបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត"**

៥៩. វិធាន ៦៧ (២) តម្រូវឱ្យ ស.ច.ស.អ លើកឡើងអំពីការពិចារណាដែលពាក់ព័ន្ធ ដែលត្រូវប្រើប្រាស់ដើម្បីវាយតម្លៃយុត្តាធិការបុគ្គល ដើម្បីជូនដំណឹងដល់លោក យឹម ទិត្យ អំពីមូលដ្ឋាននៃការវាយតម្លៃ[141]។

៦០. ស.ច.ស.អ បានកំណត់អង្គច្បាប់ដែលអាចអនុវត្តបានទៅលើយុត្តាធិការបុគ្គល ដោយយោងទៅលើខ្លឹមសារនៃមាត្រា១ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា និងមាត្រា ១ និង ២ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[142]។ ទោះជាយ៉ាងនេះក្ដី ស.ច.ស.អ មិនបានលើកឡើងពីការពិចារណាដែលពាក់ព័ន្ធ ដែលត្រូវប្រើប្រាស់ ដើម្បីវាយតម្លៃលើតួនាទីរបស់លោក យឹម ទិត្យ ជា "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត[143]" ឡើយ។ "ការបញ្ចូលតាមរយៈការយោង" នៃផ្នែកនៃដីកាមួយនៅក្នុងសំណុំរឿងដែលត្រូវបានបំបែកមួយរបស់ អ.វ.ត.ក មិនមែនជាការជូនដំណឹងគ្រប់គ្រាន់ដល់លោក យឹម ទិត្យ ឡើយ[144]។ ការជូនដំណឹងគឺជាគោលគំនិតច្បាស់លាស់ ហើយដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលជាឯកសារពេញលេញមួយ ដែលជាចម្បងមានគោលបំណងការពារសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដោយត្រូវបានជូនដំណឹងអំពីមូលដ្ឋាននៃបណ្ដឹងព្រហ្មទណ្ឌ និងទទួលបានឱកាសគ្រប់គ្រាន់ដើម្បីរៀបចំសម្រាប់ការការពារក្ដី[145] មានទម្រង់តឹងរឹង និងត្រូវមានភាពជាក់លាក់គ្រប់គ្រាន់[146]។

៦១. លើសពីនេះទៀត ស.ច.ស.អ ខកខានមិនបានលើកឡើងអំពីមូលដ្ឋានអង្គហេតុក្នុងការសម្រេចថា លោក យឹម ទិត្យ ជាបុគ្គលម្នាក់ដែល "ទទួលខុសត្រូវខ្ពស់បំផុត" និងខកខានមិនបានយោងដោយ

---

[141] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៤ ដល់កថាខណ្ឌ ២៣។

[142] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ២៧ ដល់កថាខណ្ឌ ២៩។

[143] ដូចយោងខាងលើ កថាខណ្ឌ ២៧ ដល់កថាខណ្ឌ ៣៥។

[144] ដូចយោងខាងលើ កថាខណ្ឌ ៣៣ ដល់កថាខណ្ឌ ៣៥។

[145] សេចក្ដីសម្រេចលើអញ្ញត្រកម្មរបស់អង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ១៧ ដល់កថាខណ្ឌ ២០។

[146] ដូចយោងខាងលើ កថាខណ្ឌ ២១ ដល់កថាខណ្ឌ ២៣។

ផ្ទាល់ទៅលើផ្នែកនានានៃការវិភាគលើភ័ស្តុតាង ដែលបញ្ជាក់ពីអង្គហេតុទាំងនោះឡើយ[147]។

*សេចក្តីសន្និដ្ឋាន*

៦២. ការខកខានរបស់ ស.ច.ស.អ ក្នុងការលើកឡើងពីការពិចារណាដែលពាក់ព័ន្ធ មូលដ្ឋានអង្គហេតុ និងភ័ស្តុតាងដែលគាំទ្រ ដែលត្រូវប្រើប្រាស់ ដើម្បីកំណត់ថា លោក យឹម ទិត្យ ជាបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" នោះ បណ្តាលឲ្យមានកំហុសនៅលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ[148]។ ដូច្នេះ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយធ្វើការសម្រេចលើយុត្តាធិការបុគ្គល ដោយមិនបានបញ្ជាក់ឲ្យបានសមស្របពីការពិចារណានានាពាក់ព័ន្ធទៅនឹងការវាយតម្លៃលើការទទួលខុសត្រូវបុគ្គល ដែលជាលក្ខខណ្ឌតម្រូវនៅក្នុងវិធាន៦៧ (២) វាជាការបំពានទៅលើសិទ្ធិរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវទទួលបានការជូនដំណឹងអំពីសំណុំរឿងប្រឆាំងនឹងគាត់ និងដើម្បីរៀបចំសម្រាប់ការការពារក្តី ដូចបានធានានៅក្នុងវិធាន២១ (១)(ឃ)។ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ លើលោក យឹម ទិត្យ ដែលជាបុគ្គលមួយរូបស្ថិតក្រោមយុត្តាធិការរបស់សាលាក្តីនេះ មិនមានយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលជាការបំពានលើឆន្ទានុសិទ្ធិ។ ដោយហេតុថា សុពលភាពនៃបទចោទទាំងអស់ប្រឆាំងនឹងលោក យឹម ទិត្យ ត្រូវផ្អែកលើសំអាងហេតុដែលមានសុពលភាពនៃយុត្តាធិការបុគ្គល ដូច្នេះ សំណុំរឿងនេះ ត្រូវច្រានចោលទាំងស្រុង។

## គ. មូលដ្ឋានទី ២.២៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនកំណត់ឲ្យបានត្រឹមត្រូវពីធាតុផ្សំនៃអំពើប្រល័យពូជសាសន៍ និងខកខានមិនយោងទៅលើការវិភាគលើភ័ស្តុតាងនៅក្នុងសំអាងច្បាប់របស់ខ្លួនស្តីពីយុត្តាធិការបុគ្គល

៦៣. ស.ច.ស.អ ចោទប្រកាន់លោក យឹម ទិត្យ ពីបទឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ប្រឆាំងនឹងខ្មែរ

---

[147] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩២ ដល់កថាខណ្ឌ ៩៩៩។ មតិកត់សម្គាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពី "ទស្សនៈនយោបាយរបស់ ប.ក.ក" ការពឹងផ្អែករបស់គាត់លើការប្រៀបធៀបអង្គហេតុមិនសមស្របជាមួយជំរំប្រមូលផ្តុំណាហ្ស៊ី ការយល់ឃើញរបស់គាត់អំពី "ការភ័យរន្ធត់" ឬ "ភាពមាក់ងាយដ៏អមនុស្សធម៌" និងការពិពណ៌នារបស់គាត់ដោយគ្មានការគាំទ្រអំពីឥទ្ធិពលនៃគោលនយោបាយស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ មិនបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៦៧(២) ដើម្បីបង្ហាញអំពីអង្គហេតុសំខាន់ៗនោះទេ។

[148] ដូចយោងខាងលើ កថាខណ្ឌ ២៧ ដល់កថាខណ្ឌ ៣៤ កថាខណ្ឌ ៩៩២។

ក្រោម ដោយការសម្លាប់សមាជិកនៃក្រុមខ្មែរក្រោមក្នុងតំបន់ ១៣ នៃភូមិភាគនិរតី និងតំបន់២ និង តំបន់ ៤ នៃភូមិភាគពាយ័ព្យ ដោយផ្អែកលើការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ១, សហឧក្រិដ្ឋកម្មរួម ២, ការរៀបចំផែនការ, ការបញ្ជា, ការញុះញង់ និងការទទួលខុសត្រូវរបស់ថ្នាក់លើ[149]។ សំអាងហេតុរបស់ ស.ច.ស.អ ស្តីពីអំពើប្រល័យពូជសាសន៍ មានសារៈសំខាន់ចំពោះសេចក្តីសន្និដ្ឋានរួមដែលថា លោក យឹម ទិត្យ ជាបុគ្គលដែល "ទទួលខុសត្រូវខ្ពស់បំផុត" សំអាងហេតុរបស់ ស.ច.ស.អ នេះ គឺជា "សំអាងហេតុតែមួយគត់ដែលបានដាក់លោក យឹម ទិត្យ យ៉ាងជាប់មិនឱ្យរួចពីយុត្តាធិការបុគ្គល[150]"។ អាស្រ័យហេតុនេះ មូលដ្ឋានរងខាងក្រោមនេះអាចទទួលយកបានជាបញ្ហាយុត្តាធិការ ដោយអនុលោមតាមវិធាន ៧៤(៣)(ក)។

៦៤. ស.ច.ស.អ បានកំណត់មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក[151] ជាអង្គច្បាប់។ ទោះជាយ៉ាងនេះក្តី ស.ច.ស.អ ខកខានមិនបានលើកឡើងពីធាតុផ្សំគតិយុត្តិនៃឧក្រិដ្ឋកម្ម មូលដ្ឋានអង្គហេតុនៃបទចោទ និងផ្នែកគាំទ្រនៃការវិភាគភ័ស្តុតាង ទីមួយ ទាក់ទងនឹងសំអាងហេតុដែលថា "ខ្មែរក្រោម" គឺជាក្រុមពិសេស ស្ថិតក្នុងអត្ថន័យនៃអំពើមួយនៃអំពើប្រល័យពូជសាសន៍ និងទី២ ទាក់ទងនឹងសំអាងហេតុរបស់គាត់ដែលថា លោក យឹម ទិត្យ មាន "ចេតនាពិសេស" ដែលជាលក្ខខណ្ឌសម្រាប់អំពើប្រល័យពូជសាសន៍។ ការខកខានរបស់ ស.ច.ស.អ ក្នុងការលើកឡើងអំពីធាតុផ្សំនៃឧក្រិដ្ឋកម្ម គឺជាកំហុសអង្គច្បាប់។

---

[149] ដូចយោងខាងលើ កថាខណ្ឌ ៤៧៥ ដល់កថាខណ្ឌ ៤៧៦។

[150] ដូចយោងខាងលើ កថាខណ្ឌ ៩៩៦។

[151] ដូចយោងខាងលើ កថាខណ្ឌ ៥៩ ដល់កថាខណ្ឌ ៧២។ នៅក្នុងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងបានអះអាងថា មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងថា តុលាការមានយុត្តាធិការលើ "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ("អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍") ដែលបានប្រព្រឹត្តក្នុងអំឡុងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩"។ មាត្រា ៤ ចែងថា "ការធ្វើមនុស្សឃាតទៅលើសមាជិកនៃក្រុម" គឺជាអំពើមួយក្នុងចំណោមអំពើទាំងឡាយណាដែលអាចចាត់ទុកជាអំពើប្រល័យពូជសាសន៍ នៅក្នុងនិយមន័យនេះ។ អង្គជំនុំជម្រះសាលាដំបូងក៏បានរកឃើញផងដែរថា ត្រឹមឆ្នាំ១៩៧៥ គេអាចព្យាករណ៍ និងប្រមើលមើលបានថា ជាទូទៅ អំពើប្រល័យពូជសាសន៍ ដូចមានចែងក្នុងអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ត្រូវបានផ្តន្ទាទោសជាឧក្រិដ្ឋកម្ម។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៧៨២ ដល់កថាខណ្ឌ ៨០៥។

(i) **ស.ច.ស.អ ខកខានមិនបានអនុវត្តតាមវិធាន ៦៧ (២) ក្នុងការយល់ឃើញថា ខ្មែរក្រោម គឺជា "ក្រុមពិសេស" មួយ ស្ថិតក្នុងអត្ថន័យនៃធាតុផ្សំសត្យានុម័តនៃអំពើប្រល័យពូជសាសន៍**

*ក. លក្ខខណ្ឌតម្រូវអនុលោមតាមវិធាន ៦៧ (២) ក្នុងការលើកឡើងអំពីធាតុផ្សំគតិយុត្តិ*

៦៥. ស.ច.ស.អ ខកខានមិនបានកំណត់ "មូលហេតុជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា" ជាធាតុផ្សំផ្លូវច្បាប់នៃអំពើប្រល័យពូជសាសន៍[152]។ ការពិពណ៌នាច្បោលៗរបស់ ស.ច.ស.អ អំពី "លក្ខខណ្ឌចម្រុះ ទៅតាមករណីជាក់ស្តែង" ដែលវាយតម្លៃ "អត្តសញ្ញាណវិជ្ជមានជាក់លាក់" នៃក្រុម ដោយផ្អែកលើ "លក្ខណៈសត្យានុម័ត" នៃ "បរិបទនយោបាយ សង្គម ប្រវត្តិសាស្ត្រ និងវប្បធម៌ដែលពាក់ព័ន្ធគ្នា" ហើយ "ការយល់ឃើញជាអត្តនោម័ត" ទៅលើជនរងគ្រោះ និងចារី ត្រូវបានបកស្រាយយ៉ាងទូលាយ ដោយមិនបានជូនដំណឹងឲ្យបានគ្រប់គ្រាន់ដល់លោក យឹម ទិត្យ អំពីលក្ខណៈនៃបទចោទប្រឆាំងនឹងគាត់[153]។

៦៦. ស.ច.ស.អ ខកខានមិនបានលើកឡើងអំពីលក្ខខណ្ឌសម្រាប់ "ក្រុម" មនុស្ស ដែលមានលក្ខណៈទូទៅ ដែលទទួលបានការការពារដោយអនុសញ្ញាអំពើប្រល័យពូជសាសន៍ លក្ខខណ្ឌទាំងនេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ជាលក្ខណៈសត្យានុម័ត ដោយមិនគិតថាតើត្រូវពិចារណាលើលក្ខណៈវិនិច្ឆ័យទាំងបែបអត្តនោម័ត និងទាំងបែបសត្យានុម័ត ក្នុងការវាយតម្លៃនេះ[154]។ សំខាន់ វិធីសាស្ត្រ

---

[152] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៦១ ដល់កថាខណ្ឌ ៦៣។ សូមមើលផងដែរ កថាខណ្ឌ ៥៩ ដែលដកស្រង់ដីកាដំណោះស្រាយ សំណុំរឿង ០០២ ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ឯកសារ D427 កថាខណ្ឌ ១៣១២, សាលក្រមក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* ទល់នឹង *Rutaganda* របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-96-3-T) ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ កថាខណ្ឌ ៥៩, សាលក្រមក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTR (សំណុំរឿងលេខ ICTR-96-4-T) ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៤៩៨ ដល់កថាខណ្ឌ ៤៩៩, សាលក្រមក្នុងរឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstić* របស់អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY (សំណុំរឿងលេខ IT-98-33-T) ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០១ កថាខណ្ឌ ៥៤២, មាត្រា ៤ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក, មាត្រា ២ នៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ("អនុសញ្ញាស្តីពីអំពើវប្រល័យពូជសាសន៍") ដែលត្រូវបានអនុម័ត និងបើកឲ្យចុះហត្ថលេខា ឲ្យសច្ចាប័ន តាមសេចក្តីសម្រេចលេខ ២៦០ A (III) ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៤៨ របស់មហាសន្និបាតអង្គការសហប្រជាជាតិ ។

[153] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៦១ ដល់កថាខណ្ឌ ៦៣។

[154] អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brđanin* (សំណុំរឿងលេខ IT-99-36-T) សាលក្រម ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ២៨៤, អង្គជំនុំជម្រះសាលាដំបូងទី ១ នៃតុលាការ ICTY ផ្នែក ក រឿងក្តី

បែបអត្តនោម័តសុទ្ធសាធ មិនអាចអនុវត្តបានទៅលើនិយមន័យនៃពាក្យថា ក្រុមទទួលបានការការពារឡើយ[155] សូម្បីតែក្នុងករណីដែលមានភស្តុតាងបង្ហាញដែលថា បុគ្គលជាប់ចោទបានធ្វើទុក្ខបុកម្នេញ[156] ដោយអត្តនោម័តទៅលើក្រុមនោះក៏ដោយ។ ដូច្នេះ ស.ច.ស.អ ពុំបានយកចិត្តទុកដាក់ឡើយ ទោះជាជម្រើសភស្តុតាងអត្តនោម័តអំពីការយល់ឃើញទៅលើក្រុមមួយ អាចទទួលយកបានក៏ដោយ ក៏ចាំបាច់ត្រូវគាំទ្រដោយភស្តុតាងដែលបញ្ជាក់ថា ក្រុមនោះ គឺជា "លក្ខណៈ

---

*រដ្ឋអាជ្ញា ទល់នឹង* Blagojević និង *Jokić* (សំណុំរឿងលេខ IT-02-60-T) ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៦៦៧, អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kajelijeli* (សំណុំរឿងលេខ ICTR-98-44A-T) សាលក្រម និងការផ្តន្ទាទោស ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០៣ កថាខណ្ឌ ៨១១, អង្គជំនុំជម្រះសាលាដំបូងទី ៣ នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Semanza* (សំណុំរឿងលេខ ICTR-97-20-T) សាលក្រម និងការផ្តន្ទាទោស ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៣ កថាខណ្ឌ ៣១៧។

[155] យុត្តិសាស្ត្រអន្តរជាតិមុនយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ចាត់ទុកជាស្ថាពរនូវសមាជិកភាពក្នុងក្រុមជនជាតិភាគតិចមួយដែលទទួលបានការការពារជាបញ្ហានៃអង្គហេតុសត្យានុម័ត។ តុលាការយុត្តិធម៌អន្តរជាតិ សំណុំរឿង *Nottebohm* វគ្គទី ២ (លីចថេនស្ទិន ទល់នឹងហ្គ័រតឺម៉ាឡា) សាលក្រម ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ១៩៥៥, តុលាការយុត្តិធម៌អន្តរជាតិ របាយការណ៍ឆ្នាំ១៩៥៥ [៤] ទំព័រ ២៣, តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ សិទ្ធិរបស់ជនជាតិភាគតិចនៅ Upper Silesia (អាល្លឺម៉ង់ទល់នឹងប៉ូឡូញ) សាលក្រម ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩២៦, តុលាការយុត្តិធម៌អន្តរជាតិអចិន្ត្រៃយ៍ របាយការណ៍ ស៊េរី ក លេខ ១៥ ទំព័រ ៣៣-៣៤។ ខណៈដែលសេចក្តីសម្រេចដំបូងៗរបស់តុលាការចំពោះកិច្ចត្រូវបានបកស្រាយថាមានភាពចម្រុះគ្នាលើបញ្ហានេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៅ *Statić* បានសម្រេចដោយផ្ទាល់ និងយ៉ាងម៉ឺងម៉ាត់ថា លក្ខណៈវិនិច្ឆ័យអត្តនោម័តិតែមួយមុខមិនអាចយកមកប្រើ ដើម្បីកំណត់អំពីក្រុមដែលទទួលបានការការពារណាមួយបានឡើយ។ ក្នុងនាមជាអង្គឧទ្ធរណ៍តែមួយគត់ដែលត្រូវដោះស្រាយបញ្ហានេះដោយផ្ទាល់អង្គជំនុំជម្រះបានពិនិត្យមើលឡើងវិញនូវសេចក្តីសម្រេចមុនៗរបស់តុលាការ ICTY/ICTR និងបានកំណត់យ៉ាងត្រឹមត្រូវថា គ្មានសេចក្តីសម្រេចណាមួយបានប្រើប្រាស់វិធីសាស្ត្រអត្តនោម័តិសុទ្ធសាធ ដើម្បីកំណត់និយមន័យក្រុមឡើយ ហើយអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍មិនអនុញ្ញាតឲ្យប្រើវិធីសាស្ត្របែបនេះឡើយ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* (សំណុំរឿងលេខ IT-97-24-A) សាលក្រម ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៥។ សូមមើលផងដែរ៖ អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brđanin* (សំណុំរឿងលេខ IT-99-36-T) សាលក្រម ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៦៨៥។

[156] ផលវិបាកនៃវិធីសាស្ត្រអត្តនោម័តិសុទ្ធសាធ ផ្អែកលើការយល់ឃើញរបស់ចារី ត្រូវបានបង្ហាញយ៉ាងច្បាស់លាស់ដោយលោក Kreß C. នៅក្នុងអត្ថបទដែលមានចំណងជើងថា "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ" (ឆ្នាំ២០០៦) ចុះផ្សាយក្នុងទស្សនាវដ្តី *ទីតិព្រហ្មទណ្ឌអន្តរជាតិ* លេខ ៤៦១ ទំព័រ ៤៧៤៖ "គេមិនត្រូវទុកឲ្យចារីជាអ្នកបកស្រាយកេតនភ័ណ្ឌ ដែលបានរៀបរាប់នៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មឡើយ គឺយ៉ាងហោចណាស់ ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យសត្យានុម័តិ ក្នុងកម្រិតណាមួយជាក់លាក់។ វិធីសាស្ត្រអត្តនោម័តិមិនត្រឹមតែរារាំងដល់ការសម្រេចរបស់អ្នកគាត់តែងក្នុងការកម្រិតការការពារចំពោះក្រុមមួយចំនួនប៉ុណ្ណោះទេ ថែមទាំងអាចប្រែក្លាយឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទៅជាឧក្រិដ្ឋកម្មមិនជាក់លាក់នៃការបំផ្លិចបំផ្លាញក្រុមដោយផ្អែកលើហេតុផលរើសអើងទៀតផង"។

សត្យានុម័តនៃសង្គមនោះ[157]"។ ដោយពុំបានថ្លឹងថ្លែងពីលក្ខណៈសត្យានុម័តនេះ វិធីសាស្ត្របែប អត្តនោម័តទាំងស្រុង "ឈានទៅរកភាពមិនសមហេតុផលខាងទ្រឹស្តី [ដែលចារីអាចកំណត់ ក្រុមណាមួយ][...] ដោយមិនគិតពីលក្ខណៈសត្យានុម័ត និងជាប់ពិរុទ្ធពីបទប្រល័យពូជសាសន៍"[158]។

៦៧. ស.ច.ស.អ ខកខានមិនលើកឡើងពីលក្ខខណ្ឌតម្រូវថា ក្នុងស្ថានភាពដែលយល់ឃើញថា ក្រុមពហុជាតិសាសន៍ និងជាតិពន្ធុ ត្រូវបានកំណត់គោលដៅ ហើយក្រុមនីមួយៗអាចមានលក្ខណៈខុសគ្នាលើមូលដ្ឋានច្រើនជាងមួយនោះ វាពុំសមស្របឡើយក្នុងការកំណត់តាមផ្លូវច្បាប់ក្នុងលក្ខខណ្ឌទូទៅថាជា "ក្រុមជាតិពន្ធុ" តែមួយ[159]។ សញ្ញាណនៃការយល់ដឹងស៊ីជម្រៅលើក្រុមច្បាស់លាស់មួយ ឬពីរ មានកម្រិតខ្ពស់[160]។ លើសពីនេះទៀត ស.ច.ស.អ មិនបានយោងទៅលើលក្ខខណ្ឌតម្រូវក្នុងការបង្ហាញចរិតលក្ខណៈដែលសមាជិកក្រុមនីមួយៗ មានជាទូទៅ ដែលជាការផ្ទុះបញ្ចាំងពីកម្មវត្ថុ និងគោលបំណងចម្បងនៃអនុសញ្ញាស្តីពីប្រល័យពូជសាសន៍ ដើម្បី

---

[157] អង្គជំនុំជម្រះសាលាដំបូងទី ១ នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bagilishema* (សំណុំរឿងលេខ ICTR-95-1A-T) សាលក្រម ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦៥។ នៅទីនេះ អង្គជំនុំជម្រះសាលាដំបូងធ្វើការបែងចែកយ៉ាងច្បាស់រវាងការប្រើប្រាស់ការយល់ឃើញដោយអត្តនោម័តិក្នុងការកំណត់ថាតើចារីជឿថាបុគ្គលម្នាក់ជាសមាជិកក្រុមដែរឬទេ និងការប្រើប្រាស់លក្ខណៈវិនិច្ឆ័យអត្តនោម័តិសុទ្ធសាធក្នុងការកំណត់ក្រុមណាមួយ និងកំណត់ថាតើក្រុមនោះត្រូវទទួលបានការការពារដែរឬទេ។

[158] Akhavan P. "ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅក្នុងយុត្តិសាស្ត្ររបស់តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់ប្រទេសរ្វ៉ាន់ដា" (ឆ្នាំ២០០៥) *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* លេខ ៩៨៩ ទំព័រ ១០០២។

[159] អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* (សំណុំរឿងលេខ IT-97-24-T) សាលក្រម ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៥១២, អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* (សំណុំរឿងលេខ IT-97-24-A) សាលដីកា ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១៩ កថាខណ្ឌ ២៨។

[160] សូមមើល អង្គជំនុំជម្រះសាលាឧទ្ធរណ៍ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* (សំណុំរឿងលេខ IT-97-24-A) សាលដីកា ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២៨, អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brđanin* (សំណុំរឿងលេខ IT-99-36-T) សាលក្រម ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៦៨៦, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karadžić* (សំណុំរឿងលេខ IT-95-5/18T) សាលក្រម ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១។

ការពារក្រុមមនុស្សជាក់លាក់ និងធានាពីការរួមចំណែកជាបន្តដល់ពិភពលោកចម្រុះ[161]។

៦៨. ស.ច.ស.អ ខកខានមិនបានលើកឡើងអំពីភាពខុសគ្នាផ្នែកច្បាប់រវាង "ផ្នែកនៃក្រុមមួយ" និងក្រុមដែលត្រូវបានកំណត់អត្តសញ្ញាណដោយយោងទៅលើក្រុមមួយទៀត។ ការលើកឡើងនេះ ត្រូវបានពិពណ៌នាដូចខាងក្រោម៖

> យុទ្ធនាការសម្លាប់រង្គាលមួយអាចត្រូវបានកំណត់គោលដៅបំផ្លិចបំផ្លាញកម្រិតខ្ពស់នូវសមាជិកមួយចំនួននៃក្រុមដែលត្រូវបានការពារ ដោយបានបំពេញលក្ខខណ្ឌនៃពាក្យ "ជាចំណែក"។ ប៉ុន្តែ យុទ្ធនាការនេះមិនមានលក្ខណៈប្រល័យពូជសាសន៍នោះទេ (ដូច្នេះ អ្នកចូលរួមនឹងមិនទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍នោះទេ) ប្រសិនបើជនរងគ្រោះ ត្រូវបានជ្រើសរើស មិនមែនដោយសារពួកគេស្ថិតនៅក្នុងក្រុមដែលត្រូវបានការពារទេ តែដោយសារឧទាហរណ៍ ទស្សនៈផ្នែកនយោបាយរបស់ពួកគេទៅវិញនោះ[162]។

*ខ. លក្ខខណ្ឌតម្រូវតាមវិធាន ៦៧ (២) ដើម្បីកំណត់អង្គហេតុសំខាន់ៗ និងភស្តុតាងជាមូលដ្ឋាន*

៦៩. ក្នុងផ្នែកនានានៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ ដែលមានចំណងជើង "ការកំណត់គោលដៅលើខ្មែរក្រោម[163]" និង "សំអាងហេតុស្តីពីអំពើប្រល័យពូជសាសន៍លើខ្មែរក្រោម" មិនអាចកំណត់

---

[161] Lemkin R. *Axis Rule in Occupied Europe* វ៉ាស៊ីងតោន ឆ្នាំ១៩៤៤ ទំព័រ ៩១, កំណត់ហេតុផ្លូវការរបស់មហាសន្និបាតអង្គការសហប្រជាជាតិ សម័យប្រជុំលើកទី ៣ គណៈកម្មាការទី ៦ កិច្ចប្រជុំលើកទី ៧៣ (ឆ្នាំ១៩៤៨) ទំព័រ ៩១ ៩២ ៩៦, តុលាការយុត្តិធម៌អន្តរជាតិ មតិណែនាំអំពីឧបម្រុងនៃអនុសញ្ញាស្តីពីការបង្ការ និងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៥១, តុលាការយុត្តិធម៌អន្តរជាតិ របាយការណ៍លេខ ១៥ ទំព័រ ២៣, អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krstić* (សំណុំរឿងលេខ IT-98-33-A) សាលដីកា ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ៣៦៖ "ជនណាដែលបង្កើត និងអនុវត្តអំពើប្រល័យពូជសាសន៍ ព្យាយាមដកហូតពីមនុស្សជាតិនូវភោគទ្រព្យដ៏សម្បូរបែបនៃសញ្ជាតិ ពូជសាសន៍ ជាតិពន្ធ និងសាសនារបស់ពួកគេ។ នេះជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិទាំងមូល ដោយព្យសនកម្មត្រូវបានទទួលរងដោយក្រុមដែលគេកំណត់គោលដៅសម្រាប់ការបំផ្លិចបំផ្លាញផង និងមនុស្សជាតិទាំងមូលផង"។

[162] Behrens P. "អំពើប្រល័យពូជសាសន៍ និងបញ្ហានៃហេតុផល" (ឆ្នាំ២០១២) *ទស្សនាវដ្តីយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ* (១០) លេខ ៥០១ ទំព័រ ៥០៥។

[163] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១៨៧ ដល់កថាខណ្ឌ ២០៥។

បានអង្គហេតុសំខាន់ៗឡើយ[164]។ ស.ច.ស.អ ខកខានមិនបានបញ្ជាក់ពីមូលដ្ឋានអង្គហេតុដែលបញ្ជាក់ពីស្ថានភាពរបស់ខ្មែរក្រោម ជា "ក្រុម"មួយស្ថិតនៅក្រោមអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ឬមិនបានបញ្ជាក់ពី "សំអាងច្បាប់" ស្តីពីអំពើប្រល័យពូជសាសន៍ ដោយយោងទៅលើសាក្សី ឬភ័ស្តុតាងជាឯកសារដែលពាក់ព័ន្ធក្នុងសំណុំរឿង[165]។

៧០. សំអាងហេតុរបស់ ស.ច.ស.អ ស្តីពីគោលនយោបាយ ប.ក.ក ចំពោះក្រុមជនជាតិភាគតិចខ្មែរក្រោម ខកខានមិនបានកំណត់យ៉ាងពេញលេញពីចរិតលក្ខណៈនៃក្រុមនោះឡើយ[166]។ ខណៈដែលផ្តល់ការវិភាគអំពីសង្គម-ប្រវត្តិសាស្ត្រយ៉ាងទូលំទូលាយ អំពីអត្តសញ្ញាណខ្មែរក្រោមចាប់តាំងពីសតវត្សរ៍ទី ១៧ មក[167] ស.ច.ស.អ មិនបានពន្យល់អំពីសេចក្តីសង្កេតរបស់ខ្លួនអំពីលក្ខណៈដាច់ដោយឡែករបស់ជនជាតិភាគតិចខ្មែរក្រោម ជាតិសាសន៍វៀតណាម និងលក្ខណៈជាតិពន្ធុប្រភពភូមិសាស្ត្ររបស់ខ្មែរក្រោមនៅក្នុងភាគខាងត្បូងនៃប្រទេសវៀតណាម ជាតិពន្ធុខ្មែរ និងការកំណត់អត្តសញ្ញាណបុគ្គលជា "អតីតពួកលន់ នល់" ឬគិញ ជាការកំណត់ពី "ក្រុម" នោះ[168]។

៧១. ជាក់ស្តែង ស.ច.ស.អ ខកខានមិនបានលើកឡើងពីមូលដ្ឋានអង្គហេតុសម្រាប់បែងចែកការកំណត់គោលដៅលើខ្មែរក្រោម ចេញពីក្រុមផ្សេងទៀត ដែលគាត់យល់ឃើញថាត្រូវបានកំណត់គោលដៅដោយ ប.ក.ក ទេ ។ ជារឿយៗ ស.ច.ស.អ បានសំអាងលើគោលនយោបាយរបស់ ប.ក.ក ចំពោះជនជាតិវៀតណាម ដោយថ្លែងថា "គោលនយោបាយរបស់ ប.ក.ក ចំពោះខ្មែរក្រោម មានឫសគល់ច្រើនពីការស្អប់ខ្ពើមចំពោះជនជាតិវៀតណាមដោយសារតែ "អំពើឈ្លានពានវាតទីនិយម" និងការភ័យខ្លាចជាបន្តបន្ទាប់ដែលថា វៀតណាម មានមហិច្ឆិតាចង់បានទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ"។ ប៉ុន្តែ ស.ច.ស.អ មិនបានធ្វើសំអាងហេតុច្បាស់លាស់ទាក់ទងថាតើខ្មែរក្រោមជាសមាជិកនៃក្រុមជនជាតិវៀតណាមដែរឬទេ[169]។ លើសពីនេះទៀត ស.ច.ស.អ ខកខាន

[164] ដូចយោងខាងលើ កថាខណ្ឌ ១០០៨ ដល់កថាខណ្ឌ ១០១៨។

[165] ដូចយោងខាងលើ កថាខណ្ឌ ១០០៨ ដល់កថាខណ្ឌ ១០១៨។

[166] ដូចយោងខាងលើ កថាខណ្ឌ ១៩៦ ដល់កថាខណ្ឌ ២០៣។

[167] ដូចយោងខាងលើ កថាខណ្ឌ ១៨៦ ដល់កថាខណ្ឌ ១៩៥។

[168] ដូចយោងខាងលើ កថាខណ្ឌ ១៩៦ ដល់កថាខណ្ឌ ២០៣។

[169] ដូចយោងខាងលើ កថាខណ្ឌ ១៩៧។

មិនបានពន្យល់ថាតើគាត់បានបែងចែកភាពខុសគ្នារវាងលក្ខខណ្ឌអត្តនោម័ត និងលក្ខខណ្ឌសត្យានុម័តនៃធាតុផ្សំនៃ"ក្រុម" យ៉ាងដូចម្ដេចឡើយ [170]។

## (ii) **ស.ច.ស.អ ខកខានមិនបានកំណត់ពីអង្គហេតុ និងបទចោទ ដើម្បីបញ្ជាក់ពីធាតុផ្សំនៃចេតនាជាក់លាក់**

### *ក. លក្ខខណ្ឌតម្រូវ តាមវិធាន៦៧ (២) ក្នុងការបញ្ជាក់ពីធាតុផ្សំផ្លូវច្បាប់*

៧២. ស.ច.ស.អ ខកខានមិនបានញែកចេញនូវធាតុផ្សំអត្តនោម័តនៃឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញពីចេតនាជាក់លាក់ ដែលជាលក្ខខណ្ឌតម្រូវសម្រាប់អំពើប្រល័យពូជសាសន៍ យោងទៅលើការបង្ហាញថា ចារីមានចេតនាមិនត្រឹមតែអនុវត្តទិសដៅរួមក្នុងការបំផ្លាញក្រុមដែលត្រូវបានការពារប៉ុណ្ណោះទេ គឺថែមទាំងមានចេតនាដើម្បីបំផ្លាញក្រុមនោះតែម្ដង[171]។ លក្ខខណ្ឌតម្រូវ "បែបនោះ" មានន័យថា ចាំបាច់ត្រូវមានទំនាក់ទំនងហេតុ និងបច្ច័យ រវាងទិសដៅរួមក្នុងការបំផ្លាញក្រុមដែលត្រូវបានការពារ និងមូលដ្ឋាននានាដែលក្រុមនោះត្រូវបានការពារ។ ត្រូវបញ្ជាក់ថាទិសដៅក្នុងការបំផ្លាញខ្មែរក្រោម គឺដោយសារតែពួកគេជាសមាជិកក្នុងក្រុមនោះ ជាជាងមូលហេតុផ្សេងទៀត ដូចជា ពួកគេត្រូវបានចាត់ទុកថាជាសមាជិក ឬជាសមាជិកជាក់ស្ដែងនៃក្រុមនយោបាយមួយ។

៧៣. ស.ច.ស.អ ខកខានមិនបានទទួលស្គាល់លក្ខខណ្ឌតម្រូវជាក់លាក់នានាទាក់ទងនឹងចេតនាឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ ដោយខកខានមិនបានលើកឡើងថា ចេតនារើសអើងតែប៉ុណ្ណឹងមិនគ្រប់គ្រាន់សម្រាប់ធាតុផ្សំអត្តនោម័តនោះទេ ដែលវាខុសពីឧក្រិដ្ឋកម្មផ្សេងទៀត ដូចជា

---

[170] ដូចយោងខាងលើ កថាខណ្ឌ ១៨៦ ដល់កថាខណ្ឌ ១៩៥។

[171] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង* *Sikirica* និងអ្នកឯទៀត (សំណុំរឿងលេខ IT-95-8-T) សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំឱ្យដោះលែង ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០០១ កថាខណ្ឌ ៦១៖ "ទីមួយ ត្រូវបង្ហាញអំពីចេតនាបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារណាមួយទាំងស្រុង ឬមួយផ្នែក ទីពីរ ត្រូវបង្ហាញអំពីចេតនាបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារបែបនេះផងដែរ។ ធាតុផ្សំទាំងពីរនេះបូកបញ្ចូលគ្នា ពោលគឺ អយ្យការមិនត្រឹមតែបង្ហាញអំពីចេតនាបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារប៉ុណ្ណោះទេ គឺត្រូវបង្ហាញអំពីចេតនាបំផ្លិចបំផ្លាញក្រុមដែលទទួលបានការការពារនោះផងដែរ"។

ការធ្វើទុក្ខបុកម្នេញជាដើម[172]។ ស.ច.ស.អ សង្ខេបសេចក្ដីដកស្រង់ដោយមិនត្រឹមត្រូវថា "*ចេតនារើសអើងសម្រាប់អំពើប្រល័យពូជសាសន៍ និងការធ្វើទុក្ខបុកម្នេញ*[173]"។

៧៤. លើសពីនេះទៀត ស.ច.ស.អ ខកខានមិនលើកឡើងអំពីលក្ខខណ្ឌតម្រូវដែលថា អំពើប្រល័យពូជសាសន៍ ត្រូវបានប្រព្រឹត្ត នៅពេលដែលគោលដៅចុងក្រោយបង្អស់របស់ចារី គឺដើម្បីបំផ្លាញក្រុមនោះ[174]។ ដូច្នេះ ចាំបាច់បញ្ជាក់ថា ចារីមានបំណងបំផ្លិចបំផ្លាញក្រុមនោះតែម្ដង មិនត្រឹមតែបំផ្លាញបុគ្គលមួយចំនួន ដោយហេតុថាពួកគេជាសមាជិកក្នុងក្រុមនោះឡើយ។ ស.ច.ស.អ ខកខានមិនបានញែកចេញធាតុផ្សំគតិយុត្តិនៃចេតនាប្រល័យពូជសាសន៍ ពីករណីនានាដែលធាតុផ្សំអត្តនោម័ត បណ្ដាលឲ្យមានការកំណត់គោលដៅដោយចៃដន្យទៅលើក្រុមជាតិពន្ធុមួយ។ អាចនិយាយម៉្យាងទៀតថា វាជាភាពខុសគ្នារវាងអំពើដែលបានប្រព្រឹត្តដែលគ្រាន់ជាចេតនារើសអើង ឬការដឹងឮ និងអំពើដែលបានប្រព្រឹត្តដោយមានចេតនាជាក់លាក់ខ្លាំងជាង ដើម្បីបំផ្លាញក្រុមមួយដែលត្រូវបានការពារ ដែលបុគ្គលនោះ ជាសមាជិកនៃក្រុមនោះ[175]។ ស.ច.ស.អ ខកខានមិនបានទទួលស្គាល់ថា តាមរយៈការប្រព្រឹត្តអំពើដែលបានចោទទាំងនោះ ចារីត្រូវព្យាយាមដើម្បីសម្រេចបានការបំផ្លាញក្រុមដែលត្រូវការការពារ ផ្ទុយទៅនឹងការកំណត់គោលដៅជាយថាហេតុទៅលើ

---

[172] តុលាការយុត្តិធម៌អន្តរជាតិ សំណុំរឿងពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (បូស្នី-អ៊ែរហ្សេហ្គោវីន ទល់នឹងសែប៊ី-ម៉ុងតេណាហ្គ្រោ) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧, តុលាការយុត្តិធម៌អន្តរជាតិ របាយការណ៍ឆ្នាំ២០០៧ កថាខណ្ឌ ១៨៧។

[173] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០៤០ (សេចក្ដីបញ្ជាក់បន្ថែម)។

[174] សាលក្រមសំណុំរឿង ០០២/០២ កថាខណ្ឌ ៧៩៨។ សូមមើល៖ Ambos K. "តើចេតនាបំផ្លិចបំផ្លាញនៅក្នុងអំពើប្រល័យពូជសាសន៍មានន័យយ៉ាងដូចម្ដេច?" (ឆ្នាំ២០០៩) *ទស្សនាវដ្ដីកាកបាទក្រហមអន្តរជាតិ* ៩១ (៨៧៦) ៨៣៣ ទំព័រ ៨៣៥៖ "ពិតណាស់ អំពើប្រល័យពូជសាសន៍ គឺជាឧក្រិដ្ឋកម្មដែលមានចេតនាលាក់កំបាំង ឬឧក្រិដ្ឋកម្មផ្ដោតលើគោលដៅ"។

[175] ឧទាហរណ៍ សូមមើល៖ តុលាការយុត្តិធម៌អន្តរជាតិ សំណុំរឿងពាក់ព័ន្ធនឹងការអនុវត្តអនុសញ្ញាស្ដីពីការបង្ការ និងផ្ដន្ទាទោសចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ (បូស្នី-អ៊ែរហ្សេហ្គោវីន ទល់នឹងសែប៊ី-ម៉ុងតេណាហ្គ្រោ) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧, តុលាការយុត្តិធម៌អន្តរជាតិ របាយការណ៍ឆ្នាំ២០០៧ កថាខណ្ឌ ១៨៧៖ "វាមិនគ្រប់គ្រាន់ទេក្នុងការបង្ហាញថា ការសម្លាប់ខុសច្បាប់ដោយចេតនាទៅលើសមាជិកក្រុមបានកើតឡើង។ ចេតនាបន្ថែមត្រូវបង្ហាញផងដែរ និងត្រូវកំណត់ឲ្យបានច្បាស់បំផុត។ វាមិនគ្រប់គ្រាន់ទេដែលសមាជិកក្រុមត្រូវបានកំណត់មុខសញ្ញា ដោយសារតែពួកគេជាសមាជិកនៃក្រុមនោះ គឺដោយសារតែចារីមានចេតនារើសអើង។ មានតម្រូវការបន្ថែមទៀត។ អំពើ ដូចបានរៀបរាប់ក្នុងមាត្រា ២ ត្រូវធ្វើឡើង ក្នុងចេតនាបំផ្លិចបំផ្លាញក្រុមទាំងមូល ឬមួយផ្នែក"។

បុគ្គលនានាបន្ថែមទៅលើគោលដៅសម្លាត់មួយ[176]។

៧៥. ជាសំខាន់ ស.ច.ស.អ ខកខានមិនបានលើកឡើងពីលក្ខណៈពិសេសនៃធាតុផ្សំសំខាន់ៗ "បែបនេះ" ក្នុងការតម្រូវឲ្យមានទំនាក់ទំនងរវាងចេតនាដើម្បីបំផ្លាញក្រុមត្រូវការការពារមួយ និងមូលដ្ឋានដែលត្រូវបានគិតគូរថាតើក្រុមណាដែលត្រូវបានការពារ ពោលគឺចេតនាដើម្បីបំផ្លាញ ដោយពិចារណាលើលក្ខណៈជាតិសាសន៍ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ ការបកស្រាយតឹងរឹងមួយទៅលើលក្ខខណ្ឌតម្រូវ "បែបនេះ" ទាមទារឲ្យពន្យល់អត្ថន័យច្បាស់លាស់ និងសាមញ្ញនៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ការវិវឌ្ឍន៍នៃប្រវត្តិសាស្ត្រនៃអំពើប្រល័យពូជសាសន៍[177] និង យុត្តិសាស្ត្រដែលពាក់ព័ន្ធ[178]។ ជាសំខាន់ ចារី ត្រូវបាន*ជំរុញទឹកចិត្ត* ឲ្យធ្វើការកំណត់គោលដៅក្រុមនោះ ផ្អែកលើមូលដ្ឋាននៃការរើសអើងមួយ និងស្វះស្វែងដើម្បីបំផ្លាញក្រុមនោះដោយផ្អែកលើ អត្តសញ្ញាណដែលត្រូវការការពារ ដោយហេតុថា អំពើប្រល័យពូជសាសន៍ដែលជាឧក្រិដ្ឋកម្មមួយដែលមានចេតនាជាក់លាក់ ខុសពីគោលការណ៍ច្បាប់ព្រហ្មទណ្ឌទូទៅ ដែលចេតនាបុគ្គល មិនជាប់ទាក់ទងនោះទេ[179]។ ចារី ពិតជាអាចមានចេតនាផ្សេងទៀត ដែលមិនជាប់ទាក់ទងទៅនឹង*ធាតុផ្សំអត្តនោម័ត*[180]។

---

[176] អង្គជំនុំជម្រះសាលាដំបូងទី ១ នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bagilishema* (សំណុំរឿងលេខ ICTR-95-1A-T) សាលក្រម ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០១ កថាខណ្ឌ ៦១, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kupreškić* និងអ្នកឯទៀត (សំណុំរឿងលេខ IT-95-16-T) សាលក្រម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៦៣៦។

[177] សម្រាប់ការបង្ហាញលម្អិតអំពីប្រវត្តិនៃការរៀបចំសេចក្តីព្រាង សូមមើល Schabas W. "អំពើប្រល័យពូជសាសន៍ក្នុងច្បាប់អន្តរជាតិ" សាកលវិទ្យាល័យ Cambridge ឆ្នាំ២០០៩ ទំព័រ ២៩៤-៣០២។

[178] អនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ មាត្រា ២។

[179] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* (សំណុំរឿងលេខ IT-95-14-A) សាលក្រម ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៩៤៖ "ធាតុផ្សំអត្តនោម័តិ គឺជាស្ថានភាពផ្លូវចិត្ត ឬកម្រិតនៃកំហុសដែលជនជាប់ចោទមាន ក្នុងអំឡុងពេលពាក់ព័ន្ធ។ ជាទូទៅ ហេតុផលត្រូវបានចាត់ទុកជាកត្តាដែលជំរុញឲ្យជនណាម្នាក់ធ្វើអំពើ។ អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងថា ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌ ហេតុផលមិនពាក់ព័ន្ធទេ ក្នុងច្បាប់អន្តរជាតិ ប៉ុន្តែ វាក្លាយជាពាក់ព័ន្ធ ក្នុងពេលផ្តន្ទាទោស។ ហេតុផលត្រូវបានពិចារណាផងដែរ ក្នុងកាលៈទេសៈពីរទៀត៖ ទីមួយ នៅពេលវាជាធាតុផ្សំចាំបាច់នៅក្នុងឧក្រិដ្ឋកម្ម ដូចជាឧក្រិដ្ឋកម្មមានចេតនាជាក់លាក់ជាដើម..."។

[180] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Niyitegeka* (សំណុំរឿងលេខ ICTR-96-14-A) សាលក្រម ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៥២-៥៣៖ ក្នុងរឿងក្តី *Kayishema* និង *Ruzindana* អង្គជំនុំជម្រះ

*ខ. លក្ខខណ្ឌតម្រូវតាមវិធាន៦៧(២) ដើម្បីកំណត់អង្គហេតុ និងភស្តុតាងជាមូលដ្ឋាន*

៧៦. ស.ច.ស.អ ខកខានមិនបានលើកឡើងពីអង្គហេតុសំខាន់ៗ ដែលជាមូលដ្ឋានសម្រាប់សំអាងហេតុរបស់ខ្លួន ទាក់ទងនឹងចេតនាបុគ្គលរបស់លោក យឹម ទិត្យ ដោយខកខានមិនបានបញ្ជាក់ពីអង្គហេតុណាដែលជាប់ទាក់ទងទៅនឹងលោក យឹម ទិត្យ និងអង្គហេតុណាដែលពាក់ព័ន្ធទៅនឹងគោលនយោបាយ ប.ក.ក ដោយយោងរួមគ្នាទៅលើ "ចេតនារបស់ ប.ក.ក, ចេតនារបស់ យឹម ទិត្យ និងចេតនារបស់អ្នកដែលសហការជាមួយគាត់[181]" ព្រមទាំងចេតនារបស់ "យឹម ទិត្យ និងអ្នកដែលគាត់បានសហការជាមួយនៅគ្រប់ជាន់ថ្នាក់នៃឋានានុក្រម ប.ក.ក[182]"។ ស.ច.ស.អ ខកខានមិនបានផ្តល់មូលដ្ឋានអង្គហេតុគ្រប់គ្រាន់ដល់សំអាងហេតុរបស់ខ្លួន ដែលថា លោក យឹម ទិត្យ ជាលក្ខណៈបុគ្គលមានគោលដៅរួមចង់បំផ្លាញក្រុមដែលត្រូវការការពារ[183]។

៧៧. ស.ច.ស.អ មិនបានបញ្ជាក់ពីភាពសំខាន់នៃសំអាងហេតុដែលថា សមាជិកខ្មែរក្រោម ត្រូវបានកំណត់គោលដៅ បន្ទាប់ពី ប.ក.ក បានឡើងកាន់អំណាច នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបានចាប់ផ្តើមចាប់ខ្លួន និងសម្លាប់អ្នកមានទំនាក់ទំនងជាមួយអតីតរបប លន់ នល់ ក្នុងនោះមានកម្លាំងម៉ៃក៍ហ្វស (Mike forces) និងក្រុមកន្សែង ស ដែល លន់ នល់ បានប្រើប្រាស់កាលពី

---

តុលាការកំពូលបានក្រើនរម្លឹកថា "ចេតនាឧក្រិដ្ឋ (ធាតុផ្សំអត្តនោម័តិ) មិនត្រូវច្រឡំគ្នាជាមួយហេតុផលទេ" ហើយបានបញ្ជាក់ថា "ចំពោះអំពើប្រល័យពូជសាសន៍ ហេតុផលផ្ទាល់ខ្លួនមិនត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ" ប្រសិនបើអំពើប្រល័យពូជសាសន៍ត្រូវបានប្រព្រឹត្តដោយមានចេតនាតាមការតម្រូវ។ គោលជំហរនេះត្រូវបានពង្រឹងនៅក្នុងរឿងក្តី *Jelisić* ដែលអង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានកត់សម្គាល់ថា "អត្ថិភាពនៃហេតុផលផ្ទាល់ខ្លួនមិនរារាំងចារីពីចេតនាជាក់លាក់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ឡើយ"។ ប៉ុន្តែ ពាក្យ "បែបនេះ" ជាធាតុផ្សំសំខាន់នៃអំពើប្រល័យពូជសាសន៍...។ ពាក្យ "បែបនេះ" មានឥទ្ធិពលខ្លាំងលើការបែងចែកច្បាស់លាស់ រវាងការសម្លាប់រង្គាល និងឧក្រិដ្ឋកម្ម ដែលចារីកំណត់គោលដៅលើក្រុមជាក់លាក់ណាមួយ ដោយសារតែសញ្ជាតិ ពូជសាសន៍ ជាតិពន្ធុ ឬសាសនា។ និយាយម្យ៉ាងទៀត ពាក្យ "បែបនេះ" បញ្ជាក់អំពីការតម្រូវឱ្យមានចេតនាជាក់លាក់។ ពុំមានការហាមឃាត់ការផ្តន្ទាទោសពីបទប្រល័យពូជសាសន៍ទេ ក្នុងករណីដែលចារីត្រូវបានជំរុញដោយហេតុផលផ្សេងទៀត ដែលមិនជាប់ពាក់ព័ន្ធតាមផ្លូវច្បាប់ ក្នុងបរិបទនេះ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងធ្វើត្រឹមត្រូវ ក្នុងការបកស្រាយពាក្យ "បែបនេះ" ថាជាអំពើហាមឃាត់ដែលត្រូវបានប្រព្រឹត្តលើជនរងគ្រោះ ដោយសារតែសមាជិកភាពនៅក្នុងក្រុមដែលទទួលបានការការពារ គឺមិនមែនដោយសារតែសមាជិកភាពបែបនេះតែមួយមុខទេ"។

[181] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០១១។

[182] ដូចយោងខាងលើ កថាខណ្ឌ ១០៤០។

[183] ដូចយោងខាងលើ។

អតីតកាល[184]។ ស.ចៅ.ស.អ បានទទួលស្គាល់ពីមូលដ្ឋាននយោបាយ ជាជាងមូលដ្ឋានជាតិពន្ធុក្នុងការកំណត់គោលដៅទៅលើក្រុមខ្មែរក្រោម ប៉ុន្តែ ខកខានមិនបានលើកឡើងថាតើអង្គហេតុ និងស្ថានភាពទាំងនេះ បានបញ្ជាក់ពីសំអាងហេតុរបស់គាត់ដែលថា លោក យឹម ទិត្យ មានចេតនាជាក់លាក់ដើម្បីបំផ្លាញក្រុមជនជាតិភាគតិចខ្មែរក្រោមទាំងស្រុង ឬជាផ្នែកដែរឬទេ[185]។

៧៨. ស.ចៅ.ស.អ ខកខានមិនបានលើកឡើងភ័ស្តុតាងដោយផ្ទាល់ណាមួយ នៅផ្នែកណាមួយក្នុងដីការបស់ ស.ចៅ.ស.អ ដែលថា លោក យឹម ទិត្យ មានចេតនាជាក់លាក់ដើម្បីបំផ្លាញក្រុមជនជាតិភាគតិចខ្មែរក្រោមទាំងស្រុង ឬជាផ្នែកឡើយ។ ទោះជាយ៉ាងនេះក្តី ស.ចៅ.ស.អ យល់ឃើញថា លោក យឹម ទិត្យ "បានចូលរួមក្នុងចេតនាជាក់លាក់ដើម្បីបំផ្លាញខ្មែរក្រោម តាមរយៈអំពើសំខាន់ៗនៃការសម្លាប់សមាជិកនៃប្រជាជនខ្មែរក្រោម" [186]។ នៅក្នុងប្រយោគតែមួយនេះ ដែលមិនមានការយោងទៅលើភ័ស្តុតាងដែលត្រូវបានផ្អែកលើ ស.ចៅ.ស.អ អះអាងពីការបញ្ជាក់ពីចេតនាពិសេសរបស់លោក យឹម ទិត្យ ដោយមិនបានផ្តល់សេចក្តីពន្យល់ទាក់ទងនឹងអង្គហេតុដែលត្រូវបានផ្អែកលើ ឬការកំណត់បទចោទឡើយ[187]។

*<u>សេចក្តីសន្និដ្ឋាន</u>*

៧៩. ការមិនមានភាពជាក់លាក់ទាំងស្រុងចំពោះមូលដ្ឋានអង្គហេតុសំខាន់ៗ និងការកំណត់បទចោទនៃផ្នែកនានាក្នុងដីកាដំណោះស្រាយរបស់ ស.ចៅ.ស.អ ទាក់ទងនឹងធាតុផ្សំ "ក្រុម" នៃអំពើប្រល័យពូជសាសន៍ ឬធាតុផ្សំ "ចេតនាជាក់លាក់"នៃអំពើប្រល័យពូជសាសន៍ មិនអាចកំណត់បាននូវខ្លឹមសារនៃបទចោទ និងមិនផ្តល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះក្តីលើផ្នែកទាំងនេះក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ ដែលជាការរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋានក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវបានជូនដំណឹងអំពីរឿងក្តីប្រឆាំងនឹងរូបគាត់ និងដើម្បីរៀបចំដើម្បី ការពារក្តី ជាការរំលោភបំពានលើវិធាន ២១ (១) (ឃ)។ ស.ចៅ.ស.អ មានកំហុសអង្គច្បាប់ដោយលើកឡើងបទចោទប្រល័យពូជសាសន៍ ដែលមិនស្របតាមវិធាន

---

[184] ដូចយោងខាងលើ កថាខណ្ឌ ១៩៥។

[185] ដូចយោងខាងលើ កថាខណ្ឌ ១០៤០។

[186] ដូចយោងខាងលើ កថាខណ្ឌ ១០២៣។

[187] ដូចយោងខាងលើ កថាខណ្ឌ ១០២៣។ សូមមើលផងដែរ៖ កថាខណ្ឌ ១០១១ និងកថាខណ្ឌ ១០៤០។

(៦៧)(២)។ អាស្រ័យហេតុនេះ ដីកាបញ្ជូនរឿងក្ដីលោក យឹម ទិត្យ ទៅជំនុំជម្រះរបស់ ស.ច.ស.អ ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ មិនមានយុត្តិធម៌ និងមិនសមហេតុផល ដែលជាការបំពានលើឆន្ទានុសិទ្ធិ។ ដំណោះស្រាយតែមួយគត់ក្នុងស្ថានភាពទាំងនេះ គឺត្រូវលើកលែងបទចោទអំពើប្រល័យពូជសាសន៍ទាំងស្រុង។

**ឃ. មូលដ្ឋានទី ២.៣÷ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនបានកំណត់ឲ្យបានត្រឹមត្រូវពីធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ និងខកខានមិនបានយោងទៅលើការវិភាគភ័ស្តុតាងនៅក្នុងសំអាងច្បាប់ស្តីពីយុត្តាធិការបុគ្គល**

៨០. នៅក្នុងសំអាងច្បាប់ស្ដីពីយុត្តាធិការបុគ្គល ស.ច.ស.អ បានសន្និដ្ឋានថា លោក យឹម ទិត្យ "គឺជាមេបញ្ជាការ*តាមព្រឹត្តន័យ* ទីពីររបស់តាម៉ុក និង [...] គាត់ក៏មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*ទៅលើសកម្មភាពតាមតំបន់មុនៗរបស់គាត់ផងដែរ ទោះបីជាបានទៅភូមិភាគពាយ័ព្យហើយក៏ដោយ[188]"។ ស.ច.ស.អ បានចោទប្រកាន់លោក យឹម ទិត្យពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ផ្អែកលើការទទួលខុសត្រូវក្រោមគោលការណ៍នៃការទទួលខុសត្រូវរបស់ថ្នាក់លើ[189]។

៨១. ស.ច.ស.អ បានលើកឡើងអង្គច្បាប់សម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើថាមានចែងនៅក្នុងមាត្រា ២៩ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក[190] និងបានកំណត់និយមន័យនៃធាតុផ្សំនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដោយប្រើយុត្តាធិការ អ.វ.ត.ក និងសាលាក្ដី*មិនអចិន្ត្រៃយ៍*[191]។ ក៏ប៉ុន្តែ ស.ច.ស.អ ខកខានមិនបានលើកឡើងធាតុផ្សំគតិយុត្តិត្រឹមត្រូវនៃទម្រង់នៃការទទួលខុសត្រូវនេះ ដែលជាលក្ខខណ្ឌតម្រូវនៅក្នុងវិធាន៦៧(២)ឡើយ។ ដូច្នេះ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយធ្វើការបកស្រាយមាត្រា ២៩ ដោយមិនត្រឹមត្រូវ។ លើសពីនេះទៀត ស.ច.ស.អ ខកខានមិនបានលើកឡើងពីមូលដ្ឋានអង្គហេតុនៃបទចោទ និងផ្នែកដែលគាំទ្រនៃការវិភាគភ័ស្តុតាង។ ទីមួយ ស.ច.ស.អ ខកខានមិនបានលើកឡើងពីតម្រុយនានាដែលជាលក្ខខណ្ឌតម្រូវនៃការ

---

[188] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤។

[189] ដូចយោងខាងលើ កថាខណ្ឌ ៤៧៥ ដល់កថាខណ្ឌ ៤៨៤។

[190] ដូចយោងខាងលើ កថាខណ្ឌ ៩២។

[191] ដូចយោងខាងលើ កថាខណ្ឌ ៩៧ ដល់កថាខណ្ឌ ១០៣។

គ្រប់គ្រងដោយប្រសិទ្ធភាព[192]។ ទីពីរ ស.ច.ស.អ ខកខានមិនបានលើកឡើងលក្ខខណ្ឌតម្រូវសម្រាប់ភ័ស្តុតាងនៃទំនាក់ទំនងហេតុ និងបច្ច័យ រវាងការខកខានរបស់ថ្នាក់លើក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ និងការកើតឡើងនៃឧក្រិដ្ឋកម្មនោះ[193]។ ដោយសារតែភាពខ្វះចន្លោះទាំងនេះ ស.ច.ស.អ ខកខានមិនបានបង្ហាញថា លោក យឹម ទិត្យ ជាមេដឹកនាំ*តាមព្រឹត្តន័យ* ដែលអាចទទួលខុសត្រូវតាមរយៈការទទួលខុសត្រូវរបស់ថ្នាក់លើ។ ដូច្នេះហើយ សំអាងច្បាប់ស្តីពីយុត្តាធិការបុគ្គល មានកំហុស។ សរុបមក ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនបានកំណត់ និងអនុវត្តឲ្យបានត្រឹមត្រូវនូវមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងខកខានមិនបានបំពេញលក្ខខណ្ឌតម្រូវតាមវិធាន ៦៧(២) សម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមានសុពលភាពរបស់ អ.វ.ត.ក។ កំហុសអង្គច្បាប់ទាំងនេះ បង្កឲ្យមានភាពមិនយុត្តិធម៌ និងមិនសមហេតុផល ដែលជាការរំលោភបំពានឆន្ទានុសិទ្ធិរបស់ ស.ច.ស.អ។

## (i) ស.ច.ស.អ ខកខានមិនលើកឡើងពីតម្រុយផ្សេងៗដែលជាលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងដោយប្រសិទ្ធភាព

### *ក. លក្ខខណ្ឌតម្រូវតាមវិធាន៦៧(២) ក្នុងការលើកឡើងអំពីធាតុផ្សំគតិយុត្តិ*

៨២. ស.ច.ស.អ ខកខានមិនលើកឡើងពីអង្គច្បាប់ស្តីពីការទទួលខុសត្រូវរបស់មេបញ្ជាការ ជាទម្រង់នៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានចែងក្នុងមាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។ ស.ច.ស.អ បានថ្លែងថា "ថ្នាក់លើ មិនថាជាយោធា ឬស៊ីវិល ត្រូវមានការគ្រប់គ្រងដោយប្រសិទ្ធភាព ដែលជាសមត្ថភាពខាងសម្ភារៈដែលទប់ស្កាត់ និង/ឬ ដាក់ទណ្ឌកម្មចំពោះការប្រព្រឹត្តិឧក្រិដ្ឋកម្មរបស់ចារីនៅអ្នកនៅក្រោមបង្គាប់[194]"។ នេះគឺជាការពិពណ៌នាដែលគ្រប់គ្រាន់នៃការគ្រប់គ្រងដោយប្រសិទ្ធភាព។ ជាក់ស្តែង ស.ច.ស.អ មិនបានលើកឡើងអំពីលក្ខខណ្ឌតម្រូវនៃ "ការគ្រប់គ្រងដោយប្រសិទ្ធភាព" ដែលសំខាន់ចំពោះអត្ថិភាពនៃទំនាក់ទំនងរវាងថ្នាក់លើ និងក្រោម។

[192] ដូចយោងខាងលើ កថាខណ្ឌ ៩៨។

[193] ដូចយោងខាងលើ។

[194] ដូចយោងខាងលើ។

៨៣. ការគ្រប់គ្រងដោយប្រសិទ្ធភាព គឺជា "ការកាន់អំណាចជាក់ស្តែង ឬការមិនកាន់អំណាចជាក់ស្តែង នៃការគ្រប់គ្រងលើសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់[195]"។ ស.ច.ស.អ ត្រូវបំពេញលក្ខខណ្ឌតម្រូវក្នុងការបញ្ជាក់ថា លោក យឹម ទិត្យ ពិតជាបានគ្រប់គ្រងដោយប្រសិទ្ធភាពលើសកម្មភាពឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ ដើម្បីចោទប្រកាន់គាត់ ក្រោមទម្រង់នៃការទទួលខុសត្រូវ។ ទោះជាយ៉ាងនេះក្តី ស.ច.ស.អ ខកខានមិនលើកឡើងពីតម្រុយនៃការគ្រប់គ្រងដោយប្រសិទ្ធភាព ដែលគាត់បានយកធ្វើជាសំអាងឡើយ ប្រសិនបើមាន។ តម្រុយទាំងនេះ ដែលមានភាពចាំបាច់សម្រាប់ការពិចារណា ដើម្បីកំណត់កម្រិតដែលជាលក្ខខណ្ឌតម្រូវនៃការគ្រប់គ្រងដោយប្រសិទ្ធភាព ត្រូវបានបញ្ជាក់ច្បាស់ក្នុងយុត្តិសាស្ត្រដែលពាក់ព័ន្ធ[196] រួមមាន៖

(១) <u>តួនាទីរបស់ជនជាប់ចោទ</u>៖ តួនាទីជាក់ស្តែងរបស់ជនជាប់ចោទ ចាំបាច់ត្រូវតែបានវាយតម្លៃ[197]។ ចំណុចនេះ រួមមាន ការពិចារណាលើតួនាទីផ្លូវការរបស់ជនជាប់ចោទ សមត្ថភាពរបស់គាត់ក្នុងការចេញបទបញ្ជា នីតិវិធីក្នុងការការតែងតាំង តួនាទីនៅក្នុងរចនាសម្ព័ន្ធយោធា ឬ នយោបាយ និងកិច្ចការជាក់ស្តែងដែលគាត់បានអនុវត្ត[198]។

(២) <u>កម្រិតនៃការគ្រប់គ្រងដែលត្រូវពិចារណាក្នុងបរិបទពេញលេញ</u>៖ ភស្តុតាងត្រូវតែបានវាយតម្លៃដោយផ្អែកលើភស្តុតាងផ្សេងៗទៀត ដើម្បីបញ្ជាក់ពីកម្រិតនៃការគ្រប់គ្រងលើចារី

---

[195] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucić* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-21-A) (រឿងក្តី *Čelebići*) សាលដីកា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ១៩២-១៩៤, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T) សាលក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៣៩៦, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* (សំណុំរឿងលេខ IT-95-14-T) សាលក្រម ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ កថាខណ្ឌ ៣០០-៣០៣ កថាខណ្ឌ ៣៣៥, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Aleksovski* (សំណុំរឿងលេខ IT-95-14/1/T) សាលក្រម ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៦។

[196] សាលក្រមសំណុំរឿង ០០១ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ ឯកសារ E188 កថាខណ្ឌ ៥៤១-៥៤២។

[197] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* (សំណុំរឿងលេខ IT-95-14/2-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១៨, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Delić* (សំណុំរឿងលេខ IT-04-83-T) សាលក្រម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ ៦២, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Halilović* (សំណុំរឿងលេខ IT-01-48-A) សាលដីកា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ ៥៨ ៦៨ ៧០ ១៣៩។

[198] ដូចយោងខាងលើ។

ផ្ទាល់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់[199]។ ចំណុចនេះ រួមមានលទ្ធភាពរបស់ជនជាប់ចោទក្នុងការតែងតាំង និងបណ្តេញចេញអ្នកនៅក្រោមបង្គាប់។

(៣) <u>រចនាសម្ព័ន្ធផ្លូវការ មិនគ្រប់គ្រាន់ឡើយ</u>៖ "មានតែថ្នាក់លើ *ទាំងតាមនិតិន័យ ឬទាំងតាមព្រឹត្តន័យ*" ជាយោធា ឬស៊ីវិល ដែលស្ថិតក្នុងផ្នែកយ៉ាងច្បាស់លាស់នៃខ្សែរយៈបញ្ជា ទាំងដោយផ្ទាល់ ឬទាំងដោយប្រយោល ដែលមានអំណាចជាក់ស្តែងក្នុងការគ្រប់គ្រង ឬដាក់ទោសទៅលើទង្វើរបស់អ្នកនៅក្រោមបង្គាប់ប៉ុណ្ណោះ ដែលអាចមានទទួលខុសត្រូវព្រហ្មទណ្ឌ[200]។ ដោយសារ ការគ្រប់គ្រងដោយប្រសិទ្ធភាព អាចមានអត្ថិភាពនៅខាងក្រៅរចនាសម្ព័ន្ធក្រៅផ្លូវការ គេមិនអាចសន្និដ្ឋានទាំងស្រុងបានដោយផ្អែកតែលើរចនាសម្ព័ន្ធផ្លូវការនោះទេ[201]។

(៤) <u>កម្រិតនៃសិទ្ធិអំណាច*តាមព្រឹត្តន័យ* ត្រូវតែស្មើគ្នាទៅនឹងសិទ្ធិអំណាច*តាមនីតិន័យ*៖</u> "ទោះបីជាកម្រិតនៃការគ្រប់គ្រងរបស់ថ្នាក់លើ *តាមនីតិន័យ* ឬ*តាមព្រឹត្តន័យ* អាចមានទម្រង់ខុសៗគ្នាក៏ដោយ ក៏ថ្នាក់លើ *តាមព្រឹត្តន័យ* ត្រូវបានរកឃើញថាមានអំណាចស្រដៀងគ្នាយ៉ាងសំខាន់ក្នុងការគ្រប់គ្រងទៅលើអ្នកនៅក្រោមបង្គាប់ ដើម្បីឲ្យថ្នាក់លើ *តាមនីតិន័យ* មានការទទួលខុសត្រូវ ព្រហ្មទណ្ឌចំពោះសកម្មភាពរបស់ពួកគេ[202]។"

(៥) <u>លទ្ធភាពជាក់ស្តែងក្នុងការរារាំង និងដាក់ទណ្ឌកម្ម</u>៖ ជាតម្រុយតែមួយគត់ដែលទទួលស្គាល់ដោយ ស.ច.ស.អ ការគ្រប់គ្រងដោយប្រសិទ្ធភាព តម្រូវឲ្យមានសមត្ថភាពខាងសម្ភារៈ

---

[199] អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Halilović* (សំណុំរឿងលេខ IT-01-48-A) សាលដីកា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ ៦៨ ៧០ ១៣៩។

[200] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* (សំណុំរឿងលេខ IT-95-14/2-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១៦។ សូមមើលផងដែរ៖ អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Musema* (សំណុំរឿងលេខ ICTR-96-13-A) សាលក្រម ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៤១។

[201] អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucić* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-21-A) (រឿងក្តី *Čelebići*) សាលដីកា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ១៩៣ កថាខណ្ឌ ២៥៨-២៦៨។

[202] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* (សំណុំរឿងលេខ IT-95-14/2-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១៦, អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucić* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-21-A) (រឿងក្តី *Čelebići*) សាលដីកា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៦៦។

ក្នុងការរារាំង ឬដាក់ទណ្ឌកម្មលើអាកប្បកិរិយាឧក្រិដ្ឋកម្ម[203]។ ចំណុចតម្រូវឱ្យមានការពិចារណាលើសមត្ថភាពរបស់ជនជាប់ចោទ ក្នុងការអនុវត្តវិធានការវិន័យ ក្នុងនោះរួមទាំងសិទ្ធិអំណាចក្នុងការតម្លើង ទម្លាក់តំណែង ឬដកតំណែងអ្នកនៅក្រោមបង្គាប់[204]។

(៦) ការរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចដែលបញ្ជាក់ពីការគ្រប់គ្រងមានកម្រិត៖ ការរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ចរអំពើឧក្រិដ្ឋរបស់អ្នកនៅក្រោមបង្គាប់ ដើម្បីឱ្យចាត់វិធានការសមស្រប គឺជាការបញ្ជាក់ពីលទ្ធភាពមានកម្រិតរបស់ថ្នាក់លើ ក្នុងការដាក់ទណ្ឌកម្មដែលបង្ហាញការគ្រប់គ្រងមានកម្រិតប៉ុណ្ណោះ[205]។

(៧) កិច្ចការជាក់ស្ដែងដែលត្រូវអនុវត្ត៖ វាគឺជាការចាំបាច់ក្នុងការវិភាគកិច្ចការជាក់ស្ដែងដែលធ្វើឡើងដោយជនជាប់ចោទ[206]។

(៨) សមត្ថភាពក្នុងការចេញបញ្ជាដែលត្រូវបានអនុវត្តជាក់ស្ដែង៖ វាជាការចាំបាច់ក្នុងការវិភាគ លើអំណាចដែលរងការចោទប្រកាន់ និងវិភាគថាតើកិច្ចការដែលបានបញ្ជាឱ្យអនុវត្តបានអនុវត្តតាម ឬអត់[207]។ និយាយម្យ៉ាងទៀត វាជាការចាំបាច់ក្នុងការបង្ហាញភ័ស្តុតាងដែលថា ថ្នាក់លើមិនត្រឹមតែមានលទ្ធភាពចេញបញ្ជាប៉ុណ្ណោះទេ តែថែមទាំងថា ការបញ្ជារបស់

---

[203] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Mucić* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-21-A) (រឿងក្ដី *Čelebići*) សាលដីកា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៥៦, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Aleksovski* (សំណុំរឿងលេខ IT-95-14/1/T) សាលក្រម ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៩ កថាខណ្ឌ ១០៨, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Halilović* (សំណុំរឿងលេខ IT-01-48-A) សាលដីកា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ ៥៩។

[204] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Delić* (សំណុំរឿងលេខ IT-04-83-T) សាលក្រម ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ ៦២។

[205] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Blaškić* (សំណុំរឿងលេខ IT-95-14-A) សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៤៩៩។

[206] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Halilović* (សំណុំរឿងលេខ IT-01-48-A) សាលដីកា ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៧ កថាខណ្ឌ ៦៦, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Perišić* (សំណុំរឿងលេខ IT-04-81-T) សាលក្រម ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៤៨។

[207] អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTY រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* (សំណុំរឿងលេខ IT-95-14/2-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១៩ ដល់កថាខណ្ឌ ៤២៤។

ថ្នាក់លើត្រូវបានអនុវត្តពិតប្រាកដទៀតផង[208]។ វាជាការចាំបាច់ក្នុងការពិចារណាពីអំណាចរបស់ជនចាប់ចោទក្នុងការបញ្ជាឱ្យអនុវត្តសកម្មភាពប្រយុទ្ធ និងរៀបចំឡើងវិញនូវអង្គភាពក្រោមបង្គាប់ ព្រមទាំងអំណោយផលធនធានសម្ភារៈ និងមនុស្ស[209]។

(៩) ឥទ្ធិពលសំខាន់ៗ មិនមែនជាការគ្រប់គ្រងដោយប្រសិទ្ធភាពទេ៖ "ការគ្រប់គ្រងដោយប្រសិទ្ធភាព" មិនអាចចាត់ទុកថាស្មើនឹង ឬត្រូវបានជំនួសដោយ "ឥទ្ធិពលសំខាន់ៗ"[210] នោះទេ។ មានតែភ័ស្តុតាងនៃការគ្រប់គ្រងដោយប្រសិទ្ធភាព ទើបអាចមានលក្ខណៈគ្រប់គ្រាន់ដល់ការទទួលខុសត្រូវ ព្រហ្មទណ្ឌ[211]។

(១០) ការគ្រប់គ្រង ចាំបាច់ត្រូវមានប្រសិទ្ធភាព នៅពេលប្រព្រឹត្តឧក្រិដ្ឋកម្ម៖ ថ្នាក់លើម្នាក់មិនអាចត្រូវបានចាត់ទុកថាមានការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយអ្នកនៅក្រោម

---

[208] អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Popović* និងអ្នកឯទៀត (សំណុំរឿងលេខ IT-05-88-T) សាលក្រម ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១០៣៨, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* (សំណុំរឿងលេខ IT-95-14-A) សាលដីកា ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៦៩, អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Strugar* (សំណុំរឿងលេខ IT-01-42-A) សាលដីកា ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៨ កថាខណ្ឌ ២៥៤ និងកថាខណ្ឌ ២៥៦, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* (សំណុំរឿងលេខ IT-95-14/2-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤២១។

[209] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Perišić* (សំណុំរឿងលេខ IT-04-81-T) សាលក្រម ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៤៨, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Strugar* (សំណុំរឿងលេខ IT-01-42-T) សាលក្រម ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៥ កថាខណ្ឌ ៣៩៣-៣៩៧។

[210] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Mucić* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-21-A) (រឿងក្តី *Čelebići*) សាលដីកា ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ២៦៦ និងកថាខណ្ឌ ៣០៣។ សូមមើលផងដែរ៖ អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Krnojelac* (សំណុំរឿងលេខ IT-97-25-T) សាលក្រម ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០០២ កថាខណ្ឌ ៩៣, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stakić* (សំណុំរឿងលេខ IT-97-24-T) សាលក្រម ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៤៥៩, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karera* (សំណុំរឿងលេខ ICTR-01-74-T) សាលក្រម ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ៥៦៤។

[211] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kordić* និង *Čerkez* (សំណុំរឿងលេខ IT-95-14/2-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៤១៥-៤១៦។

បង្គាប់នោះទេ មុនពេលថ្នាក់លើរូបនេះ បានទទួលតួនាទី ជាថ្នាក់លើរបស់អ្នកនៅក្រោមបង្គាប់ចំពោះបញ្ហាដែលរងការចោទប្រកាន់[212]។ វាត្រូវតែមានការបញ្ជាក់ថា គាត់មានការគ្រប់គ្រងដោយប្រសិទ្ធភាពក្នុងពេលការប្រព្រឹត្តបទល្មើស[213]។

៨៤. ស.ច.ស.អ ខកខានមិនបានពន្យល់អំពីលក្ខខណ្ឌតម្រូវនៃកម្រិតអប្បរមាដើម្បីបញ្ជាក់អំពីការទទួលខុសត្រូវរបស់មេបញ្ជាការឡើយ[214]។ វាមិនមានភាពច្បាស់លាស់ថាតើមានមូលដ្ឋានគតិយុត្តិអ្វីដែល ស.ច.ស.អ សំអាងលើ ដើម្បីកំណត់ថា លោក យឹម ទិត្យ បានធ្វើការគ្រងគ្រងដោយប្រសិទ្ធភាពទៅលើអ្នកនៅក្រោមបង្គាប់ដែលត្រូវបានចោទនោះ។

*ខ. លក្ខខណ្ឌតម្រូវតាមវិធាន ៦៧(២) ក្នុងការកំណត់ពីអង្គហេតុសំខាន់ៗ និងភ័ស្តុតាងជាមូលដ្ឋាន*

៨៥. ស.ច.ស.អ ខកខានមិនបានលើកឡើងពីតម្រុយនៃការគ្រប់គ្រងដោយប្រសិទ្ធភាព និងកំណត់ថាអ្វីជាអង្គហេតុសំខាន់ៗ ដែលបង្ហាញពីអត្ថិភាពនៃតម្រុយទាំងនោះ ប្រសិនជាមាន។ ដោយសារការខកខាននេះ សំអាងហេតុរបស់ ស.ច.ស.អ ដែលថា លោក យឹម ទិត្យ ជា ""គឺជាមេបញ្ជាការ *តាមព្រឹត្តន័យ* ទីពីររបស់តាម៉ុក និង [...] គាត់ក៏មានសិទ្ធិអំណាច *តាមព្រឹត្តន័យ* ទៅលើសកម្មភាពតាមតំបន់មុនៗរបស់គាត់នៅក្នុងភូមិភាគពាយ័ព្យហើយក៏ដោយ[215]" និង "បានធ្វើការគ្រប់គ្រងដោយប្រសិទ្ធភាពទៅលើកម្មាភិបាលស៊ីវិល និងយោធាដែលជាអ្នកនៅក្រោមបង្គាប់របស់គាត់[216]" ពុំមានមូលដ្ឋានគាំទ្រ និងពុំមានសុពលភាពឡើយ។

៨៦. អង្គហេតុសំខាន់ៗ និងភ័ស្តុតាងជាមូលដ្ឋាន ត្រូវតែផ្តល់មូលដ្ឋានគាំទ្រដល់អត្ថិភាពនៃការគ្រប់គ្រង

---

[212] អង្គជំនុំជម្រះសាលាដំបូងទី ២ នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Popović* និងអ្នកឯទៀត (សំណុំរឿងលេខ IT-05-88-T) សាលក្រម ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ១០៣៩។

[213] អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Kunarac* និងអ្នកឯទៀត (សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T) សាលក្រម ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៣៩៩, អង្គជំនុំជម្រះសាលាដំបូង នៃតុលាការ ICTR រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karera* (សំណុំរឿងលេខ ICTR-01-74-T) សាលក្រម ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០០៧ កថាខណ្ឌ ៥៦៤។

[214] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៧ ដល់កថាខណ្ឌ ១០៣។

[215] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤។

[216] ដូចយោងខាងលើ កថាខណ្ឌ ១០៣៣។

ដោយប្រសិទ្ធភាព។ ដូច្នេះ តម្រុយនៃការគ្រប់គ្រងដោយប្រសិទ្ធភាព គឺជាកត្តាដែលមានគុណតម្លៃភស្តុតាងដ៏សំខាន់ដែលត្រូវពិចារណា[217]។ ជាពិសេស វាមានសារៈសំខាន់ នៅពេលទំនាក់ទំនងរវាងថ្នាក់លើ និងអ្នកនៅក្រោមបង្គាប់ មានអត្ថិភាព*តាមព្រឹត្តិន័យ* ដូចបានលើកឡើងនៅក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស.អ[218]។ ទោះជាយ៉ាងនេះក្តី សំអាងច្បាប់របស់ ស.ច.ស.អ ដែលថា លោក យឹម ទិត្យ ធ្វើការគ្រប់គ្រងដោយប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់ ពុំត្រូវបានគាំទ្រដោយអង្គហេតុសំខាន់ៗ ឬភស្តុតាងជាមូលដ្ឋានទាំងនោះទេ[219]។ ស.ច.ស.អ ខកខានមិនបានលើកឡើងថា តម្រុយអ្វីខ្លះដែលគាត់បានសំអាងក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ បានធ្វើការគ្រប់គ្រងដោយប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់ ប្រសិនបើមាន។ ដូច្នេះ ស.ច.ស.អ ខកខានមិនបានលើកឡើងអង្គហេតុសំខាន់ៗ ដែលគាត់យល់ឃើញថា មានគុណតម្លៃភស្តុតាងសម្រាប់សំអាងហេតុស្តាពររបស់គាត់ដែលថា មានអត្ថិភាពនូវការគ្រប់គ្រងដោយប្រសិទ្ធភាពនោះ ប្រសិនបើមាន។ នៅក្នុងសំអាងច្បាប់ស្តីពីយុត្តាធិការបុគ្គល និងការទទួលខុសត្រូវរបស់ថ្នាក់លើ ស.ច.ស.អ មិនបានលើកឡើងអំពីតម្រុយនៃការគ្រប់គ្រងដោយប្រសិទ្ធភាព និងមិនដកស្រង់មូលដ្ឋានអង្គហេតុណាដែលអាចគាំទ្រដល់អត្ថិភាពនៃការគ្រប់គ្រងដោយប្រសិទ្ធភាពឡើយ[220]។

៨៧. ស.ច.ស.អ ខកខានមិនបានលើកឡើងពីលក្ខខណ្ឌតម្រូវដែលត្រឹមត្រូវ ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវរបស់ថ្នាក់លើ មូលដ្ឋានអង្គហេតុ និងភស្តុតាងគាំទ្រ ដែលត្រូវបានប្រើ ដើម្បីកំណត់ថា លោក យឹម ទិត្យ គឺមេបញ្ជាការទី ២ នៃភូមិភាគនិរតី និងភូមិភាគពាយព្យ ដូច្នេះគឺជា "បុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលបណ្តាលឲ្យមានកំហុសនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ[221]។ ដោយហេតុថា បទចោទទាំងអស់ប្រឆាំងនឹងលោក យឹម ទិត្យ ផ្អែកលើសំអាងហេតុមានសុពលភាពនៃយុត្តាធិការបុគ្គល និងតួនាទីរបស់គាត់ជា "បុគ្គលដែលទទួលខុសត្រូវជាន់ខ្ពស់បំផុត" ម្នាក់នោះ សំណុំរឿងនេះត្រូវច្រានចោលទាំងស្រុង។

[217] សូមមើលខាងលើ កថាខណ្ឌ ៨៣។

[218] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩៤។

[219] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤ ១០៣៣។

[220] ដូចយោងខាងលើ។

[221] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤។

**(ii) ស.ច.ស.អ ខកខានមិនបានលើកឡើងអំពីលក្ខខណ្ឌតម្រូវនៃភស្តុតាងបង្ហាញពីទំនាក់ទំនងហេតុ និងបច្ច័យរវាងការខកខានរបស់ថ្នាក់លើក្នុងការគ្រប់គ្រងលើអ្នកនៅក្រោមបង្គាប់ និងការកើតឡើងនៃឧក្រិដ្ឋកម្ម**

*ក. លក្ខខណ្ឌតម្រូវយោងតាមវិធាន៦៧ (២) ក្នុងការលើកឡើងធាតុផ្សំគតិយុត្តិ*

៨៨. ដោយផ្អែកទាំងស្រុងទៅលើយុត្តាសាស្ត្ររបស់សាលាក្តី *មិនអចិន្ត្រៃយ៍* ស.ច.ស.អ បានថ្លែងដោយមិនត្រឹមត្រូវថា "គេពុំបាច់បង្ហាញទំនាក់ទំនងហេតុ និងបច្ច័យរវាងការខកខានរបស់ថ្នាក់លើក្នុងការទប់ស្កាត់ឧក្រិដ្ឋកម្មរបស់អ្នកនៅក្រោមបង្គាប់ និងការកើតឡើងនៃឧក្រិដ្ឋកម្មទាំងនោះឡើយ[222]។" ក្នុងការច្រានចោលលក្ខខណ្ឌតម្រូវអំពីទំនាក់ទំនងនេះ ស.ច.ស.អ បានសំអាងមិនត្រឹមត្រូវលើយុត្តិសាស្ត្រ ដែលមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[223]។ ក្រុមមេធាវីការពារអះអាងថា វាមានភាពចាំបាច់ក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ក្នុងការបង្ហាញពីទំនាក់ទំនងហេតុ និងបច្ច័យ រវាងការខកខានរបស់ថ្នាក់លើក្នុងការគ្រប់គ្រងឲ្យបានសមស្របលើអ្នកនៅក្រោមបង្គាប់ និងការកើតឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់។

៨៩. អត្ថិភាពនៃលក្ខខណ្ឌហេតុ និងបច្ច័យ ដែលមានចែងក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ត្រូវបាន គាំទ្រដោយខ្លឹមសារក្នុងមាត្រា៨៦(១) នៃពិធីសារបន្ថែម I ដែលចែងថា៖

> ភាគីជាប់កិច្ចសន្យាជាន់ខ្ពស់ និងភាគីផ្សេងៗទៀតនៃជម្លោះ ត្រូវបញ្ឈប់ការរំលោភបំពានធ្ងន់ធ្ងរ និងចាត់វិធានការនានាដែលចាំបាច់ក្នុងការដោះស្រាយការរំលោភបំពានដទៃទៀតទាំងអស់លើអនុសញ្ញានេះ ឬពិធីសារនេះ *ដែលបណ្តាលមកពី* ការខកខានក្នុងការចាត់វិធានការ នៅពេលដែលខ្លួនមានភារកិច្ចក្នុងការធ្វើដូច្នេះ[224]។

---

[222] ដូចយោងខាងលើ កថាខណ្ឌ ៨៨។

[223] ដូចយោងខាងលើ កថាខណ្ឌ ៨៨ ដកស្រង់៖ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Hadžihasanović* និង *Kubura* (សំណុំរឿងលេខ IT-01-47-A) សាលដីកា ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ ៤០។

[224] ពិធីសារទី ១ បន្ថែមទៅនឹងកិច្ចព្រមព្រៀងទីក្រុងហ្សឺណែវ មាត្រា ៨៦(១) (សេចក្តីបញ្ជាក់បន្ថែម)។

៩០. គួរឱ្យកត់សម្គាល់ ការបញ្ជាក់នេះត្រូវបានឆ្លុះបញ្ចាំងក្នុងមាត្រា ២៨ នៃលក្ខន្តិកៈក្រុងរ៉ូម[225] ហើយ និងមានការកំណត់ពីយុត្តាធិការអន្តរជាតិនាពេលថ្មីនេះពីអ្វីដែលបានសម្រេចនៅសាលាក្តី *មិនអចិន្ត្រៃយ៍* ចាប់តាំងឆ្នាំ ២០១៨ ថា លក្ខខណ្ឌទំនាក់ទំនងនេះ នៅតែជាផ្នែកសំខាន់មួយនៃបទដ្ឋានទំនៀមទម្លាប់អន្តរជាតិរហូតមកពេលបច្ចុប្បន្ន[226]។ ដូចចៅក្រម Monageng និង Hofmański នៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) បានទទួលស្គាល់ "ការទទួលខុសត្រូវ "ផ្នែកព្រហ្មទណ្ឌរបស់មេបញ្ជាការចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការតុលាការ" ត្រូវបានប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ អាចទទួលយកបាន និងមានភាពសមហេតុផល ប្រសិនបើមានទំនាក់ទំនងជាបុគ្គល រវាងឧក្រិដ្ឋកម្ម និងថ្នាក់លើ" ដោយហេតុថា "វានឹងមិនស្របទៅនឹងគោលការណ៍ជាមូលដ្ឋាននៃច្បាប់ព្រហ្មទណ្ឌឡើយ ប្រសិនបើថ្នាក់លើ ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលពុំមានទំនាក់ទំនងជាមួយខ្លួនទេនោះ"[227]។

៩១. ទោះបីជាលក្ខខណ្ឌហេតុ និងបច្ច័យ មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ក៏ដោយ ក៏មានការបញ្ជាក់យ៉ាងច្បាស់បែបនោះ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ[228]។ ដូច្នេះ ស.ច.ស.អ ត្រូវអនុវត្តគោលការណ៍ *lex mitior* និងអនុវត្តច្បាប់ដែលតម្រូវឱ្យមាន

---

[225] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៨។

[226] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Jean-Pierre Bemba Gombo ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទី ៣ អនុលោមតាមមាត្រា៧៤ នៃលក្ខន្តិកៈ" "យោបល់ដោយឡែករបស់ចៅក្រម Sanji Mmasenono Monageng និងចៅក្រម Piotr Hofmański" ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ សំណុំរឿងលេខ ICC-01/05-01/08-3636-Anx1-Red កថាខណ្ឌ ៣៣៤, សាលក្រម អនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ យោបល់ដោយឡែករបស់ចៅក្រម Sylvia Steiner ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៦ សំណុំរឿងលេខ ICC-01/05-01/08-3343 កថាខណ្ឌ ៦-៨ ដកស្រង់៖ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ *មតិយោបល់លើពិធីសារបន្ថែម ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៧៧ ទៅនឹងអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩* (ឆ្នាំ១៩៨៧) ទំព័រ ១០១០ កថាខណ្ឌ ៣៥៣៨។

[227] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bemba* "សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក Jean-Pierre Bemba Gombo ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងទី ៣ អនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ" យោបល់ដោយឡែករបស់ចៅក្រម Sanji Mmasenono Monageng និងចៅក្រម Piotr Hofmański ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ សំណុំរឿងលេខ ICC-01/05-01/08-3636-Anx1-Red កថាខណ្ឌ ៣៣៤។

[228] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៨។

លក្ខខណ្ឌហេតុ និងបច្ច័យ[229]។

*ខ. លក្ខខណ្ឌតម្រូវក្រោមវិធាន៦៧(២) ដើម្បីកំណត់ពីអង្គហេតុសំខាន់ៗ និងភ័ស្តុតាងជាមូលដ្ឋាន*

៩២. ស.ច.ស.អ ខកខានមិនបានកំណត់អង្គហេតុសំខាន់ៗ និងភ័ស្តុតាងជាមូលដ្ឋាននៃទំនាក់ទំនងហេតុ និងបច្ច័យ រវាងការខកខានរបស់លោក យឹម ទិត្យ ដែលត្រូវបានចោទថាជាថ្នាក់លើ ក្នុងការគ្រប់គ្រងលើអ្នកនៅក្រោមបង្គាប់ឲ្យបានសមស្រប និងការកើតឡើងនៃឧក្រិដ្ឋកម្មដែលប្រព្រឹត្តដោយអ្នកនៅក្រោមបង្គាប់ទាំងនោះ។ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនទទួលស្គាល់លក្ខខណ្ឌហេតុ និងបច្ច័យដ៏សំខាន់នេះ និងដោយខកខានមិនបានផ្តល់មូលដ្ឋានភ័ស្តុតាងមួយសម្រាប់ទំនាក់ទំនងហេតុ និងបច្ច័យនេះ។ មិនឃើញមាននៅក្នុងសំអាងច្បាប់របស់ ស.ច.ស.អ ស្តីពីយុត្តាធិការបុគ្គល និងការទទួលខុសត្រូវរបស់ថ្នាក់លើ ថាតើការខកខានរបស់លោក យឹម ទិត្យ ដែលជាថ្នាក់លើនោះ បង្កឲ្យមាន ឬមានទំនាក់ទំនងបែបណាចំពោះឧក្រិដ្ឋកម្មនីមួយៗក្នុងចំណោមឧក្រិដ្ឋកម្មជាច្រើនដែលរងការចោទរបស់អ្នកនៅក្រោមបង្គាប់របស់គាត់។ ជាលទ្ធផលនៃការខកខាននេះ ស.ច.ស.អ មិនបានព្យាយាមធ្វើការបែកចែករវាងឧក្រិដ្ឋកម្មដែលបានកើតឡើងក្រោម "ទម្រង់នៃការទទួលខុសត្រូវតាមផ្លូវច្បាប់ និងអង្គហេតុ" នៃការខកខានមិនបានទប់ស្កាត់ និងមិនបានដាក់ទណ្ឌកម្ម[230]។

*<u>សេចក្តីសន្និដ្ឋាន</u>*

៩៣. ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនលើកឡើងអំពីធាតុផ្សំគតិយុត្តិនៃមាត្រា ២៩ និងខកខានផងដែរមិនបានបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៦៧(២) ដោយមិនបានបញ្ជាក់គ្រប់គ្រាន់អំពីអង្គហេតុសំខាន់ៗ និងភ័ស្តុតាងទាក់ទងនឹងតម្រុយនៃការគ្រប់គ្រងដោយប្រសិទ្ធភាពសម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ និងលក្ខខណ្ឌទំនាក់ទំនងហេតុ និងបច្ច័យ ដែលធ្វើឲ្យក្រុមមេធាវីការពារក្តី មិនអាចកំណត់បានពីខ្លឹមសារនៃបទចោទ និងមិនផ្តល់មូលដ្ឋានគ្រប់គ្រាន់សម្រាប់ការជំនុំជម្រះក្តីលើផ្នែកទាំងនេះនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដែលរំលោភបំពានទៅលើសិទ្ធិជាមូលដ្ឋាន

---

229 សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ៣៣៣ កំណត់សម្គាល់ជើងទំព័រលេខ ៩០៥។

230 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០០ កថាខណ្ឌ ១០៣៣។

ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ដែលត្រូវបានជូនដំណឹងអំពីរឿងក្តីប្រឆាំងនឹងរូបគាត់ និងដើម្បីរៀបចំសម្រាប់ការការពារក្តី ជាការរំលោភបំពានលើវិធាន ២១ (១) (ឃ)។

## ខ. សេចក្តីសន្និដ្ឋាន

៩៤. ផ្អែកលើសំអាងហេតុខាងលើ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះមិនបានបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៦៧ (២) និងរំលោភបំពានលើសិទ្ធិរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ បទចោទអំពើប្រល័យពូជសាសន៍ទាំងនេះ និងបទចោទផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើ ត្រូវតែច្រានចោល ផ្អែកលើកំហុសនីតិវិធីទាំងនោះ ដែលបានសំអាងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ។ ការមិនអនុវត្តស្របតាមវិធាន ៦៧(២) ស្តីពីសំអាងហេតុលើ "ការទទួលខុសត្រូវខ្ពស់បំផុត" តម្រូវឲ្យច្រាលចោលបទចោទដែលសេសសល់ទាំងអស់។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ ស.ច.ស.អ ទៅលើលោក យឹម ទិត្យ ជាបុគ្គលស្ថិតក្នុងយុត្តាធិការនៃសាលាក្តីនេះ មិនមានយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលជាការបំពានលើឆន្ទានុសិទ្ធិ។ ដោយហេតុថា សុពលភាពនៃបទចោទទាំងអស់ប្រឆាំងនឹងលោក យឹម ទិត្យ ត្រូវផ្អែកទៅលើសំអាងហេតុដែលមានសុពលភាពនៃយុត្តាធិការបុគ្គលនោះ សំណុំរឿងនេះត្រូវច្រានចោលទាំងស្រុង។

## III. មូលដ្ឋានទី ៣៖ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារបានពង្រីកវិសាលភាពអង្គហេតុនៅក្នុងកិច្ចស៊ើបសួរ

## ក. វិធាន ៥៥(២) កម្រិតវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ

៩៥. វិធាន ៥៥(២) ចែងថា "សហចៅក្រមស៊ើបអង្កេតត្រូវធ្វើស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"។ ស.ច.ស ទាំងពីរ អាចចោទប្រកាន់បញ្ជូនទៅជំនុំជម្រះផ្អែកលើកិច្ចស៊ើបសួរចំពោះអង្គហេតុដែលខ្លួនទទួលវិនិច្ឆ័យប៉ុណ្ណោះ គឺ អង្គហេតុដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿង

ឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[231]។ វិធាន ៥៥(២) ចែងច្បាស់ថា ស.ច.ស ទាំងពីរពុំមានយុត្តាធិការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះនូវអង្គហេតុទាំងឡាយណានៅក្រៅកិច្ចស៊ើបសួរនោះឡើយ[232]។ អញ្ញត្រកម្មតែមួយគត់នៅក្នុងវិធាន ៥៥(៣) គឺពាក់ព័ន្ធនឹងស្ថានទម្ងន់ទោស និងពុំបញ្ចូលអំពើល្មើសរបស់រូបវន្តបុគ្គលនោះទេ[233]។

៩៦. វិធាន ៦៧(១) ចែងថា ស.ច.ស ទាំងពីរ "សហចៅក្រមស៊ើបអង្កេតត្រូវបញ្ចប់កិច្ចស៊ើបសួរដោយចេញដីកាដំណោះស្រាយថាត្រូវចោទប្រកាន់ និងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬ លើកលែងការចោទប្រកាន់"។ ស.ច.ស ទាំងពីរ និង អ.ប.ជ បានសម្រេចថា មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ស្របតាមវិធាន ៦៧(១) តែប៉ុណ្ណោះ ដែលអាចយកមកពិចារណាចោទប្រកាន់បាន[234]។ អ.ប.ជ បានសម្រេចថា "សហចៅក្រមស៊ើបអង្កេតនៅតែទទួលបានគ្រប់អង្គហេតុទាំង

---

[231] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៨, ឯកសារ D308/3/1/20 មតិយោបល់របស់ចៅក្រម Beauvallet និង Baik កថាខណ្ឌ ១២៨។

[232] សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេកអ៊ាវ ហៅ "ឌុច" ចុះថ្ងៃទី៥ ខែធ្នូ ឆ្នាំ ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៣៦៖ "សហចៅក្រមស៊ើបអង្កេតមិនមានយុត្តាធិការក្នុងការស៊ើបសួរអំពើផ្សេងៗឡើយ លើកលែងតែមានការស្នើសុំពីសហព្រះរាជអាជ្ញា"។

[233] វិធាន ៥៥(៣) ចែងថាកា អង្គហេតុដែលកម្រិតត្រឹម "ស្ថានទម្ងន់ទោស" ពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានដែលមានស្រាប់មិនអាចទាមទារឱ្យមានសេចក្តីសន្និដ្ឋានបន្ថែមនោះទេ។

[234] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ ២០១៧ ឯកសារ D308/3 កថាខណ្ឌ ២៤៥។ សំណុំរឿង ០០៤/២ ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D360 កថាខណ្ឌ ៤៧។ សំណុំរឿង ០០៤/២ ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០១៨ ឯកសារ D359 កថាខណ្ឌ ៧៤។ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹង ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៥៖ "នៅក្នុងប្រព័ន្ធស៊ីវិលឡូ មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ជាមុនតែប៉ុណ្ណោះទើបអាចយកមកពិចារណាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន។ [...] សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់យ៉ាងច្បាស់ថា [...] សហចៅក្រមស៊ើបអង្កេតនឹងធ្វើសេចក្តីសម្រេចនៅក្នុងដីកាដំណោះស្រាយអំពីអង្គហេតុទាំងអស់ដែលសហចៅក្រមស៊ើបអង្កេតបានទទួលត្រឹមត្រូវ "ដោយអាចនឹងធ្វើការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះនៅមុខអង្គជំនុំជម្រះសាលាដំបូង បន្ទាប់ពីដាក់ពួកគេឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ឬ ចេញដីកាលើកលែងការចោទប្រកាន់ [...]"។ ការសម្រេចនេះផ្ទុះបញ្ចាំងបទប្បញ្ញត្តិជាក់លាក់នៃវិធាន ៦៧(១) នៃវិធានផ្ទៃក្នុង ដែលយោងតាមបទប្បញ្ញត្តិនេះដីកាដំណោះស្រាយអាចចោទ

អស់នៅឡើយ ហើយអាចកែប្រែបទចោទបានរហូតដល់ពេលចេញដីកាដំណោះស្រាយ”[235]។ ដូច្នេះ ទោះបីជាដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវផ្អែកលើការចោទប្រកាន់ពីមុនក៏ដោយ ក៏វិសាលភាពនៃអង្គហេតុដែលអាចចោទប្រកាន់បាន នៅតែបន្តស្ថិតក្រោមការកំណត់ដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម រហូតដល់ពេលមានការចេញដីកាដំណោះស្រាយ[236]។

## ខ. ដីកាដំណោះស្រាយរបស់ ស.ច.ស.អ ពង្រីកហួសវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលច្បាប់អនុញ្ញាត

៩៧. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម កំណត់ព្រំដែនវិសាលភាពពេលវេលា និងភូមិសាស្ត្រនៃកិច្ចស៊ើបសួរ៖

ក. ការចោទប្រកាន់នៅក្នុងភូមិភាគនិរតីចាប់ពីឆ្នាំ១៩៧៦ រហូតដល់ ឆ្នាំ១៩៧៨[237]។

ខ. ការចោទប្រកាន់នៅក្នុងភូមិភាគពាយ័ព្យចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី០៦

---

ប្រកាន់ “ជនត្រូវចោទ” បញ្ជូនទៅជំនុំជម្រះ ហើយនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងបារាំង ដែលយោងតាមនីតិវិធីទាំងនេះ បុគ្គលដែលត្រូវបានចោទប្រកាន់ជាមុនទើបអាចត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន”។

[235] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៨។

[236] វិធាន ៥៧(១) ចែងថា ស.ច.ស ត្រូវជូនដំណឹង និងចោទប្រកាន់ លោក យឹម ទិត្យ ចំពោះអង្គហេតុថ្មីនៅមុនពេលចោទប្រកាន់បញ្ជូនគាត់ទៅជំនុំជម្រះ ដោយតម្រូវឲ្យ ស.ច.ស បើកកិច្ចស៊ើបសួរឡើងវិញដើម្បីផ្ដល់ឱកាសឲ្យ លោក យឹម ទិត្យសម្រេចត ត្រៀមរៀបចំការពារក្ដី និងអនុវត្តសិទ្ធិរបស់គាត់។ សូមមើល សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរ ទាក់ទងអំពើហិង្សាផ្លូវភេទ នៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៨ ឯកសារ D365/3/1/5 កថាខណ្ឌ ៣៥ ដល់ កថាខណ្ឌ ៣៦។

[237] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់ ស.ព.អ ឯកសារ D1 កថាខណ្ឌ ៩៣។ “តាទិត ជាលេខាស្រុកគីរីវង់ (ស្រុក ១០៩) នៅក្នុងខេត្តតាកែវ ដែលជាផ្នែកមួយរបស់តំបន់ ១៣ ភូមិភាគនិរតី ចាប់ពីឆ្នាំ១៩៧៦ រហូតដល់ចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨”។

ខែមករា ឆ្នាំ១៩៧៩[238]។

៩៨. ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមពុំបានពង្រីកវិសាលភាពពេលវេលា ឬភូមិសាស្ត្រនៃកិច្ចស៊ើបសួរនៅក្រៅការកំណត់ទាំងនេះទេ[239]។

**(i) ក្រោយ "ដើមឆ្នាំ១៩៧៨" នៅក្នុងភូមិភាគនិរតី**

៩៩. ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយបានចោទប្រកាន់បញ្ជូនលោក យឹម ទិត្យ ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មនៅក្នុងភូមិភាគនិរតី ដោយផ្អែកលើមូលដ្ឋានថា ការទទួលខុសត្រូវរបស់គាត់ជាសមាជិកនៃ "សហឧក្រិដ្ឋកម្មរួម ខ" និង "សហឧក្រិដ្ឋកម្មរួម គ" បានបន្តរហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[240]។ ករណីនេះហួសដែនកំណត់នៃយុត្តាធិការពេលវេលា "រហូតដល់ដើមឆ្នាំ១៩៧៨" នៅក្នុងភូមិភាគនិរតី[241]។

១០០. ស.ច.ស.អ បានយល់ឃើញថា លោក យឹម ទិត្យ "មានសិទ្ធិអំណាចនៅលើតំបន់នៃភូមិភាគនិរតីហើយនៅតែបន្ត បន្ទាប់ពីបានផ្លាស់មកភូមិភាគពាយព្យ"[242] (ការសម្រេចដែល ស.ច.ស.អ បានយកមកសំអាងដើម្បីវាយតម្លៃយុត្តាធិការបុគ្គល[243])។ ស.ច.ស.អ បានទទួលស្គាល់អនីត្យានុកូល

---

[238] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់ ស.ព.អ ឯកសារ D1 កថាខណ្ឌ ៩៤។ "នៅពាក់កណ្តាលឆ្នាំ១៩៧៧ តាម៉ុក តា ទិត និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត របស់បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំផែនការ និងបានផ្តួចផ្តើមឲ្យមានការបោសសម្អាតយ៉ាងរង្គាលមួយនៅក្នុភូមិភាគពាយ័ព្យ [...]"។

[239] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០១១ ឯកសារ D65 កថាខណ្ឌ ១៣៖ "ដូចដែលបានលើកឡើងរួចមកហើយនៅក្នុងកថាខណ្ឌទី៩៣ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី ជនជាប់ចោទឈ្មោះ យឹម ទិត ហៅ តា ទិត គឺជាលេខា ប.ក.ក នៃស្រុកគីរីវង្ស ចាប់តាំងពីឆ្នាំ១៩៧៦ ដល់ ឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨"។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191 កថាខណ្ឌ ៨៖ "យឹម ទិត បានក្លាយជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យនៅពាក់កណ្តាលឆ្នាំ១៩៧៨ [...]"។

[240] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០១៦(ii) និង (iii) និងកថាខណ្ឌ ១០១៨។

[241] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់ ស.ព.អ ឯកសារ D1 កថាខណ្ឌ ៩៣។

[242] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០២០៖ "ចំណុចដែលត្រូវបញ្ជាក់គឺថា ទោះបីជាមិនចោទប្រកាន់ដូច្នេះក៏ដោយ"។

[243] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤ កថាខណ្ឌ ៩៩៦។

នៃការសំអាងលើអង្គហេតុទាំងនេះ ដែលកើតឡើងនៅក្រោយ "ដើមឆ្នាំ១៩៧៨" ប៉ុន្តែ បែរជាបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ហើយយកអង្គហេតុទាំងនេះមកពិចារណាទៅវិញ[244]។ ស.ច.ស.អ ពុំមានអំណាចធ្វើដូច្នេះនោះទេ។

**(ii) មុនបំណាច់ឆ្នាំ១៩៧៥ នៅមន្ទីរសន្តិសុខវត្តព្រះធាតុក្នុងភូមិភាគនិរតី**

១០១. ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារបានចោទប្រកាន់បញ្ជូន លោក យឹម ទិត្យ ទៅជំនុំជម្រះពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់គាត់ក្នុងក្របខណ្ឌ "សហឧក្រិដ្ឋកម្មរួម គ" ចាប់ពីខែកញ្ញា ឆ្នាំ១៩៧៥ "នៅពេលគាត់បានឡើងកាន់តំណែងជាច្រើននៅក្នុងស្រុកគីរីវង់" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តព្រះធាតុ[245] (ការសម្រេចដែល ស.ច.ស.អ យកមកសំអាងដើម្បីវាយតម្លៃលើយុត្តាធិការបុគ្គល[246])។ វិសាលភាពផ្នែកអង្គហេតុនៃកិច្ចស៊ើបសួរលើការទទួលខុសត្រូវរបស់លោក យឹម ទិត្យ ចំពោះឧក្រិដ្ឋកម្មនៅវត្តព្រះធាតុ ដែលស្ថិតនៅក្នុងភូមិភាគនិរតី ត្រូវបានកំណត់ដោយ ស.ព.អ ត្រឹម "ចាប់ពីឆ្នាំ១៩៧៦ រហូតមក"[247]។

**(iii) នៅមុន "ពាក់កណ្តាលឆ្នាំ១៩៧៧" នៅក្នុងភូមិភាគពាយ័ព្យ**

១០២. ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារបានចោទប្រកាន់លោក យឹម ទិត្យ ទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្ម នៅក្នុងភូមិភាគពាយ័ព្យចាប់ពី "យ៉ាងហោចណាស់ ដើមឆ្នាំ១៩៧៩" ក្នុងនាមជាសមាជិក "សហឧក្រិដ្ឋកម្មរួម ក" នៅមុនពេលគាត់ត្រូវបានគេអះអាងថាត្រូវបានបញ្ចូលក្នុងតួនាទីផ្លូវការនៅភូមិភាគពាយ័ព្យ[248] (ការសម្រេចដែល ស.ច.ស.អ យកមកសំអាងដើម្បីវាយតម្លៃលើយុត្តាធិការបុគ្គល[249])។ ស.ច.ស.អ បានលើកឡើងថា លោក យឹម ទិត្យ "សិទ្ធិអំណាច*តាមព្រឹត្តន័យ* របស់គាត់ហួសពីការផ្តល់ឲ្យគាត់ជាផ្លូវការតាមរយៈការតែងតាំងជាផ្លូវការរបស់គាត់ទៅទៀត ប៉ុន្តែ វាបានកើតឡើងតាមរយៈទំនាក់ទំនងជាបុគ្គលយ៉ាងជិតស្និទ្ធជាមួយតាម៉ុក ដែលជា

---

[244] ដូចយោងខាងលើ កថាខណ្ឌ ១០២០។

[245] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(i) និងកថាខណ្ឌ ១០១៧(i)។

[246] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤ កថាខណ្ឌ ៩៩៧។

[247] ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបី របស់ ស.ព.អ ឯកសារ D1 កថាខណ្ឌ ៩៣។

[248] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០១៦(i) និងកថាខណ្ឌ ១០១៧(i)។

[249] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤ កថាខណ្ឌ ៩៩៨។

មនុស្សកំពូលសម្រាប់ប្រតិបត្តិការនៅក្នុងភូមិភាគទាំងពីរ"[250]។ ស.ច.ស.អ បានទទួលស្គាល់ពីភាពអនីត្យានុកូលនៃកិច្ចស៊ើបសួរ ឬចោទប្រកាន់បញ្ជូនលោក យឹម ទិត្យ ទៅជំនុំជម្រះចំពោះការទទួលខុសត្រូវរងបស់គាត់នៅក្នុងភូមិភាគពាយ័ព្យ នៅមុន "ពាក់កណ្ដាលឆ្នាំ១៩៧៧" ប៉ុន្តែបែរជាបានបំពានឆន្ទានុសិទ្ធិរបស់ខ្លួន ហើយបានយកករណីនេះមកពិចារណាទៅវិញ[251]។

## គ. សេចក្តីសន្និដ្ឋាន

១០៣. ស.ច.ស.អ បានបកស្រាយមិនត្រឹមត្រូវលើវិធាន ៥៥(២) និងបានពង្រីកវិសាលភាពអង្គហេតុនៃកិច្ចស៊ើបសួរដោយបានចោទប្រកាន់លោក យឹម ទិត្យ ទៅជំនុំជម្រះ ដោយផ្អែកលើការចោទប្រកាន់អំពីអំពើរបស់គាត់នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ដោយក្នុងអង្គហេតុនេះ ស.ច.ស.អ ពុំដែលបានទទួលមកវិនិច្ឆ័យជាផ្លូវការនោះទេ[252]។ កំហុសអង្គច្បាប់នេះមានភាពអយុត្តិធម៌ និងមិនសមហេតុផលខ្លាំង ដែលជាការបំពានឆន្ទានុសិទ្ធិ។ ហេតុដូច្នេះ អ.ប.ជ ត្រូវមោឃភាពបទចោទទាំងអស់របស់ ស.ច.ស.អ ដែលបានសំអាងលើ៖

- ការទទួលខុសត្រូវរបស់ លោក យឹម ទិត្យ ក្រោយ "ដើមឆ្នាំ១៩៧៨" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងភូមិភាគនិរតី រួមទាំង មន្ទីរសន្តិសុខវត្តព្រះធាតុផងដែរ។
- លើសពីនេះ ការទទួលខុសត្រូវរបស់ លោក យឹម ទិត្យ នៅមុនថ្ងៃទី១ ខែមករា ឆ្នាំ១៩៧៦ ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តព្រះធាតុ។
- ការទទួលខុសត្រូវរបស់ លោក យឹម ទិត្យ នៅមុន "ពាក់កណ្ដាលឆ្នាំ១៩៧៧" ចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងភូមិភាគពាយ័ព្យ។

---

[250] ដូចយោងខាងលើ កថាខណ្ឌ ១០២០។

[251] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបី របស់ ស.ព.អ ឯកសារ D1 កថាខណ្ឌ ៩៤។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពុំពង្រីកវិសាលភាពនៃកិច្ចស៊ើបសួរនៅក្នុងករណីនេះទេ។

[252] សំណុំរឿង ០០៤/១ សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៨ មតិយោបល់របស់ចៅក្រម Beauvallet និង Baik ឯកសារ D308/3/1/20 កថាខណ្ឌ ១២៨។

## IV. មូលដ្ឋានទី ៤÷ ស.ច.ស.អ មានកំហុសអង្គច្បាប់ ដោយសារបានប្រើប្រាស់ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ជាមូលដ្ឋានសម្រាប់កត្តាពាក់ព័ន្ធ ដើម្បីវាយតម្លៃលើយុត្តាធិការបុគ្គល

១០៤. កិច្ចប្រឹងប្រែងខ្លាំងបំផុតរបស់មេធាវីការពារក្តីក្នុងការស្វែងយល់សំអាងច្បាប់របស់ ស.ច.ស.អ ស្តីពីយុត្តាធិការបុគ្គល បង្ហាញថា ការទទួលខុសត្រូវនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានប្រើប្រាស់ដើម្បីជាមូលដ្ឋានពិចារណា ដែលបង្ហាញថា លោក យឹម ទិត្យ គឺជាអ្នកទទួលខុសត្រូវខ្ពស់បំផុតម្នាក់[253]។ ភាសាដែលប្រើប្រាស់ដោយ ស.ច.ស.អ នៅក្នុងសំអាងច្បាប់របស់ខ្លួន រួមជាមួយ រចនាសម្ព័ន្ធនៃដីកាដំណោះស្រាយរបស់ ស.ច.ស.អ ជារួម បង្ហាញថា ស.ច.ស.អ បានពិចារណាការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមនៅពេលវាយតម្លៃលើយុត្តាធិការបុគ្គល[254]។ មេធាវីការពារក្តីមានកាតព្វកិច្ចយកចិត្តទុកដាក់ក្នុងការលើកឡើងពីអ្វីដែលខ្លួនជឿជាក់ថាជាការសំអាងមិនត្រឹមត្រូវរបស់ ស.ច.ស.អ លើការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម។

### ក. ភាពអាចទទួលយកបាន អនុលោមតាមវិធាន ៧៤(៣)(ក) និងវិធាន ២១

១០៥. ក្រៅពីសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីស្តីពីភាពអាចទទួលយកបានខាងលើ[255] មូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ដោយសារការវាយតម្លៃរបស់ ស.ច.ស.អ លើយុត្តាធិការបុគ្គល (រួមទាំង និយមន័យផ្លូវច្បាប់ និងសំអាងហេតុ) ស្ថិតនៅក្នុងប្រភេទបញ្ហាដែលបើកផ្លូវ

---

[253] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៩៩២ ដល់ កថាខណ្ឌ ៩៩៩។

[254] ដូចយោងខាងលើ កថាខណ្ឌ ៩៩២ ដល់ កថាខណ្ឌ ៩៩៩។ ស.ច.ស.អ ទំនងបានសំអាងការសម្រេចរបស់ខ្លួនលើសិទ្ធិអំណាចតាមឋានានុក្រមរបស់លោក យឹម ទិត្យ ដែលនៅ "ដាច់ឆ្ងាយខ្លាំង" ពីគេបើយោងតាមភូមិសាស្ត្រ ចំណងគ្រួសាររបស់លោក យឹម ទិត្យ ជាមួយ តាម៉ុក ដែល តាមការចោទប្រកាន់ គាត់បាន "ធ្វើដំណើរទៅគ្រប់ទីកន្លែង" និង "ចូលរួមកិច្ចប្រជុំ *។ល។*" [sic គូសបញ្ជាក់បន្ថែម] ការទទួលខុសត្រូវរបស់លោក យឹម ទិត្យ ចំពោះ "បទប្រល័យពូជសាសន៍នៃការសម្លាប់រង្គាល" [sic] និង "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងអំពើមនុស្សឃាតក្រោមច្បាប់ជាតិ ជាច្រើនប្រភេទផ្សេងទៀត" ការទទួលខុសត្រូវរបស់លោក យឹម ទិត្យ លើបុគ្គលដែលដំណើរការមន្ទីរសន្តិសុខ និងការដ្ឋានការងារនៃរបបកម្ពុជាប្រជាធិបតេយ្យដែលការប្រព្រឹត្តរបស់ពួកគេ តាមការយល់ឃើញរបស់ ក.ស.ច.ស អាចប្រហាក់ប្រហែលនឹងអំពើឃោរឃៅនៅក្នុងជំរំប្រមូលផ្តុំ នៅក្នុងរបបណាហ្ស៊ី របស់អាល្លឺម៉ង់ និងការអនុវត្តគោលនយោបាយស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំរបស់ ប.ក.ក។ ការរៀបរាប់អង្គហេតុទាំងនេះពុំសំដៅលើការប្រព្រឹត្តជាលក្ខណៈបុគ្គលរបស់ យឹម ទិត្យ នោះទេ ប៉ុន្តែ វាជាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្រោមទ្រឹស្តីនៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម។

[255] កថាខណ្ឌ ១៣ ខាងលើ។

ឲ្យមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ អនុលោមតាម ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង (យុត្តាធិការបុគ្គល គឺជា "បញ្ហាពាក់ព័ន្ធនឹងការបញ្ជាក់យុត្តាធិការនៃអ.វ.ត.ក")[256]។

១០៦. សិទ្ធិប្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី អនុលោមតាមវិធាន ៧៤(៣)(ក) ក៏ឃើញមានចែងបញ្ជាក់បន្ថែមនៅក្នុងវិធាន ២១ ផងដែរ។ ដោយសារវាជាបញ្ហាចម្បងផ្នែកយុត្តាធិការនៅក្នុងរឿងក្តីរបស់លោក យឹម ទិត្យ ឋានៈរបស់គាត់ក្នុងនាមជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះបទឧក្រិដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺជាបញ្ហាដែលបណ្តាលឲ្យមានព្យសនកម្មមិនអាចជួសជុលបានដល់សិទ្ធិទទួលបានការជំនុំជម្រះរបស់គាត់ ដោយសារបានកំណត់ដោយមិនត្រឹមត្រូវ ហើយពុំបើកផ្លូវឲ្យអង្គជំនុំជម្រះសាលាដំបូងជួសជុលកែតម្រូវនោះទេ[257]។

១០៧. ការសំអាងមិនត្រឹមត្រូវដោយ ស.ច.ស.អ លើការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ថាជាកត្តាពាក់ព័ន្ធមួយដើម្បីវាយតម្លៃលើយុត្តាធិការបុគ្គល បានបំពានលើសិទ្ធិរបស់លោក យឹម ទិត្យ ក្នុងការទទួលបានការជំនុំជម្រះដោយយុត្តិធម៌អនុលោមតាមច្បាប់ និងត្រូវប្រព្រឹត្តឲ្យបានស្មើគ្នាចំពោះជនជាប់ចោទផ្សេងទៀត ទៅតាមលក្ខខណ្ឌដូចមានចែងនៅក្នុងមាត្រា ៣១(២) នៃរដ្ឋធម្មនុញ្ញកម្ពុជា[258] មាត្រា ១៤(១) នៃកតិកាសញ្ញាអន្តរជាតិ[259] (ដែលអាចយកមកអនុវត្តបាន

---

[256] អ.ប.ជ យល់ថា ការសម្រេចអំពីយុត្តាធិការបុគ្គលអាចពិនិត្យមើលឡើងវិញបាន។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២៦។

[257] សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឲ្យស្ថិតក្រោមការត្រួតពិនិត្យ *ដោយកំបាំងមុខ* ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ ២០១៦ ឯកសារ D239/1/8 កថាខណ្ឌ ១៧។

[258] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣១(២) ចែងថា ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ។

[259] កតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(១) ចែងថា ជនគ្រប់រូបត្រូវមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសាលាក្តី។ នៅពេលសម្រេចអំពីបទចោទព្រហ្មទណ្ឌប្រឆាំងនឹងខ្លួន ឬ សិទ្ធិ និងកាតព្វកិច្ចនៅក្នុងបណ្តឹងតាមផ្លូវច្បាប់ ជនគ្រប់រូបត្រូវមានសិទ្ធិទទួលបានសវនាការសាធារណៈ និងដោយយុត្តិធម៌ ដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលម្អៀង បង្កើតឡើងដោយច្បាប់។

តាមរយៈមាត្រា ១៣(១) នៃកិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា[260] និងមាត្រា ៣៣ *ថ្មី* នៃច្បាប់ អ.វ.ត.ក ដែលចែងថា ការជំនុំជម្រះត្រូវតែយុត្តិធម៌ និងធ្វើឡើងឲ្យបានឆាប់រហ័ស ស្របតាមនីតិវិធីជាធរមាន ដោយត្រូវគោរពពេញលេញលើសិទ្ធិរបស់ជនជាប់ចោទ[261]។ វិធាន ២១(១)(ខ) ចែងថា "បុគ្គលទាំងឡាយដែលរកឃើញថា ស្ថិតនៅក្នុងស្ថានភាពស្រដៀងគ្នា និងត្រូវបានចោទប្រកាន់ចំពោះបទល្មើសដូចគ្នា ត្រូវយកវិធានដូចគ្នាមកអនុវត្ត"។ ការខកខានអនុវត្តកត្តាទាំងនេះនៅក្នុងសំណុំរឿង ០០៤ គឺជាការប្រាសចាកដែលមិនអាចទទួលយកបានការអនុវត្តរបស់ ស.ច.ស នៅក្នុងសំណុំរឿង ០០៤/១ ដែលបានបង្កើតឲ្យមានភាពមិនជាក់លាក់ផ្នែកច្បាប់ ដែលបំពានវិធាន ២១[262]។

## ខ. ស.ច.ស.អ មានកំហុស ដោយបានប្រើប្រាស់សហឧក្រិដ្ឋកម្មរួម យកមកបង្ហាញពីយុត្តាធិការបុគ្គល

១០៨. ស.ច.ស.អ បានសំអាងដោយមិនសមស្របលើការទទួលខុសត្រូវ ដែលបានដាក់បន្ទុកលើលោក យឹម ទិត្យ ថាជាសមាជិកសហឧក្រិដ្ឋកម្មម្នាក់ ជាកត្តាពាក់ព័ន្ធដើម្បីសម្រេចថា លោក យឹម ទិត្យ គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ ស.ច.ស.អ ខកខានមិនវាយតម្លៃលើយុត្តាធិការបុគ្គល

[260] កិច្ចព្រមព្រៀង អ.ស.ប-រាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៣(១) ចែងអំពីការការពារសិទ្ធិរបស់ជនជាប់ចោទស្របតាមមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ សូមមើលផងដែរ ច្បាប់ អ.វ.ត.ក មាត្រា ៣៥ថ្មី ដែលចែងអំពីភាពអាចអនុវត្តបាននៃការធានាជាអប្បបរមានៅក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ៖ "នៅក្នុងការសម្រេចលើបទចោទប្រឆាំងនឹងជនជាប់ចោទ ជនជាប់ចោទត្រូវមានសិទ្ធិស្មើគ្នាក្នុងការទទួលបានការធានាអប្បបរមាដូចខាងក្រោម ស្របតាមមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ"។

[261] ច្បាប់ អ.វ.ត.ក មាត្រ ៣៣ថ្មី ចែងបញ្ជាក់បន្ថែមអំពីសិទ្ធិរបស់ជនត្រូវចោទ នៅក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុង ដែលចែងថា៖ "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង"។

[262] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៣៧ ដល់ កថាខណ្ឌ ៤១។

លើលោក យឹម ទិត្យ ឲ្យដូចគ្នានឹងជនជាប់ចោទនៅក្នុងសំណុំរឿង ០០៤/១[263]។

១០៩. សំណុំរឿង ០០៤/១ គឺជារឿងក្តីទីមួយ ដែល ស.ច.ស ទាំងពីរ ត្រូវបានស្នើសុំឲ្យបញ្ជាក់មូលដ្ឋានផ្លូវច្បាប់ចំពោះការសម្រេចលើយុត្តាធិការបុគ្គលរបស់ខ្លួន ដោយត្រូវបង្ហាញកត្តាពាក់ព័ន្ធចាំបាច់ក្នុងការធ្វើសេចក្តីសម្រេចបែបនោះ[264]។ ស.ច.ស ទាំងពីរ បានវិភាគច្បាប់ជាធរមាន និងបានពិនិត្យបទប្បញ្ញត្តិពាក់ព័ន្ធនៃកិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្ររបស់ អ.ជ.ត.ក[265] ដោយបានចាត់ទុកតួនាទីរបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជាមកពិចារណា[266] និងអានុភាពនៃ *វិមតិសង្ស័យត្រូវបានប្រយោជន៍ដល់ជនជាប់ចោទ* ការបកស្រាយតឹងរ៉ឹង យុត្តាធិការ និងការចោទប្រកាន់តាមការជ្រើសរើស ដែលជាកត្តាប៉ះពាល់ដល់ការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស នៅពេលកំណត់ថាតើ នរណាគឺជា "អ្នកទទួល ខុសត្រូវខ្ពស់បំផុតនោះ"[267]។ ស.ច.ស ទាំងពីរ កំណត់លក្ខណវិនិច្ឆ័យសម្រាប់ការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[268]។

១១០. ស.ច.ស ទាំងពីរបានប្រកាសនៅក្នុងសំណុំរឿង ០០៤/១ ថា "សច្ចធារណ៍ដោយស្វ័យប្រវត្តិនៃការទទួលខុសត្រូវ" ចំពោះបុគ្គលដែលត្រូវបាននាំមកចំពោះមុខតុលាការដោយសារការចោទប្រកាន់របស់ ក.ស.ព "មិនត្រូវ និងមិនអាចប្រដូចនឹងសច្ចធារណ៍មានទោស"[269] ហើយសច្ចធារណ៍បែបនេះ "ត្រូវធ្វើឡើងក្នុងលក្ខណៈផ្សេងពីនេះ"[270]។ ស.ច.ស ទាំងពីរបានបង្ហាញសំអាងហេតុថា៖

> ក្រោយរយៈពេលកន្លងហួសយូរមក ភ័ស្តុតាងសំខាន់តាមរយៈសាក្សី ឬ ប្រភពផ្សេងទៀតអាចបាត់បង់ដល់កម្រិតមួយដែលពិបាករកព័ត៌មានលម្អិតអាចទុកចិត្តបាន ហើយតាមពិត

---

[263] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៩៩២ ដល់ កថាខណ្ឌ ៩៩៩។

[264] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៣៧ ដល់ កថាខណ្ឌ ៤១។

[265] ដូចយោងខាងលើ កថាខណ្ឌ ៣ ដល់ កថាខណ្ឌ ១០។

[266] ដូចយោងខាងលើ កថាខណ្ឌ ១១ ដល់ កថាខណ្ឌ ២៥។

[267] ដូចយោងខាងលើ កថាខណ្ឌ ២៦ ដល់ កថាខណ្ឌ ៣៦។

[268] ដូចយោងខាងលើ កថាខណ្ឌ ៣៧ ដល់ កថាខណ្ឌ ៤១។

[269] ដូចយោងខាងលើ កថាខណ្ឌ ៣៥។

[270] ដូចយោងខាងលើ កថាខណ្ឌ ៣៦។

សាក្សីអាចពិបាកនឹងមកផ្តល់សក្ខីកម្ម។ ករណីនេះគឺពុំមែនការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវឱ្យមេធាវីការពារក្តីនៅក្នុងការស៊ើបអង្កេតព្រហ្មទណ្ឌនោះទេ ឬ នាំឱ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬការផ្តន្ទាទោសនោះឡើយ[271]។

១១១. ស.ច.ស សម្រេចថែមទៀតនៅក្នុងសំណុំរឿង ០០៤/១ ថា ជនជាប់ចោទ "មានសិទ្ធិទទួលបាននូវការវាយតម្លៃឱ្យបានសមហេតុផលលើភ័ស្តុតាង និងការបកស្រាយច្បាប់នៅក្នុងឋានានុក្រមតុលាការនៃ អ.វ.ត.ក គ្រប់ជាន់ថ្នាក់ ដោយគិតចាប់ផ្តើមពី ក.ស.ច.ស"[272]។

១១២. យោងតាមលក្ខណវិនិច្ឆ័យរបស់ ស.ច.ស សម្រាប់ការអនុវត្តឆន្ទានុសិទ្ធិតាមផ្លូវតុលាការនៅក្នុងសំណុំរឿង ០០៤/១ កត្តាពាក់ព័ន្ធដែលត្រូវយកមកដោះស្រាយបញ្ហាចោទយុត្តាធិការបុគ្គលមានលក្ខណៈស្រដៀងគ្នានឹងកត្តាដែលគេប្រើប្រាស់សម្រាប់ការកំណត់ទោស[273]។ ស.ច.ស បានលើកឡើងពីកត្តាពាក់ព័ន្ធដូចខាងក្រោម៖

- តួនាទីផ្លូវការរបស់បុគ្គលនៅក្នុងឋានានុក្រម[274]។
- កម្រិតដែលជនជាប់ចោទអាចចូលរួមចំណែក ឬ កំណត់គោលនយោបាយ និង/ឬ ការអនុវត្តវា[275]។
- ស្ថានទម្ងន់នៃអំពើផ្ទាល់របស់បុគ្គល និងផលប៉ះពាល់របស់វា[276]។

១១៣. ស.ច.ស ទាំងពីរបានសម្រេចទៀតថា អង្គហេតុទូទៅមួយចំនួនប្រាកដណាស់បានដឹង ដូចជា៖

- ការធ្វើសេចក្តីសម្រេចនៅក្នុងកម្ពុជាប្រជាធិបតេយ្យពុំមែនជាដំណើរការប្រជាធិបតេយ្យផ្លូវការមួយនោះទេ ដោយសារវាអាចមានការផ្តល់យោបល់ពីថ្នាក់ក្រោមៗ។ សេចក្តី

---

[271] ដូចយោងខាងលើ។

[272] ដូចយោងខាងលើ កថាខណ្ឌ ៣៦។

[273] ដូចយោងខាងលើ កថាខណ្ឌ ៣៨។

[274] ដូចយោងខាងលើ កថាខណ្ឌ ៣៩។

[275] ដូចយោងខាងលើ។

[276] ដូចយោងខាងលើ កថាខណ្ឌ ៣៨។

សម្រេចធ្វើឡើងនៅថ្នាក់លើ និងបន្ទាប់មកអនុវត្តដោយថ្នាក់ក្រោម ហើយមានផលវិបាកជាលក្ខណៈបុគ្គលនៅគ្រប់ជាន់ថ្នាក់ ប្រសិនបើបញ្ជាទាំងនេះមិនអនុវត្តតាម។ ជានិច្ចជាកាល និយមន័យចុងក្រោយចំពោះអត្ថន័យនៃគោលនយោបាយ និងមធ្យោបាយនៃការអនុវត្ត ស្ថិតនៅលើថ្នាក់លើៗ ដែលអាចជ្រៀតជ្រែកតាមអំពើចិត្ត។

- គំនិតផ្តួចផ្តើមផ្ទាល់របស់បុគ្គលម្នាក់នៅក្នុងកាលៈទេសៈទាំងនេះមិនមែនជាលក្ខណវិនិច្ឆ័យមួយ ដែលអាចឲ្យពួកគេធ្លាក់ចូលប្រភេទជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ និយមន័យចុងក្រោយចំពោះអត្ថន័យនៃគោលនយោបាយ និងមធ្យោបាយនៃការអនុវត្ត ស្ថិតនៅលើថ្នាក់លើ ដែលតែងតែអាចជ្រៀតជ្រែកតាមអំពើចិត្ត[277]។

- ការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងខ្សែបណ្តោយជាលក្ខណៈទូទៅនៅក្នុងខ្សែសង្វាក់បញ្ជា និងការសម្ងាត់ ពុំអនុញ្ញាតឲ្យអនុវត្តតាមខ្សែទទឹងដើម្បីផ្លាស់ប្តូរព័ត៌មានយុទ្ធវិធី និងប្រតិបត្តិការ ទៅថ្នាក់ណាដែលស្ថិតនៅក្រោមថ្នាក់កំពូលនោះទេ ហើយការពិភាក្សាជាចំហលើការណែនាំពី*អង្គការ* អាចត្រូវបានថ្នាក់លើចាត់ទុកថាជាការមិនស្តាប់បង្គាប់ ហើយអាចត្រូវរាយការណ៍នាំឲ្យមានផលប៉ះពាល់អវិជ្ជមានលើបុគ្គលដែលបានពិភាក្សាបញ្ហានេះ បានន័យថា “គ្មាននរណាម្នាក់អាចមានសុវត្ថិភាព”[278]។

១១៤. នៅក្នុងរឿងក្តីដាក់បន្ទុកលើលោក យឹម ទិត្យ ស.ច.ស.ជ នៅតែប្រកាន់ភ្ជាប់ទៅនឹងការវិភាគរួមគ្នាដូចបានបង្ហាញនៅក្នុងសំណុំរឿង ០០៤/១[279] ដោយបានប្រើប្រាស់កត្តាពាក់ព័ន្ធដូចគ្នានៅក្នុងការសម្រេចលើយុត្តាធិការបុគ្គលដូចបានសម្រេចក្នុងរឿងក្តីមុន[280]។ នៅពេលអនុវត្តលក្ខណវិនិច្ឆ័យដូចគ្នាចំពោះលោក យឹម ទិត្យ ស.ច.ស.ជ បានរក “មិនមានភស្តុតាងដែលអាចឲ្យយើងរកឃើញ

---

[277] ដូចយោងខាងលើ កថាខណ្ឌ ៤០។

[278] ដូចយោងខាងលើ កថាខណ្ឌ ៤១។ អ.ប.ជ នៅក្នុងសំណុំរឿង ០០៤/១ បានគូសបញ្ជាក់អំពីសារសំខាន់នៃការវាយតម្លៃលើស្ថានទម្ងន់នៃសកម្មភាពរបស់ជនជាប់ចោទ អំពើល្មើសរបស់ពួកគេទាំងមូល កម្រិតនៃការចូលរួមនៅក្នុងឧក្រិដ្ឋកម្ម និងតួនាទីការទទួលខុសត្រូវក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំណុំរឿង ០០៤/១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងសំអាងហេតុនៃដីកាដំណោះស្រាយ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ៣២៨ ដល់ កថាខណ្ឌ ៣៣២, កថាខណ្ឌ ៣៣៩។

[279] ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ កថាខណ្ឌ ៥៩៨ ដល់ កថាខណ្ឌ ៦៣១។

[280] ដូចយោងខាងលើ កថាខណ្ឌ ៦៣៩ និងកថាខណ្ឌ ៦៦៥។

ថា យឹម ទិត្យ គឺជាមេដឹកនាំជាន់ខ្ពស់ ឬ ក៏ជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនៅក្នុង របបកម្ពុជាប្រជាធិបតេយ្យឡើយ”[281] ព្រមទាំងបានសម្រេចថា អ.វ.ត.ក ពុំមានយុត្តាធិការបុគ្គល លើរូបគាត់[282] និងលើកលែងចោលការចោទប្រកាន់ចំពោះរូបគាត់[283]។

១១៥. ស.ច.ស.អ ពុំបានអនុវត្តតាមលក្ខណវិនិច្ឆ័យដែលបានបង្កើតឡើងជាមួយនឹងសហចៅក្រមរបស់ខ្លួននៅក្នុងសំណុំរឿង ០០៤/១ តែបែរជាងាកមកអនុវត្តទ្រឹស្តីសហឧក្រិដ្ឋកម្មរួម ដើម្បីផ្តល់យុត្តិកម្មលើការសម្រេចរបស់ខ្លួនថា លោក យឹម ទិត្យ គឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” មួយរូបទៅវិញ[284]។ ចំណុចដែលចម្រូងចម្រាស់នោះគឺថា សហឧក្រិដ្ឋកម្មរួមពុំទាមទារលក្ខខណ្ឌថា ទាល់តែជនជាប់ចោទបំពេញធាតុផ្សំ *សត្យានុម័តណាមួយ* នៃបទល្មើសដែលបានប្រព្រឹត្ត ទើបអាចសម្រេចលើពិរុទ្ធភាពបាន (សហឧក្រិដ្ឋកម្មរួមពុំទាមទារលក្ខខណ្ឌថា ជនជាប់ចោទបានប្រព្រឹត្ត បញ្ជា ឬផ្តើមគំនិតបទល្មើសនោះទេ)[285]។ ហេតុដូច្នេះ ការសម្រេចពិរុទ្ធភាពក្រោមការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួមពុំបានបែងចែករវាងសមាជិកសហឧក្រិដ្ឋកម្មរួម ដោយផ្អែកលើកម្រិតនៃការចូលរួមចំណែកចំពោះបទល្មើសនោះទេ[286] ហើយការធានាតែមួយគត់ប្រឆាំងនឹងសហឧក្រិដ្ឋកម្មរួមដែលអាចរួចផុតពីការសម្រេចពិរុទ្ធភាពប្រព្រឹត្តដោយក្រុម គឺនៅដំណាក់កាលកំណត់ទោសនៅក្នុងរឿងក្តី[287]។

១១៦. ចំណុចសំខាន់បំផុត ស.ច.ស.អ ខកខានក្នុងការប្រើប្រាស់កត្តាពាក់ព័ន្ធពីសំណុំរឿង ០០៤/១ ថាការចូលរួមចំណែករបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ត្រូវយកមកវាយតម្លៃដោយយោងលើ “ភាពធ្ងន់ធ្ងរនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ និងផលវិបាកនៃ

---

[281] ដូចយោងខាងលើ កថាខណ្ឌ ៦៦ ដល់ កថាខណ្ឌ ៦៨៥។

[282] ដូចយោងខាងលើ កថាខណ្ឌ ៦៨៦។

[283] ដូចយោងខាងលើ កថាខណ្ឌ ៦៨៧។

[284] សំណុំរឿង ០០៤/១ ដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៣៦ ដល់ កថាខណ្ឌ ៤១។

[285] អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* Brđanin (IT-99-36-A) សាលដីកា ចុះថ្ងៃទី៣ ខែមេសា ឆ្នាំ២០០៧ (“សាលដីកា Brđanin”) កថាខណ្ឌ ៤២៧។

[286] ដូចយោងខាងលើ កថាខណ្ឌ ៤៣២។

[287] ដូចយោងខាងលើ កថាខណ្ឌ ៤២៦ និងកថាខណ្ឌ ៤៣២។

អំពើទាំងនោះ”[288] ជាជាងការសំអាងមិនសមស្របលើសហឧក្រិដ្ឋកម្មរួម ទម្រង់នៃការទទួលខុសត្រូវដែលយោងតាមយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិ ត្រូវបានបង្កើតឡើងត្រឹមត្រូវដើម្បីសម្រេចឲ្យជនជាប់ចោទទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ទោះបីជាខ្លួនទំនងមិនបានប្រព្រឹត្ត *អំពើពិរុទ្ធ* ផ្នែកណាមួយក៏ដោយ[289]។ អ្វីដែលសំខាន់ជាមូលដ្ឋានសម្រាប់សហឧក្រិដ្ឋកម្មរួមគឺ ជនជាប់ចោទអាចត្រូវបានសម្រេចឲ្យទទួលខុសត្រូវមិនមែនចំពោះការចូលរួមចំណែករបស់ខ្លួននោះទេ ប៉ុន្តែចំពោះអំពើរបស់សមាជិកសហឧក្រិដ្ឋកម្មរួមរបស់ខ្លួនដែលជំរុញការសម្រេចឧក្រិដ្ឋកម្មនោះ[290]។ ដូចសាលាក្តី ICTY បានទទួលស្គាល់នៅក្នុងរឿងក្តី *Brđanin* អនុភាពនៃលក្ខខណ្ឌតម្រូវនេះគឺ ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម “ពុំមានការបែងចែកផ្លូវការរវាងសមាជិកសហឧក្រិដ្ឋកម្មរួមដែលបានចូលរួមចំណែកធំធេង និងសមាជិកសហឧក្រិដ្ឋកម្មរួមដែលការចូលរួមចំណែករបស់ពួកគេ ទោះសំខាន់ក៏ដោយ ប៉ុន្តែមិនមានលក្ខណៈធំធេង”[291]។

១១៧. នៅក្នុងរឿងក្តី *Brđanin* អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា ភាពខុសគ្នារវាងសមាជិកសហឧក្រិដ្ឋកម្មរួមដែលបានចូលរួមចំណែកធំធេង និងសមាជិកសហឧក្រិដ្ឋកម្មរួមដែលបានចូលរួមចំណែកតិចតួច “សមស្របសម្រេចនៅដំណាក់កាលកំណត់ទោស”[292]។ ជាក់ស្តែង ការទទួលខុសត្រូវរបស់បុគ្គលក្រោមសហឧក្រិដ្ឋកម្មរួម នឹងត្រូវបានសម្រេចឡើងវិញនៅដំណាក់កាលកំណត់ទោស ដោយត្រូវយោងលើពិរុទ្ធភាពរបស់បុគ្គលនោះ តម្រូវឲ្យទោស “មានលក្ខណៈឯកត្តបុគ្គល

---

[288] សំណុំរឿង ០០៤/១ *ដីកាដំណោះស្រាយ (សំអាងហេតុ)* ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៣៨។

[289] សាលដីកា Brđanin កថាខណ្ឌ ៤២៧។

[290] ដូចយោងខាងលើ កថាខណ្ឌ ៤៣១។

[291] ដូចយោងខាងលើ កថាខណ្ឌ ៤៣១។ សហឧក្រិដ្ឋកម្មរួម ចាប់ឲ្យជនជាប់ចោទទទួលខុសត្រូវលើឧក្រិដ្ឋកម្មចំបង ឬបទល្មើសដើម ដែលបានប្រព្រឹត្ត ដោយមិនគិតពីតួនាទីដែលខ្លួនមាននៅក្នុងក្រុមនោះទេ។ តួនាទីសំខាន់របស់ជនជាប់ចោទជាក់លាក់ម្នាក់ៗនៅក្នុងសហឧក្រិដ្ឋកម្មរួម ពុំបានឆ្លុះបញ្ចាំងនៅក្នុងកម្រិតនៃការចូលរួមចំណែកលើការទទួលខុសត្រូវនោះទេ បើទោះជាករណីនេះត្រូវយកមកពិចារណានៅពេលសម្រេចអំពីការកំណត់ទោសក៏ដោយ។ *សូមមើល* អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា* ទល់ *Miluntinovic និងអ្នកផ្សេងទៀត* (IT-05-87-T) សាលក្រម ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ១០៦។ ការចំបាច់នោះគឺ ការកំណត់ទោសនីមួយៗគឺផ្តោតលើគោលការណ៍ឯកត្តកម្ម។ អង្គជំនុំជម្រះតុលាការកំពូល នៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា* ទល់ *Šainović និងអ្នកផ្សេងទៀត* (IT-05-87-A) សាលដីកា ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៤ កថាខណ្ឌ ១៨៣៩។

[292] សាលដីកា Brđanin កថាខណ្ឌ ៤៣១។

និងសមាមាត្រ” ដែលផ្អែកលើ “ការវិភាគដែលមានលក្ខណៈជាសត្យានុម័ត មានហេតុផលសមរម្យ និងមានការថ្លឹងថ្លែងត្រឹមត្រូវ ទាំងទៅលើអំពើរបស់ជនជាប់ចោទ និងទាំងទៅលើព្យសនកម្មនានា ដែលជាផលវិបាកនៃការប្រព្រឹត្តិអំពើទាំងនោះ” រួមទាំងទម្រង់ និងកម្រិតនៃការចូលរួមរបស់ជនជាប់ចោទនៅក្នុងឧក្រិដ្ឋកម្ម[293]។

១១៨. ដូច្នេះ សហឧក្រិដ្ឋកម្មរួមមានកំហុសជាសារវ័ន្ត នៅពេលចាត់ទុកកត្តាពាក់ព័ន្ធសម្រាប់ការសម្រេចថា លោក យឹម ទិត្យ គឺជា “អ្នកទទួលខុសត្រូវខ្ពស់បំផុត” ដោយសារវាគឺជាទម្រង់នៃការទទួលខុសត្រូវមួយប្រភេទដែលពុំបែងចែកកម្រិតនៃការទទួលខុសត្រូវនោះទេ។ ជាពិសេស លក្ខណៈនៃសហឧក្រិដ្ឋកម្មរួម មានភាពមិនសមស្របយ៉ាងខ្លាំងក្នុងករណីសហឧក្រិដ្ឋកម្មរួមត្រូវបានបកស្រាយយ៉ាងទូលំទូលាយ ដើម្បីរាប់បញ្ចូលសមាជិកជាច្រើននាក់នៅក្នុងឋានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ។ នៅក្នុងរឿងក្តីរបស់លោក យឹម ទិត្យ ការចោទប្រកាន់ពីសហឧក្រិដ្ឋកម្មរួមពង្រីកតាំងពីកម្មាភិបាល និងបុគ្គលិកមន្ទីរសន្តិសុខថ្នាក់លើបំផុតរហូតដល់ថ្នាក់ទាបបំផុត[294]។ នៅក្នុងសវនាការរបស់ អោ អាន លើបណ្តឹងឧទ្ធរណ៍នៃដីកាដំណោះស្រាយ ស.ព.អ បានទទួលយកវិសាលភាពទូលំទូលាយនៃសហឧក្រិដ្ឋកម្មរួមដោយត្រង់ៗតែម្តង៖

> [...] ពិតហើយថាមានមនុស្សច្រើនណាស់ចូលរួមពាក់ព័ន្ធចាប់តាំងពី ប៉ុល ពត ដោយសារគោលនយោបាយវាចេញមកពីថ្នាក់មជ្ឈិម។ អានេះជំហររបស់យើខ្ញុំអីចឹងឯង។ ហើយរួមទាំងអ្នកបើកបររបស់ អោ អាន នោះ ដែលគាត់ដើរតួនាទីសំខាន់ក្នុងការនាំសារ និងបញ្ជា ដែលស្តីអំពីថាអ្នកណាត្រូវតែទៅសម្លាប់នោះ[295]។

១១៩. ស.ច.ស ទាំងពីរ បានទទួលស្គាល់នៅក្នុងសំណុំរឿង ០០៤/១ ថា អ្នកព្រាងច្បាប់ អ.វ.ត.ក ពុំបានថែងប្រមើលមើលទុកថា យុត្តាធិការបុគ្គលនឹងរួមបញ្ចូលទាំង “ចារីជាច្រើន” នៃកងទ័ព និងកម្មា

---

[293] សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១០៦៧ ដល់ កថាខណ្ឌ ១០៦៨។

[294] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០១៦។ សហឧក្រិដ្ឋកម្មរួមដ៏ទូលំទូលាយ “ចាប់ពី ប៉ុល ពត ដល់ អ្នកបើកបររបស់បើកបររបស់ អោ អាន” ត្រូវបាន ស.ព.អ បកស្រាយនៅក្នុងសំណុំរឿង ០០៤/២។ សំណុំរឿង ០០៤/២ *ប្រតិចារឹកនៃសវនាការលើបណ្តឹងឧទ្ធរណ៍* ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D360/19.1 ទំព័រ ១៤ ជួរ ១៩-២៥។

[295] ដូចយោងខាងលើ។

ភិបាលដែល "ម្នាក់ៗអាចទទួលខុសត្រូវក្នុងការសម្លាប់មនុស្សរាប់រយ ឬ រាប់ពាន់នាក់"[296] និងទទួលស្គាល់ "គម្លាតនិទណ្ឌភាពជាខ្លាំងសម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ"[297]។ នៅក្នុងសំណុំរឿង ០០៤/១ ស.ច.ស ទាំងពីរ បានឯកភាពថា កត្តាពាក់ព័ន្ធសម្រាប់កំណត់យុត្តាធិការបុគ្គលគឺប្រហាក់ប្រហែលនឹងតម្រុយនៃពិរុទ្ធភាពបុគ្គលដែលត្រូវបានប្រើប្រាស់សម្រាប់ការដាក់ទោស[298]។ នៅក្នុងសំណុំរឿង ០០៤ ស.ច.ស.អ ខកខានក្នុងការផ្តល់សំអាងហេតុចំពោះការងាកចេញមិនប្រើប្រាស់វិធីសាស្ត្រនេះ ហើយ ផ្ទុយមកវិញ គាត់បានផ្អែកការវាយតម្លៃរបស់ខ្លួនចំពោះ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" លើវិធីសាស្ត្របកស្រាយទូលំទូលាយ "តាមបែបពន្លាត" ការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ជាហេតុធ្វើឱ្យពង្រីកវិសាលភាពយុត្តាធិការបុគ្គលរហូតដល់ប្រភេទចារីជាច្រើននាក់ដែល ស.ច.ស ទាំងពីរ បានបកស្រាយយ៉ាងប្រុងប្រយ័ត្ននៅក្នុងសំណុំរឿង ០០៤/១។

## គ. សេចក្តីសន្និដ្ឋាន

១២០. ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយបានយកការទទួលខុសត្រូវដែលបានចោទប្រកាន់ចំពោះលោក យឹម ទិត្យ ជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម មកធ្វើជាមូលដ្ឋានសម្រាប់បង្កើតយុត្តាធិការបុគ្គល។ ការសំអាងរបស់ ស.ច.ស.អ លើសហឧក្រិដ្ឋកម្មរួម បានបង្កឱ្យមានព្យសនកម្មមិនអាចជួសជុលបានចំពោះសិទ្ធិជំនុំជម្រះក្តីដោយយុត្តធម៌របស់លោក យឹម ទិត្យ ដោយត្រូវទទួលបានការប្រព្រឹត្តិស្មើគ្នាដូចជនជាប់ចោទនៅ អ.វ.ត.ក ផ្សេងទៀត និងត្រូវទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនតែប៉ុណ្ណោះ ទៅតាមលក្ខខណ្ឌនៅក្នុងគោលការណ៍នៃពិរុទ្ធភាពបុគ្គល *ពោលគឺ គ្មានទោសប្រសិនបើគ្មានកំហុស* ដែលត្រូវបានការពារ អនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ២៤ នៃក្រមព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៥(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ[299]។ ផ្អែកតាមការទទួលខុសត្រូវចោទប្រកាន់ចំពោះលោក យឹម ទិត្យ ក្រោម

---

[296] សំណុំរឿង ០០៤/1 *ដីកាដំណោះស្រាយ (សំអាងហេតុ)* កថាខណ្ឌ ១៨ ដល់ កថាខណ្ឌ ១៩។

[297] ដូចយោងខាងលើ កថាខណ្ឌ ២៥។

[298] ដូចយោងខាងលើ កថាខណ្ឌ ៣៨។

[299] សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/១ ចុះថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ១៦។ សំណុំរឿង ០០២ សាលក្រមសំណុំរឿង ០០២/២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១។ អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICTY បានរៀបរាប់គោលការណ៍នេះជា "មូលដ្ឋាននៃការការទទួលខុសត្រូវព្រហ្មទណ្ឌ"។ អង្គជំនុំ

ការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម អ្នកវិនិច្ឆ័យអង្គហេតុដោយមិនលម្អៀងមិនអាចសន្និដ្ឋានថា គាត់គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ។ ការសំអាងរបស់ ស.ច.ស.អ លើការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម មិនមានភាពយុត្តិធម៌ និងមិនសមហេតុផល ដែលជាការបំពានលើធន្ទានុសិទ្ធិរបស់គាត់។ ដំណោះស្រាយតែមួយគត់សម្រាប់កំហុសអង្គច្បាប់របស់ ស.ច.ស.អ នៅក្នុងការសំអាងលើកត្តាមិនសមស្របចំពោះយុត្តាធិការបុគ្គលគឺការបដិសេធចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះ។

## V. មូលដ្ឋានទី ៥ ÷ ស.ច.ស.អ មានកំហុសអង្គហេតុ និងអង្គច្បាប់ ចំពោះការសម្រេចថា លោក យឹម ទិត្យ គឺជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" និងស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក

១២១. នៅក្នុងសំអាងច្បាប់ស្តីពីយុត្តាធិការបុគ្គល ស.ច.ស.អ មានកំហុសដោយបានសម្រេចថា លោក យឹម ទិត្យ "បានឡើងឋានៈយ៉ាងឆាប់រហ័សពីមុខតំណែងជាអនុលេខាស្រុកភូមិភាគនិរតី ទៅជាអនុលេខាភូមិភាគ ហើយរហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ គាត់ប្រហែលជាបានឡើងឋានៈជាលេខាភូមិភាគពេញលេញនៃភូមិភាគពាយ័ព្យ"[300]។

១២២. ស.ច.ស.អ មានកំហុសដោយបានសម្រេចថា "ការឡើងឋានៈដូចដុំថ្មធ្លាក់ពីលើមេឃ" ត្រូវបាន "គាំទ្រដោយចំណងគ្រួសារយ៉ាងជិតស្និទ្ធរបស់គាត់" ជាមួយ តាម៉ុក "ដែលត្រូវជាបងថ្លៃគាត់" ហើយ យឹម ទិត្យ "គឺជាមេបញ្ជាការ*តាមព្រឹត្តន័យ* ទីពីររបស់ តាម៉ុក ទាំងនៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ"[301]។

១២៣. ការសម្រេចរបស់ ស.ច.ស.អ អំពី "ចំណងគ្រួសារយ៉ាងជិតស្និទ្ធ" រវាងលោក យឹម ទិត្យ និង តាម៉ុក បានផ្អែកលើការសង្កេតរបស់សាក្សីមួយរូបអំពីទំនាក់ទំនងរវាងលោក យឹម ទិត្យ និង តាម៉ុក នៅក្នុងតំបន់ ១៣[302] រួមជាមួយនឹងការសម្រេចថា លោក យឹម ទិត្យ និង តាម៉ុក "ឃើញធ្វើ

ជម្រះតុលាការកំពូលនៃតុលាការ ICTY រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Tadić* (IT-94-1-A) សាលដីកា ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ ១៨៦។

[300] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៩៩២ ដល់ កថាខណ្ឌ ៩៩៣។

[301] ដូចយោងខាងលើ កថាខណ្ឌ ៩៩៤។

[302] ដូចយោងខាងលើ កថាខណ្ឌ ៣៤៨ ដល់ កថាខណ្ឌ ៣៥១។

ដំណើររួមគ្នា "នៅទូទាំង" ភូមិភាគពាយ័ព្យ "ចូលរួមប្រជុំ ជាដើម" ដែល "តាំងពីមុនពេលបញ្ចូលក្នុងតួនាទីផ្លូវការ [របស់ យឹម ទិត្យ] នៅភូមិភាគពាយ័ព្យទៅទៀត"[303]។ នៅក្នុងសំអាងច្បាប់ស្ដីពីយុត្តាធិការបុគ្គល ស.ច.ស.អ ពុំបានបញ្ជាក់លើភ័ស្តុតាងបង្ហាញអំពីការអនុវត្តអំណាច*តាមព្រឹត្តន័យ*ដែលបានចោទប្រកាន់លើលោក យឹម ទិត្យ នៅក្នុងភូមិភាគនិរតី ឬ ភូមិភាគពាយ័ព្យនោះទេ[304]។

**ក. មូលដ្ឋានទទី ៥.១÷ ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា ទំនាក់ទំនងសាច់ញាតិរបស់ លោក យឹម ទិត្យ ជាមួយនឹង តាម៉ុក មានន័យស្មើនឹងការសន្និដ្ឋានអំពីសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ និងថា លោក យឹម ទិត្យ ជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត"**

១២៤. ដូចដែលការវិភាគលើសំអាងហេតុរបស់ ស.ច.ស.អ លើមុខតំណែង*តាមនិតិន័យ*របស់ យឹម ទិត្យ នៅក្នុងតំបន់ ១៣ នឹងបង្ហាញ ពុំមានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការតំបន់១៣នៃភូមិភាគនិរតីឡើយ[305]។ ដោយប្រឈមនឹងកង្វះភ័ស្តុតាងនេះ ស.ច.ស.អ បានបង្ហាញហួសហេតុពីទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយនឹងតាម៉ុក[306] និងសន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងតំបន់ ១៣ ដោយផ្អែកលើទំនាក់ទំនងនេះ[307]។

១២៥. ស.ច.ស.អ បានផ្អែកលើសំអាងហេតុនេះលើភ័ស្តុតាងសាក្សីដែលថា យឹម ទិត្យ និង តាម៉ុក គឺប្រៀបដូច "ឪ និងកូន" ពួកគេធ្វើដំណើរជាមួយគ្នាទូទាំងភូមិភាគនិរតី ត្រួតពិនិត្យការដ្ឋាន មន្ទីររបស់ពួកគេស្ថិតនៅជិតគ្នា និងថា លោក យឹម ទិត្យ ត្រូវបានឃើញចូលរួមប្រជុំជាមួយ តា ម៉ុក និងធ្វើការនៅមន្ទីរភូមិភាគនិរតី ថា តាម៉ុក និង យឹម ទិត្យ "រស់នៅជាមួយគ្នានៅក្នុងបរិវេណមួយយ៉ាងធំខាងលិចសាលាខេត្តបច្ចុប្បន្ន"[308]។ គ្មានការសង្កេតណាមួយខាងលើណាមានភាពពាក់ព័ន្ធ

---

[303] កថាខណ្ឌ ១០២ ខាងលើ និងកថាខណ្ឌ ២២៣ ខាងក្រោម។

[304] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៩៩២ ដល់ កថាខណ្ឌ ៩៩៩។

[305] *សូមមើលខាងក្រោម* កថាខណ្ឌ ១៥៣ ដល់ ១៦៣។

[306] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៤៩ ដល់ ៣៥២។

[307] ដូចយោងខាងលើ កថាខណ្ឌ ៣៤៨។

[308] ដូចយោងខាងលើ កថាខណ្ឌ ៣៤៩។

សម្រាប់ការវាយតម្លៃទៅលើសិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់ យឹម ទិត្យ និងការបញ្ជា និងគ្រប់គ្រងរបស់គាត់ឡើយ[309]។

១២៦. ក្រៅពីការពឹងផ្អែករបស់ ស.ច.ស.អ លើកត្តាពាក់ព័ន្ធក្នុងការសន្និដ្ឋានលើសិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់ យឹម ទិត្យ ស.ច.ស.អ បានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយពឹងផ្អែកដោយមិនត្រឹមត្រូវ និងមិនសមហេតុផល លើផ្នែកផ្សេងៗនៃភស្តុតាង ក្នុងការគាំទ្រសំអាងហេតុរបស់ខ្លួនអំពី "ចំណងជិតស្និទ្ធ" រវាងតាម៉ុក និង លោក យឹម ទិត្យ ខណៈដែលមិនយកចិត្តទុកដាក់លើផ្នែកផ្សេងៗនៃភស្តុតាងដែលមានលក្ខណៈផ្ទុយទៅនឹងសំអាងហេតុរបស់ខ្លួន។ ឧទាហរណ៍ល្អបំផុតមានដូចខាងក្រោម៖

- រៀល សន និយាយថា គាត់ពុំមានការទាក់ទងជាមួយ យឹម ទិត្យ ឡើយនៅក្នុងអំឡុងរបបខ្មែរក្រហម ប៉ុន្តែបានជឿថា យឹម ទិត្យ បាន "ធ្វើការនៅមន្ទីរមួយជាក្នុងភ្នំពេញជាមួយប៉ុល ពត" ក្នុងអំឡុងសម័យខ្មែរក្រហម និងបានទទួលមរណភាពមុនពេល រៀល សន ផ្តល់កិច្ចសម្ភាសន៍នេះ (ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៤)[310]។ រៀល សន ក៏បានពន្យល់ដែរថា "តាទិត្យ មិនសកម្មណាស់ណាទេ" ហើយ "មិនឃោរឃៅទេ ពីព្រោះគាត់ធ្លាប់បួសជាព្រះសង្ឃ"[311]។ រៀល សន មិនដែលបរិយាយអំពី លោក យឹម ទិត្យ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់នានាមុនដំបូងជាមួយ ក.ស.ច.ស[312] ឬសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង០០២ ក្នុងនោះរួមទាំងនៅពេលដែលគេសួរគាត់អំពីបញ្ហាពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៃតំបន់១៣[313]។

[309] សូមមើលខាងលើ កថាខណ្ឌ ៨៣។

[310] ឯកសារ D118/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ឆ.៧០-៧៣ ERN 00975630។

[311] ឯកសារ D118/181 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន ឆ.៨១ ERN 00975631។

[312] ឯកសារ D6.1.671 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រៀល សន។

[313] ឯកសារ D315.2.6 រៀល សន ប្រតិចារឹក។ ឯកសារ D315.2.7 រៀល សន ប្រតិចារឹក។ ឯកសារ D315.2.8 រៀល សន ប្រតិចារឹក។ ឯកសារ D315.1.17 រៀល សន ប្រតិចារឹក ម៉ោង 10.48.42-10.54.07 ទំព័រ ៣២ បន្ទាត់ ១៦ ដល់ទំព័រ ៣៣ បន្ទាត់ ១៦ EN 01076506-7។

- សាន់ ឡូន បានលើកឡើងជាច្រើនលើកច្រើនសាថា គាត់មិនដឹងអ្វីទាំងអស់អំពីទំនាក់ទំនងរបស់ តាម៉ុក ជាមួយ យឹម ទិត្យ[314] និងថា គាត់មិនដឹងអ្វីទាំងអស់អំពី យឹម ទិត្យ និង គ្រាន់តែ "បានឮឈ្មោះគាត់" ដោយគ្មានបញ្ជាក់កាលៈទេសៈ ឬពេលវេលាដែលគាត់ឮឈ្មោះគាត់ឡើយ[315]។

- ណុប ធឹម និយាយថា តាម៉ុក និង "[តាទិត្យ]ត្រូវគ្នាណាស់"[316] ប៉ុន្តែគាត់មិនដឹង "មុខតំណែងរបស់តាទិត្យ នៅក្នុងភូមិភាគនិរតី[317] ឬជ្រាបអំពីរចនាសម្ព័ន្ធភូមិភាគនីរតីឡើយ លើកលែងតែថាតាម៉ុក គឺជាលេខាភូមិភាគនីរតី[318]។

១២៧. ស.ច.ស.អ សន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងរបស់ ចាន់ វិចិត្រ ថា លោក យឹម ទិត្យ និង តាម៉ុក ទទួលខុសត្រូវ "តាកែវទាំងមូល និង ភូមិភាគទាំងមូល" លោក យឹម ទិត្យ "ទទួលខុសត្រូវ ជាពិសេសផ្នែកខាងលិចទាំងមូលនៃខេត្តតាកែវ" និង ធ្វើជា "តំណាងរបស់តាម៉ុក" ទោះបីជាលើបញ្ហា យោធា និងបញ្ហាសន្តិសុខក្តី និងថា តួនាទីរបស់ យឹម ទិត្យ គឺ "ខ្ពស់ជាងថ្នាក់តំបន់" ដោយហេតុថា គាត់មានទំនាក់ទំនងជិតស្និទ្ធជាមួយ តាម៉ុក។ ស.ច.ស.អ សង្កេតឃើញថា សាក្សីបានចំណាយពេលចំនួន ៤ ខែនៅតាកែវ ប៉ុន្តែថា សាក្សី "មិនបញ្ជាក់ពេលវេលាជាក់លាក់ឡើយ"[319]។

១២៨. ទីមួយ ស.ច.ស.អ មានកំហុសដែលអះអាងថា ចាន់ វិចិត្រ មិនបានបញ្ជាក់អំពីពេលវេលាជាក់លាក់នៅពេលគាត់នៅតាកែវ។ គាត់បញ្ជាក់ច្បាស់ហើយថា គាត់នៅតាកែវៈ

---

[314] ឯកសារ D219/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.១៤៨, ឆ.១៩២, ឆ.១៩៥, ឆ.១៩៦ ERN 01029157-8។

[315] ឯកសារ D219/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡូន ឆ.១៦៥-ឆ.១៦៦ ERN 01029156 ឆ.១៨៧ ERN 01029157។

[316] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១៦ ERN 01008699 ។

[317] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.៩-ឆ.១២ ERN 01008698, ឆ.១៨-ឆ.១៩ ERN 01008699 ។

[318] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធឹម ឆ.១៤-ឆ.១៥ ERN 01008698។

[319] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៥០។

- និរសារក្នុងកងពលលេខ២ វរសេនាធំលេខ១១ ចាប់តាំងពីឆ្នាំ១៩៧៣[320]។

- ឈរជើងនៅក្នុងខេត្តកំពតឆ្នាំ១៩៧៤[321]។

- ចូលរួមវាយចូលភ្នំពេញក្នុងខែមេសា ឆ្នាំ១៩៧៥[322]។

- នៅអង្គភាពរបស់គាត់ក្នុងវត្តត្រគាតជិតទួលគី (បច្ចុប្បន្នស្ថិតនៅផ្លូវជាតិលេខ៣ ខណ្ឌមានជ័យ ភ្នំពេញ) ដែលគាត់បានស្នាក់នៅអស់រយៈពេល១ឆ្នាំ[323]។

- ផ្លាស់ទៅខេត្តតាកែវ ១ ឆ្នាំក្រោយមក ប៉ុន្តែ មូលដ្ឋានយោធា និងភស្តុភាររបស់គាត់ស្ថិតនៅទួលគ្រី[324]។

- ផ្លាស់មកជាមួយកងពលលេខ២របស់គាត់នៅព្រំប្រទល់អន្លង់ទាន ស្រុកកោះអណ្តែត ខេត្តតាកែវដើម្បីការពារព្រំដែនពីការវាយប្រហាររបស់វៀតណាមក្នុងខែមេសា ឆ្នាំ១៩៧៧[325]។

- តាម៉ុក បានកេណ្ឌគាត់ក្នុងខែកក្កដា ឆ្នាំ១៩៧៧ ឲ្យធ្វើយោធា និងផ្លាស់មកស្វាយរៀងក្នុងភូមិភាគ បូព៌ា ដែលនៅទីនោះគាត់ទទួលបន្ទុកវរសេនាធំមួយ[326]។

- រងរបួសក្នុងខែកញ្ញា ឆ្នាំ១៩៧៧ និងបញ្ជូនទៅភ្នំពេញ នៅក្នុងមន្ទីរពេទ្យមួយ[327]។

- សម្រាកព្យាបាលនៅមន្ទីរពេទ្យ រហូតដល់វៀតណាមវាយលុកភ្នំពេញក្នុងឆ្នាំ១៩៧៩។[328]

---

[320] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318438-01318440, ERN 01318448-01318449, ERN 01318451-01318453។

[321] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318443-01318444។

[322] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318443-01318444។

[323] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318449-01318451។

[324] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318449-01318451។

[325] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318452-01318455។ ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៩-ឆ.១១ ERN 01340634-01340635។

[326] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318455-01318457។

[327] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318457-01318460។

[328] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318460-01318461។

- ក្នុងខែកុម្ភៈ ឆ្នាំ១៩៧៩ ចុះចូលជាមួយវៀតណាម[329]។

១២៩. ចាន់ វិចិត្រ ក៏បានលើកឡើងដែរថា គាត់មិនស្គាល់ "តាទិត្យ" មុនពេលគាត់មក អន្លង់ទាន ខេត្តតាកែវ ក្នុងខែមេសា ឆ្នាំ១៩៧៧[330] ថា គាត់មិនឃើញ "តាទិត្យ" ម្តងទៀតទេ ក្រោយពេលគាត់ចាកចេញ[331] ទៅស្វាយរៀងក្នុងភូមិភាគបូព៌ា ក្នុងខែកក្កដា ឆ្នាំ១៩៧៧[332] និងថា នៅពេលគាត់ចាកចេញទៅភូមិភាគបូព៌ា "តាទិត្យ" ស្នាក់នៅខេត្តតាកែវ[333]។ ជាការសមហេតុផលក្នុងការសន្និដ្ឋានថា ចាន់ វិចិត្រ បានចំណាយពេល ៤ ខែ ក្នុងខេត្តតាកែវ ពីខែមេសា ដល់ខែ កក្កដា ឆ្នាំ១៩៧៧។ គួរកត់សម្គាល់ថា ចាន់ វិចិត្រ ក៏ថ្លែងដែរថា នៅកំឡុងពេល ៤ ខែនេះ គាត់ឃើញ "តាទិត្យ" ស្ទើររាល់ថ្ងៃ[334] និងថា ប្រសិនបើ "តាទិត្យ"ធ្វើដំណើរ គាត់យកកូន ២ នាក់ទៅជាមួយគាត់ដែលរស់នៅជាមួយគាត់[335]។ នេះគឺពិតជាពេលវេលាដែល សៅ ជាប់ បានលើកឡើងថា បានឃើញ "តាទិត្យ"នៅក្នុងភូមិភាគពាយ័ព្យ ហើយដែលផ្អែកលើចំណុចនេះ ស.ច.ស.អ ផ្តល់សំអាងនៅក្នុងសំអាងច្បាប់របស់ខ្លួនលើយុត្តាធិការបុគ្គលថា លោក យឹម ទិត្យ បានធ្វើដំណើរ "ពេញ" ភូមិភាគពាយ័ព្យជាមួយ តាម៉ុក "តាំងពីមុនពេលគេចាត់តាំងគាត់ផ្លូវការនៅក្នុងភូមិភាគពាយ័ព្យទៀតផង"[336]។ ពុំមានចំណុចណាមួយនៅក្នុងដីកាដំណោះស្រាយរបស់ស.ច.ស.អ បង្ហាញថា ស.ច.ស.អ បានពិចារណាលើផ្នែកនេះនៃភ័ស្តុតាងថាមានលក្ខណៈផ្ទុយនឹងភ័ស្តុតាងរបស់ សៅ ជាប់ ឡើយ។

---

[329] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318461-01318463។

[330] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៩ ERN 01340636។

[331] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៧៨, ឆ.១៨១ ERN 01340657-01340658។

[332] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318455-01318457។

[333] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318469-01318470។

[334] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៩-ឆ.១៥ ERN 01340634-01340635, ឆ.២០ 01340636។

[335] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៧២ ERN 01340642, ឆ.១០៥ ERN 01340646។ ឯកសារ D219/853.1 ចាន់ វិចិត្រ ឧបសម្ព័ន្ធ កៈ គំនូសទីកន្លែង។ ; ឆ.១០៧ ERN 01340647។

[336] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៩៩៥។

១៣០. មិនតែប៉ុណ្ណោះ ពាក់ព័ន្ធនឹងឋានៈរបស់លោក យឹម ទិត្យ ជា "ជនទទួលខុសត្រូវខ្ពស់បំផុត" ស.ច.ស.អ ខានមិនបានយកមកពិចារណានូវភ័ស្តុតាងផ្ទុយរបស់ ចាន់ វិចិត្រ និងភ័ស្តុតាងដែលគាត់ផ្តល់ ដោយព្យាយាមបំភ្លឺភ័ស្តុតាងរបស់គាត់។ ចាន់ វិចិត្រ ថ្លែងថា៖

- គាត់មិនដឹងថា "តាទិត្យ" និង តាម៉ុក ជាសាច់ញាតិនឹងគ្នា និង ត្រូវជាអ្វីនឹងគ្នា[337]។

- មន្ទីរ "តាទិត្យ" ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគ និង "តាទិត្យ" បង្រៀនក្មេងៗនៅទីនោះ[338]។ គាត់សង្កេតឃើញ "តាទិត្យ" ធ្វើការជាមួយតាម៉ុក ប៉ុន្តែមិនដឹងថាពួកគាត់ត្រូវជាអ្វីនឹងគ្នាឡើយ[339]។

- គាត់បំភ្លឺថា "តាទិត្យ" ក្លាយជាតំណាងរបស់តាម៉ុកលើបញ្ហាយោធាតែប៉ុណ្ណោះ ក្រោយពេលសង្គ្រាមចប់ទៅ និងថា គាត់មិនមែនជា "តំណាងរបស់តាម៉ុកនៅក្នុងកំឡុងសង្គ្រាមឡើយ" ដែលតាមការពិត គាត់គឺជាតំណាងផ្នែកបង្កើបង្កើនផលស្រូវក្នុងស្រុកគិរីវង់[340]។

- ថា ការទទួលខុសត្រូវរបស់ "តាទិត្យ" មិននៅដដែល ហើយ "ប្រសិនបើនណាម្នាក់ត្រូវបានចាត់តាំងឲ្យធ្វើការនៅក្នុងស្រុកគិរីវង់នៅពេលព្រឹក ការទទួលខុសត្រូវរបស់គាត់អាចបញ្ចប់នៅពេលគាត់ត្រឡប់ទៅវិញក្នុងពេលរសៀល"[341]។

- "តាទិត្យ" មិនមែនជាលេខាស្រុកទេ ប៉ុន្តែជាតំណាងឲ្យតាម៉ុកម្តងម្កាល ឬមួយភ្លែតៗតែប៉ុណ្ណោះ។ ក្រោយពេលបំពេញការងាររួច ក៏រលាយរលត់អស់ដែរ[342]។

---

[337] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៩-ឆ.១១ ERN 01340634-01340635។។ ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៤៣ ERN 01340652។

[338] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៧ ERN 01340635។

[339] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318469-01318470។

[340] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៥៩-ឆ.៦០ ERN 01340640-01340641។

[341] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៦១ ERN 01340640-01340641។

[342] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៦២ ERN 01340640-01340641។

- "តាទិត្យ" ពុំមានមុខតំណែងផ្លូវការទេ[343] មិនដែលស្ថិតក្នុងគណៈកម្មាធិការតំបន់ណាមួយ[344] ពុំមានប្រវត្តិក្លាយជាមេបញ្ជាការខ្លាំងបំផុតទេ គាត់បានត្រឹមតែធ្វើការជាមួយអ្នកដទៃ[345] និងមិនដែលមានមុខតំណែងនៅក្នុងគណៈកម្មាធិការស្រុកឡើយ[346]។

- នៅពេលតាម៉ុកអវត្តមានពីខេត្តតាកែវ តាប៊ិត ដែលជាលេខាតំបន់៣៥ គ្រប់គ្រង "មូលដ្ឋាន" ហើយ តាទិត្យ ទទួលខុសត្រូវតែផ្នែកតូចមួយនៃការងារ "មូលដ្ឋាន"[347]ប៉ុន្តែ មិនមែនផ្នែកយោធាទេ[348]។

- តាទិត្យ មិនធ្វើការលើបញ្ហាយោធាទេ គាត់នៅជាមួយមូលដ្ឋាន គាត់មិនមានឥទ្ធិពលលើទាហានឡើយ[349]។

១៣១. ភ័ស្តុតាងរបស់ ចាន់ វិចិត្រ លើចំណុចនេះត្រូវបានបញ្ជាក់បន្ថែមដោយភ័ស្តុតាងរបស់ វណ្ណ កុសល ជា ទាហានម្នាក់ទៀតដែលជាមេបញ្ជាការអនុសេនាតូចក្នុងវរៈសេនាធំលេខ១២ កងពលលេខ២ ចាប់ពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨[350]។ វណ្ណ កុសល ស្ថិតនៅក្នុងខេត្តតាកែវក្នុងពេលវេលាដូចគ្នា ជាមួយនឹង ចាន់ វិចិត្រ មុនពេលគេផ្លាស់មកស្វាយរៀងនៃភូមិភាគបូព៌ា ក្នុងឆ្នាំ១៩៧៨[351]

---

[343] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៧១ ERN 01340656។

[344] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318469-01318470។

[345] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318469-01318470។

[346] ឯកសារ D219/815.1 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ចាន់ វិចិត្រ ERN 01318469-01318470។

[347] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៤៨ ERN 01340652-01340653។

[348] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៥០-ឆ.១៥១, ឆ.១៥៣ ERN 01340653។

[349] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៨៨ ERN 01340644។ ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៣១ ERN 01340650។

[350] ឯកសារ D219/901 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វណ្ណ កុសល ឆ.៣ ERN 01381113, ឆ.១២-ឆ.១៦ ERN 01381114។

[351] ឯកសារ D219/901 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វណ្ណ កុសល ឆ.៩-ឆ.១១ ERN 01381113- ERN 01381114។

ហើយគាត់មិនស្គាល់តាទិត្យ នៅពេលនោះទេ ប៉ុន្តែ ធ្លាប់បានឮគាត់ធ្វើការ "នៅមូលដ្ឋាន" និង មិនដឹងថាតំបន់ណាទេ[352]។

១៣២. ស.ច.ស.អ ក៏បានសន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងរបស់ ចាន់ វិចិត្រ ថា លោក យឹម ទិត្យ បាន ចូលរួមប្រជុំមួយជាមួយតំណាងគណៈស្រុកនៅមន្ទីរភូមិភាគ[353]។ ស.ច.ស.អ ក៏ខកខានមិនបាន ពិចារណាលើភ័ស្តុតាងផ្ទុយរបស់ ចាន់ វិចិត្រ និងភ័ស្តុតាងដែលគាត់ផ្តល់ ដោយព្យាយាមបំភ្លឺ ចម្លើយរបស់គាត់។ ចាន់ វិចិត្រ ផ្តល់ចម្លើយថា៖

- "តាទិត្យ" មានផ្ទះមួយ មិនមែនមន្ទីរទេ[354] និងថា កូន និងប្រពន្ធរស់នៅជាមួយគាត់[355]។
- គាត់មិនដែលចូលក្នុងមន្ទីររបស់ "តាទិត្យ" ទេ ហើយគាត់មិនដឹងថាតើគាត់ទទួលភ្ញៀវនៅ ក្នុងមន្ទីររបស់គាត់ដែរឬទេ[356]។
- គាត់មិនដឹងអំពីការងាររបស់ "តាទិត្យ"[357]ទេ ប៉ុន្តែធ្លាប់ឃើញមានមនុស្សមកជួបគាត់ និង សន្មតថាពួកគេមកពីគណៈកម្មាធិការស្រុក ដោយហេតុថា ពួកគេមានកង់[358] ប៉ុន្តែក្រោយ មកបំភ្លឺថា អ្នកដែលមកជួប "តាទិត្យ" គឺជាសាច់ញាតិរបស់គាត់មកពីស្រុកត្រាំកក់[359]។

១៣៣. ចំណុចចុងក្រោយ ស.ច.ស.អ យល់ឃើញដោយផ្អែកលើភ័ស្តុតាងរបស់សាក្សីនេះថា លោក យឹម ទិត្យ បានបញ្ជាឲ្យគេអនុវត្តភារកិច្ច និងត្រួតពិនិត្យការដ្ឋានទូទាំងភូមិភាគ។ ស.ច.ស.អ បកស្រាយ ខុសលើភ័ស្តុតាង និងខកខានមិនបានពិចារណាលើភ័ស្តុតាងដោះបន្ទុកពី ចាន់ វិចិត្រ ដែលថ្លែងថា៖

---

[352] ឯកសារ D219/901 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វណ្ណ កុសល ឆ.៣៥-ឆ.៤០ ERN 01381116។

[353] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៥០។

[354] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.២៦ ERN 01340636។

[355] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១០៥ ERN 01340646។ ឯកសារ D219/853.1 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឧបសម្ពន្ធ ក: គំនូសទីកន្លែង។ ឆ.១០៧ ERN 01340647។

[356] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៣១-ឆ.៣២ ERN 01340637។

[357] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៣១-ឆ.៣២ ERN 01340637។

[358] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៣៤-ឆ.៣៧ ERN 01340637-01340638។

[359] ឯកសារ D219/853 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១០៧-ឆ.១១២ ERN 01340647, ឆ.១៥២ ERN 01340653។

- គាត់មិនដឹងកិច្ចការរបស់ "តាទិត្យ" នៅពេលគាត់ធ្វើដំណើរទៅកាន់បណ្ដាស្រុកនានា[360] ប៉ុន្តែ "តាទិត្យ" យកកូនតូចចំនួន ២ នាក់ នៅពេលគាត់ធ្វើដំណើរទៅកាន់បណ្ដាស្រុកនានា[361]។

- គាត់មិនយល់ច្បាស់អំពីការចាត់តាំងការងារ "មូលដ្ឋាន" ពីព្រោះគាត់ចូលរួមតែការងារយោធាប៉ុណ្ណោះ[362]។

- គាត់ឮថា "តាទិត្យ" បានបញ្ជាឲ្យគេកាប់ដើមឈើ និងឫស្សីមកធ្វើទូ[363] ឬយកក្បាលត្រីប្រឡាក់ឲ្យអ្នកដែលកាប់ឫស្សីនៅលើភ្នំ ឬឲ្យអ្នកបើកឡានធំដើម្បីឲ្យដឹកឫស្សីទៅកន្លែងណាមួយ[364]។

- អ្នកដែល "តាទិត្យ"បញ្ជា គឺមានមុខតំណែងតូចៗនៅក្នុងបណ្ដាស្រុក[365]។

១៣៤. ស.ច.ស.អ ក៏ពិចារណាផងដែរលើការសង្កេតរបស់ ម៉ឹង វ៉េត ពីកិច្ចប្រជុំមួយនេះ ដែលគាត់បានចូលរួម ដែលថា លោក យឹម ទិត្យ "មានអំណាច" ជាងតាផែន ដែលត្រូវបានលើកឡើងថាជាអនុលេខាតំបន់ ១៣ ដោយសារអាយុរបស់គាត់ និងទំនាក់ទំនងសាច់ញាតិជាមួយតាម៉ុក[366]។ ស.ច.ស.អ មិនយកចិត្តទុកដាក់លើចំណុចដែលថា ពុំមានភស្តុតាងក្នុងសំណុំរឿង ដែលបង្ហាញថាតាផែន គឺជាអនុលេខាតំបន់១៣ក្នុងឆ្នាំ១៩៧៦ ឬតើគាត់មានអាយុប៉ុន្មាន និងមិនយកចិត្តទុកដាក់លើចំណុចដែលថា ម៉ឹង វ៉េត ពុំមានពន្យល់ថាតើហេតុអ្វីបានជាគាត់មានអារម្មណ៍ថា មុខតំណែងនោះមានន័យថា "តាទិត្យ" កាន់តួនាទីកម្រិតតំបន់ និង "មានអំណាចជាងអនុលេខាតំបន់" ឬពុំមានពន្យល់ថា តើគាត់អាចកំណត់អត្តសញ្ញាណលោក យឹម ទិត្យ ដោយរបៀបណា ជាពិសេស

[360] ឯកសារ D219/853 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៦៦ ERN 01340641។

[361] ឯកសារ D219/853 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៧២ ERN 01340642។

[362] ឯកសារ D219/853 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១២៩-ឆ.១៣០ ERN 01340650។

[363] ឯកសារ D219/853 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.៦៧ ERN 01340641។

[364] ឯកសារ D219/853 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៥៤ ERN 01340654, ឆ.១៥៨ ERN 01340654។

[365] ឯកសារ D219/853 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ចាន់ វិចិត្រ ឆ.១៥៨ ERN 01340654។

[366] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៥១។

ពីព្រោះ "តាទិត្យ" មិនដែលថ្លែងសុន្ទរកថានៅក្នុងកិច្ចប្រជុំនេះទេ[367] និងមិនបានពន្យល់ថា តើគាត់ដឹងពីតួនាទីផ្លូវការរបស់ "តាទិត្យ" ដោយរបៀបណានៅក្នុងកិច្ចប្រជុំនេះ។ ស.ច.ស.អ មិនបានផ្តល់ហេតុផលថាតើ "តាទិត្យ" មានវត្តមាន ប៉ុន្តែមិននិយាយនៅលើវេទិកានៅចុងឆ្នាំ១៩៧៦ ជាមួយនឹងទំនាក់ទំនងគ្រួសារជាមួយតាម៉ុក មានន័យស្មើ ភ័ស្តុតាងដែលថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងតំបន់ ១៣ នោះឡើយ។

*សិទ្ធិអំណាច និងការទទួលខុសត្រូវត្រួតគ្នានៅក្នុងភូមិភាគទាំងពីរ "ស្រដៀងគ្នានឹងតាម៉ុក"*

១៣៥. ស.ច.ស.អ សន្និដ្ឋានថា សាក្សីមួយចំនួនផ្តល់ចម្លើយថា លោក យឹម ទិត្យ បន្តធ្វើដំណើរទៅវិញទៅមកនៅភូមិភាគនិរតី សូម្បីតែក្រោយពី "ការតែងតាំងផ្លូវការរបស់គាត់" នៅក្នុងភូមិភាគពាយ័ព្យ តាមការលើកឡើងក៏ដោយ និងថា ភ័ស្តុតាងរបស់សាក្សីទាំងនោះបញ្ជាក់បន្ថែមទៅលើ "សក្ខីកម្មរបស់សាក្សីថា គាត់បានសិទ្ធិអំណាច និងការទទួលខុសត្រូវត្រួតគ្នានៅក្នុងភូមិភាគទាំងពីរ ស្រដៀងគ្នានឹងសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ តាម៉ុក ដែរ[368]។

១៣៦. ពុំមានសាក្សីណាមួយដែល ស.ច.ស.អ បានពឹងផ្អែកលើ ក្នុងការធ្វើសំអាងហេតុនេះ ផ្តល់ភ័ស្តុតាងអំពី សិទ្ធិអំណាច*តាមព្រឹត្តន័យ* និង*តាមនីតិន័យ*របស់ យឹម ទិត្យ នៅក្នុងភូមិភាគទាំងពីរ ក្រោយខែមិថុនា ឆ្នាំ១៩៧៨ ឡើយ និងពុំច្បាស់ ថាតើភ័ស្តុតាងនេះត្រូវបានបញ្ជាក់ដោយរបៀបណា។ ជាពិសេស៖

- សាន់ ឡួន មិនដឹងអ្វីទាំងអស់អំពីមុខតំណែងរបស់ យឹម ទិត និងគ្រាន់តែ "បានឮឈ្មោះគាត់" ដោយគ្មានបញ្ជាក់ពីពេលវេលាដែលគាត់ឮឈ្មោះគាត់ឡើយ[369]។

- ពេជ្រ ជឹម និយាយអំពីការផ្សាយវិទ្យុអំពីតំបន់ ១៣ នៅចុងឆ្នាំ ១៩៧៨ ដែលក្រោយមកគាត់ប្តូរភ័ស្តុតាងរបស់គាត់នៅពេលគាត់និយាយថា គាត់លែងជឿទៀតហើយថាគាត់បានឮការផ្សាយនោះដោយខ្លួនគាត់[370]។

---

[367] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤៦-ឆ.៥១ ERN 01136708-01136709។

[368] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៥២។

[369] ឯកសារ D219/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡួន ឆ.១៦៥-ឆ.១៧៤ ERN 01029156, ឆ.១៨៧-ឆ.១៨៨ ERN 01029157។

- សឹម ឈឿន និយាយថា គាត់ជឿថា "តាទិត្យ" មិនដែលចាកចេញពីស្រុកគិរីវង់ទេ នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ពីព្រោះគាត់មិនដែលឮថា តាទិត្យ ផ្លាស់ចេញ ទោះបីជាគាត់មិន ឃើញ តាទិត្យ ក៏ដោយ[371]។

- ប៉ាន់ សារូ និយាយថា "តាទិត្យ" គឺជាគណៈស្រុកគិរីវង់" រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែក៏ផ្លាស់ប្តូរសក្ខីកម្មរបស់គាត់វិញ និងនិយាយថា គាត់ "សន្និដ្ឋានដោយផ្អែកលើការសង្កេតរបស់គាត់" ថា នៅចុងរបបខ្មែរក្រហម "តាទិត្យ" ត្រូវបានតម្លើងតួនាទីជាសមាជិករដ្ឋសភា ពីព្រោះគាត់ជាសាច់ញាតិរបស់តាម៉ុក[372]។

- ភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម ពាក់ព័ន្ធនឹងព្រឹត្តិការណ៍នៅក្នុងឆ្នាំ១៩៧៦ និង ១៩៧៧ និងមិនពាក់ព័ន្ធនឹងបញ្ហានេះទេ។

<u>*សន្និដ្ឋាន*</u>

១៣៧. ស.ច.ស.អ ខកខានមិនបានបង្ហាញថា ទំនាក់ទំនងគ្រួសាររបស់លោក យឹម ទិត្យ ជាមួយតាម៉ុក មានន័យស្មើនឹងសិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់ យឹម ទិត្យ នៅក្នុងតំបន់១៣ នៃភូមិភាគនិរតី និង នៅក្នុងភូមិភាគពាយ័ព្យ និងថា យឹម ទិត្យ គឺជាអនុរបស់តាម៉ុក នៅក្នុងភូមិភាគទាំងពីរ។ ការដែលថា មានទំនាក់ទំនងគ្រួសារ និងភ័ស្តុតាងចេញពីទស្សនៈយល់ឃើញរបស់សាក្សីពាក់ព័ន្ធនឹងឥទ្ធិពលនៃទំនាក់ទំនងនេះលើសិទ្ធិអំណាចជាក់ស្តែងរបស់ យឹម ទិត្យ សុទ្ធតែមិនមែនជាមូលដ្ឋានក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ គឺជាអនុរបស់តាម៉ុកឡើយ។ ពុំមានភ័ស្តុតាងនៅក្នុងសំណុំរឿងបញ្ជាក់ពីសារៈសំខាន់បែបនេះចំពោះទំនាក់ទំនងគ្រួសារ ឬប្រភពច្បាប់ណាមួយ ដូចជាករណីយុត្តិសាស្ត្ររបស់ អវតក និង សាលាក្តីអន្តរជាតិដទៃទៀត បង្ហាញថា "ចំណងសាច់ញាតិ" គឺជាការចង្អុលបង្ហាញអំពីការបញ្ជា និងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពឡើយ។ ស.ច.ស.អ ខកខានមិនបានផ្តល់សំអាងហេតុសម្រាប់ការសន្និដ្ឋាននេះ ដែលអាចធ្វើឱ្យមានការវាយតម្លៃសមស្របលើភាពមានហេតុផលនៃការសន្និដ្ឋាននេះទេ។

---

[370] ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.១៣៦-ឆ.១៣៧ ERN 00997041។

[371] ឯកសារ D219/189 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឹម ឈឿន ឆ.២៣-ឆ.២៧ ERN 01068051-2។

[372] ឯកសារ D118/302 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាន់ សារូ ឆ.២៦ ERN 01024563, ឆ.៤៦-ឆ.៥២ ERN 01024565។

១៣៨. ទន្ទឹមគ្នានេះដែរ ស.ច.ស.អ មិនយកចិត្តទុកដាក់លើលក្ខណវិនិច្ឆ័យនៃការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដែលត្រូវបានបង្កើតត្រឹមត្រូវនៅក្នុងករណីយុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិ គឺ ភាពជាម្ចាស់ជាក់ស្តែង ភាពមិនមែនជាម្ចាស់ នៃអំណាចការគ្រប់គ្រងលើសកម្មភាពរបស់អ្នកនៅក្រោមបង្គាប់[373] ហេតុដូច្នេះ ស.ច.ស.អ ខកខានមិនបានកំណត់បានគ្រប់គ្រាន់នូវច្បាប់សម្រាប់អនុវត្តលើការទទួលខុសត្រូវរបស់បញ្ជាការ និងកំណត់ជាក់លាក់នូវមូលដ្ឋានអង្គហេតុនៃការវាយតម្លៃតាមផ្លូវច្បាប់ របស់ខ្លួនលើយុត្តាធិការបុគ្គល និងខកខានមិនបានជូនដំណឹងដល់ យឹម ទិត្យ អំពីបទចោទប្រឆាំងនឹងគាត់[374]។

១៣៩. ស.ច.ស.អ ខកខានមិនបានបង្ហាញថា យឹម ទិត្យ ពិតជាមានមនុស្សនៅក្រោមបង្គាប់ កុំថាឡើយគាត់មានអំណាចគ្រប់គ្រងលើសកម្មភាពរបស់បុគ្គលសូម្បីតែម្នាក់។

១៤០. ការវិភាគខាងលើបង្ហាញថា ការមមែរបស់ ស.ច.ស.អ ទៅនឹងទំនាក់ទំនងគ្រួសាររបស់ យឹម ទិត្យ ជាមួយ តាម៉ុក មានឥទ្ធិពលដោយផ្ទាល់លើការវាយតម្លៃរបស់ខ្លួនទៅលើសិទ្ធិអំណាច*តាមព្រឹត្តន័យ* របស់យឹម ទិត្យ តាមការចោទប្រកាន់ និងការបញ្ជា និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់គាត់នៅក្នុង ភូមិភាគពាយ័ព្យ និងនៅក្នុងភូមិភាគនិរតី។ ស.ច.ស.អ មិនយកចិត្តទុកដាក់ទៅលើភ័ស្តុតាងផ្ទុយ ខកខានមិនបានពិចារណាលើការពិនិត្យពិច័យពាក់ព័ន្ធ និងបានពិចារណាលើការពិនិត្យពិច័យដែលពុំពាក់ព័ន្ធ ឬដែលមិនសមហេតុផល ដើម្បីធ្វើឲ្យប៉ះពាល់ដល់ភ័ស្តុតាងដោះបន្ទុក។ ស.ច.ស.អ ក៏ខកខានមិនបានផ្តល់ទស្សនៈដែលមានហេតុផលថាតើ មូលហេតុអ្វីបានជាគាត់យល់ឃើញថា ភ័ស្តុតាងបែបនេះ ពុំមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលអាចឈានទៅសន្និដ្ឋានផ្សេងណាមួយក្នុងការអនុវត្តបទដ្ឋាន "*ភវនីយភាព*"[375]នេះនោះ។

១៤១. ការមមែរបស់ ស.ច.ស.អ នឹងទំនាក់ទំនងសាច់ញាតិរបស់ យឹម ទិត្យ ជាមួយ តាម៉ុក បានឃ្លាតឆ្ងាយពីការវាយតម្លៃលើសិទ្ធិអំណាច*តាមព្រឹត្តន័យ* និងការបញ្ជា និងគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពរបស់ យឹម ទិត្យ។ ការវិភាគរបស់មេធាវីការពារក្តីទៅលើការវាយតម្លៃរបស់ ស.ច.ស.អ ក៏នឹងបង្ហាញថា ការមមៃបែបនេះជាមួយ តាម៉ុក បានលាបពណ៌ដល់ការវាយតម្លៃ

---

[373] សូមមើលខាងលើ កថាខណ្ឌ ៨២ ដល់ ៨៤។

[374] សូមមើលខាងលើ កថាខណ្ឌ ៨០ ដល់ ៩៤។

[375] *ដូចយោងខាងលើ* កថាខណ្ឌ ១៧ ដល់ ១៩។

ទាំងមូលរបស់ខ្លួនទៅលើមុខងាររបស់ យឹម ទិត្យ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងបានធ្វើឱ្យប្រឡូកប្រលាក់ដល់ការសន្និដ្ឋានរបស់គាត់អំពី ការប្រព្រឹត្តិរបស់ យឹម ទិត្យ និងសមាជិកភាព និងការចូលរួមចំណែករបស់ យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មទាំងបីទម្រង់ តាមការលើកឡើង ដែលសមាជិកដែលមានឈ្មោះ យោងតាម ស.ច.ស.អ គឺ មានតែ តាម៉ុក និង យឹម ទិត្យ តែប៉ុណ្ណោះ[376]។ ស.ច.ស.អ ផ្តល់ការវាយតម្លៃដោយគ្មានកង្វល់លើភ័ស្តុតាង និងការបកស្រាយច្បាប់ដល់ជនជាប់ចោទដទៃទៀត[377] ប៉ុន្តែ ក្នុងលក្ខណៈមិនជាក់លាក់ ស.ច.ស.អ មិនបានផ្តល់ប្រយោជន៍ដូចគ្នានេះដល់លោក យឹម ទិត្យ ឡើយ។

**ខ. មូលដ្ឋានទី ៥.២៖ ស.ច.ស.អ មានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសន្និដ្ឋានថា លោក យឹម ទិត្យ មានមុខតំណែងផ្លូវការ ឬមានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ និងថា គាត់គឺជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម**

**(i) ស.ច.ស.អ មានកំហុសឆ្គងដែលសន្និដ្ឋានថា លោក យឹម ទិត្យ គឺជា "មេដឹកនាំស្រុកគិរីវង់"**

១៤២. ស.ច.ស.អ សន្និដ្ឋានថា លោក យឹម ទិត្យ គឺជា "អ្នកដឹកនាំស្រុកគិរីវង់"ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[378]។ ការសន្និដ្ឋាននេះគឺជាកំហុសឆ្គង។

*ស.ច.ស.អ មានកំហុសពាក់ព័ន្ធនឹង មុខតំណែងតាមនិតិន័យរបស់ លោក យឹម ទិត្យ នៅក្នុងគណៈកម្មាធិការស្រុកគិរីវង់តាមការចោទប្រកាន់*

១៤៣. ស.ច.ស.អ ខកខានក្នុងការធ្វើសំអាងហេតុអំពីមុខតំណែង*តាមនិតិន័យ*របស់ យឹម ទិត្យ នៅក្នុងគណៈកម្មាធិការស្រុកគិរីវង់និងរយៈពេលពាក់ព័ន្ធ។ ស.ច.ស.អ ធ្វើសំអាងហេតុថា "មិនច្បាស់ទេថា នៅពេលណា យឹម ទិត្យ ត្រូវបានតែងតាំងជាគណៈស្រុកគិរីវង់"[379] សមាជិកភាពរបស់គាត់

---

[376] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១០១៦i និង ii។

[377] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៣៦។

[378] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣២៨ ដល់ ៣៤២, ៤៦៣ ដល់ ៤៦៩។

[379] *ដូចយោងខាងលើ* កថាខណ្ឌ ៣២៨។

អាចមាន រយៈពេលខ្លីគឺពីខែតុលា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៦[380] និង គាត់ចាកចេញពីស្រុកគិរីវង់នៅដើមខែមករា ឆ្នាំ១៩៧៦[381]។ ជាការផ្ទុយទៅនឹងសំអាងហេតុនេះ ស.ច.ស.អ ក៏សន្និដ្ឋានថា លោក យឹម ទិត្យ "បានក្លាយជាលេខាស្រុកគិរីវង់ក្រោយពីគេដក តា តុំ" ដែលតាមការស្មានផ្ទាល់របស់ស.ច.ស.អ គឺថា "នៅក្នុងរវាងចុងឆ្នាំ១៩៧៦ ដល់ខែកញ្ញា ឆ្នាំ១៩៧៧" ឬថាលោក យឹម ទិត្យ ទំនងជាកាន់តួនាទីនេះ ក្រោយ "តាសៀង កាន់តួនាទីនេះមួយរយៈ"[382]។

១៤៤. ស.ច.ស.អ ពុំបានផ្តល់សំអាងហេតុអំពីចំណុចពេលវេលានៅពេលដែលលោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាស្រុក ខណៈដែលគាត់នៅក្នុងស្រុកគិរីវង់ និង ខកខានមិនបានពន្យល់អំពីភ័ស្តុតាង ផ្ទុយៈ

- តុប ផាន "មិនដឹង មុខតំណែងរបស់លោក យឹម ទិត្យ"[383]។
- ម៉ុង វេត ថ្លែងថា "តាទិត្យ មិនធ្វើការងារស្រុកដោយផ្ទាល់ទេ"[384]។

១៤៥. ស.ច.ស.អ ពឹងផ្អែកលើសក្ខីកម្មរបស់សាក្សីអំពីត្រឹមតែវត្តមានរបស់ យឹម ទិត្យ នៅក្នុងស្រុកគិរីវង់ក្នុងអំឡុងឆ្នាំ១៩៧២ ១៩៧៣ និង ១៩៧៤[385] តាមការចោទប្រកាន់។ នេះមិនមែនជាភ័ស្តុតាងដែលថាលោក យឹម ទិត្យ កាន់មុខតំណែង*តាមនិតិន័យ*នៅក្នុងពេលវេលាណាមួយពាក់ព័ន្ធឡើយ។

១៤៦. ពុំមានអ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផលណាម្នាក់អាចធ្វើការសន្និដ្ឋានដូចការសន្និដ្ឋានរបស់ ស.ច.ស.អ ទេអំពី "ភាពជាអ្នកដឹកនាំ"របស់យឹម ទិត្យ នៅស្រុកគិរីវង់ ផ្អែកលើភ័ស្តុតាងដែលមិនមានលក្ខណៈគ្រប់គ្រាន់ទាល់តែសោះ។ ជាការពិតណាស់ នៅក្នុងដីកាដំណោះស្រាយរបស់ខ្លួន ស.ច.ស.ជ មិនអាចធ្វើការសន្និដ្ឋានដាច់ខាតថាតើ លោក យឹម ទិត្យ បានធ្វើជាលេខាស្រុកគិរីវង់ពីខែមិថុនា ឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៧ ឡើយ[386]។ ស.ច.ស.ជ មិនបានសន្និដ្ឋានថា យឹម ទិត្យ

---

[380] *ដូចយោងខាងលើ* កថាខណ្ឌ ៣២៨ ដល់ ៣៣១, ៣៤២។

[381] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤២ "យឹម ទិត្យ បានចាកចេញពីស្រុងគិរីវង់នៅឆ្នាំ ១៨៧៦ ឬ ១៩៧៧"។

[382] *ដូចយោងខាងលើ* កថាខណ្ឌ ៣៣០ ដល់ ៣៣១។

[383] ឯកសារ D118/305 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប ផាន ឆ.២៧-ឆ.២៨ ERN 01024599។

[384] ឯកសារ D119/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ុង វេត ឆ.២៣-ឆ.២៤ ERN 00975767។

[385] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣២៨។

[386] ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ កថាខណ្ឌ ៦៦៧។

អាចធ្វើជាគណៈស្រុកនោះមុនខែមករា ឆ្នាំ១៩៧៦ ហើយ សំអាងហេតុរបស់ ស.ច.ស.ជ មិន គាំទ្រសំអាងហេតុរបស់ស.ច.ស.អ ត្រង់ចំណុចនេះទេ[387]។

*ស.ច.ស.អ មានកំហុសក្នុងការធ្វើសំអាងហេតុថា លោក យឹម ទិត្យ មាន "សិទ្ធិអំណាចតាមព្រឹត្តន័យ" ក្នុងស្រុកគិរីវង់*

១៤៧. ស.ច.ស.អ មានកំហុសឆ្គងក្នុងការផ្តល់សំអាងហេតុថា លោក យឹម ទិត្យ មានសិទ្ធិអំណាច *តាមព្រឹត្តន័យ* នៅក្នុងស្រុកគិរីវង់ពេញរយៈពេលនោះ[388]។ ស.ច.ស.អ បកស្រាយខុសលើភស្តុតាងរបស់សាក្សី និង ខកខាន មិនបានរៀបរាប់ភស្តុតាងផ្ទុយនិងដោះបន្ទុក។

១៤៨. ទឹម ភួន ថ្លែងថា៖

- គាត់មិនដឹងថា យឹម ទិត្យ ជាគណៈស្រុកទេ[389] ថា "គាត់មិនដឹងអំពីតួនាទីរបស់ តា ទិត្យ ទេ"[390] ថា គាត់មិនដឹងថាតើ "តាទិត្យ" គឺជាកម្មាភិបាលជាន់ខ្ពស់[391] និង ថា "កាលពេលនោះ ខ្ញុំមិនសូវចាប់អារម្មណ៍លើតួនាទីរបស់គាត់ឡើយ។ ខ្ញុំគ្រាន់តែដឹងថាគាត់គឺជាពូរបស់ខ្ញុំ ហើយគាត់ឲ្យខ្ញុំស្នងស្រូវនៅទីនោះ"[392]។
- គាត់មិនដឹងថាយឹម ទិត្យ មានមុខតំណែងអ្វីនៅក្នុងឆ្នាំ "១៩៧៦ ឬ១៩៧៧" ទេ[393]។
- គាត់ "មិនដឹងមុខតំណែងរបស់ តាទិត្យ ទេ"[394]។

---

[387] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣២៨ ដល់ ៣៣១, ៣៤២។

[388] *ដូចយោងខាងលើ* កថាខណ្ឌ ៣៣២ ដល់ ៣៤២, ៤៦៣ ដល់ ៤៦៩។

[389] ឯកសារ D11 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម ភួន ERN 00686999 "តើនៅស្រុកគីរីវង់ លោកដឹងថា តាទិត ជាគណៈស្រុក និងមានសិទ្ធិបញ្ជាឲ្យចាប់ និងសម្លាប់មនុស្សដែរឬទេ? ឆ. ខ្ញុំមិនបានដឹងទេ។ ខ្ញុំទើបតែមានអាយុ ១៧ ឆ្នាំប៉ុណ្ណោះ"។

[390] ឯកសារ D118/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.៧ ERN 00891142 "ស៖ តើ តាទិត មានតួនាទីអ្វីដែរ? ឆ.៧៖ ខ្ញុំមិនបានដឹងទេ ព្រោះគេបញ្ជូនខ្ញុំពីភូមិផ្សេងទៅនៅទីនោះ។ ដូច្នេះ ខ្ញុំមិនបានដឹងពីតួនាទីរបស់គាត់ទេ"។

[391] ឯកសារ D118/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.៨ ERN 00891142 "ស៖ តើលោកដឹងទេថា តា ទិត ជាកម្មាភិបាលកម្រិតខ្ពស់ ឬយ៉ាងណា? ឆ.៨៖ ខ្ញុំមិនឹងទេ"។

[392] ឯកសារ D118/20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.៩ ERN 00891142។

[393] ឯកសារ D219/466 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម ភួន ឆ.៩៣, ១០៣ ERN 01132107-01132108។

១៤៩. ង៉ែត ងយ ថ្លែងថា គាត់មិនដឹងអ្វីទាំងអស់អំពី លោក យឹម ទិត្យ តាមការឆ្លងកាត់ផ្ទាល់របស់គាត់[395] និងមិនបានផ្តល់កាលបរិច្ឆេទច្បាស់លាស់ថាពេលណា យឹម ទិត្យ ធ្វើជាលេខាស្រុកគិរីវង់[396]។ ស.ច.ស.អ ពឹងផ្អែកដោយមិនត្រឹមត្រូវលើ ង៉ែត ងយ ជាប្រភពនៃសំអាងហេតុដែលថា លោក យឹម ទិត្យ គឺជា "ថ្នាក់លើ"របស់តាគុំ[397]។

១៥០. ភ័ស្តុតាងរបស់ មុឹង វេត ពាក់ព័ន្ធនឹងរយៈពេលខ្លីមួយចាប់ពី "ប្រហែលចុងឆ្នាំ១៩៧៦" រហូតដល់យ៉ាងយូរបំផុត ខែមករា ឆ្នាំ១៩៧៧[398] ហើយប្រភពនៃការដឹងរបស់គាត់នេះគឺចេញពីម្តាយរបស់គាត់ ដែលដឹងអំពី "តាទិត" ពី "សាច់ញាតិរបស់និងមិត្តភក្តិរបស់គាត់" នៅ "ទីកន្លែងផ្សេងៗគ្នា" ឬ ការយល់ឃើញរបស់ មុឹង វេត[399]។

*<u>សេចក្តីសន្និដ្ឋានអំពីស្រុកគិរីវង់</u>*

១៥១. ស.ច.ស.អ ខកខានមិនបានរៀបរាប់ពីភ័ស្តុតាងដែលផ្ទុយនឹងការសន្និដ្ឋានរបស់ខ្លួនដែលថា លោក យឹម ទិត្យ គឺជា "មេដឹកនាំស្រុកគិរីវង់"។ ក្រៅពីខ្វះភាពច្បាស់លាស់ថាតើនៅពេលណា យឹម ទិត្យ បានធ្វើការគ្រប់គ្រងក្នុងស្រុកគិរីវង់ ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដែលថាគាត់បានអនុវត្ត ឬបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ឬថាតើតួនាទី និងការទទួលខុសត្រូវជាក់លាក់ទាំងនោះមានអ្វីខ្លះ។ ស.ច.ស.អ ខកខានមិនបានផ្តល់សំអាងហេតុគ្រប់គ្រាន់ឡើយសម្រាប់ការសន្និដ្ឋានរបស់ខ្លួនដែលថា លោក យឹម ទិត្យ មានសិទ្ធិអំណាចទូទៅលើស្រុកគិរីវង់។

---

[394] ឯកសារ D118/305 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប ផាន ឆ.២៧-ឆ.២៨ ERN 01024599។

[395] ឯកសារ D118/44 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ង៉ែត ង៉យ ឆ.៩ ERN 00905848។

[396] ឯកសារ D118/44 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ង៉ែត ង៉យ ឆ.៤-ឆ.៥, ៩ ERN 00905848។

[397] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ ជើងទំព័រ ៨៦៩។

[398] ឯកសារ D119/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុឹង វេត ឆ.៧ ERN 00975764។ ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុឹង វេត ឆ.៤១, ឆ.៤៦, ERN 01136707-01136708, ឆ.៩៣-៩៥, ឆ.១០៣, ឆ.១០៦ ERN 01136716-01136718។

[399] ឯកសារ D119/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុឹង វេត ឆ.២៨, ២៩, ៣០ ERN 00975768 (សៈ ហេតុអ្វីបានជាលោកដឹងរឿងនេះ? ឆ.២៥ៈ ខ្ញុំដឹងរឿងនេះពីម្តាយរបស់ខ្ញុំ [...]។ សៈ តាមដែលលោកដឹង តើគេចាប់តា គុំ ដោយវិធីណា? ឆ.២៨ៈ យោងតាមម្តាយរបស់ខ្ញុំ គាត់ប្រាប់ខ្ញុំថា [...]។ សៈ ហេតុអ្វីម្តាយរបស់លោកដឹងអំពីរឿងនេះ? ឆ.២៩ៈ ខ្ញុំគិតថាម្តាយរបស់ខ្ញុំទទួលបានព័ត៌មានអំពីរឿងនេះតាមរយៈសាច់ញាតិរបស់គាត់ និងមិត្តភក្តិរបស់គាត់ [...]។ សៈ តើលោកដឹងថាគេចាប់តាម គុំ ដោយរបៀបណាទេ? ឆ.៣០ៈ ទេ ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងព័ត៌មានពីម្តាយរបស់ខ្ញុំប៉ុណ្ណោះ")។

១៥២. លើភ័ស្តុតាងខ្សោយ និងមិនអាចជឿបានអំពីប្រតិបត្តិការ*តាមព្រឹត្តន័យ*របស់គណៈកម្មាធិការនោះ និង ការសន្និដ្ឋានរបស់ ស.ច.ស.អ ដែលថា ភ័ស្តុតាង "មិនច្បាស់លាស់" បង្ហាញថា លោក យឹម ទិត្យ អាចត្រូវបានតែងតាំង*តាមនិតិន័យ*ឱ្យកាន់តួនាទីខ្លះនៅក្នុងគណៈកម្មាធិការស្រុករយៈពេលប៉ុន្មានខែ រវាងខែតុលា ឆ្នាំ១៩៧៥ និង ខែមករា ឆ្នាំ១៩៧៦[400] ពុំមានអ្នកវិនិច្ឆ័យអង្គេតដ៏សមហេតុផលអាចឈានដល់ការសន្និដ្ឋានថា យឹម ទិត្យ គឺជា "មេដឹកនាំស្រុកគិរីវង់" ដោយគ្មានបញ្ជាក់ពេលវេលាជាក់លាក់ឡើយ[401]។ ស.ច.ស.អ ខកខានមិនបានពិចារណាពីភាពផ្ទុយគ្នា និងភាពមិនប្រាកដប្រជានៅក្នុងភ័ស្តុតាងសំណុំរឿង និងខកខានមិនបានផ្តល់ការសន្និដ្ឋានដែលមានសំអាងហេតុដែលធ្វើឱ្យប៉ះពាល់ដល់ភាពអាចជឿទុកចិត្តបាននៃការវាយតម្លៃរបស់ ស.ច.ស.អ ទៅលើសំណុំរឿង។ កំហុសឆ្គងធ្វើមានមោឃភាពដល់ ការសន្និដ្ឋាននៅក្នុងដីកាដំណោះស្រាយអំពីស្រុកគិរីវង់ និងធ្វើឱ្យមានភាពអយុត្តិធម៌ដែលតម្រូវឱ្យ អ.ប.ជ បដិសេធសេចក្តីសន្និដ្ឋានរបស់ ស.ច.ស.អ។

### (ii) ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ មាន "សិទ្ធិអំណាចជាក់ស្តែងច្រើន" ទូទាំងតំបន់១៣

១៥៣. ស.ច.ស.អ សន្និដ្ឋានថា លោក យឹម ទិត្យ "មានសិទ្ធិអំណាចជាក់ស្តែងច្រើន"ទូទាំងតំបន់១៣ និង ភូមិភាគនិរតី[402]។ ស.ច.ស.អ ដែលរកមិនឃើញភ័ស្តុតាងគ្រប់គ្រាន់លើការតែងតាំង លោក យឹម ទិត្យ ជាផ្លូវការ*តាមនិតិន័យ*ជាគណៈតំបន់ ១៣ បានផ្អែកសេចក្តីសន្និដ្ឋានរបស់ខ្លួនលើសំអាងហេតុដែលមានកំហុសឆ្គងអំពី សិទ្ធិអំណាច*តាមព្រឹត្តន័យ*របស់ យឹម ទិត្យ[403]។

*ស.ច.ស.អ មានកំហុសពាក់ព័ន្ធនឹង ការតែងតាំងលោក យឹម ទិត្យ ជាគណៈតំបន់ ១៣ តាមនិតិន័យ*

---

[400] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣២៨, ៣៤២។

[401] *ដូចយោងខាងលើ* កថាខណ្ឌ ៣៣២។ ស.ច.ស.អ យល់ច្រឡំទៅលើការលបរិច្ឆេទ ប៉ុន្តែ ទោះជាយ៉ាងនេះក្តី ក៏គាត់បានសំអាងទៅលើ*អំណាចតាមព្រឹត្តន័យ*នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ ដោយលើកឡើងថា "ដោយមិនគិតពីតួនាទីផ្លូវការរបស់គាត់នៅក្នុងគណៈកម្មាធិការស្រុកគីរីវង្ស សាក្សីជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា យឹម ទិត្យ ជាក់ស្តែងជាមេដឹកនាំស្រុក សូម្បីតែនៅក្នុងអំឡុងពេលដែល យឹម ទិត្យ និង តាគុំនៅជាមួយគ្នាក្នុងគណៈកម្មាធិការស្រុក"។

[402] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៤៨ ដល់ ៣៥២។

[403] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៨ ដល់ ៣៥២។

១៥៤. ស.ច.ស.អ មិនអាចសន្និដ្ឋានច្បាស់លាស់អំពី ការតែងតាំង យឹម ទិត្យ ជាគណៈតំបន់១៣[404] តាមការ ចោទប្រកាន់។ ស.ច.ស.អ លើកឡើងថា "សាក្សីមួយចំនួនផ្តល់ភ័ស្តុតាងថា យឹម ទិត្យ គឺជាគណៈតំបន់១៣ យ៉ាងឆាប់បំផុតគឺ ឆ្នាំ១៩៧៦"[405] ដោយយោងទៅលើភ័ស្តុតាងរបស់សមាជិកដទៃទៀតនៃគណៈតំបន់នោះ និងរយៈពេលនៃការទទួលតួនាទីនោះ ក្នុងនោះ រួមមានបុគ្គលជាជម្រើសចំនួន ៥ នាក់ផ្សេងទៀត ដែលអាចបានធ្វើជាលេខាតំបន់ ១៣ ក្រៅពី យឹម ទិត្យ[406]។ ស.ច.ស.អ សន្និដ្ឋានថា មានមុខតំណែងចំនួនគណៈតំបន់ចំនួន៣ ដែលមានការទទួលខុសត្រូវរៀងៗខ្លួន "លេខា១នាក់ អនុលេខា១នាក់ ជាទូទៅទទួលខុសត្រូវសន្តិសុខ និង សមាជិក១នាក់ជាទូទៅទទួលខុសត្រូវសេដ្ឋកិច្ច"[407]។ ស.ច.ស.អ ខកខានមិនបានបញ្ជាក់ឲ្យបានជាក់លាក់ថាតើ យឹម ទិត្យ បានកាន់តំណែងជាលេខា តាមការចោទប្រកាន់ អនុលេខា ឬសមាជិក នៅក្នុងពលវេលាជាក់លាក់នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ឬអ្វីដែលជាការទទួលខុសត្រូវរបស់គាត់ ដូចជា ការតែងតាំងមុខតំណែងនៅក្នុងគណៈកម្មាធិការនោះ ពោលគឺតំណែង សន្តិសុខ ឬសេដ្ឋកិច្ច។

១៥៥. ស.ច.ស.អ រកឃើញភ័ស្តុតាងមិនគ្រប់គ្រាន់លើការតែងតាំងយឹមទិត្យ ជាលេខាតំបន់១៣[408]។ "មិនអាចកំណត់កាលបរិច្ឆេទជាក់លាក់ ឬរយៈពេលនៃការកាន់មុខតំណែងរបស់គាត់ឡើយ"[409]។ ស.ច.ស.អ ពិចារណាលើ ភ័ស្តុតាងរបស់ អ៊ុល ហឿន, នុត នៅ, ម៉ឹង វេត, សាន់ ឡុន, ពេជ្រ ជឹម, វ៉ាន់ យ៉ាន់, និង ណុប សាន និង យល់ឃើញថា គាត់មិនអាចធ្វើការសន្និដ្ឋានថា លោក យឹម ទិត្យ ធ្វើជាលេខាតំបន់១៣[410] ឬមានសិទ្ធិអំណាចតាមផ្លូវច្បាប់ផ្សេងទៀត នៅក្នុងគណៈកម្មាធិការនោះសម្រាប់រយៈពេលជាក់លាក់ណាមួយឡើយ[411]។

---

[404] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៣ ដល់ ៣៥៤។

[405] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៣។

[406] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៤ ដល់ ៣៤៥។

[407] *ដូចយោងខាងលើ* កថាខណ្ឌ ១៧១, ១៧៨។

[408] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៤ ដល់ ៣៤៧។

[409] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៦។

[410] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៦ ដល់ ៣៤៧។

[411] *ដូចយោងខាងលើ* កថាខណ្ឌ ៣៤៤ ដល់ ៣៤៥។

*ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ មាន "សិទ្ធិអំណាចតាមព្រឹត្តន័យ" នៅក្នុងតំបន់១៣*

១៥៦. ដូចដែលបានបញ្ជាក់លម្អិតខាងលើ ស.ច.ស.អ បានផ្អែកការវាយតម្លៃរបស់ខ្លួនអំពី "សិទ្ធិអំណាច *តាមព្រឹត្តន័យ*"របស់ យឹម ទិត្យ ក្នុងតំបន់១៣ លើសំអាងហេតុដែលមានកំហុសឆ្គងអំពីទំនាក់ទំនងរវាងលោក យឹម ទិត្យ និង តាម៉ុក[412]។ ស.ច.ស.អ បានពឹងផ្អែកលើការសន្និដ្ឋានពិរុទ្ធភាពតាមរយៈទំនាក់ទំនងជាមួយតាម៉ុក ដើម្បីប៉ះប៉ូវជាមួយនឹងការខ្វះភ័ស្តុតាងនៃអំពើ និងការប្រព្រឹត្តរបស់ យឹម ទិត្យ[413]។

១៥៧. ស.ច.ស.អ បានធ្វើការសន្និដ្ឋានដោយគ្មានហេតុផលថា លោក យឹម ទិត្យ "មានការប្រជុំ និងទទួលភ្ញៀវនៅមន្ទីរតំបន់១៣ជាទៀងទាត់"[414] ដោយផ្អែកលើភ័ស្តុតាងដែលគ្មានការគាំទ្ររបស់ ប៊ិច ជឹម ថាគាត់ឮការផ្សាយវិទ្យុនៅចុងឆ្នាំ១៩៧៨ថា "តាទិត្យ ទទួលស្វាគមន៍ភ្ញៀវនៅមន្ទីរតំបន់១៣"[415]។ មិនតែប៉ុណ្ណោះ ស.ច.ស.អ ខកខានមិនបានពិចារណាថា ពេជ្រ ជឹម ក្រោយមក ផ្លាស់ប្តូរភ័ស្តុតាងដោយនិយាយថា គាត់លែងជឿទៀតហើយថា គាត់បានឮវិទ្យុផ្សាយដោយខ្លួនឯងផ្ទាល់ ប៉ុន្តែផ្ទុយទៅវិញគាត់ត្រូវបាននិរសារនិយាយប្រាប់នៅថ្ងៃបន្ទាប់ ដោយពុំបានបញ្ជាក់អំពីកាលៈទេសៈ ឬពេលវេលាឡើយ[416]។

១៥៨. ស.ច.ស.អ ក៏ពឹងផ្អែកលើសេចក្តីដកស្រង់ទស្សនៈដែលមានលក្ខណៈផ្ទុយ និងពុំមានការបញ្ជាក់ និងភ័ស្តុតាងចចាមអារ៉ាមរបស់កម្មាភិបាលថ្នាក់ក្រោម ឈ្មោះ ម៉ឹង វេត[417] ដើម្បីសន្និដ្ឋានថា លោក

---

[412] សូមមើលខាងលើ កថាខណ្ឌ ១២៤ ដល់ ១៤១។

[413] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៤៨។

[414] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៤៩។

[415] ឯកសារ D118/79 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.១៨-ឆ.២០ ERN 00934402។

[416] ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.១៣៦-ឆ.១៣៧ ERN 00997041។

[417] ឯកសារ D219/899.1.4 ម៉ឹង វេត ប្រតិចារឹកសវនាការ ERN 01329894-01329895 ម៉ោង ១១.១២.០៥-១១.១៦.១០ ទំព័រ ៣២ បន្ទាត់ ២ ដល់ទំព័រ ៣៣ បន្ទាត់ ៦។

យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ*នៅក្នុងតំបន់១៣[418]។ ស.ច.ស.អ ពឹងផ្អែកលើ ចម្លើយរបស់ ម៉ឹង វេត៖

- "តាទិត្យ" ដំបូងឡើយធ្វើជា "ជំនួយការ តាសោម និង ចាត់ចែងការងារនៅក្នុងអង្គភាពនិរសារក្នុងតំបន់១៣ ថា ម៉ឹង វេត ឮពីប្រភពមិនស្គាល់[419] "ប៉ុន្តែមិនយកចិត្តទុកដាក់នឹងភស្តុតាងផ្ទុយដែលថា ម៉ឹង វេត មិនដឹងច្រើន"អំពី លោក យឹម ទិត្យ និង គណៈតំបន់១៣[420] និងមិនយកចិត្តទុកដាក់ថា ភស្តុតាងទាំងមូលរបស់គាត់អំពីតួនាទីរបស់ "តាទិត្យ" គឺជាភស្តុតាងចចាមអារ៉ាមដែលមានលក្ខណៈផ្ទុយគ្នា[421]។

- គាត់ឃើញ "តាទិត្យ" នៅក្នុងកិច្ចប្រជុំនៅក្នុងតំបន់១៣ នៅចុងឆ្នាំ១៩៧៦ អង្គុយនៅលើវេទិកានៅខាងស្តាំដៃរបស់ តាសោម ដែលពេលនោះជាលេខាតំបន់១៣[422]។ តាមទស្សនៈយល់ឃើញរបស់គាត់ នៅខាងលេខាតំបន់គឺគេបម្រុងទុកសម្រាប់អនុលេខា។ ប៉ុន្តែ ស.ច.ស.អ មិនបានរៀបរាប់ភស្តុតាងរបស់សាក្សីដែលផ្ទុយគ្នា ដែលគាត់យល់ច្រឡំឬបំផ្លើសការដឹងរបស់គាត់ទៅលើការរៀបចំកន្លែងអង្គុយ[423] និងថា "តាទិត្យ" អង្គុយ

---

[418] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៥១។

[419] ឯកសារ D119/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៤ ERN 00975696។

[420] ឯកសារ D119/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៤ ERN 00975696 "ស៖ តាមដែលលោកដឹង តើ *តា ទិត* ធ្លាប់ធ្វើជាគណៈតំបន់ដែរឬទេ កាលជំនាន់កម្ពុជាប្រជាធិបតេយ្យ? ឆ.៣៤៖ ខ្ញុំឮថា គាត់ក្លាយជាគណៈតំបន់ ១៣ នៅឆ្នាំ ១៩៧៨។ ខ្ញុំមិនដឹងអ្វីច្រើនទៀតទេ ពីព្រោះខ្ញុំចាកចេញពីភូមិភាគនរតីបាត់ទៅហើយ។ ប៉ុន្តែ ខ្ញុំឮថាគាត់ទទួលខុសត្រូវតំបន់ ១៣ មួយរយៈ មុនការមកដល់របស់ពួកវៀតណាម"។

[421] ឯកសារ D119/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៤ ERN 00975696។ ឯកសារ D119/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេតត ឆ.២១ ERN 00975766។ ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៣៤-ឆ.៣៧, ឆ.៤០-ឆ.៤១ ERN 01136706-7។ ឯកសារ D119/84.2 មជ្ឈមណ្ឌលឯកសារកម្ពុជាសម្ភាសន៍ជាមួយ ម៉ឹង វេត ERN 00975724-00975727។

[422] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៥៤។

[423] ឯកសារ D119/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.១១-ឆ.១២ ERN 00975765។ ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៤០ ERN 01136707។

"នៅកន្លែងដដែល" ដូចតាគុំ ដែល "ប្រហែលជា"នៅជាមួយសមាជិកនៃគណៈកម្មាធិការស្រុក[424]។

១៥៩. ស.ច.ស.អ ពុំបានផ្តល់សំអាងហេតុអំពី "សិទ្ធិអំណាច*តាមព្រឹត្តន័យ*" របស់បុគ្គលដទៃទៀតដែលត្រូវបានចោទថាស្ថិតនៅក្នុងគណៈតំបន់១៣ពាក់ព័ន្ធនឹង "សិទ្ធិអំណាច*តាមព្រឹត្តន័យ*"របស់ យឹម ទិត្យ និងពុំផ្តល់ សំអាងហេតុសម្រាប់ការសន្និដ្ឋានដែលថា "សិទ្ធិអំណាច*តាមព្រឹត្តន័យ*"របស់ យឹម ទិត្យ ខ្លាំងជាងអ្នកដទៃ។ ឧទាហរណ៍ ភ័ស្តុតាងឯកសាររបស់ Timothy Carney សរសេរថា កម្មាភិបាលភូមិភាគនិរតី ម្នាក់ឈ្មោះ វ៉ាញ់ បិត "ប្រហែលដឹកនាំប្រតិបត្តិការប្រចាំថ្ងៃនៅភូមិភាគនិរតី"[425]។ វ៉ាញ់ បិត ត្រូវបានសំដៅដល់ អនុលេខារបស់ តាម៉ុក នៅភូមិភាគនិរតី និង កាន់មុខតំណែងនេះនៅស្របពេលជាមួយនឹង ឈ្មោះ ចុង ហៅ ប្រសិទ្ធ។ វ៉ាញ់ បិត ក្លាយជាសមាជិកគណៈប្រធានរដ្ឋ "ក្រោយពេលមានការបោះសម្អាត"[426] ប្រហែលក្នុងពេលដំណាលគ្នាដែល ចុង ហៅ ប្រសិទ្ធ ទទួលបន្ទុកតំបន់១១ នៃភូមិភាគបស្ចិម[427]។

១៦០. ស.ច.ស.អ ខកខានមិនបានពិចារណាលើភ័ស្តុតាងរបស់សាក្សីចំនួន ៣៦ នាក់ដែលត្រូវបានស្តាប់ចម្លើយ ដោយ ក.ស.ច.ស ដែលបានផ្តល់ចម្លើយថា ពួកគេមិនដែលឮឈ្មោះ យឹម ទិត្យ ឡើយ ទោះបីជាសាក្សីទាំងនោះ រស់នៅ និងធ្វើការនៅក្នុងតំបន់១៣ក្នុងរយៈកាលនៃសម័យកម្ពុជាប្រជាធិបតេយ្យក៏ដោយ ក្នុងនោះគឺ អ៊ុក សុគន្ធា, បាវ ណៃម, ជាវ វ៉ាន់, ឌឹក ប៉ែត, ហង់ សៀន, ហ៊ុន គីមសេង, អ៊ឹង ដែន ហៅ សាច់ ដែន, ខន គីម, ឃិន ស្វ, គង់ សំណាង, ឡាច សែម, ម៉ៅ ង្វូវ, មុំ ផល្លា, ប៉ុល ញ៉ាន, សំ គុណ, សំ ទូច, សាន ទូច, សូត្រ សាំង, សែម សួន, សែន ស៊ីម, ស៊ែត

[424] ឯកសារ D219/488 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ឹង វេត ឆ.៥៦-ឆ.៥៧ ERN 01136710។

[425] ឯកសារ D1.3.15.2 ផ្នែករបស់ Timothy Carney, ជំពូក៖ "ការរៀបចំអំណាច" នៅក្នុងសៀវភៅនិពន្ធដោយ Karl Jackson មានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" បោះពុម្ពដោយរោងពុម្ពសកលវិទ្យាល័យ Princeton ERN 00332370 ដល់ 00332373។

[426] ឯកសារ D1.3.15.2 ផ្នែករបស់ Timothy Carney, ជំពូក៖ "ការរៀបចំអំណាច" នៅក្នុងសៀវភៅនិពន្ធដោយ Karl Jackson មានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" បោះពុម្ពដោយរោងពុម្ពសកលវិទ្យាល័យ Princeton ERN 00332370-00332373។

[427] ឯកសារ D1.3.15.2 ផ្នែករបស់ Timothy Carney, ជំពូក៖ "ការរៀបចំអំណាច" នៅក្នុងសៀវភៅនិពន្ធដោយ Karl Jackson មានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" បោះពុម្ពដោយរោងពុម្ពសកលវិទ្យាល័យ Princeton ERN 00332381-00332383។

យ៉ែម, ស្រី ថន, សួ លន, តឹម ប៊ុនលី, ថាន់ ធីម, តុប ង៉ែត, តឹម ហ៊ី, អ៊ុក ហ៊ីម, វ៉ាន សឿន, យ៉ង ញឹម, យិន តេង, ហ៊ុន រ៉េត, តួច ភឿន, ឆឹង ជឿន, វង់ សាន, និង អ៊ុក ហ៊ឹង[428]។ បញ្ជីនេះ

---

[428] *សូមមើល* ឧបសម្ព័ន្ធ ក: សាក្សីដែលមិនធ្លាប់ឮឈ្មោះ យឹម ទិត្យ។ ឯកសារ D219/229 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ុក សុគន្ធា ឆ.៥១ ERN 01076337។ ឯកសារ D119/63 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាវ ណោម ឆ.១១ ERN 00951946។ ឯកសារ D219/724 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាវ វ៉ាន់ ERN 01213620។ ឯកសារ D118/203 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដឹក ប៉ែត ឆ.១៦៥ ERN 00979217។ ឯកសារ D219/942 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ សៀន ឆ.១៣ ERN 01415365។ ឯកសារ D219/522 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន គឹមសេង ឆ.៨៩ ERN 01149853។ ឯកសារ D219/100 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ីង ដែន ហៅ សាច់ ដែន ឆ.៤១ ERN 01043211។ ឯកសារ D118/47 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខាន់ គីម ឆ.៩ ERN 00905865។ ឯកសារ D118/291 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី យិន សួរ ឆ.១៨០ ERN 01022447។ ឯកសារ D118/253 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី គង់ សំណាង ឆ.៧២ ERN 00993601។ ឯកសារ D118/233 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឡាច សែម ឆ.១៣៤ ERN 00987242។ ឯកសារ D219/316 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ៅ ង៉ូវ ឆ.១៧៤ ERN 01097771។ ឯកសារ D219/568 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ផល្លា ឆ.១២៤ ERN 01165973។ ឯកសារ D118/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ុល ញ៉ន ឆ.១៥-ឆ.១៦ ERN 00920163។ ឯកសារ D219/591 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ គុណ ឆ.៩២ ERN 01169873។ ឯកសារ D219/604 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សំ ទូច ឆ.១០៩ ERN 01173503។ ឯកសារ D118/131 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សាន់ ទូច ឆ. ERN 00960608។ ឯកសារ D134/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូត្រ សាំង ឆ.១១៦ ERN 00964491។ ឯកសារ D119/142 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែម នួន ឆ.៥៨ ERN 01007928។ ឯកសារ D219/610 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេន ស៊ឹម ឆ.៤០ ERN 01175273។ ឯកសារ D219/2 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សែត យ៉ែម ឆ.៧៥ ERN 01024796។ ឯកសារ D118/134 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស្រី ថន ឆ.៥២ ERN 00960649។ ឯកសារ D118/293 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ូ លន ឆ.៦២-ឆ.៦៣ ERN 01023145។ ឯកសារ D118/300 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តឹម ប៊ុនលី ឆ.២៦០ ERN 01024543។ ឯកសារ D118/269 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ឆ.១១៧ ERN 00998125។ ឯកសារ D219/49 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត តុប ឆ.១៤៩, ឆ.១៥៨ ERN 01032602, 01032603។ ឯកសារ D118/166 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទឹម ហ៊ី ឆ. ERN 00968166។ ឯកសារ D118/276 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ហ៊ីម ឆ.៨៦ ERN 01000030។ ឯកសារ D118/167 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ៉ាន់ សឿន ឆ.១០៨ ERN 00968183។ ឯកសារ D118/284 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យង់ ញឹម ឆ. ERN 01008192។ ឯកសារ D219/135 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យិន តេង ឆ.៥៣៦ ERN 01052746។ ឯកសារ D219/926 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុន រ៉េត ឆ. ១០ ERN 01392958។ ឯកសារ

មិនរាប់បញ្ចូលបុគ្គលដែល ក.ស.ច.ស បានទាក់ទងក្នុងកំឡុងពេលស៊ើបអង្កេតដែលមិនដែលឮឈ្មោះ យឹម ទិត្យ និង ដែលមិនត្រូវបានស្តាប់ចម្លើយឡើយ។ ស.ច.ស.អ ធ្វើមិនដឹងមិនឮថាភ័ស្តុតាងរបស់សាក្សីទាំងនេះ នៅពេលផ្គុំគ្នា ធ្វើឲ្យលុបការសន្និដ្ឋានរបស់ខ្លួនដែលថា យឹម ទិត្យ មានសិទ្ធិអំណាចធំទូទាំងតំបន់។

*សេចក្តីសន្និដ្ឋានអំពីតំបន់១៣*

១៦១. ការសន្និដ្ឋានរបស់ស.ច.ស.អ លើសិទ្ធិអំណាច "ដាក់ស្តែងធំ" នៅក្នុងតំបន់១៣ និង អ្វីដែលហៅថា "ភូមិភាគនិរតីទាំងមូល" ខ្វះហេតុផល។ ស.ច.ស.អ ខកខានមិនបានពន្យល់ថាតើ យឹម ទិត្យ អាចមាន "សិទ្ធិអំណាច*តាមព្រឹត្តន័យ*" ដោយរបៀបណា ដោយខ្វះភ័ស្តុតាងបង្ហាញអំពីមុខតំណែង*តាមនិតិន័យ*នៅក្នុងគណៈតំបន់ និងភ័ស្តុតាងជាច្រើនរបស់បុគ្គលទាំងឡាយដែលមិនធ្លាប់ឮឈ្មោះ យឹម ទិត្យ ធ្វើអ្វីនៅក្នុងតំបន់១៣[429]។ ដូចដែលបានលើកទឡ្ហីករណ៍ខាងលើ ស.ច.ស.អ ខកខានមិនបានបង្ហាញភ័ស្តុតាងដើម្បីគាំទ្រអត្ថិភាពនៃ "ទំនាក់ទំនងជិតស្និទ្ធ" រវាង តាម៉ុក និង យឹម ទិត្យ និងខកខានមិនបានពន្យល់ថាតើទំនាក់ទំនងគ្រួសារបានផ្តល់ យឹម ទិត្យ នូវសិទ្ធិអំណាចដោយរបៀបណា។

១៦២. ស.ច.ស.អ ខកខានមិនបានពិចារណាភ័ស្តុតាងផ្ទុយពីសាក្សីដូចគ្នាដែលគាត់បានផ្អែកលើ ក៏ដូចជាភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុកពីសាក្សីដទៃទៀត។ ស.ច.ស.អ មិនបានផ្តល់មូលហេតុនៃការខ្វះការយោងដល់ភ័ស្តុតាងនេះឡើយ។

១៦៣. ដោយខកខានមិនបានពិចារណាលើភ័ស្តុតាងសាក្សីសំខាន់ៗ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយអនុវត្តបទដ្ឋានគតិយុត្តមិនត្រឹមត្រូវនៅក្នុងការវាយតម្លៃលើភ័ស្តុតាង និងខកខានមិនបានផ្តល់ការសន្និដ្ឋាន ដែលមានសំអាងហេតុ ដែលប៉ះពាល់ដល់ភាពគួរឲ្យជឿទុកចិត្តបានទូទៅនៃការវាយតម្លៃរបស់ ស.ច.ស.អ លើសំណុំរឿង និងមោឃភាពដល់ដីកាដំណោះស្រាយ។ ស.ច.ស.អ មានកំហុសអង្គហេតុដោយទាញសេចក្តីសន្និដ្ឋានមិនត្រឹមត្រូវយ៉ាងចំហរអំពី សិទ្ធិអំណាច "*តាម*

---

D118/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តួច ភឿន ឆ.១៩ ERN 00945399។ ឯកសារ D119/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹង ជឿន ឆ.១៥ ERN 01024772។ ឯកសារ D219/919 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វង់ សន ឆ.៦២ ERN 01390487។ ឯកសារ D219/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុក ប៊ាង ឆ.១៣៧ ERN 01025507។

[429] *សូមមើល* ឧបសម្ព័ន្ធ ក៖ សាក្សីដែលមិនធ្លាប់ឮឈ្មោះ យឹម ទិត្យ។

*ព្រឹត្តន័យ*" របស់ យឹម ទិត្យ ទូទាំងតំបន់ ១៣ តាមការចោទប្រកាន់ ដែលបណ្តាលឲ្យបានភាពអយុត្តិធម៌ ដែលតម្រូវឲ្យ អ.ប.ជ បដិសេធការសន្និដ្ឋានរបស់ ស.ច.ស.អ។

**(iii) ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ ជាលេខាតំបន់១**

*ស.ច.ស.អ មានកំហុសឆ្គងក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់១ ក្នុងខែមិថុនា ឆ្នាំ១៩៧៨*

១៦៤. ស.ច.ស.អ មានកំហុសឆ្គងក្នុងការសន្និដ្ឋានថា យឹម ទិត្យ ក្លាយជាលេខាតំបន់១ ក្នុងខែមិថុនា ឆ្នាំ ១៩៧៨ និងអនុវត្តសិទ្ធិអំណាចរបស់ខ្លួនរហូតដល់ចប់របបនោះ[430]។ ក្នុងការធ្វើសេចក្តីសន្និដ្ឋាននេះ ស.ច.ស.អ បានផ្អែកលើការដកពីតំណែងនិងចាប់ខ្លួន តាប៉ែត ដែលត្រូវបានតែងតាំងជាលេខាតំបន់១[431] និងសន្និដ្ឋានថា លោក យឹម ទិត្យ ឡើងជំនួស តាប៉ែត[432]។ ការសន្និដ្ឋាននេះមានកំហុសឆ្គង និងពុំមានភ័ស្តុតាងគាំទ្រ។

១៦៥. ស.ច.ស.អ សន្និដ្ឋានថា លោក យឹម ទិត្យ ឡើងជំនួស តាប៉ែត ក្រោយពីតាប៉ែត ត្រូវបានដកពីតួនាទី ជាលេខាតំបន់១ ក្នុងខែមិថុនា ឆ្នាំ១៩៧៨[433]។ ប៉ុន្តែ ពុំមានសាក្សីណាម្នាក់ដែល ស.ច.ស.អ សំអាង គាំទ្រការសន្និដ្ឋាននេះ បានផ្តល់ភ័ស្តុតាងផ្ទាល់ពាក់ព័ន្ធនឹងការតែងតាំង លោក យឹម ទិត្យ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ តាមការចោទប្រកាន់នោះឡើយ។

---

[430] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦០ ដល់ ៣៧១, ៩៩៣។ ថ្វីបើមេធាវីការពារក្តីគាំទ្រសេចក្តីសន្និដ្ឋានរបស់ ស.ច.ស.ជ ថា យឹម ទិត្យ មិនស្ថិតនៅក្នុងរង្វង់យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដោយសារតែមូលហេតុដែលបានលើកឡើងនៅក្នុងនេះក្តី ប៉ុន្តែ មេធាវីការពារក្តីមិនយល់ស្របជាមួយការសម្រេចរបស់ ស.ច.ស.ជ អំពីការតែងតាំងលោក យឹម ទិត្យ ទៅក្នុងគណៈកម្មាធិការតំបន់ ១ ដូចបានលើកក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស.ជ កថាខណ្ឌ ៦៦៩, ៦៧៣, ៦៨០ ដែរ។

[431] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦១។ *សូមមើល ផងដែរ:* ឯកសារ D1.3.15.2 ផ្នែករបស់ Timothy Carney ជំពូក៖ "The ការរៀបចំអំណាច" នៅក្នុងសៀវភៅនិពន្ធដោយ Karl Jackson មានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការការណាត់ជួបជាមួយសេចក្តីស្លាប់" បោះពុម្ពដោយរោងពុម្ពសកលវិទ្យាល័យ Princeton ERN 00332368 ដែលយោងទៅសមាជ ប.ក.ក ខែសីហា ឆ្នាំ១៩៧៨៖ សមាជិកគណៈកម្មាធិការមជ្ឈិម និងតារាងទី ៣។

[432] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦១។

[433] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦០ ដល់ ៣៦២។

- តុប សឹង មកភូមិភាគពាយ័ព្យ ពីភូមិភាគនិរតី[434]ប៉ុន្តែគាត់មិនស្គាល់ "តាទិត្យ" ខណៈពេលដែល គាត់នៅទីនោះ[435]។ គាត់លើកឡើងថាបានឃើញ "តាទិត្យ" នៅទំនប់កង្គត់ជាលើកទីមួយនៅ"ពាក់កណ្តាលឆ្នាំ១៩៧៨" ពីរបីខែមុនពេលវៀតណាមមកដល់[436] ប៉ុន្តែគាត់មិនដែលបានចូលរួមប្រជុំជាមួយ "តាទិត្យ"ទេ[437] និង ដឹងអំពីមុខតំណែងរបស់ "តាទិត្យ" ពីប្រធានកងរបស់ខ្លួនប្រាប់[438]។ តុប សឹង មិនស្គាល់អត្តសញ្ញាណ យឹម ទិត្យ ច្បាស់ទេ។

- លេក ពៀវ "មិនដឹងប្រាកដពីតួនាទីរបស់ តា ប៉ែត និង តា ទិត្យ" ទេ[439] ហើយគាត់មិនស្គាល់អត្តសញ្ញាណ លោក យឹម ទិត្យ ច្បាស់ទេ។

- ឆាំ លុយ មិនដែលជួប "តាទិត្យ"[440] និង មិនដែលឮពីតាទិត្យ មុនពេលគាត់រត់ពីអង្គភាពយោធារបស់គាត់ត្រឡប់ទៅភូមិកំណើតនៅបុសខ្នុរ វិញក្នុងខែវិច្ឆិកា ឬខែធ្នូ ឆ្នាំ ១៩៧៨[441]។ នៅពេលគាត់មកដល់ភូមិវិញ ទើបគាត់ឮប្រជាជនក្នុងភូមិប្រាប់ថា "តាទិត្យ" គឺជាប្រធានតំបន់១[442]។

---

[434] ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឹង ឆ.៤-ឆ.៩, ឆ.១៤-ឆ.១៥ ERN 01046460-01046461។

[435] ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឹង ឆ.២៥ ERN 01046462។

[436] ឯកសារ D219/117 កំណត់ហេតុស្តាប់ចម្លើយសាក្សី តុប សឹង ឆ.៦៨ ERN 01046466, ឆ.៨៥ ERN 01046468។

[437] ឯកសារ ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឹង ឆ.១៤៤-១៤៧ ERN 01046474-01046475។

[438] ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឹង ឆ.៧៩-ឆ.៨០ ERN 01046467។

[439] ឯកសារ D219/236 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ឆ.១៨ ERN 01080844។

[440] ឯកសារ D118/243 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ឆ.១៣ ERN 00990630។

[441] ឯកសារ D219/263 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ឆ.៦២-ឆ.៦៣ ERN 01086097-01086098។ ឯកសារ D118/243 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ឆ.៦ ERN 00990629។ ឯកសារ D219/263 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ឆ.១០៩ ERN 01086102។ ឯកសារ D219/263 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ឆ.១០៩ ERN 01086102។

[442] ឯកសារ D118/243 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆាំ លុយ ឆ.១០-ឆ.១១ ERN 00990630។

- ជួន ថន និយាយថា "តាទិត្យ"គឺជាអ្នកដែលជំនួស តាវ៉ាញ នៅក្នុងខែមិថុនា ឆ្នាំ ១៩៧៧[443]។ គាត់និយាយថាគាត់បានឃើញ "តាទិត្យ" តែម្តងគត់[444] នៅក្នុងឆ្នាំ១៩៧៨[445] នៅក្នុងកិច្ចប្រជុំមួយនៅភ្នំសំពៅ តំបន់៣[446] នៅទីនោះគេណែនាំ "តាទិត្យ" ប៉ុន្តែគាត់មិនចាំឈ្មោះអ្នកដែលណែនាំ តាទិត្យ ទេ[447]ឬមិនអាចចាំឈ្មោះអ្នកណាម្នាក់ដែលមានវត្តមានក្នុងកិច្ចប្រជុំនោះទេ[448]។ ជួន ថន មិនសូវដឹងច្បាស់អំពីរចនាសម្ព័ន្ធរដ្ឋបាលរបស់តំបន់១ ឬតំបន់៣ឡើយ[449] គាត់មិនដែលឃើញនរណាម្នាក់ពីគណៈភូមិភាគ ហើយគាត់មិនដែលចូលរួមប្រជុំណាមួយដែលរៀបចំឡើងដោយកម្មាភិបាលតំបន់ឡើយ[450]។ ពុំមានភ័ស្តុតាងបញ្ជាក់នៅក្នុងសំណុំរឿងអំពីការជួបប្រជុំនៅភ្នំសំពៅតាមការចោទប្រកាន់នោះទេ។

- វី ផាន់ និយាយថា "តាទិត្យ" បានមកដល់តំបន់របស់គាត់ប្រហែលក្នុងខែវិច្ឆិកា ឆ្នាំ ១៩៧៨[451] ហើយលើកទីមួយដែលគាត់ឃើញ "តាទិត្យ" និង តាប៉ែត គឺនៅក្នុងកិច្ចប្រជុំមួយនៅទំនប់កង្ហតដែលពេលនោះ "តាប៉ែត" ប្រកាសថា "តាទិត្យ" ដែលមកពីភូមិភាគពាយ័ព្យ បានមក "ជួយគ្រប់គ្រងតំបន់១"[452]។

---

[443] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.៥ ERN 00990643។

[444] ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.២៦ ERN 01023877។

[445] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១២ ERN 00990644។

[446] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៣ ERN 00990645។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៣ ERN 01023875។

[447] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៨ ERN 00990646។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.២៣-ឆ.២៤ ERN 01023877។

[448] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៦ ERN 00990645។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆ.២០ ERN 01023876។

[449] ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៦-ឆ.១៩ ERN 01023876។

[450] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.៥-ឆ.៦ ERN 00990643។

[451] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.២-ឆ.៣ ERN 01040093-4។

[452] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.២-ឆ.៣ ERN 01040093-4។ ឯកសារ D219/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ERN 01364043-01364044។

- ណុប ងឹម មិនដែលឮការប្រកាសផ្លូវការអំពីមុខតំណែងរបស់ "តាទិត្យ" ឡើយ[453] ប៉ុន្តែគាត់ សន្មតថា "តាទិត្យ" គឺជា "គណៈតំបន់១" ក្នុងឆ្នាំ១៩៧៨"[454] និងគាត់មិនដឹងថា "តាទិត្យ" មានមុខតំណែងផ្សេងពីនេះឡើយ[455]។

- ណាង នី ហៅ លៀស គង់ បានឃើញ "តាទិត្យ" តែម្តងគត់[456] នៅក្នុងកិច្ចប្រជុំមួយនៅបាយដំរាំ។ យោងតាម ណាង នី បានឲ្យដឹងថា កិច្ចប្រជុំនេះបានធ្វើឡើងប្រហែលក្នុងខែតុលា ឆ្នាំ១៩៧៨[457] ប៉ុន្តែ លៀស គង់ និយាយថាកិច្ចប្រជុំនេះធ្វើឡើងក្នុងខែកក្កដា ឆ្នាំ១៩៧៨[458]។ ណាង នី សន្មតថា "តាទិត្យ គឺជា គណៈតំបន់" ពីព្រោះគាត់ "កាន់ក្បាលមីក្រូ និងប្រកាស" នៅកំឡុងពេលប្រជុំនេះ[459] ប៉ុន្តែ លៀស គង់ និយាយថា "តាទិត្យ" បានប្រកាសថា គាត់គឺជាគណៈតំបន់"[460]។ ណាង នី ពិពណ៌នាថា "តាទិត្យ" មានមាឌធំសម្បុរជ្រះ"[461] ប៉ុន្តែ លៀស គង់ និយាយថា "តាទិត្យ" មានរាងខ្ពស់ និង សម្បុរខ្មៅ[462]។ ស.ច.ស.អ ខកខានមិនបានរៀបរាប់អំពីភាពផ្ទុយទាំងនេះនៅក្នុងភ័ស្តុតាងសាក្សីទេ។

- នួន មួន ឮថា "តាទិត្យ" ជំនួស តាប៉ែត[463] ក្រោយពី តាប៉ែត "ត្រូវបានផ្ទេរចេញ" នៅក្នុងខែតុលា ឬខែវិច្ឆិកា ឆ្នាំ១៩៧៧[464]។

---

[453] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.១០ ERN 01008698។

[454] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៧ ERN 01008697។

[455] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៦០-ឆ.៦៤ ERN 01008707។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៩២-ឆ.៩៣ ERN 01329398។

[456] ឯកសារ D118/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.២៩ ERN 00934389។ ឯកសារ D219/416 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស គង់ ឆ.១៣ ERN 01117356។

[457] ឯកសារ D118/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.២៥ ERN 00934389។

[458] ឯកសារ D219/416 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.១១-ឆ.១២ ERN 01117355- 6។

[459] ឯកសារ D118/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.២៤ ERN 00934388។

[460] ឯកសារ D219/416 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស គង់ ឆ.១១ ERN 01117355- 6។

[461] 461 ឯកសារ D118/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.២៤ ERN 00934388។

[462] ឯកសារ D219/416 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លៀស គង់ ស/ឆ.១ ERN 01117352-3។

[463] ឯកសារ D118/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន មួន ឆ.១២-ឆ.១៣ ERN 00920212។

[464] ឯកសារ D118/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នួន មួន ឆ.១១ ERN 00920212។

- ស.ច.ស.អ ក៏លើកមកសំអាងផងដែរនូវភ័ស្តុតាងរបស់ ឈឿន ប៊ាន ដែលថា "តាទិត្យ" មកជំនួស តាព្រំ និង តាវ៉ាញ[465] នៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨[466] ដែលមិនពាក់ព័ន្ធនឹងមុខតំណែងរបស់ យឹម ទិត្យ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ និងផ្ទុយនឹង ការសន្និដ្ឋានរបស់ ស.ច.ស.អ ខ្លួនឯងផ្ទាល់ដែលថា តា វ៉ាញ ត្រូវបានជំនួសដោយតាប៉ែតជាលេខាតំបន់១ ក្នុងខែមិថុនា ឆ្នាំ១៩៧៧[467]នៅពេលដែល តា ញឹម គឺជាលខាភូមិភាគពាយ័ព្យ[468]។

១៦៦. លើសពីនេះទៀត ស.ច.ស.អ សន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងមិនស៊ីសង្វាក់របស់សាក្សីតែម្នាក់ គឺ ឈាន ប៊ា ដែលថា តាប៉ែត ត្រូវបានចាប់ខ្លួនក្រោយពី យឹម ទិត្យ មកដល់ ប្រហែលក្នុខែសីហា ឆ្នាំ១៩៧៨ និងថា "និរសារ តាម៉ុក ពីរនាក់ និង យឹម ទិត្យ" មានការពាក់ព័ន្ធនឹង "ការដក" តាប៉ែត[469]។

១៦៧. ស.ច.ស.អ ខកខានមិនបានពិចារណាថា ឈាន ប៊ា មិនស្គាល់ អង្គរក្ស និរសារ ឬ អ្នកបើកឡានរបស់ "តាទិត្យ" ទេ និងគ្រាន់តែនិយាយថា និរសាររបស់ តាម៉ុក "មកប្រាប់តាប៉ែតឲ្យរៀបចំឥវ៉ាន់ដើម្បីផ្លាស់មកកន្លែងផ្សេង"[470] មិនមែនថា តាប៉ែត ត្រូវបានចាប់ខ្លួននោះទេ។

១៦៨. ស.ច.ស.អ មិនយកចិត្តទុកដាក់លើភ័ស្តុតាងផ្ទុយ និងដោះបន្ទុករបស់សាក្សីនេះទេ។ ឈាន ប៊ា បាន រត់គេចទៅសហករណ៍ សង់រ៉ង់ រួចហើយរត់ចូលព្រៃ[471] នៅពេល និរសាររបស់ តាម៉ុក មកជួប តាប៉ែត[472] នៅក្នុង ខែវិច្ឆិកា ឆ្នាំ១៩៧៨[473] និងមិនបានឃើញការចាប់ខ្លួន តាប៉ែត

---

[465] ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១០-ឆ.១៤ ERN 01110175។

[466] ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១៤-ឆ.១៧ ERN 01110175-6។

[467] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦១។

[468] *ដូចយោងខាងលើ* កថាខណ្ឌ ២៩៥ និង ៣៨២។

[469] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦២។

[470] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២ ERN 00960662-3។

[471] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២ ERN 00960662-3។

[472] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២ ERN 00960662-3។

[473] សាក្សីបានរត់ទៅសហករណ៍សាំងរាំងបីខែ មុនវៀតណាមវាយចូល (ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២០ ERN 00960666)។ កងទ័ពវៀតណាមបានចូលមកដល់បាត់ដំបងក្នុងខែកុម្ភៈ ឆ្នាំ (ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២០ ERN 00960666)។

តាមការចោទប្រកាន់ឡើយ។ ចំណុចពេលវេលានេះ ស៊ីសង្វាក់គ្នាជាមួយនឹងការលើកឡើងរបស់ វី ផាន់ ដែលនិយាយថា "តាទិត្យ" បានមកដល់តំបន់នេះប្រហែលក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨[474] និងជាលើកទីមួយដែលគាត់ឃើញ "តាទិត្យ" និង "តាប៉ែត" នៅក្នុង កិច្ចប្រជុំនៅទំនប់កង្កួត ដែលនៅទីនោះ "តាប៉ែត" ប្រកាសថា "តាទិត្យ" ដែលមកពីភូមិភាគនិរតី មក "ជួយគ្រប់គ្រងតំបន់១"[475]។ ឈាន ប៊ា ក៏និយាយផងដែរថា ក្រោយឆ្នាំ១៩៧៩ គាត់បានជួប "តាប៉ែត" ហើយ តាប៉ែត ប្រាប់គាត់ថា "គេចាត់តាំងឲ្យគាត់ទៅកាប់ឫស្សីមួយគុម្ពក្នុងមួយថ្ងៃនៅភ្នំឱរ៉ាល់ ខេត្តកំពង់ស្ពឺ"[476] មិនមែនថាគាត់ត្រូវបានចាប់ខ្លួននោះទេ។

១៦៩. លើសពីនេះទៀត ស.ច.ស.អ មិនយកចិត្តទុកដាក់លើភ័ស្តុតាងផ្ទុយផ្សេងទៀត៖

- ហាន ធី បានចូលរួមកិច្ចប្រជុំនៅបាត់ដំបងក្នុងឆ្នាំ១៩៧៨ បីថ្ងៃមុនពេលវៀតណាមមកដល់[477] ដែលនៅទីនោះ តាប៉ែត មានវត្តមាន"[478]។

- ភ័ស្តុតាងឯកសារក្នុងសំណុំរឿង ដែលមានចំណងជើងថា "ការរៀបចំអំណាច" បង្ហាញថានៅក្នុងខែសីហា ឆ្នាំ១៩៧៨[479] ហេង ទាវ ហៅ "តាប៉ែត" គឺជាសមាជិកគណៈ

---

[474] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.២-ឆ.៣ ERN 01040093-4។

[475] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.២-ឆ.៣ ERN 01040093-4។ ឯកសារ D219/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ERN 01364043-01364044។

[476] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២ ERN 00960662-5។

[477] ឯកសារ D1.3.11.55 កំណត់ហេតុនៃកិច្ចសម្ភាសន៍របស់ ស.ព.អ ជាមួយ ហាន់ ធី EN 00221584-5, EN 00221587។ ឯកសារ D20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាន់ ធី ERN 00699642-6។

[478] ឯកសារ D105/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាន់ ធី ឆ.១៣-ឆ.១៦ ERN 00794127-8។

[479] ឯកសារ D1.3.15.2 អត្ថបទរៀបរៀងដោយ Timothy Carney៖ "ការរៀបចំអំណាច" ដែលត្រូវបានបោះពុម្ពផ្សាយជាផ្នែកមួយនៃសៀវភៅនិពន្ធដោយ Karl Jackson មានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" បោះពុម្ពដោយរោងពុម្ពសកលវិទ្យាល័យ Princeton ERN 00332368 ដែលយោងទៅសមាជ ប.ក.ក ខែសីហា ឆ្នាំ១៩៧៨៖ សមាជិកគណៈកម្មាធិការមជ្ឈិម និងតារាងទី ៣។

អចិន្ត្រៃយ៍ សមាជិកគណៈមជ្ឈិម និងជាសមាជិកគណបក្សតំបន់ក្នុងខែសីហា ឆ្នាំ ១៩៧៨[480]។ ឈ្មោះ យឹម ទិត្យ មិនមាននៅក្នុងឯកសារនេះទេ។

*ស.ច.ស.អ មានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ បានអនុវត្តសិទ្ធិអំណាចតាមព្រឹត្តន័យនៅក្នុងតំបន់១ (ក្នុងនាមជាលេខាតំបន់១)*

១៧០. ស.ច.ស.អ មានកំហុសឆ្គងក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ បានអនុវត្តសិទ្ធិអំណាចគ្រប់បែបយ៉ាងនៅក្នុងតំបន់១[481]។

១៧១. ស.ច.ស.អ សន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងមិនមានការបញ្ជាក់របស់សាក្សីម្នាក់ ឈ្មោះ សឿន ម៉ាត់ ថា យឹម ទិត្យ មានសិទ្ធិអំណាច និងការគ្រប់គ្រងដោយផ្ទាល់លើយោធានៅក្នុងតំបន់១[482]។ ស.ច.ស.អ ខកខានមិនបានពិចារណាភ័ស្តុតាងរបស់ សឿន ម៉ាត់ ដែលថាគាត់មិនស្គាល់នរណាទទួលបន្ទុកតំបន់១នៅពេលនោះទេ[483] និងថា "តាទិត្យ" គឺជាមេបញ្ជាការយោធាពីព្រោះគាត់ឮ "ប្រធានភូមិ និងប្រធានកងនិយាយអំពីកូនទាហានរបស់តាទិត្យ"[484]។ សឿន ម៉ាត់ មិនបានផ្តល់ក្របខ័ណ្ឌពេលវេលានៃភ័ស្តុតាងរបស់ខ្លួនទេ ហើយក៏មិនត្រូវបានស្នើឲ្យផ្តល់ដែរ។ ពុំមានសាក្សីផ្សេងទៀត ឬឯកសារផ្សេងទៀតនៅសល់ក្នុងសំណុំរឿងដើម្បីបញ្ជាក់លើការសន្និដ្ឋានរបស់ ស.ច.ស.អ ដែលផ្អែកលើភ័ស្តុតាងរបស់ សឿន ម៉ាត់ ឡើយ។

១៧២. ស.ច.ស.អ សន្និដ្ឋានថា លោក យឹម ទិត្យ មានសិទ្ធិអំណាចលើ "បញ្ហាផ្ទាល់ខ្លួននៅក្នុងតំបន់" ប៉ុន្តែខកខានមិនបានពន្យល់ថាតើសញ្ញាណនៃពាក្យ "បញ្ហាផ្ទាល់ខ្លួន" មានសេចក្តីយ៉ាងដូចម្តេចឡើយ[485]។

---

[480] ឯកសារ D1.3.15.2 អត្ថបទរៀបរៀងដោយ Timothy Carney៖ "ការរៀបចំអំណាច" ដែលត្រូវបានបោះពុម្ពផ្សាយជាផ្នែកមួយនៃសៀវភៅនិពន្ធដោយ Karl Jackson មានចំណងជើងថា "កម្ពុជាពីឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបសេចក្តីស្លាប់" តារាងទី ៣ ERN 00332381-00332383។

[481] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៤ ដល់ ៣៧១។

[482] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៤.i។

[483] ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត ឆ.៥ ERN 01155821។

[484] ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត ឆ.៥៤-ឆ.៥៦ ERN 01155829។

[485] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៤.i ជើងទំព័រ ៩៥៤។

ស.ច.ស.អ គាំទ្រការសន្និដ្ឋាននេះជាមួយនឹងភ័ស្តុតាងរបស់សាក្សីពីរនាក់៖

- វី ផាន់ ដែលផ្តល់ភ័ស្តុតាងអំពីកិច្ចប្រជុំតែមួយលើកដែលគាត់មានជាមួយ "តាទិត្យ" ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ដែលនៅទីនោះ "តាទិត្យ" និយាយអំពីការវ៉ៃជាមួយយួន"[486] និង
- ជួន ថន ដែលផ្តល់ភ័ស្តុតាងអំពីកិច្ចប្រជុំមួយនៅក្នុងតំបន់៣ ក្នុងឆ្នាំ១៩៧៨[487] ដែលនៅពេលនោះ គាត់លើកឡើងថាបានឮ "តាទិត្យ" និយាយអំពីការលួច និងសកម្មភាពខ្មាំង[488]។

១៧៣. ពីភ័ស្តុតាងដែលលើកឡើងនៅក្នុងដីកាដំណោះស្រាយរបស់ ស.ច.ស.អ មិនអាចយល់បានអ្វីដែល ស.ច.ស.អ ចង់លើកឡើង នៅពេលដែលគាត់លើកឡើងពី "បញ្ហាបុគ្គល" ឬថាតើ ការលើកឡើងនៅក្នុងកិច្ចប្រជុំ ក្នុងតំបន់៣ មានការពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់នណាម្នាក់ក្នុងតំបន់១ ដោយរបៀបណា។

១៧៤. ស.ច.ស.អ សន្និដ្ឋានថា យឹម ទិត្យ មានសិទ្ធិអំណាចលើអ្នកនៅក្រោមបង្គាប់របស់គាត់ក្នុងបញ្ហាសន្តិសុខនៅក្នុងតំបន់ ណែនាំពួកគេឲ្យរាយការណ៍អំពីសកម្មភាពខ្មាំង និង "អប់រំ" ឬ "កម្ទេច"[489] និងដឹកនាំ និងកោះប្រជុំជាមួយតំណាងមកពីបណ្តាស្រុក ឃុំ និង សហករណ៍ ក្នុងនោះរួមមាន ឈ្លប និងកងចល័ត ដែលនៅក្នុងកំឡុងពេលនោះ គាត់បានផ្តល់ការណែនាំដល់អ្នកចូលរួមអំពីបញ្ហាសន្តិសុខ និងប្រាប់ពួកគេឲ្យរាយការណ៍ពីសកម្មភាពខ្មាំង "អប់រំ"ឬ "កម្ទេច"[490]។ ស.ច.ស.អ ផ្អែកលើចម្លើយរបស់សាក្សីមួយចំនួន ដោយខកខាន មិនបានរៀបរាប់ភ័ស្តុតាងផ្ទុយ និងការពិចារណានានាដែលពាក់ព័ន្ធ[491]។

---

[486] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.២-ឆ.៥ ERN 01040093-4។ ឯកសារ D219/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ERN 01364043-01364044។

[487] ឯកសារ D118/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៣ ERN 00990645។ ឯកសារ D118/299 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជួន ថន ឆ.១៣ ERN 01023875។

[488] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៤.i ជើងទំព័រ ៩៥៤។

[489] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៤.ii។

[490] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៥។

[491] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៤.ii ជើងទំព័រ ៩៥៥។

- ភ័ស្តុតាងរបស់ វី ផាន់ ពាក់ព័ន្ធនឹងកិច្ចប្រជុំដែលគាត់មានជាមួយ "តាទិត្យ" ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨ ដែលក្នុងពេលនោះ "តាទិត្យ" "និយាយអំពីការវ៉ៃយួន"[492]។

- ភ័ស្តុតាងរបស់ ជួន ថន មិនពាក់ព័ន្ធនឹងតំបន់១ ដោយហេតុថាគាត់និយាយតែអំពីកិច្ចប្រជុំមួយ ក្នុងតំបន់៣[493]។

- ភ័ស្តុតាងរបស់ ណុប ង៉ឹម ពាក់ព័ន្ធនឹងកិច្ចប្រជុំមួយនៅបាត់ដំបងក្នុងខែកញ្ញា ឆ្នាំ១៩៧៨[494] គាត់មិនអាចចងចាំបាននូវអ្វីដែល "តាទិត្យ" ពិភាក្សានៅពេលប្រជុំនេះ[495]។

- ភ័ស្តុតាងរបស់ ឈឿន ប៊ាន ពាក់ព័ន្ធនឹងកិច្ចប្រជុំមួយដែលធ្វើឡើងនៅក្នុងខែកញ្ញា ឬតុលា ឆ្នាំ១៩៧៨[496] និង "តាទិត្យ"ពុំត្រូវបានឧទ្ទេសនាមនៅក្នុងកិច្ចប្រជុំនេះ"[497]។

- ឈឹង ឈឿត ត្រូវបានលើកឡើងថាបានឃើញ "តាទិត្យ" តែម្តងគត់នៅក្នុងកិច្ចប្រជុំមួយ ដែលប្រព្រឹត្តទៅនៅចុងសម័យកម្ពុជាប្រជាធិបតេយ្យ ដែលយោងតាម ឈឹង ឈឿត សភាពការណ៍ទូទៅគឺ ច្របូកច្របល់[498]។ គាត់មិនបានឃើញ "តាទិត្យ"ជាក់ស្តែងទេ[499]

---

[492] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.២-ឆ.៥ ERN 01040093-4។ ឯកសារ D219/245 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ERN 01364043-01364044។

[493] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៤.i ជើងទំព័រ ៩៥៤។

[494] ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៨៥ ERN 01329397។ ឯកសារ D219/298 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.១៣ ERN 01095987។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៦១-ឆ.៦៣ ERN 1329395។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៨១-ឆ.៨៣ ERN 01329397។ ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៨៣ ERN 01008710, ឆ.៦៨ ERN 01008708។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៧៩-ឆ.៨០ ERN 01329397។

[495] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ង៉ឹម ឆ.៨៦ ERN 01008711។

[496] ឯកសារ D219/368 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ៨៧-ឆ.៩៥ ERN 01110185-7។

[497] ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១២៨ ERN 01122420។

[498] ឯកសារ D219/953 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.២០ ERN 01425165, ឆ.៥៥-ឆ.៥៨ ERN 01425173។

[499] ឯកសារ D219/953 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.៦៩ ERN 01425175។

គាត់មិនអាចប្រាប់ពីមុខមាត់របស់តាទិត្យ[500] និង "មិនអាចស្តាប់សំឡេងច្បាស់" ដោយសារមនុស្សច្រើនពេក។ ផ្ទុយទៅវិញ គាត់គ្រាន់តែ "ឮគេហៅថាតា"[501]។

- ភ័ស្តុតាងរបស់ ណាង នី ពាក់ព័ន្ធនឹងកិច្ចប្រជុំមួយនៅ បាយដំរាំ បីខែមុនវៀតណាមមកដល់[502] ប្រហែលក្នុងខែតុលា ឆ្នាំ១៩៧៨ ដែលក្នុងកំឡុងពេលនោះ គាត់លើកឡើងថា បានឃើញ "តាទិត្យ" ជាលើកទី១ និង តែម្តងគត់[503]ទោះបីជាគាត់មិនស្គាល់មុខ លោក យឹម ទិត្យ ច្បាស់ក៏ដោយ។

១៧៥. ក្នុងចំណោមសាក្សីទាំងអស់ដែល ស.ច.ស.អ បានលើកមកសំអាង ពុំមានសាក្សីណាម្នាក់បាននិយាយ ថា "តាទិត្យ"បានចេញបញ្ជា ឬថាអ្នកចូលរួមប្រជុំទាំងនោះបានដាក់របាយការណ៍ជូន "តាទិត្យ" អំពីបញ្ហាណា មួយដែលមានការពិភាក្សានៅក្នុងកំឡុងកិច្ចប្រជុំទាំងនោះ ឬថា "តាទិត្យ" បានផ្តល់ការណែនាំឲ្យ "អប់រំ" ឬ "កម្ទេច" ដូចដែល ស.ច.ស.អ បានអះអាង[504]។ ស.ច.ស.អ ខកខានមិនបានផ្តល់សំអាងហេតុថាតើគាត់ សន្និដ្ឋានដោយវិធីណាពីភ័ស្តុតាងដែលថា លោក យឹម ទិត្យ មានអ្នកនៅក្រោមបង្គាប់ និង ស.ច.ស.អ ខកខាន មិនបានកំណត់អត្តសញ្ញាណអ្នកនៅក្រោមបង្គាប់ ឬពន្យល់ឲ្យជាក់លាក់ថាលោក យឹម ទិត្យ ធ្វើការគ្រប់គ្រង ប្រកបដោយប្រសិទ្ធភាពទៅលើពួកគេលើបញ្ហាសន្តិសុខនៅក្នុងតំបន់១ ដោយរបៀបណា។ ការខកខានរបស់ ស.ច.ស.អ ក្នុងការពិចារណាអំពីចំណុចពេលវេលានៃកិច្ចប្រជុំ មិនយុត្តិធម៌ និងមិនសមហេតុផលដែលបង្កើតបានជាការរំលោភឆន្ទានុសិទ្ធិរបស់ខ្លួន។

១៧៦. ស.ច.ស.អ សន្និដ្ឋានដោយផ្អែកលើភ័ស្តុតាងមិនមានការបញ្ជាក់របស់សាក្សីតែម្នាក់គត់ គឺ ផា ប៉ែត ដែលនិយាយថា លោក យឹម ទិត្យ មានអំណាចការពារមិនឲ្យគេចាប់ខ្លួន ឬសម្លាប់បុគ្គល[505] ពីព្រោះលោក យឹម ទិត្យ "បានបញ្ជាឲ្យដោះលែងទាហានដែលឃុំខ្លួននៅវត្តព្រៃតូចដែលត្រូវបាន

[500] ឯកសារ D219/953 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.៧៩ ERN 01425177។

[501] ឯកសារ D219/953 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.៦៩ ERN 01425175។

[502] ឯកសារ D118/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.២៥ ERN 00934389។

[503] ឯកសារ D118/77 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណាង នី ឆ.២៩ ERN 00934389។

[504] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៥ ជើងទំព័រ ៩៧១ និង ៩៧២។

[505] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៤.iii. ជើងទំព័រ ៩៥៦ ដែលយោងលើឯកសារ D118/244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផរ ប៉ែត ឆ.៥ ERN 00990637។

ចោទថាបានបាញ់ កម្មាភិបាលភូមិភាគនិរតីម្នាក់”[506]។ ស.ច.ស.អ ថ្លែងខុសអំពីភ័ស្តុតាងនេះ។ សម្រាប់ផលប្រយោជន៍របស់ អ.ប.ជ ការដកស្រង់សំដីពិតប្រាកដនៅផ្នែកភ័ស្តុតាងរបស់ ផា ប៉ែត គឺយ៉ាងដូច្នេះ៖

> ខ្ញុំស្គាល់តាទិត។ ខ្ញុំសូមជម្រាបតើពេលណាដែលខ្ញុំបានជួប តាទិត។ ពីដំបូង គេបានបញ្ជូនកងខ្ញុំ ទៅកង្គួត ក្រោយមកទៀត ទើបគេបញ្ជូនបន្តទៅព្រៃតូច។ នៅពេលយើងមកដល់ព្រៃតូច យោធាខ្មែរក្រហម នៅនឹងទីនេះ បាននាំពួកយើងទៅដាក់វត្តព្រៃតូច។ ពេលនោះ គេបានដកកាំភ្លើងពួកយើងអស់ ហើយគេបានហៅពួកយើងទៅប្រជុំនៅក្នុងវត្តព្រៃតូច។ ពេលនោះ ម្នាក់ឈ្មោះ ណោន បានចូលមកដល់ ហើយបានប្រកាស យើងថា “ពួកអ្នកឯងមកនេះ មិនមែនមកសប្បាយទេ គឺយើងយកមកសម្លាប់”។ ពេលដែន ណោន កំពុងតែប្រកាស តាទិត ក៏បានចូលមកដល់ ហើយក៏បាននិយាយទៅកាន់ ណោន ថា៖ “បើសិនជា ណោន ឯងសម្លាប់ពួកទាំងនេះ តើមាននរណាការពារ ណោន ឯង”។ បន្ទាប់មក តាទិត បានប្រគល់កាំភ្លើងឲ្យមកពួកយើងវិញ ហើយបានឲ្យឡានមួយមកដឹកពួកយើងយកទៅធ្វើការនៅទន្លេសាប។ ខ្ញុំបានជួប តាទិត តែម្តងទេ[507]។

១៧៧. ពុំមានអ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយភាពសមហេតុផល អាចសន្និដ្ឋានពីភ័ស្តុតាងនេះថា លោក យឹម ទិត្យ “បានបញ្ជា”ឲ្យដោះលែងទាហានជាប់ឃុំ ឬសូម្បីតែសន្និតថាឈ្មោះ “តាទិត្យ”ដែល ផា ប៉ែត បានលើកឡើង គឺពិតជាយឹម ទិត្យ ក៏មិនអាចដែរ ដោយហេតុថាគាត់មិនស្គាល់ យឹម ទិត្យ ច្បាស់ ឡើយនៅក្នុងចម្លើយរបស់គាត់។

១៧៨. មិនតែប៉ុណ្ណោះ ស.ច.ស.អ ខកខានមិនបានពិចារណាលើ ភ័ស្តុតាងរបស់ ផា ប៉ែត ដែលថា គាត់ជឿថា តា ណោន គឺជាគណៈស្រុកមួយរូប(ទោះបីជាគាត់មិនដឹងថាមួយណាក៏ដោយ)[508] គាត់មិនដឹងថាតើ “តាទិត្យ” ឬ តាណោន មួយណាមានឋានៈខ្ពស់ជាងឡើយ[509] គាត់មិនស្គាល់ សមាជិកភូមិភាគ តំបន់ និង ស្រុកទាំងអស់ គាត់មិន ដែលឮឈ្មោះ តាវ៉ាញ, តាញឹម ឬ “តាប៉ែត”

---

[506] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៤.iii. ជើងទំព័រ ៩៥៦ ដែលយោងលើឯកសារ D118/244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផវ ប៉ែត ឆ.៥ ERN 00990637។

[507] ឯកសារ D118/244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផវ ប៉ែត ឆ.៥ ERN 00990637។

[508] ឯកសារ D118/244 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផវ ប៉ែត ឆ.៩ ERN 00990638។

[509] ឯកសារ D219/546 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផវ ប៉ែត ឆ.៥២ ERN 01157550។

និងឮឈ្មោះតាម៉ុក តែម្តងគត់ក្រោយពេលគាត់ត្រូវបានចាប់ខ្លួន[510]។ ពុំមានអ្នកវិនិច្ឆ័យអង្គហេតុប្រកបដោយហេតុផល អាចនឹងសន្និដ្ឋានពីភស្តុតាងនេះថា លោក យឹម ទិត្យ "បញ្ជាឱ្យគេដោះលែងទាហានមួយចំនួន" ឬមានអំណាចការពារមិនឱ្យគេចាប់ខ្លួនឬសម្លាប់មនុស្ស ឡើយ។

១៧៩. ស.ច.ស.អ ក៏បានសន្និដ្ឋានផងដែរថា លោក យឹម ទិត្យ "បានទុកជីវិតឱ្យកម្មាភិបាលភូមិភាគពាយ័ព្យម្នាក់ (តាសាម៉ន) ពីព្រោះគាត់មានប្រយោជន៍សម្រាប់កម្មាភិបាលភូមិភាគនិរតីដែលចូលមក"[511] ដោយផ្អែក ការសន្និដ្ឋាននេះលើភស្តុតាងមិនមានការគាំទ្ររបស់ ឈឿង ប៊ាន ដែលឃើញតាសាម៉ន ក្រោយឆ្នាំ១៩៧៨ និង សន្និដ្ឋានថា តាសាម៉ន នៅរស់រានមានជីវិត ពីព្រោះ "តាទិត្យ" ឱ្យគាត់រួចខ្លួន[512]។ ស.ច.ស.អ ខកខានមិនបាន ផ្តល់ហេតុផលថាតើហេតុអ្វីបានជាគាត់សន្និដ្ឋានថា ការយល់ឃើញរបស់ ឈឿង ប៊ាន គួរឱ្យជឿបានរហូតដល់ថា គាត់មិនចាំបាច់ពិចារណាលើហេតុផលណាផ្សេងទៀតសម្រាប់ ការដែល តាសាម៉ន នៅរស់ក្រោយឆ្នាំ១៩៧៨ ក្រៅពីការចោទប្រកាន់ថា លោក យឹម ទិត្យ បានឱ្យគាត់រួចខ្លួន។

១៨០. ស.ច.ស.អ សន្និដ្ឋានថា លោក យឹម ទិត្យ "ទទួលខុសត្រូវ" សេដ្ឋកិច្ចក្នុងតំបន់១ (ខណៈដែលមិនផ្តល់ការពន្យល់ណាមួយថាតើ "ទទួលបន្ទុក" មានន័យយ៉ាងដូចម្តេចក្នុងន័យការទទួលខុសត្រូវព្រហ្មទណ្ឌ និងផ្អែកការសន្និដ្ឋានរបស់ខ្លួនលើសុន្ទរកថារបស់ លោក យឹម ទិត្យ ពាក់ព័ន្ធនឹងធារាសាស្ត្រ ការបង្កបង្កើនផល និង "ការទៅពិនិត្យជាទៀងទាត់" នៅទំនប់កង្កត[513]។ បើទោះបីជាសន្មតឱ្យតែបានជាឡូកែករណ៍ថា ភស្តុតាងទាំងអស់ ដែលបានលើកមកសំអាង អាចជឿទុកចិត្តបានដែលមិនអាចជឿទុកចិត្តបាន(ដូចដែលស្នើខាងលើ) ស.ច.ស.អ ខកខានមិនបានផ្តល់ហេតុផលហេតុអ្វីបានជាគាត់អាចសន្និដ្ឋានថា លោក យឹម ទិត្យ "ទទួលបន្ទុក" សេដ្ឋកិច្ចក្នុងតំបន់១ ដោយគ្មានភស្តុតាង សូម្បីតែបទបញ្ជាពី ឬរបាយការណ៍បញ្ជូនដល់ លោក យឹម ទិត្យ នោះ ដោយគ្រាន់

[510] ឯកសារ D219/545 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផរ ប៉ែត ឆ.៦-ឆ.៨ ERN 01157537។ ឯកសារ D219/546 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផរ ប៉ែត ឆ.៦៥ ERN 01157551។

[511] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៥.iii។

[512] ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៊ានន ឆ.២០-ឆ.២១ ERN 01122398។

[513] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៥.iv។

តែផ្អែកលើសុន្ទរកថាពីរបីដែលលោក យឹម ទិត្យ ធ្វើឡើងប៉ុន្មានខែមុនពេលវៀតណាមមកដល់តែប៉ុណ្ណោះ[514]។

១៨១. ស.ច.ស.អ សន្និដ្ឋានថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមនិតិន័យ*លើកម្មាភិបាលថ្នាក់ស្រុក និងឃុំ ក្នុងតំបន់១[515]។ ទីមួយ ដូចដែលបានពិភាក្សាពីមុនមកហើយ[516]ស.ច.ស.អ ខកខានមិនបានកំណត់ថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់១ ដែលអាចនឹងផ្តល់ឲ្យគាត់នូវសិទ្ធិអំណាច "*តាមនិតិន័យ*" លើកម្មាភិបាលថ្នាក់ស្រុក និងឃុំនៅក្នុងតំបន់១[517]។ លើសពីនេះទៀត ពុំមានភ័ស្តុតាងណាមួយដែលបានយោងដោយ ស.ច.ស.អ នៅក្នុងជើងទំព័រ៩៦២ ដែលមានសាក្សី ១៤ នាក់[518] និង លក្ខន្តិកៈ ប.ក.ក[519] យោងដល់ការតែងតាំង លោក យឹម ទិត្យ ជាលេខាតំបន់១ ឡើយ ហេតុដូចនេះ មិនបង្កើតបានជាសិទ្ធិអំណាច*តាមនិតិន័យ*លើកម្មាភិបាលថ្នាក់ ស្រុក និងឃុំនៅក្នុងតំបន់១ឡើយ[520]។ ស.ច.ស.អ ខកខានមិនបានផ្តល់ហេតុផលថាតើហេតុអ្វីបានជាគាត់ចាត់ទុកថាភ័ស្តុតាងនេះពាក់ព័ន្ធនឹងការកំណត់ថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមនិតិន័យ*។ ការសន្និដ្ឋានរបស់ ស.ច.ស.អ គឺមិនមានហេតុផល។

១៨២. ស.ច.ស.អ សន្និដ្ឋានផ្អែកលើភ័ស្តុតាងរបស់សាក្សីម្នាក់ ឈ្មោះ ណុប ងឹម ថា "ការប្រជុំជាមួយតំណាង មកពីតំបន់និងស្រុកត្រូវបានដឹកនាំដោយ យឹម ទិត្យ និងតាម៉ុក មួយខែម្តងនៅក្រុងបាត់ដំបង" ដែលនៅទីនោះ លោក យឹម ទិត្យ និងតាម៉ុក បានរួមគ្នាដឹកនាំកិច្ចប្រជុំផ្តល់ការណែនាំរម្លឹកអ្នកចូលរួមឲ្យ "កម្ទេច" ខ្មាំង និងលើកឡើងអំពីអត្រាកំណើត និងគោលដៅបង្កបង្កើនផល[521]។ ស.ច.ស.អ ក៏សន្និដ្ឋានថា កិច្ចប្រជុំទាំងនេះគឺជាកិច្ចប្រជុំថ្នាក់ភូមិភាគ[522]។ ស.ច.ស.អ

---

[514] *ដូចយោងខាងលើ* ។

[515] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៤.v។

[516] សូមមើលខាងលើ កថាខណ្ឌ ១៦៤ ដល់ ១៦៩។

[517] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ១៧៨។

[518] ទេព សៀន, Craig Etcheson, ប៉ាន ដួង, ប៊ុន ធឿន, តិម ផល, ពេជ្រ ជឹម, ខឹម ហឿន, ទុំ សឿន, ស៊ូ ណាន់, សៅ ផេន, ប៊ុន ឡឹងចូយ, សៅ សារុន, ណង នី, ឆឹង ជឿន។

[519] ឯកសារ D1.3.20.1. លក្ខន្តិកៈបក្សកុម្មុយនិស្តកម្ពុជា ចុះខែមករា ឆ្នាំ១៩៧៦។

[520] ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៤.v។

[521] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៦ ដល់ ៣៦៧។

[522] *ដូចយោងខាងលើ* ។

ខកខានមិនបានញែកឲ្យដាច់រវាងតួនាទី និងសកម្មភាពរបស់ លោក យឹម ទិត្យ និង តាម៉ុក នៅក្នុង កិច្ចប្រជុំទាំងនេះ។

១៨៣. ខណៈដែល ស.ច.ស.អ ពិចារណាថា នៅក្នុងការផ្តល់ចម្លើយក្រោយមកទៀត ណុប ងឹម បដិសេធ ភ័ស្តុតាងរបស់ខ្លួន និងនិយាយថា គាត់ត្រូវបានកោះប្រជុំតែម្តងគត់ជាមួយ "តាទិត្យ" នៅផ្ទះរបស់ គាត់ (អ្នកដទៃទៀតឬតាម៉ុក មិនត្រូវបាននិយាយថាមានវត្តមានឡើយ" ស.ច.ស.អ ចាត់ទុក ការប្តូរភ័ស្តុតាងនេះ ថាខ្វះភាពគួរឲ្យជឿទុកចិត្តបាន ពីព្រោះ យោងតាម ស.ច.ស.អ ណុប ងឹម "ពិតជា" មានបំណងការពារមុខតំណែងរបស់គាត់ដោយហេតុថា ប្តីរបស់គាត់ ឈ្មោះ ព្រាប កប បានថ្លែងថា គាត់អមដំណើរប្រពន្ធគាត់ទៅប្រជុំ ៥ ទៅ ៦ ដង[523] ក្នុងនាមជានិរសារ[524]។

១៨៤. ស.ច.ស.អ សន្និដ្ឋានដោយមិនសមហេតុផលថា ការដកភ័ស្តុតាងវិញរបស់ ណុប ងឹម ខ្វះភាពគួរ ឲ្យជឿទុកចិត្តបាន។ នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤ មុនពេល ណុប ងឹម លើកឡើងអំពីភ័ស្តុតាង របស់ខ្លួន ស.ច.ស.អ បានចេញលិខិតធានាចំពោះ ណុប ងឹម ដោយសន្យាថា ចម្លើយរបស់គាត់ ចំពោះ ស.ច.ស.អ នឹងមិនអាចត្រូវបានប្រើប្រាស់ប្រឆាំងនឹងគាត់វិញឡើយ ទោះជាក្នុងកាលៈទេសៈ ណាក៏ដោយ ទោះជាផ្ទាល់ ឬប្រយោល ជាផ្នែកមួយនៃការចោទប្រកាន់ណាមួយ[525]។ ដោយមាន លិខិតនេះ ណុប ងឹម មិនចាំបាច់ការពារមុខតំណែងរបស់គាត់ទេ ដូចដែល ស.ច.ស.អ បាន លើកឡើងដោយមិនសមហេតុផលរួចមកហើយ។ មិនតែប៉ុណ្ណោះ ស.ច.ស.អ ខកខានមិនបាន ពិចារណាថា ព្រាប កប ពិការភ្នែក និងមិនអាចរំកិលខ្លួនដោយគ្មានជំនួយឡើយ[526] ធ្វើឲ្យគាត់មិន អាចបម្រើការជានិរសារបាន។ ស.ច.ស.អ ក៏ខកខានមិនបានពិចារណាលើភ័ស្តុតាងផ្ទុយរបស់ ព្រាប កប ថា ប្រពន្ធរបស់គាត់ឈ្មោះ ណុប ងឹម មិនដែលអនុញ្ញាតឲ្យគាត់ពាក់ព័ន្ធនឹងការងារ របស់គាត់ឡើយ និងថា គាត់មិនដឹងអ្វីទាំងអស់ដែលពាក់ព័ន្ធនឹងការងាររបស់ប្រពន្ធ[527]។ លើស ពីនេះទៅទៀត ណុប ងឹម មិនបានបញ្ជាក់ នៅក្នុងចម្លើយជាច្រើនរបស់គាត់ថាប្តីរបស់គាត់ឈ្មោះ

---

[523] *ដូចយោងខាងលើ* កថាខណ្ឌ ៣៦៦។

[524] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រាប កប ឆ.៦៤ ERN 01037147។

[525] ឯកសារ D118/285/1 ខិតធានារបស់ ស.ច.ស.អ ជូនលោក ណុប ងឹម ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៤។

[526] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រាប កប ឆ.១៤-ឆ១៧ ERN 01037138-9។

[527] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយ ព្រាប កប ឆ.៥៥-ឆ.៦០ ERN 01037146។

ព្រាប កប ធ្លាប់ជូនគាត់ទៅប្រជុំ ឬថា គាត់មិនដែលនិយាយជាមួយប្ដីអំពីកិច្ចការរបស់គាត់ក្នុងនាមជាអនុលេខាស្រុកនោះទេ[528]។

១៨៥. ស.ច.ស.អ ខកខានមិនបានពិចារណាថា កិច្ចប្រជុំមួយនេះរវាង ណុប ង៉ឹម ជាមួយលោក យឹម ទិត្យ កើតឡើងតែក្រោយខែកញ្ញា ឆ្នាំ១៩៧៨ ប៉ុណ្ណោះ នៅពេលដែល ណុប ង៉ឹម ត្រូវបានតែងតាំងជាអនុលេខាស្រុកសំឡូត តំបន់១[529]។

១៨៦. ស.ច.ស.អ សន្និដ្ឋានផ្អែកលើភ័ស្តុតាងរបស់ ណុប ង៉ឹម ថា "អនុលេខាស្រុកសំឡូតនាពេលនោះរម្លឹកឡើងវិញថា ស្រុកទទួលការណែនាំ សរសេរដោយដៃ យឹម ទិត្យ មកពីតំបន់"[530]។ ស.ច.ស.អ បង្ហាញខុសពីភ័ស្តុតាងរបស់ ណុប ង៉ឹម។ គាត់មិនដែលនិយាយថា ការណែនាំត្រូវបានសរសេរដោយដៃ លោក យឹម ទិត្យ ឡើយ[531] ហើយ ក្នុងករណីណាក៏ដោយ ដោយសារគាត់មិនចេះអក្សរ គាត់អាចមិនអាចអានដាច់ ឬមិនស្គាល់សំណេររបស់នរណាម្នាក់ទេ[532]។

*<u>សេចក្ដីសន្និដ្ឋានអំពីតំបន់ ១</u>*

១៨៧. ស.ច.ស.អ មានកំហុសអង្គហេតុ និងអង្គច្បាប់ក្នុងការសន្និដ្ឋានថា យឹម ទិត្យ គឺជាលេខាតំបន់១ ភូមិភាគពាយ័ព្យ *តាមនីតិន័យ* និង/ឬ*តាមព្រឹត្តន័យ* នៅត្រង់ចំណុចពេលវេលាណាមួយក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ពុំមានភ័ស្តុតាងនៅក្នុងសំណុំរឿងដែលបង្ហាញថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ១ ឡើយ។ ត្រឹមតែវត្តមានរបស់លោក យឹម ទិត្យ នៅក្នុងកិច្ចប្រជុំពីរបីលើកនៅប៉ុន្មានខែចុងក្រោយនៃរបបខ្មែរក្រហមនៅក្នុងតំបន់១ និងទំនាក់ទំនង

---

528 ឯកសារ D123/2/2.17a បទសម្ភាសន៍របស់ DC-Cam ជាមួយ ណុប ង៉ឹម។ ឯកសារ D118/285, D219/298, D219/835 កំណត់ហេតុនៃការស្ដាប់ចម្លើយ ណុប ង៉ឹម។ ឯកសារ D219/974.1.2 ណុប ង៉ឹម ប្រតិចារឹកសវនាការ ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ ២០១៦។

529 ឯកសារ D219/298 កំណត់ហេតុនៃការស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.៦ ERN 01095985។ ឯកសារ D219/835 កំណត់ហេតុនៃការស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.៧២-ឆ.៧៦ ERN 01329396-7។

530 ដីកាដំណោះស្រាយរបស់ ស.ច.ស.អ កថាខណ្ឌ ៣៦៩ ដល់ ៣៧០។

531 ឯកសារ D118/285 កំណត់ហេតុនៃការស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.៨២ ERN 01008710។

532 ឯកសារ D118/285 កំណត់ហេតុនៃការស្ដាប់ចម្លើយ ណុប ង៉ឹម ឆ.៣៦ ERN 01008702។

គ្រួសារជាមួយ តាម៉ុក មិនអាចស្មើនឹងការសន្និដ្ឋានដែលថា លោក យឹម ទិត្យ មានសិទ្ធិអំណាច *តាមព្រឹត្តន័យ*ជាលេខាតំបន់១ ទេ[533]។

១៨៨. ស.ច.ស.អ ខកខានមិនបានវាយតម្លៃដោយត្រឹមត្រូវលើចម្លើយរបស់សាក្សី ខកខានមិនបានពិចារណាភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុក និងខកខានមិនបានផ្តល់ហេតុផលថា តើមូលហេតុអ្វីបានជាគាត់យល់ឃើញថា ភ័ស្តុតាងដែលគាត់ពឹងផ្អែក មានលក្ខណៈគួរឲ្យជឿទុកចិត្តបាន រហូតដល់ពុំមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលអាចធ្វើការសន្និដ្ឋានផ្សេងក្រៅពីនេះនោះ ហេតុនេះ ស.ច.ស.អ មានកំហុសអង្គច្បាប់ដោយខកខានមិនបានអនុវត្តបទដ្ឋាន "*ភវនីយភាព*"[534]។ ដោយផ្អែកលើទំនាក់ទំនងគ្រួសាររបស់លោក យឹម ទិត្យ ជាមួយ នឹងតាម៉ុក និងមិនពិចារណាលើភ័ស្តុតាងផ្ទុយពាក់ព័ន្ធ ក្នុងការធ្វើការសន្និដ្ឋាននេះ ស.ច.ស.អ ខកខានមិនបានអនុវត្តគោលការណ៍ វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ[535]។ ហេតុដូច្នេះ ស.ច.ស.អ មានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយទាញការសន្និដ្ឋានមិនត្រឹមត្រូវជាក់ស្តែងថា លោក យឹម ទិត្យ គឺជាលេខាតំបន់១ *តាមនីតិន័យ* និង*តាមព្រឹត្តន័យ* ដែលធ្វើឲ្យមានភាពអយុត្តិធម៌ ដែលតម្រូវឲ្យ អ.ប.ជ បដិសេធការសន្និដ្ឋានទាំងនេះ។

**(iv) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាលេខាតំបន់ ៣**

១៨៩. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយសម្រេចថា "នៅឆមាសទី២ ឆ្នាំ១៩៧៨ យឹម ទិត្យ ក៏បានទទួលមុខតំណែងជាលេខាតំបន់ ៣ ដែរ"[536]។ ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថា ពាក្យ "បានទទួល" មានន័យដូចម្តេច ចំពោះតួនាទី និងការទទួលខុសត្រូវរបស់ លោក យឹម ទិត្យ ហើយសំខាន់បំផុតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានសន្និដ្ឋានថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* ឬ*តាមនីតិន័យ* នៅក្នុងតំបន់ ៣ ទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអាចសន្និដ្ឋានបែបនេះបានឡើយ ព្រោះសាក្សីតែមួយរូប

---

[533] សូមមើលខាងលើ កថាខណ្ឌ ៨៣ និងកថាខណ្ឌ ១២៤ ដល់ ១៤៣។

[534] សូមមើលខាងលើ កថាខណ្ឌ ១៧ ដល់ ១៩។

[535] *ដូចយោងខាងលើ*។

[536] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧២។

ដែលលើកឡើងអំពីវត្តមានរបស់ 'តាទិត្យ' នៅក្នុងតំបន់ ៣ គឺ ឈ្មោះ មូល អេង មិនដែលឮអំពីការតែងតាំង 'តាទិត្យ' ទៅក្នុងតួនាទីនេះឡើយ[537]។ មូល អេង ធ្វើការសន្និដ្ឋានថា 'តាទិត្យ' កាន់តួនាទីជាលេខាតំបន់ ដោយសារតែលោក យឹម ទិត្យ មកទីនោះម្តងនៅចុងខែកញ្ញា ឬដើមខែតុលា ឆ្នាំ១៩៧៨ "មកមើលស្រូវ"[538] ហើយគាត់បានឮនៅពេលក្រោយថា តា ម៉ុក "បានកាត់ បារិលឲ្យ យឹម ទិត្យ គ្រប់គ្រង"[539] ប៉ុន្តែគាត់មិនច្បាស់ថាតោះ គាត់បានឮថា 'តាទិត្យ' ជាលេខាតំបន់ ២ ឬ តំបន់ ៣ ឡើយ[540]។

១៩០. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានដឹកនាំការប្រជុំនៅក្នុងតំបន់ ៣ ហើយបានតែងតាំងកម្មាភិបាលឲ្យកាន់តំណែងនៅក្នុងតំបន់ ៣ ចាប់ពីខែមិថុនា ឆ្នាំ១៩៧៨ មក[541]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើភ័ស្តុតាងរបស់សាក្សីចំនួនពីររូប គឺ អ៊ឹម អាន់ និង កែវ ផៃ[542] ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកបង្ហាញដោយមិនត្រឹមត្រូវ។ អ៊ឹម អាន់ បានបញ្ជាក់យ៉ាងច្បាស់ថា គាត់ធ្លាប់ឮឈ្មោះ 'តាទិត្យ' ប៉ុន្តែគាត់មិនដែលឃើញតាទិត្យឡើយ[543] ហើយថា "តាទិត្យ" មិនមែនជាកម្មាភិបាលជាន់ខ្ពស់ នៅក្នុងតំបន់ ៣ ឡើយ[544] និងថា គាត់មិនបានដឹងថា នរណាជា "គណៈតំបន់៣" ទេ ក្រោយឆ្នាំ ១៩៧៧[545]។ កែវ ផៃ បានបញ្ជាក់ថា គាត់ឃើញ 'តាទិត្យ' ម្តងម្កាលបើកឡានមកពីប៉ៃលិន ប៉ុន្តែ កែវ ផៃ ក៏បញ្ជាក់ផងដែរថា គាត់មិនប្រាកដថា មនុស្សដែលគាត់ឃើញបើកឡាន មកពីប៉ៃលិននោះ

---

[537] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៦១-ឆ.៦២ ERN 01095244-01095245 ឆ.៦៨-ឆ.៧៣ ERN 01095249។

[538] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៧៥ ERN 01095247 ឆ.៤៧-ឆ.៤៨ ERN 01095242។

[539] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.១១២ ERN 01095252 ឆ.១២៧ ERN 01095255។

[540] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.១១០ ERN 01095252 ឆ.១៥៧-ឆ.១៥៨ ERN 01095259-01095260។

[541] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧២។

[542] ដូចយោងខាងលើ កថាខណ្ឌ ៣៧២ ជើងទំព័រ ៩៩០។

[543] ឯកសារ D118/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ឆ.១៥ ERN 00920193។

[544] ឯកសារ D118/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ឆ.២០ ERN 00920194។

[545] ឯកសារ D118/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ឆ.១៣ ERN 00920193។

គឺជា 'តាទិត្យ' មែន ឬមិនមែននោះទេ[546] ព្រមទាំងថា គាត់មិនបានអំពីតួនាទីរបស់ 'តាទិត្យ' ហើយគាត់មិនដែលចូលរួមប្រជុំជាមួយ យឹម ទិត្យឡើយ[547]។ ការបង្ហាញដោយមិនត្រឹមត្រូវរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីភ័ស្តុតាងរបស់សាក្សីទាំងពីររូប ដើម្បីគាំទ្រដល់ការសម្រេចថា លោក យឹម ទិត្យ បានដឹកនាំការប្រជុំ និងតែងតាំងកម្មាភិបាលឲ្យកាន់តំណែងនានា នៅក្នុងតំបន់ ៣ គឺជារឿងអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដូច្នេះហើយគឺជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

១៩១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ ក្នុងនាមជាលេខាតំបន់ ៣ "បានផ្ញើ និងទទួលលិខិតទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ទៅថ្នាក់ស្រុកស្តីពីបញ្ហានានា ដែលពាក់ព័ន្ធនឹងសន្តិសុខ និងសេដ្ឋកិច្ច" និង "តែងតាំងមនុស្សឲ្យកាន់មុខតំណែងនានា នៅក្នុងរចនាសម្ព័ន្ធតំបន់៣"[548]។

១៩២. មិនមានសាក្សីណាម្នាក់ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់យកមក[549] បានបញ្ជាក់ថា លោក យឹម ទិត្យ បានផ្ញើ និងទទួលលិខិតទំនាក់ទំនងជាលាយលក្ខណ៍អក្សរ ទៅថ្នាក់ស្រុកស្តីពីបញ្ហានានាទាក់ទងនឹងសេដ្ឋកិច្ច និងសន្តិសុខឡើយ។

១៩៣. លើសពីនេះទៀត សាក្សីដែលបានដកស្រង់ មិនមាននរណាម្នាក់[550] ដែលបញ្ជាក់ថា លោក យឹម ទិត្យ បានតែងតាំងមនុស្សឲ្យកាន់តំណែងនៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលនៃតំបន់ ៣ ឡើយ។ សំខាន់បំផុតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញដោយមិនត្រឹមត្រូវពីភ័ស្តុតាង ដោយសន្និដ្ឋានថា "ការសន្និដ្ឋានទូទៅនេះ មិនផ្ទុយពីសក្ខីកម្មរបស់សាក្សី កែ ផៃ (ឬកែវ ផៃ) ដែលបានផ្តល់ចម្លើយចំនួនពីរផ្សេងគ្នា អំពីអ្នកដែលតែងតាំងគាត់ផ្ទាល់ ឲ្យកាន់មុខតំណែងនៅថ្នាក់ឃុំ គឺ យឹម ទិត្យ ឬ តាម៉ុក"[551]។ មិនមានភ័ស្តុតាងនៅក្នុងសក្ខីកម្មណាមួយរបស់ កែវ ផៃ ដែលថា លោក

---

[546] ឯកសារ D118/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ ផៃ ឆ.២០ ERN 00947271។

[547] ឯកសារ D118/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ ផៃ ឆ.២១-ឆ.២៣ ERN 00947272។

[548] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧៥។

[549] ដូចយោងខាងលើ កថាខណ្ឌ ៣៧៤ ជើងទំព័រ ៩៨៧។

[550] ដូចយោងខាងលើ។

[551] ដូចយោងខាងលើ កថាខណ្ឌ ៣៧៥។

យឹម ទិត្យ បានតែងតាំងគាត់ដោយផ្ទាល់ ទៅកាន់តំណែងឃុំ ឬតំណែងណាមួយផ្សេងឡើយ[552]។ ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះភ័ស្តុតាងរបស់ កែវ ផៃ មានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដូច្នេះហើយគឺជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

១៩៤. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ "ក្នុងនាមជាលេខាតំបន់ ៣ បានដឹកនាំការប្រជុំ ដែលមានការចូលរួមពីកម្មករ និងកម្មាភិបាលថ្នាក់ស្រុក ពីតំបន់ ៣"[553]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ភ័ស្តុតាងរបស់សាក្សីប្រាំមួយរូប ដើម្បីគាំទ្រដល់ការសម្រេចនេះ[554]។ ភ័ស្តុតាងរបស់សាក្សីប្រាំរូប ក្នុងចំណោមសាក្សីទាំងអស់នោះ មិនពាក់ព័ន្ធជាមួយនឹងការសម្រេចនេះឡើយ ហើយមិនអាចជឿជាក់បានទេ ដោយសារតែសាក្សីទាំងនោះមិនបានកំណត់អត្តសញ្ញាណ លោក យឹម ទិត្យ ដោយត្រឹមត្រូវ មិនមានវត្តមាននៅក្នុងកិច្ចប្រជុំជាមួយ លោក យឹម ទិត្យ ឬបានជួប លោក យឹម ទិត្យ នៅក្នុងតំបន់ ៣។

- ណុប ណាន គឺជាកម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានបញ្ជូនទៅភូមិភាគពាយ័ព្យ នៅក្នុងខែឧសភា ឬខែមិថុនា ឆ្នាំ១៩៧៨[555]។ គាត់បានដឹងអំពីតួនាទីរបស់ 'តាទិត្យ' ទេ នៅក្នុងភូមិភាគពាយ័ព្យ ហើយគាត់មិនដែលជួប 'តាទិត្យ' ទេ នៅក្នុងភូមិភាគពាយ័ព្យ[556]។ គាត់គ្រាន់តែឮថា 'តាទិត្យ' គឺជា "ចៅហ្វាយខេត្តបាត់ដំបង" នៅពេលដែលគាត់ "កំពុងតែរត់ទៅទល់ដែនថៃ"[557] ដែលប្រាកដណាស់ថាពេលនៅប្រហែលក្នុងខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧៩[558]។

- កែវ ផៃ បានបញ្ជាក់ថា គាត់បានឃើញ 'តាទិត្យ' ម្តងម្កាល បើកឡានពីប៉ៃលិន ប៉ុន្តែគាត់

---

[552] ឯកសារ D118/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ ផៃ។ ឯកសារ D123/1/2.19a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ កែវ ផៃ។

[553] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧៥ ជើងទំព័រ ៩៩៧។

[554] ដូចយោងខាងលើ។

[555] ឯកសារ D118/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ណាន ឆ.៣-ឆ.៥ ERN 00947252។

[556] ឯកសារ D118/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ណាន ឆ.១៦ ERN 00947254។

[557] ឯកសារ D118/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ណាន ឆ.១២ ERN 00947254។

[558] ឯកសារ D118/92 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ណាន ឆ.១៦ ERN 00947254។

មិនប្រាកដថាតើ នោះគឺពិតជា 'តាទិត្យ' មែន ឬមិនមែន[559]។ កែវ ផៃ មិនដឹងអំពីតួនាទីរបស់ 'តាទិត្យ' ហើយគាត់មិនដែលបានចូលរួម ការប្រជុំជាមួយ 'តាទិត្យ' ឡើយ[560]។

- ទេព សៀន គឺជាកម្មាភិបាលភូមិភាគនិរតី ដែលត្រូវបានបញ្ជូនទៅខេត្តបាត់ដំបង ភូមិភាគពាយ័ព្យ នៅក្នុងឆ្នាំ ១៩៧៨ ហើយគាត់មិនស្គាល់ឈ្មោះ ស្រុក និងតំបន់ ដែលគេបញ្ជូនគាត់ទៅឡើយ[561]។ ទេព សៀន មិនដែលស្គាល់ 'តាទិត្យ' ឡើយ នៅមុនពេលគាត់មកដល់បាត់ដំបង ហើយក៏មិនដឹងថា 'តាទិត្យ' មកពីទីណាដែរ[562]។ គាត់អះអាងថា គាត់ឃើញ 'តាទិត្យ' តែម្ដងគត់នៅក្នុងឆ្នាំ១៩៧៨ ហើយគាត់មិនអាចកំណត់អត្តសញ្ញាណ 'តាទិត្យ' បានត្រឹមត្រូវឡើយ[563]។

- ជួន ថន គឺជាកម្មាភិបាលថ្នាក់ទាបនៅសហករណ៍ទ្រាំង ស្រុករតនមណ្ឌល តំបន់ ១[564] ដែលត្រូវបានគេអះអាងថា ត្រូវបានអញ្ជើញឱ្យចូលរួមការប្រជុំនៅភ្នំសំពៅ ដែលស្ថិតនៅក្នុងតំបន់ ៣[565]។ គាត់មិនអាចចងចាំ សូម្បីតែឈ្មោះមនុស្សម្នាក់ ក្នុងចំណោមមនុស្សជិត ១០០ នាក់ ដែលគាត់និយាយថា បានចូលរួមការប្រជុំ[566] លើកលែងតែឈ្មោះមួយ គឺ 'តាទិត្យ'[567]។ គាត់មិនបានកំណត់អត្តសញ្ញាណ លោក យឹម ទិត្យ ដោយត្រឹមត្រូវឡើយ។

- ភ័ស្តុតាងរបស់ វី ផាន់ គឺស្ដីពីការប្រជុំមួយនៅទំនប់កង្កួត តំបន់ ១ ក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៨

---

[559] ឯកសារ D118/94 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែវ ផៃ ឆ.២០ ERN 00947271។

[560] ឯកសារ D118/94 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែវ ផៃ ឆ.២១-ឆ.២៣ ERN 00947272។

[561] ឯកសារ D118/87 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព សៀនឆ.៧ ERN 00945428។

[562] ឯកសារ D118/87 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព សៀនឆ.២៧ ERN 00945430។

[563] ឯកសារ D118/87 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ទេព សៀនឆ.២៨ ERN 00945430។

[564] ឯកសារ D118/245 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.៤ ERN 00990644។

[565] ឯកសារ D118/245 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.១៣ ERN 00990645។ ឯកសារ D118/299 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.១៣ ERN 01023875។

[566] ឯកសារ D118/245 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.១៦ ERN 00990645។ ឯកសារ D118/299 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.២០ ERN 01023876។

[567] ឯកសារ D118/245 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.១៨ ERN 00990646។ ឯកសារ D118/299 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ជួន ថន ឆ.២៣-ឆ.២៤ ERN 01023877។

ហើយភស្តុតាងនេះមិនពាក់ព័ន្ធជាមួយតំបន់ ៣ ឡើយ[568]។

១៩៥. សាក្សីតែមួយរូប ដែលពាក់ព័ន្ធជាមួយនឹងហេតុការណ៍នៅតំបន់ ៣ ហើយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់[569] គឺ មូល អេង ជាលេខាស្រុកបរិល ដែលភស្តុតាងដោះបន្ទុករបស់គាត់ ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនយកមកពិចារណា។ មូល អេង បានបញ្ជាក់ថា គាត់បានទំនាក់ទំនងជាមួយ 'តាទិត្យ' ចាប់ពីខែកញ្ញា ឬតុលា នៅពេលដែល 'តាទិត្យ' មកមន្ទីររបស់គាត់ជាលើកដំបូង[570] រហូតដល់ខែវិច្ឆិកា ឬខែធ្នូ នៅពេលដែលពួកគាត់បានជួបគ្នាជាលើកទីពីរ និងជាលើកចុងក្រោយ[571]។ នៅក្នុងអំឡុងពេលដ៏ខ្លីនេះ មូល អេង បាននិយាយថា ពួកគេទំនាក់ទំនងគ្នា "តាមនិរសាមួយអាទិត្យម្តង ជូនកាលមួយខែម្តង" ហើយពួកគាត់ទំនាក់ទំនងអំពី "ដំណាំផលស្រូវ ឬក៏បញ្ហាដែលកើតឡើងពីការដាំដុះផ្សេងៗ ដូចជា អំពើអីជាដើម"[572]។ ទាំង មូល អេង និងសាក្សីដទៃទៀត ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់មក មិនបានលើកឡើងអំពីការទំនាក់ទំនងជាលាយលក្ខណ៍អក្សរអំពីសន្តិសុខ ឬការតែងតាំងមនុស្សរបស់ លោក យឹម ទិត្យ នៅក្នុងរចនាសម្ព័ន្ធរដ្ឋបាលតំបន់ ៣ នៅក្នុងឆ្នាំ ១៩៧៨ ហើយមិនមានភស្តុតាងថា លោក យឹម ទិត្យ បានចុះទៅមន្ទីរស្រុកណាផ្សេងឡើយក្នុងតំបន់ ៣ ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចនោះទេ[573]។

*<u>សេចក្តីសន្និដ្ឋានអំពីតំបន់ ៣</u>*

១៩៦. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ ដែលសម្រេចថា លោក យឹម ទិត្យ "បានទទួលមុខតំណែងជា លេខាតំបន់ ៣" នៅឆមាសទីពីរឆ្នាំ ១៩៧៨។ មិនមានភស្តុតាងនៅក្នុងសំណុំរឿងដែលថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ៣ ឡើយ។ ការទំនាក់ទំនងរបស់លោក យឹម ទិត្យ ជាមួយលេខាស្រុកបរិល អំពីការដាំដុះស្រូវ ធ្វើឡើងត្រឹមពីរខែ មុនពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំប៉ុណ្ណោះ ហើយទំនាក់ទំនងសាច់ញាតិរបស់គាត់

---

[568] ឯកសារ D219/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វី ផាន់ ឆ.១-ឆ.៦ ERN 01040093-01040094។

[569] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧៥ ជើងទំព័រ ៩៩៧។

[570] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៧៥ ERN 01095247។

[571] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៩៩-ឆ.១០១ ERN 01095250-01095251។

[572] ឯកសារ D219/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៩៨ ERN 01095250។

[573] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧៤-៣៧៦។

ជាមួយ តា ម៉ុក មិនអាចធ្វើឱ្យមានការសម្រេចថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* ជាលេខាតំបន់ ៣ ទេ[574]។

១៩៧. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានវាយតម្លៃដោយត្រឹមត្រូវទៅលើចម្លើយរបស់សាក្សី ហើយមិនបានពិចារណាទៅលើភស្តុតាងផ្ទុយ និងដោះបន្ទុក ព្រមទាំងមិនបានផ្តល់សំអាងហេតុសម្រាប់ការដែលគាត់សម្រេចថា ភស្តុតាងដែលគាត់ពឹងផ្អែក គួរឱ្យជឿជាក់ខ្លាំង ដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសន្និដ្ឋានណាផ្សេងបានឡើយ ដូច្នេះហើយមានកំហុសអង្គច្បាប់ តាមរយៈការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានអនុវត្តបទដ្ឋានភរនីយភាព[575]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានធ្វើការសម្រេចដោយបកស្រាយខុសឆ្គងចំពោះភស្តុតាងរបស់សាក្សី ក្នុងលក្ខណៈមួយដែលអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដូច្នេះហើយគឺជាការរំលោភបំពាន់ទៅលើឆន្ទានុសិទ្ធរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[576]។ ដោយពឹងផ្អែកទៅលើចំណងសាច់ញាតិរបស់លោក យឹម ទិត្យ ជាមួយតាម៉ុក ហើយមិនពិចារណាអំពីភស្តុតាងផ្ទុយគ្នាដែលពាក់ព័ន្ធ នៅពេលធ្វើការសម្រេចនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានអនុវត្តគោលករណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*[577]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ នៅពេលធ្វើការសន្និដ្ឋានដោយមិនត្រឹមត្រូវថា លោក យឹម ទិត្យ "បានទទួលមុខតំណែងជាលេខាតំបន់ ៣" ដែលធ្វើឱ្យមានភាពអយុត្តិធម៌ ដែលតម្រូវឱ្យអង្គបុរេជំនុំជម្រះផ្លាស់ប្តូរការសម្រេចទាំងអស់នេះ។

### (v) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាលេខាតំបន់ ៤

១៩៨. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ៤ នៅពាក់កណ្តាលឆ្នាំ ១៩៧៨[578]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការ

---

[574] ខាងលើ កថាខណ្ឌ ៨៣, ១២៤-១៤៣។

[575] ខាងលើ កថាខណ្ឌ ១៧-១៩។

[576] ដូចយោងខាងលើ។

[577] ដូចយោងខាងលើ។

[578] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៧៧។

សម្រេចនេះ ដោយផ្អែកលើភស្តុតាងរបស់សាក្សីតែមួយរូប គឺ ឡុច អេង[579] ជាកម្មាភិបាលមកពីស្រុកសំរោង ភូមិភាគនិរតី ដែលមកដល់ខេត្តបាត់ដំបង នៅក្នុងខែកក្កដា ឆ្នាំ១៩៧៨[580] ដោយគាត់ត្រូវបានចាត់តាំងដោយ តារិន[581] ដែលជាលេខាតំបន់៥[582] ដើម្បីធ្វើជាសមាជិកសហករណ៍ នៅឃុំបឹងព្រៃ ដែលស្ថិតក្នុងស្រុកដូនទាវ[583] តំបន់ ៥[584]។

១៩៩. ក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាលេខាតំបន់ ៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាដល់ភស្តុតាងដទៃទៀតរបស់ ឡុច អេង និងភស្តុតាងរបស់សាក្សីផ្សេង ដែលផ្ទុយពីការសម្រេចនេះ ហើយដែលជាភស្តុតាងដោះបន្ទុក។ ដំបូង ឡុច អេង បានបញ្ជាក់ថា 'តាទិត្យ' មកដល់ក្រោយគាត់ (ក្រោយខែកក្កដា ឆ្នាំ១៩៧៨) ដើម្បីមកជំនួសតារិន[585]។ ផ្ទុយពីចម្លើយនេះ ទុំ សឿន បានផ្តល់ភស្តុតាងថា រិន គឺជាលេខាតំបន់ ៥ រហូតដល់បញ្ចប់របបនេះ[586]។ នៅពេលបន្ទាប់មក ឡុច អេង បានផ្លាស់ប្តូរភស្តុតាងរបស់គាត់ ហើយបញ្ជាក់ថា គាត់មិនបានដឹងច្បាស់អំពីតួនាទីរបស់ 'តាទិត្យ' ទេ ព្រោះ "អាហ្នឹង៧៨ ៧៩ ហើយ"[587] ហើយ 'តាទិត្យ' មិនដែលត្រូវបានណែនាំថាជា លេខាតំបន់ទេ នៅក្នុងតំបន់៥[588]។ ឡុច អេង ក៏បានបញ្ជាក់ផងដែរថា លើកដំបូងដែលគាត់បានឮឈ្មោះ 'តាទិត្យ' គឺប្រហែលកន្លះខែ បន្ទាប់ពីគាត់មកដល់ឃុំបឹងព្រៃ[589] ប៉ុន្តែគាត់បានចូលរួមការប្រជុំតែមួយគត់ ដែលមានវត្តមានរបស់ 'តាទិត្យ'[590]នៅចុងឆ្នាំ

[579] ដូចយោងខាងលើ កថាខណ្ឌ ៣៧៧ ជើងទំព័រ ១០០១។

[580] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៤ ERN 00947288។

[581] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៨ ERN 00947288។

[582] ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ឆ.២២៤ ERN 00953050។

[583] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៤-ឆ.៦ ERN 00947288។

[584] ឡុច អេង ចាំមិនបានថាតើស្រុកនេះស្ថិតនៅក្នុងតំបន់ណានោះទេ នៅពេលនោះ (ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៥ ERN 00947288។ ប៉ុន្តែ តាមចម្លើយរបស់ ជូ យ៉ន (ឯកសារ D219/900.1 បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ERN 00730921-00730923 ស្រុកនេះស្ថិតនៅក្នុងតំបន់ ៥)។

[585] ឯកសារ D219/627 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៣ ERN 01184314។

[586] ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ឆ.២២៤ ERN 00953050។

[587] ឯកសារ D219/884 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៧, ឆ.១៨ ERN 01362502-01362503។

[588] ឯកសារ D219/884 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៣ ERN 01362502។

[589] ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៣០ 00947291។

[590] ឯកសារ D219/627 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.១៣ ERN 01184314។

១៩៧៨[591] គឺនៅជិតដល់ពេលបញ្ចប់របបនោះ[592]។ ឡុច អេង បាននិយាយសំដៅទៅទីតាំងនៃការប្រជុំនេះ "នៅនឹងកន្លែងការដ្ឋានធ្វើការ ដែលមានពួកចល័តធ្វើស្រែ នៅនឹងកន្លែងនោះចូលរួម"[593]។ មិនមានព័ត៌មានគ្រប់គ្រាន់ទេ ដើម្បីសន្និដ្ឋានថាតើ ឡុច អេង អាចកំណត់អត្តសញ្ញាណ 'តាទិត្យ' ដោយរបៀបណា នៅក្នុងកិច្ចប្រជុំដែលបានលើកឡើងនោះ ដោយសារតែហេតុការណ៍នេះ ជាលើកដំបូង និងជាលើកចុងក្រោយ ដែលគាត់បានឃើញលោក យឹម ទិត្យ។

២០០. មិនមានភ័ស្តុតាងដទៃទៀតឡើយ ទាក់ទងនឹងវត្តមានរបស់លោក យឹម ទិត្យ នៅក្នុងតំបន់៤។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាថា មិនមានភ័ស្តុតាងណាមួយនៅក្នុងសំណុំរឿង ដែលថា លោក យឹម ទិត្យ ប្រើប្រាស់សិទ្ធិអំណាចដូចការចោទប្រកាន់ ក្នុងនាមជាលេខាតំបន់៤ទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏មិនបានពិចារណាលើការសម្រេចផ្ទាល់របស់គាត់ ដែលថាមិនមានភ័ស្តុតាងនៅក្នុងសំណុំរឿង ដែលថា លោក យឹម ទិត្យ បានទៅពិនិត្យទីតាំងឧក្រិដ្ឋកម្មណាមួយ នៅក្នុងតំបន់៤ គឺមន្ទីរសន្តិសុខវត្តសម្តេច[594] មន្ទីរសន្តិសុខវត្តពោធិ៍លង្ការ/កាច់រទេះ[595] ឬឃុំកំពង់ព្រៀង និងរាំងកេសីឡើយ[596]។

*<u>សេចក្តីសន្និដ្ឋានលើតំបន់ ៤</u>*

២០១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសលើអង្គហេតុ និងលើអង្គច្បាប់ ក្នុងការសម្រេចថា លោក យឹម ទិត្យ "ត្រូវបានតែងតាំងជាលេខាតំបន់ ៤" នៅពាក់កណ្តាលឆ្នាំ១៩៧៨។ មិនមានភ័ស្តុតាងដែលអាចជឿជាក់បាននៅក្នុងសំណុំរឿង ដែលថា លោក យឹម ទិត្យ ធ្លាប់ត្រូវបានតែងតាំងជា លេខាតំបន់ ៤ ឡើយ។

២០២. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានវាយតម្លៃដោយត្រឹមត្រូវទៅលើភ័ស្តុតាងរបស់សាក្សីតែមួយរូប ដែលគាត់ពឹងផ្អែកទៅលើ ហើយមិនបានពិចារណាលើ ភ័ស្តុតាងដោះបន្ទុក និងភ័ស្តុតាង

---

[591] ឯកសារ D219/627 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.២០ ERN 01184315។

[592] ឯកសារ D219/627 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៣១ ERN 01184316។

[593] ឯកសារ D219/627 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.២២ ERN 01184315។

[594] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៨០៩។

[595] ដូចយោងខាងលើ កថាខណ្ឌ ៨៩៣។

[596] ដូចយោងខាងលើ កថាខណ្ឌ ៩២០។

ផ្ទុយ ព្រមទាំងមិនបានផ្តល់សំអាងហេតុ ថាតើហេតុអ្វីទើបគាត់សម្រេចថា ភ័ស្តុតាងដែលគាត់ពឹងផ្អែកទៅលើនោះ គួរឲ្យជឿជាក់ខ្លាំង ដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសន្និដ្ឋានណាផ្សេងបានឡើយ ដូច្នេះហើយមិនបានអនុវត្តបទដ្ឋានភរនីយភាព[597]។ ដោយពឹងផ្អែកទៅលើចំណងសាច់ញាតិរបស់លោក យឹម ទិត្យ ជាមួយតាម៉ុក ហើយដោយមិនពិចារណាអំពីភ័ស្តុតាងផ្ទុយគ្នាដែលពាក់ព័ន្ធ នៅពេលធ្វើការសម្រេចនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានអនុវត្តគោលករណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*[598]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយធ្វើការសន្និដ្ឋានដោយមិនត្រឹមត្រូវថា លោក យឹម ទិត្យ "ត្រូវបានតែងតាំងជាលេខាតំបន់ ៤" នៅពាក់កណ្តាលឆ្នាំ ១៩៧៨ ដែលធ្វើឲ្យមានភាពអយុត្តិធម៌ និងតម្រូវឲ្យអង្គបុរេជំនុំជម្រះផ្លាស់ប្តូរការសម្រេចទាំងអស់នេះ។

**(vi) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ**

២០៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ ហើយថា គាត់គឺជា "មនុស្សទីពីរដែលមានអំណាចជាងគេ នៅភូមិភាគពាយ័ព្យ បន្ទាប់ពីតាម៉ុក"[599]។ ដូចដែលបានលើកឡើងពីខាងលើ ការប្រកាន់ខ្ជាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើចំណងសាច់ញាតិរបស់លោក យឹម ទិត្យ ជាមួយតាម៉ុក មានឥទ្ធិពលដោយផ្ទាល់ទៅលើការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចំពោះភ័ស្តុតាងនានា[600]។

២០៤. ទីមួយ មិនមានភ័ស្តុតាងនៅក្នុងសំណុំរឿងដែលថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យទេ។

២០៥. ដើម្បីសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើចម្លើយតែមួយរបស់

---

[597] ខាងលើ កថាខណ្ឌ ១៧-១៩។

[598] ខាងលើ កថាខណ្ឌ ១៧-១៩, ១២៤-១៤៣។

[599] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៨០-៣៨២, ៩៩៤។

[600] ខាងលើ កថាខណ្ឌ ១២៤-១៤៣។

អង្គរក្ស និងជានិរសារបស់តាប៉ែត ឈ្មោះ ឈាន ប៊ា[601] ដែលបញ្ជាក់ថា គាត់ធ្លាប់អមដំណើរ តាប៉ែត ទៅកិច្ចប្រជុំមួយ (នៅថ្ងៃខែដែលគាត់មិនចាំ) តែគាត់មិនបានចូលរួមទេ។ ក្រោយកិច្ចប្រជុំនោះ តាប៉ែត បានប្រាប់គាត់ថា "យឹម ទិត្យបានប្រកាសថា មេដឹកនាំភូមិភាគពាយ័ព្យជាពួកក្បត់ ហើយថា យឹម ទិត្យ បានបង្ហាញឯកសារពីមជ្ឈិមឲ្យគាត់មើល ដែលបានតែងតាំង យឹម ទិត្យ ឲ្យទទួលខុសត្រូវនៅភូមិភាគពាយ័ព្យ"[602]។ តាប៉ែត មិនបានបង្ហាញឯកសារនោះទៅឲ្យ ឈាន ប៊ា ទេ។ មិនមានភ័ស្តុតាងនៅក្នុងសំណុំរឿង ដែលគាំទ្រការចោទប្រកាន់ថា មានកិច្ចប្រជុំបែបនេះ ឬថាមានឯកសារដែល ឈាន ប៊ា មិនដែលបានឃើញនេះទេ។

២០៦. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយដែលពាក់ព័ន្ធដទៃរបស់សាក្សីនេះឡើយ។ ឈាន ប៊ា បានបញ្ជាក់ថា គាត់មិនដែលបានចូលរួមការប្រជុំណាមួយជាមួយ 'តាទិត្យ' ទេ[603]។ គាត់បានឃើញ 'តាទិត្យ' តែម្តងគត់នៅក្នុងខែតុលា ឬខែវិច្ឆិកា ឆ្នាំ១៩៧៨[604] ហើយថា តាប៉ែតគឺជា "ប្រធានទីពីរ" ភូមិភាគពាយ័ព្យ ក្រោយ តា គី ត្រូវបានដកចេញពីតំណែងនេះ[605]។ ឈាន ប៊ា ក៏បានទទួលស្គាល់ថា ទោះបីជាគាត់ធ្វើការងារឲ្យតាប៉ែតតាំងពីឆ្នាំ១៩៧៥[606] ប៉ុន្តែ នៅពេលវេលានោះ គាត់នៅក្មេងពេក មិនអាចយល់ដឹងថាតើ តាញឹម និងតាគី មានតួនាទីអ្វីឡើយ[607]។

២០៧. ការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា លឹម ទីម អះអាងប្រហែលគ្នាជាមួយ ឈាន ប៊ា[608] គឺជារឿងខុសឆ្គង។ លឹម ទីម បានផ្តល់ភ័ស្តុតាងអំពី ការប្រជុំនៅរោងចក្រស្ករ នៅពាក់កណ្តាលឆ្នាំ១៩៧៨ ដែល 'តាទិត្យ' ត្រូវបានចោទថាមានវត្តមាន ហើយត្រូវបានគេ

---

[601] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៨៤ ជើងទំព័រ ១០១៥។

[602] ដូចយោងខាងលើ កថាខណ្ឌ ៣៨៤។

[603] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៩ ERN 00960664។

[604] ឯកសារ D118/271 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២៥-ឆ.២៦ ERN 00998557។ ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២០ ERN 00960666។

[605] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៦ ERN 00960663។ ឯកសារ D219/233 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៥៦ ERN 01078142។

[606] ឯកសារ D118/136 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.២ ERN 00960662។

[607] ឯកសារ D118/271 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈាន ប៊ា ឆ.៤៤-ឆ.៤៥ ERN 00998560។

[608] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៨៤។

ណែនាំខ្លួនថាជាគណៈកម្មាធិការភូមិភាគពាយ័ព្យ[609]។ ទោះជាបែបនេះក្តី លឹម ទីម នៅពេលក្រោយមកបានផ្លាស់ប្តូរចម្លើយរបស់គាត់ ហើយបាននិយាយថា 'តាទិត្យ' មិនដែលទៅរោងចក្រនោះឡើយ[610]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខ្លួនឯងផ្ទាល់បានសន្និដ្ឋានថា មិនមានភ័ស្តុតាងគួរឲ្យជឿជាក់ថា លោក យឹម ទិត្យ បានទៅរោងចក្រស្ករកំពង់គុល[611] ហើយសម្រេចថា ភ័ស្តុតាងរបស់ លឹម ទីម មិនអាចជឿជាក់បាន[612]។

២០៨. សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏បានសម្រេចផងដែរថា "អង្គហេតុដែលថា យឹម ទិត្យ កាន់មុខតំណែងនៅក្នុងគណៈកម្មាធិការភូមិភាគពាយ័ព្យ និង*តាមព្រឹត្តន័យ* ជាមនុស្សមានអំណាចទីពីរព្រមទាំងជាអនុរបស់ តាម៉ុក នោះ បានទទួលការគាំទ្រពីសាក្សីផ្សេងទៀតដែរ"[613]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបង្ហាញភ័ស្តុតាងដោយមិនត្រឹមត្រូវ។ សម្រាប់សំអាងហេតុខាងក្រោមនេះ មិនមានសាក្សីណាមួយដែលបានដកស្រង់ បានគាំទ្រដល់ការសម្រេចបែបនេះឡើយ៖

- ហាន់ ធី បានឃើញ 'តាទិត្យ' ជាលើកដំបូង នៅបីថ្ងៃមុនពេលវៀតណាមចូលមកដល់[614]។

- សហចៅក្រមស៊ើបអង្កេតអន្តរជាតិខ្លួនគាត់ផ្ទាល់ បានសម្រេចថា ភ័ស្តុតាងរបស់ លឹម ទីម មិនអាចជឿជាក់បាន[615]។

- ហែម មឿន មានដែលមានវត្តមាន នៅក្នុងការប្រជុំជាមួយ 'តាទិត្យ' ទេ[616] ប៉ុន្តែ បានអះអាងថា គាត់បានស្តាប់ឮ គឺនៅមួយសប្តាហ៍បន្ទាប់ពីគាត់មកដល់បាត់ដំបង គឺនៅក្នុង

---

[609] ឯកសារ D118/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ឆ.១៨ ERN 00951928។ ឯកសារ D219/649 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ឆ.៣៧ ERN 01196459។

[610] ឯកសារ D118/108 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ទីម ឆ.១៦ ERN 00951928។

[611] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៧៤៦។

[612] ដូចយោងខាងលើ កថាខណ្ឌ ៧៤១។

[613] ដូចយោងខាងលើ កថាខណ្ឌ ៣៨៣។

[614] ឯកសារ D20 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហាន់ ធី *ERN* 00699643។

[615] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៧៤១។

[616] ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.៦២ ERN 00968004។

រដូវវស្សាក្នុងឆ្នាំ១៩៧៨[617] ការប្រកាសមួយដែលថា 'តាទិត្យ' ជាអ្នកដែលត្រូវជំនួស តាម៉ុក នៅក្នុងភូមិភាគពាយ័ព្យ នៅពេលដែលតាម៉ុកអវត្តមាន[618]។ ប៉ុន្តែ ក្រោយមកគាត់បានប្តូរចម្លើយនៅក្នុងសវនាការសំណុំរឿង ០០២/០២ នៅពេលដែលគាត់និយាយថា គាត់មិនដែលចូលរួមការប្រជុំបែបនេះទេ ហើយគាត់បន្ថែមថា គាត់មិនបានដឹងអំពីខ្លឹមសារនៃការប្រជុំឡើយ[619]។

- ពៅ គឿន មិនធ្លាប់ស្គាល់អ្នកដឹកនាំណា ដែលគ្រប់គ្រងភូមិភាគ និងតំបន់[620] មិនដែលជួប 'តាទិត្យ'[621] និងមិនស្គាល់មេដឹកនាំភូមិភាគពាយ័ព្យទេ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីមកដល់[622]។

២០៩. ដូចបានលើកឡើងពីខាងលើ[623] សហចៅក្រមស៊ើបអង្កេតអន្តរជាតិព្យាយាមគាំទ្រដល់សម្រេចរបស់គាត់ ដោយប្រើគំនិតរបស់សាក្សីអង្គហេតុ ទាក់ទងនឹងចំណងសាច់ញាតិរវាងតាម៉ុក និង លោក យឹម ទិត្យ ហើយនឹងអង្គការរដ្ឋបាលរបស់ភូមិភាគពាយ័ព្យ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិយកមកប្រើប្រាស់ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់[624] ដែលមិនអាចអះអាងបានអំពីតួនាទី *តាមព្រឹត្តន័យ* ឬ *តាមនីតិន័យ* របស់លោក យឹម ទិត្យ ជាអនុលេខាភូមិភាគពាយ័ព្យ។ ចំណុចនេះពិតជាត្រឹមត្រូវ ជាពិសេស នៅពេលដែលទាក់ទងជាមួយនឹងចម្លើយដែលត្រូវបានដកស្រង់ដោយអន្លើពីសាក្សី ពេជ្យ ជឹម ដែលភ័ស្តុតាងរបស់គាត់ពាក់ព័ន្ធនឹងភូមិភាគនិរតី[625] មិនមែនពាក់ព័ន្ធនឹងភូមិភាគពាយ័ព្យទេ។ ក្នុងពេលជាមួយគ្នានោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាអំពីភ័ស្តុតាងដោះបន្ទុកសំខាន់ៗ ទាក់ទងនឹងតួនាទីរបស់អនុលេខា ភូមិភាគពាយ័ព្យ

---

[617] ឯកសារ D118/222 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.១៧ ERN 00983235។

[618] ឯកសារ D118/222 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.១៤ ERN 00983235។

[619] ឯកសារ D339.1.1 ហែម មឿន ប្រតិចារឹកសវនាការ ថ្ងៃទី០២ ខែសីហា ឆ្នាំ២០១៦ ទំព័រ ៦៤ បន្ទាត់ ១៦-១៨ EN 01351805។

[620] ឯកសារ D219/682 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.១៧-ឆ.១៩ ERN 01203900។

[621] ឯកសារ D219/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.៣១ ERN 01037176។

[622] ឯកសារ D219/682 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.១៧ ERN 01203900។

[623] ខាងលើ កថាខណ្ឌ ១២៤-១៤១។

[624] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៨១, ៣៨៣។

[625] ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.១៤០ ERN 00997041។

នៅពេលវេលាពាក់ព័ន្ធ ដែលគាត់បានពិចារណាដោយមិនត្រឹមត្រូវថាមាន "ភាពពាក់ព័ន្ធតិចតួច ចំពោះគោលបំណងនៃដីកាដំណោះស្រាយនេះ" ដោយមិនបានពន្យល់បកស្រាយបន្ថែម[626]។

២១០. កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលជាក់ស្តែងទៅ គឺជា "សាក្សីតារា" នៅក្នុងសវនាការទាំងអស់ នៅចំពោះមុខ អ.វ.ត.ក រហូតមកដល់ពេលនេះ[627] ហើយដែលមិនបានលើកឡើងអំពីលោក យឹម ទិត្យ

[626] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៨៥។

[627] យោងតាមទិន្នន័យដែលមេធាវីការពារក្តីមាន ឌុច បានផ្តល់ចម្លើយចំនួន ៣ លើកទៅ UNHCHR នៅឆ្នាំ១៩៩៩ (ឯកសារ D1.3.29.7a ឯកសារ D1.3.29.7b និងឯកសារ D1.3.29.7c បទសម្ភាសន៍របស់ UNHCHR ជាមួយជនសង្ស័យ កាំង ហ្កេកអ៊ាវ ហៅ ឌុច) ចម្លើយចំនួនមួយលើកទៅចៅក្រមស៊ើបអង្កេតនៃតុលាការយោធានៃព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៩៩ (ឯកសារ D6.1.882 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច) បទសម្ភាសន៍ចំនួន ១៩ លើកជាមួយ ក.ស.ច.ស នៅក្នុងសំណុំរឿង ០០១ និង ០០២ (ឯកសារ D1.3.29.4 ឯកសារ D6.1.1065 ឯកសារ D6.1.1066 ឯកសារ D6.1.1067 ឯកសារ D1.3.29.2 ឯកសារ D6.1.1051 ឯកសារ D1.3.29.3 ឯកសារ D6.1.1052 ឯកសារ D6.1.1056 ឯកសារ D6.1.1063 ឯកសារ D6.1.1070 ឯកសារ D6.1.1072 ឯកសារ D1.3.29.6 ឯកសារ D1.3.29.5 ឯកសារ D1.3.29.8 ឯកសារ D6.1.91 ឯកសារ D6.1.92 ឯកសារ D6.1.93 និងឯកសារ D6.1.95 កំណត់ហេតុសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច) សក្ខីកម្មក្នុងឋានៈជាជនជាប់ចោទ នៅក្នុងសំណុំរឿង ០០១ រយៈពេល ២៤ ថ្ងៃ (ឯកសារ D6.1.869 ឯកសារ D6.1.872 ឯកសារ D6.1.875 ឯកសារ D6.1.861 ឯកសារ D219/702.1.126 ឯកសារ D219/702.1.128 ឯកសារ D219/702.1.114 ឯកសារ D219/702.1.8 ឯកសារ D219/702.1.133 ឯកសារ D6.1.862 ឯកសារ D6.1.863 ឯកសារ D6.1.865 ឯកសារ D219/702.1.137 ឯកសារ D219/702.1.117 ឯកសារ D219/702.1.119 ឯកសារ D219/702.1.120 ឯកសារ D6.1.866 ឯកសារ D219/702.1.127 ឯកសារ D6.1.867 ឯកសារ D219/702.1.129 ឯកសារ D6.1.870 ឯកសារ D219/702.1.140 ឯកសារ D6.1.871 និងឯកសារ D219/702.1.139 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០១) បទសម្ភាសន៍ចំនួន ៤ លើកបន្ថែមទៀតជាមួយ ក.ស.ច.ស នៅក្នុងសំណុំរឿង ០០២ (ឯកសារ D6.1.637 ឯកសារ D6.1.736 ឯកសារ D6.1.796 និងឯកសារ D219/702.1.150 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងសំណុំរឿង ០០២) សក្ខីកម្មក្នុងឋានៈជាសាក្សី នៅក្នុងសំណុំរឿង ០០២/០១ រយៈពេល ៥ ថ្ងៃ នៅឆ្នាំ២០១២ (ឯកសារ D127/2.1.12 ឯកសារ D179/1.2.9 ឯកសារ D179/1.2.11 និងឯកសារ D179/1.2.13 កាំង ហ្កេកអ៊ាវ ហៅ ឌុច ប្រតិចារឹកសវនាការក្នុងសំណុំរឿង ០០២/០១) សក្ខីកម្មក្នុងឋានៈជាសាក្សី នៅក្នុងសំណុំរឿង ០០២/០២ រយៈពេល ១២ ថ្ងៃ នៅឆ្នាំ២០១៦ (ឯកសារ D219/852.1.1 ឯកសារ D219/852.1.2 ឯកសារ D219/852.1.3 ឯកសារ D219/852.1.4 ឯកសារ D219/852.1.5 ឯកសារ D219/852.1.6 ឯកសារ D219/852.1.7 ឯកសារ D219/852.1.8 ឯកសារ D219/852.1.9 ឯកសារ D219/852.1.10 ឯកសារ D219/852.1.11 និងឯកសារ D219/852.1.12) និងបទសម្ភាសន៍ចំនួន ៣ លើកនៅក្នុងសំណុំរឿង ០០៣ និង ០០៤ (ឯកសារ D219/672 ឯកសារ D219/673 និងឯកសារ D219/674 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្កេកអ៊ាវ ហៅ ឌុច ក្នុងសំណុំរឿង ០០៣ និង ០០៤)។ ភស្តុតាងរបស់ ឌុច ដែលត្រូវបានជ្រើសរើស ត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿង ០០៤ និងមានចំនួនសរុប ៧១ ឯកសារ។

នៅក្នុងឯកសារទាំង ៧១ ដែលមាននៅក្នុងសំណុំរឿង ០០៤ បានបញ្ជាក់ថា នៅក្នុងខែមករា ឆ្នាំ ១៩៧៩ សារុន គឺជា "អនុលេខាភូមិភាគពាយ័ព្យ (ដែលលេខាភូមិភាគគឺតាម៉ុក) ដែលខ្ញុំរត់គេចជាមួយទៅសំឡូត"[628]។

២១១. លើសពីនេះទៀត អត្ថបទរបស់ Timothy Carney ដែលមានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើង "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់"[629] បានរៀបរាប់អំពីរចនាសម្ព័ន្ធ និងតួនាទីរបស់បក្សកុម្មុយនីស្តកម្ពុជា។ អត្ថបទនេះមានការវិភាគលើមុខងារ និងរចនាសម្ព័ន្ធរបស់ គណៈ កម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ និងតារាងមួយកំណត់អត្តសញ្ញាណសមាជិកនៃគណៈកម្មាធិការទាំងនេះ ចាប់ពីឆ្នាំ១៩៧៥ រហូតដល់ឆ្នាំ១៩៧៨[630]។ ឈ្មោះរបស់លោក យឹម ទិត្យ មិនមានបង្ហាញនៅក្នុងតារាងទាំងអស់នេះទេ។

២១២. ផ្ទុយទៅវិញ នៅក្នុង "ការរៀបចំអំណាច" លោក Timothy Carney បានអះអាងថា នៅក្នុងខែសីហា ឆ្នាំ១៩៧៨[631] ហេង ទាវ ហៅ តាប៉ែត គឺជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ សមាជិកគណៈកម្មាធិការមជ្ឈិម និងជាសមាជិកគណៈកម្មាធិការបក្សភូមិភាគ[632]។ អ្នកនិពន្ធក៏បានផ្តល់តារាងមួយ ដែលមានឈ្មោះ តួនាទី និងកាលបរិច្ឆេទចាប់ខ្លួន និងស្លាប់របស់កម្មាភិបាល នៅក្នុង

[628] ឯកសារ D6.1.1052 កំណត់ហេតុនៃការស្តាប់ចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN 00159561-00159562។

[629] ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney មានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើងថា "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់"។

[630] ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney មានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើងថា "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" ERN 00332368-00332372 និង ERN 00332378-00332385។

[631] ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney មានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើងថា "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" ERN 00332368 យោងទៅសមាជ ប.ក.ក ខែសីហា ឆ្នាំ១៩៧៨ សមាជិកគណៈកម្មាធិការមជ្ឈិម និងតារាងទី ៣។

[632] ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney មានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើងថា "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" តារាងទី ៣ ERN 00332381-00332383។

អំឡុងពេលបោសសម្អាតភូមិភាគពាយ័ព្យ[633]។ មិនមានការលើកឡើងថា តាប៉ែត ត្រូវបានបោសសម្អាតនៅពេលណាមួយឡើយ[634]។

២១៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើអង្គហេតុដែលថា មិនមានអត្ថិភាពភ័ស្តុតាងនៅក្នុងសំណុំរឿងដែលថា លោក យឹម ទិត្យ បានប្រើប្រាស់សិទ្ធិអំណាចរបស់គាត់ ក្នុងនាមជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ ឬ*តាមព្រឹត្តន័យ* ជាអ្នកមានសិទ្ធិអំណាចទីពីរ បន្ទាប់ពីតាម៉ុកទេ។

*ការសន្និដ្ឋានលើការចោទប្រកាន់ពីសមាជិកភាពរបស់គណៈកម្មាធិការភូមិភាគពាយ័ព្យ*

២១៤. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ ក្នុងការសម្រេចថា លោក យឹម ទិត្យ គឺជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ និងជាមនុស្សទីពីរដែលមានអំណាចជាងគេ បន្ទាប់ពីតាម៉ុក នៅពេលណាមួយក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មិនមានភ័ស្តុតាងក្នុងសំណុំរឿងដែលថា លោក យឹម ទិត្យ ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ ឬថា គាត់ជាមនុស្សទីពីរដែលមានអំណាចជាងគេ បន្ទាប់ពីតាម៉ុក។ ត្រឹមតែការលើកឡើងពីវត្តមានរបស់លោក យឹម ទិត្យ នៅក្នុងការប្រជុំមួយចំនួន នៅប៉ុន្មានខែចុងក្រោយនៃរបបខ្មែរក្រហមនោះ នៅក្នុងតំបន់ ១ ព្រមទាំងចំណងសាច់ញាតិរបស់គាត់ ជាមួយតាម៉ុក មិនបានកំណត់ថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* ឬ*តាមនីតិន័យ* នៅក្នុងភូមិភាគពាយ័ព្យទេ[635]។

២១៥. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានវាយតម្លៃដោយត្រឹមត្រូវទៅលើចម្លើយរបស់សាក្សី មិនបានពិចារណាទៅលើភ័ស្តុតាងដោះបន្ទុក និងភ័ស្តុតាងផ្ទុយ និងមិនបានផ្តល់សំអាងហេតុ អំពី

---

[633] ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney មានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើងថា "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" ERN 00332386-00332391។

[634] ឯកសារ D1.3.15.2 អត្ថបទរបស់ Timothy Carney មានចំណងជើងថា "ការរៀបចំអំណាច" ចេញផ្សាយនៅក្នុងសៀវភៅរបស់ Karl Jackson មានចំណងជើងថា "ប្រទេសកម្ពុជា ឆ្នាំ១៩៧៥-១៩៧៨៖ ការណាត់ជួបជាមួយសេចក្តីស្លាប់" ERN 00332386-00332388។

[635] ខាងលើ កថាខណ្ឌ ៨៣, ១២៤-១៤៣។

មូលហេតុដែលគាត់សម្រេចថា ភស្តុតាងដែលគាត់ពឹងផ្អែកលើ មានភាពគួរឱ្យជឿជាក់ខ្លាំង ដែលមិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសន្និដ្ឋានណាផ្សេងបានឡើយ ដូច្នេះហើយមានកំហុសអង្គច្បាប់ តាមរយៈការមិនបានអនុវត្តបទដ្ឋានភាវនីយភាព[636]។ ដោយពឹងផ្អែកទៅលើចំណងសាច់ញាតិរបស់លោក យឹម ទិត្យ ជាមួយ តាម៉ុក ហើយដោយមិនពិចារណាអំពីភស្តុតាងផ្ទុយគ្នាដែលពាក់ព័ន្ធ នៅពេលធ្វើការសម្រេចនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានអនុវត្តគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ*[637]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយធ្វើការសន្និដ្ឋានដោយមិនត្រឹមត្រូវជាក់ស្តែងថា លោក យឹម ទិត្យ ជាសមាជិកគណៈកម្មាធិការភូមិភាគពាយ័ព្យ និងជាមនុស្សទីពីរដែលមានអំណាចជាងគេ បន្ទាប់ពីតាម៉ុក ដែលធ្វើឱ្យមានភាពអយុត្តិធម៌ និងតម្រូវឱ្យអង្គបុរេជំនុំជម្រះផ្លាស់ប្តូរការសម្រេចទាំងអស់នេះ។

*<u>សេចក្តីសន្និដ្ឋាន</u>*

២១៦. សម្រាប់សំអាងហេតុដូចបានលើកឡើងខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ ដោយសម្រេចថា លោក យឹម ទិត្យ មានតួនាទីផ្លូវការនៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ មិនមានភស្តុតាងដែលគួរឱ្យជឿជាក់នៅក្នុងសំណុំរឿងដែលថា លោក យឹម ទិត្យធ្លាប់ជា "មេស្រុកគីរីវង្ស" ដែលមាន "សិទ្ធិអំណាចជាក់ស្តែងធំធេង" នៅក្នុងតំបន់ ១៣ ហើយត្រូវបានតែងតាំងជាលេខាតំបន់ នៅក្នុងតំបន់១ តំបន់៣ និងតំបន់៤ ឬត្រូវបានតែងតាំងជាគណៈកម្មាធិការភូមិភាគពាយ័ព្យឡើយ។

២១៧. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់ តាមរយៈការពឹងផ្អែកយ៉ាងខ្លាំងរបស់គាត់ទៅលើ "សិទ្ធិអំណាច*តាមព្រឹត្តន័យ*" នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ។ នេះគឺជាផ្ទាំងបិទបាំងភាពខ្វះខាតភស្តុតាងដែលអាចជឿជាក់បាននានា សម្រាប់ពេលវេលា តួនាទី និងការទទួលខុសត្រូវជាក់លាក់នានា ដែលចោទប្រកាន់ចំពោះលោក យឹម ទិត្យ។ បន្ថែមពីលើភាពខ្វះចន្លោះនៃភស្តុតាងទាំងនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានធ្វើការពិចារណាទៅលើសាក្សីជាច្រើន ដែល ក.ស.ច.ស បានជ្រើសរើសដើម្បីស្តាប់ចម្លើយនៅក្នុងសំណុំរឿង ០០៤

---

[636] ខាងលើ កថាខណ្ឌ ១៧-១៩។

[637] ដូចយោងខាងលើ។

ហើយដែលមិនដែលធ្លាប់ឮពី លោក យឹម ទិត្យ[638]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបាន ពិចារណាទៅលើអង្គហេតុដែលថា លោក យឹម ទិត្យ មិនដែលនៅក្នុងគណៈកម្មាធិការអចិន្ត្រៃយ៍ ឬ គណៈកម្មាធិការមជ្ឈិម បើទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "គណៈ កម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមទទួលខុសត្រូវចំពោះការបង្កើតគោលនយោបាយ និងការណែនាំ"[639]ក្តី។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណា ឬអនុវត្តដោយមិន ត្រឹមត្រូវចំពោះការសម្រេចផ្ទាល់របស់ខ្លួន នៅក្នុងសំណុំរឿង ០០៤/១ ដែលថា "សេចក្តីសម្រេច ត្រូវបានធ្វើឡើងនៅថ្នាក់កំពូល និងបន្ទាប់មកត្រូវបានអនុវត្ត ដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពី ផលវិបាក ក្នុងលក្ខណៈបុគ្គលទោះនៅថ្នាក់ណាក៏ដោយ" ហើយបើទោះបីជាមាន "ការលំបាកកាន់ តែខ្លាំងនៃការរក្សារចនាសម្ព័ន្ធអង្គការលេខ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ" "ការកំណត់ន័យលើខ្លឹមសានៃគោលនយោបាយ និងមធ្យោបាយអនុវត្តគោលនយោបាយ ស្ថិតនៅ លើថ្នាក់កំពូល ដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ"[640]។

២១៨. នៅក្នុងការវិភាគលើភ័ស្តុតាងទាំងស្រុងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការវាយតម្លៃ ទៅលើការចោទប្រកាន់ នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ គាត់មិនបានពិចារណាជាប្រព័ន្ធ ទៅ លើភ័ស្តុតាងផ្ទុយដែលទទួលបានពីសាក្សីតែមួយដែលគាត់បានពឹងផ្អែកទៅលើ ព្រមទាំងភ័ស្តុតាង ផ្ទុយ និងដោះបន្ទុករបស់សាក្សីដទៃទៀត។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់ជា ប្រព័ន្ធនូវសំអាងហេតុសម្រាប់ការសម្រេចរបស់គាត់ រួមទាំងមិនបានបង្ហាញថា ហេតុអ្វីទើបគាត់ ពេញចិត្តទាំងស្រុងទៅលើការសន្និដ្ឋានដាក់បន្ទុក ជាជាងការវាយតម្លៃដោយយុត្តិធម៌ទៅលើការ សន្និដ្ឋានដោយសមហេតុផលដទៃទៀត។

២១៩. ដោយសារតែកំហុសអង្គហេតុ និងអង្គច្បាប់ ជាក់ស្តែងយ៉ាងច្រើនបែបនេះ នៅក្នុងការសម្រេច របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ទើបសហចៅក្រម ស៊ើបអង្កេតអន្តរជាតិមិនបានកំណត់ធាតុផ្សំ "សមាជិកភាព" នៃសហឧក្រិដ្ឋកម្មរួម នៅក្នុងភូមិ ភាគនិរតី និងពាយ័ព្យ។

---

[638] សូមមើល ឧបសម្ព័ន្ធ ក៖ សាក្សីដែលមិនធ្លាប់ឮពីឈ្មោះ យឹម ទិត្យ។

[639] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១៥២។

[640] សំណុំរឿង ០០៤/១ ដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ ឯកសារ D308/3 កថាខណ្ឌ ៤១។

២២០. ដោយផ្អែកលើមូលដ្ឋាននៃភស្តុតាងក្នុងសំណុំរឿងអំពីការចោទប្រកាន់ប្រឆាំង លោក យឹម ទិត្យ នៅភូមិភាគនិរតី និងភូមិភាគពាយ័ព្យ ទើបមិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសន្និដ្ឋាន ដូចដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើឡើងនោះទេ ដូច្នេះហើយ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនសមហេតុផលទាល់តែសោះ ដែលគឺជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តបទដ្ឋានគតិយុត្តិ ដែលមិនត្រឹមត្រូវក្នុងការវាយតម្លៃទៅលើភស្តុតាង និងមិនបានផ្តល់ការសម្រេចដែលមានសំអាងហេតុ ដែលធ្វើឲ្យប៉ះពាល់ដល់ភាពអាចជឿជាក់បានជារួមរបស់ការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើសំណុំរឿង ដែលធ្វើឲ្យដីកាដំណោះស្រាយគ្មានសុពលភាព ដោយសារតែភាពអយុត្តិធម៌ ដែលតម្រូវឲ្យអង្គបុរេជំនុំជម្រះផ្លាស់ប្តូរការសម្រេចទាំងអស់នេះ។

## គ. មូលដ្ឋានទី ៥.៣៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គច្បាប់ និងអង្គហេតុ ដោយសម្រេចថា លោក យឹម ទិត្យ បានរួមចំណែកចំពោះសហឧក្រិដ្ឋកម្មរួម

២២១. នៅក្នុងការវាយតម្លៃទៅលើ ស្ថានទម្ងន់នៃអំពើរបស់លោក យឹម ទិត្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសន្និដ្ឋាននៅក្នុងការសម្រេចលើអង្គច្បាប់ សម្រាប់យុត្តាធិការបុគ្គលថាលោក យឹម ទិត្យ បានចូលរួមប្រព្រឹត្តនិងរៀបចំអំពើប្រល័យពូជសាសន៍ ទៅលើខ្មែរក្រោមនៅក្នុងតំបន់ ដែលគាត់ទទួលខុសត្រូវ[641] និង "ជនស៊ីវិលផ្សេងទៀត និងអតីតកម្មាភិបាលប.ក.ក ដែលបានក្លាយជាជនរងគ្រោះ នៅក្រោម យឹម ទិត្យ និងដោយ យឹម ទិត្យ [...] តាមរយៈការសម្លាប់ជាបន្តបន្ទាប់ និងក្នុងទ្រង់ទ្រាយធំ ដោយមានការរៀបចំយ៉ាងល្អ ព្រមទាំងការប្រព្រឹត្តដ៏ឃោរឃៅ និងអមនុស្សធម៌ តាមរយៈការដាក់ក្នុងមន្ទីរឃុំឃាំង និងពលកម្មយ៉ាងវេទនា [...] នៅតាមបណ្តាមន្ទីរសន្តិសុខ និងការដ្ឋានការងារ"[642] ព្រមទាំងតាមរយៈគោលនយោបាយ រៀបអាពាហ៍ពិពាហ៍ដោយបង្ខំ[643]។ ដូចដែលបានពិភាក្សាខាងលើ[644] ពាក្យពេចន៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បាន

[641] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩៦។

[642] ដូចយោងខាងលើ កថាខណ្ឌ ៩៩៧។

[643] ដូចយោងខាងលើ កថាខណ្ឌ ៩៩៨។

[644] ខាងលើ កថាខណ្ឌ ១០៥-១២០។

ប្រើប្រាស់នៅក្នុងការសម្រេចលើអង្គច្បាប់ សម្រាប់យុត្តាធិការបុគ្គល[645] ព្រមទាំងរចនាសម្ព័ន្ធទាំងស្រុង នៃដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ធ្វើការវាយតម្លៃលើស្ថានទម្ងន់ នៃអំពើរបស់លោក យឹម ទិត្យ តាមរយៈការចោទប្រកានពីការចូលរួម ទៅក្នុងសហឧក្រិដ្ឋកម្មរួម។ ការវាយតម្លៃរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើការរួមចំណែករបស់លោក យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម គឺមិនត្រឹមត្រូវ។

**(i) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ក**

២២២. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយវិភាគភ័ស្តុតាងទាក់ទង ការចោទប្រកាន់ពីសិទ្ធិអំណាចរបស់លោក យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យពីពាក់កណ្តាលឆ្នាំ១៩៧៦ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៨ មិនបានរកឃើញថា លោក យឹម ទិត្យ មានសិទ្ធិអំណាច*តាមព្រឹត្តន័យ* ឬ*តាមនីតិន័យ* ឡើយ នៅក្នុងភូមិភាគពាយ័ព្យ មុនពេលដែលគាត់ត្រូវបានតែងតាំងជាផ្លូវការ នៅខែមិថុនា ឆ្នាំ១៩៧៨ តាមការចោទប្រកាន់នោះ[646]។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថាលោក យឹម ទិត្យ មានការចូលរួមក្នុងសហឧក្រិដ្ឋកម្មរួម នៅក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍និងការដ្ឋាន ភូមិភាគពាយ័ព្យ ដែលចាប់ផ្តើមតាំងពីឆ្នាំ១៩៧៦[647]។ ការសម្រេចនេះមិនត្រឹមត្រូវទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានទទួលការចោទប្រកាន់ ពីអំពើឧក្រិដ្ឋរបស់លោក យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ មុនពាក់កណ្តាលឆ្នាំ១៩៧៧ ទេ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសផ្លូវអង្គច្បាប់ ដោយការអនុវត្តហួស វិសាលភាពពេលវេលា នៃការស៊ើបអង្កេត[648]។ លើសពីនេះទៀត ការវិភាគទៅលើភ័ស្តុតាងបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការសម្រេចថា អំពើរបស់លោក យឹម ទិត្យ នៅក្នុងភូមិភាគពាយ័ព្យ នាំទៅដល់ការសន្និដ្ឋានថាលោក យឹម ទិត្យ គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត"។

---

[645] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៩៩២-៩៩៩។

[646] ដូចយោងខាងលើ កថាខណ្ឌ ៣៥៣-៣៥៦។

[647] ដូចយោងខាងលើ កថាខណ្ឌ ៣៩៨-៤១១។

[648] ខាងលើ កថាខណ្ឌ ៩៥-១០៣។

២២៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានរួមចំណែកដល់ការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន ដោយ "ពិនិត្យ" ការដ្ឋាននិងសហករណ៍ នៅក្នុងភូមិភាគពាយ័ព្យ ចាប់ពីពាក់កណ្ដាលឆ្នាំ១៩៧៦[649]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើភ័ស្តុតាង ដែលមិនមានការគាំទ្ររបស់សាក្សីបីនាក់ ហើយមិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយ និងដោះបន្ទុក៖

- សោម វណ្ណា ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបានបញ្ជាក់ថា គាត់ធ្វើការនៅទំនប់កង្ហូត[650] មិនបានធ្លាប់ឃើញ 'តាទិត្យ' ទេ គឺគ្រាន់តែបានឮឈ្មោះគាត់ប៉ុណ្ណោះ[651] មិនបានដឹងអំពីតួនាទីរបស់គាត់[652] មិនដែលឃើញគាត់ចូលរួមការប្រជុំ នៅទំនប់កង្ហូត[653] ហើយ 'តាទិត្យ' មិនដែលមកការដ្ឋានរបស់គាត់ឡើយ[654]។

- ឈឿង ប៊ាន បានបញ្ជាក់ថា 'តាទិត្យ' ចាប់ផ្ដើមមកការដ្ឋាន ទំនប់កង្ហូតនៅក្នុងខែឧសភា មិថុនា និងកក្កដា ឆ្នាំ១៩៧៨[655] ប៉ុន្តែ បន្ទាប់មកគាត់បានប្ដូរចម្លើយរបស់គាត់ ហើយគាត់បាននិយាយថា គាត់បានឃើញ 'តាទិត្យ' ជាលើកដំបូងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨[656]។

- សៅ ជាប់ បានអះអាងថា គាត់ស្គាល់មនុស្សពីរនាក់ឈ្មោះ 'តាទិត្យ' ប៉ុន្តែ គាត់មិនអាច

---

[649] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤០០-៤០១។

[650] ឯកសារ D219/46 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.២៤-ឆ.២៥ ERN 01032221-01032222។

[651] ឯកសារ D219/46 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៣៨-ឆ.៤០ ERN 01032223។

[652] ឯកសារ D219/46 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៤១ ERN 01032223។

[653] ឯកសារ D219/46 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៣១-ឆ.៣៧ ERN 01032222-01032223 ឆ.៤៧ ERN 01032224។

[654] ឯកសារ D219/46 កំណត់ហេតុនៃការស្ដាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៤២ ERN 01032223។

[655] ឯកសារ D219/430 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.១២១ ERN 01122419។

[656] ឯកសារ D219/430 កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ឈឿង ប៊ាន ឆ.៩៩ ERN 01122414 ឆ.១២៨ ERN 01122420។

បញ្ជាក់នៅក្នុងភស្តុតាងរបស់គាត់ថា ពួកគេគឺជានរណាឡើយ[657]។ នៅក្នុងការផ្តល់ចម្លើយទាំងប្រាំពីររបស់គាត់ គាត់បញ្ជាក់ដូចៗគ្នាថា ទីមួយ គាត់អាចត្រឹមផ្តល់ភស្តុតាងអំពីពេលវេលាដែលកម្មាភិបាលភូមិភាគពាយ័ព្យកាន់អំណាច ដោយសារតែគាត់បានរត់គេចទៅក្នុងព្រៃ នៅពេលដែលកម្មាភិបាល ភូមិភាគនិរតីមកដល់ នៅពាក់កណ្តាលឆ្នាំ១៩៧៧[658] និង

---

[657] ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៤៩-ឆ.៥២ ERN 01244124។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៥៩-ឆ.៦៤ ERN 01244125-01244126។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៥៣-ឆ.៥៤ ERN 01244124។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៨១ ERN 01244128។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៥៥-ឆ.៥៨ ERN 01244125។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៦៥-ឆ.៦៨ ERN 01244126។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៦៩-ឆ.៧០ ERN 01244127។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៧១ ERN 01244127។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១២៦-ឆ.១៣១ ERN 01244134-01244135។។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១៣៤ ERN 01244135។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១៣៧ ERN 01244136។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ERN 01425216។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២ ERN 01425216។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២២-ឆ.២៣ ERN 01425220-01425221។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៩-ឆ.១១ ERN 01425218។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១៧-ឆ.១៨ ERN 01425219។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២០-ឆ.២១ ERN 01425220 ឆ.២៧ ERN 01425221។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៧ ERN 01425221។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១៥ ERN 01425219 ឆ.៣៦ ERN 01425223។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣៧ ERN 01425223។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣៩ ERN 01425223 ឆ.៥៩ ERN 01425227។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៨ ERN 01425221។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១១ ERN 01425218 ឆ.៦៤ ERN 01425228។ ឯកសារ D219/980 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ស./ឆ.៧ ERN 01477597-01477598។

[658] ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៤៤-៤៥ ERN 01244123។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៥ ERN 01425221 ឆ.៣៥ ERN 01425222 ឆ.៦៤ ERN 01425228។ ឯកសារ D219/981 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២២-ឆ.២៣ ERN 01477610។ ឯកសារ D219/982 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣៣ ERN 01477629។ ឯកសារ D219/983 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.២៩-ឆ.៣១ ERN 01477640-01477641 ឆ.៥៩ ERN 01477645។

ទីពីរ 'តាទិត្យ' ជាមេបញ្ជាការអនុសេនាធំ នៅក្រោមបញ្ជារបស់ភូមិភាគពាយ័ព្យ[659]។ ភ័ស្តុតាងរបស់ សៅ ជាប់ ពាក់ព័ន្ធការចោទប្រកាន់ ដែលស្ថិតក្រៅវិសាលភាពពេលវេលានៅកិច្ចស៊ើបអង្កេត ដែលដូច្នេះហើយចាំបាច់ត្រូវទុកមិនយកមកពិចារណា។

២២៤. នៅក្នុងការសម្រេចថា លោក យឹម ទិត្យ ចូលរួមចំណែកដល់ "ការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន" តាមរយៈការ "ពិនិត្យ" ការដ្ឋាននិងសហករណ៍ នៅក្នុងភូមិភាគពាយ័ព្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មានកំហុសឆ្គងក្នុងការសម្រេចផងដែរថា លោក យឹម ទិត្យ "ពិនិត្យ" ទៅលើការដ្ឋានកំពឹងពួយ នៅក្នុងឆ្នាំ១៩៧៧ (ដែលមិនត្រូវបានចោទប្រកាន់ ថាជាទីតាំងឧក្រិដ្ឋកម្ម)[660]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានទទួលការចោទប្រកាន់ពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅការដ្ឋានកំពឹងពួយទេ[661] ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏មិនបានចោទប្រកាន់លោក យឹម ទិត្យ ពីការចូលរួមរបស់គាត់នៅក្នុងហេតុការណ៍នៅការដ្ឋាននេះដែរ[662]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសន្និដ្ឋានថា លោក យឹម ទិត្យ "ពិនិត្យ" ការដ្ឋានកំពឹងពួយនៅក្នុងឆ្នាំ១៩៧៧ ដោយផ្អែកតែទៅលើភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម

---

ឯកសារ D219/984 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១១-ឆ.១២ ERN 01477654។ ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៣៤ ERN 01244122។

[659] ឯកសារ D219/763 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.៥៣-ឆ.៥៤ ERN 01244124។ ឯកសារ D219/956 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១៧, ឆ.២៧ ERN 01425219-01425221។ ឯកសារ D219/981 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ ជាប់ ឆ.១៨-ឆ.២៣ ERN 01477609-01477610។ សម្រាប់ការវិភាគលម្អិតទៅលើចម្លើយរបស់ សៅ ជាប់ សូមមើល ចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១០៧៧-១១២២។

[660] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤០១។

[661] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ឯកសារ D1។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D65។ ដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ឯកសារ D191។ ចម្លើយតបទៅនឹងដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៥ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពាក់ព័ន្ធនឹងវិសាលភាពនៃកិច្ចស៊ើបសួរទៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្នុងតំបន់ ១ និងតំបន់ ៤ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៥ ឯកសារ D272/1។

[662] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០៨៨-១០១៤។

ដែលចម្លើយរបស់គាត់ ពាក់ព័ន្ធនឹងហេតុការណ៍ ចាប់ពីដំណាច់ឆ្នាំ១៩៧៦[663] នៅពេលដែលគាត់អះអាងថា បានមើលខ្សែភាពយន្តរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបង្ហាញពីលោក យឹម ទិត្យ "ពិនិត្យ" អាងទឹករាមគុណ និងគម្រោងតំបន់៣ នៅអាងទឹកកំពឹងពួយ។ ហេតុការណ៍នេះស្ថិតក្រៅវិសាលភាពពេលវេលានៃការស៊ើបអង្កេត ហើយភ័ស្តុតាងរបស់សាក្សីរូបនេះចាំបាច់ត្រូវតែទុកមិនយកមកពិចារណា។

២២៥. លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាង ដែលផ្ទុយជាមួយនឹងភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម។ ជាការកត់សម្គាល់ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ធៀម របៀប ដែលធ្វើការនៅការដ្ឋានកំពឹងពួយ ហើយដែលបង្ហាញខ្លួននៅក្នុងខ្សែភាពយន្ត[664] បានបញ្ជាក់ថា គាត់មិនដែលឮ ឬឃើញលោក យឹម ទិត្យ ទៅពិនិត្យការដ្ឋានកំពឹងពួយឡើយ[665] កុំថាឡើយដល់បង្ហាញខ្លួននៅក្នុងខ្សែភាពយន្តនេះ។ សាក្សីពីររូបផ្សេងទៀត ដែលត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដកស្រង់ដើម្បីគាំទ្រដល់ភ័ស្តុតាងរបស់ ហ៊ុយ ក្រឹម[666] បានបញ្ជាក់ថា ពួកគាត់មិនដែលបានជួប ឬបានឮពីលោក យឹម ទិត្យ ទេ[667]។ ចម្លើយរបស់ ហ៊ុយ ក្រឹម ដែលថា ឈ្លបមិនស្គាល់ឈ្មោះ ដែលបង្ហាញគាត់នូវអត្ថបទមួយ នៅក្នុង "ទស្សនាវដ្តីកម្ពុជាប្រជាធិបតេយ្យ" ឆ្នាំ១៩៧៦ ដោយមានរូបថតរបស់លោក យឹម ទិត្យ នៅក្នុងអំឡុងពេលចុះពិនិត្យគម្រោងផ្លូវរថភ្លើង និងសំណង់ នៅក្នុងភូមិភាគពាយ័ព្យ[668] គ្មានការគាំទ្រនៅក្នុងសំណុំរឿងទេ។ ទស្សនាវដ្តីទាំង ៦១ ដែលមាននៅក្នុងសំណុំរឿង មិនមានទស្សនាវដ្តីណាមួយ ដែលលើកឡើងពី

---

[663] ដូចយោងខាងលើ កថាខណ្ឌ ៤០១ ជើងទំព័រ ១០៦០។

[664] ឯកសារ D219/914 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធៀម របៀប ឆ.២៥-ឆ.២៦, ឆ.៣៩-ឆ.៤៣ ERN 01388652-01388655។

[665] ឯកសារ D219/914 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ធៀម របៀប ឆ.៣៨ ERN 01388654។

[666] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤០១ ជើងទំព័រ ១០៦២។

[667] ឯកសារ D6.1.165 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ (យឹម ទិត្យ មិនត្រូវបានលើកឡើងនោះទេ)។ ឯកសារ D118/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម អាន់ ERN 00920193។ ឯកសារ D219/784 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុំ ក្រាត ឆ.៤៨ ERN 01300425។

[668] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤០១។

ឈ្មោះលោក យឹម ទិត្យ ឬមានរូបថតលោក យឹម ទិត្យ ឡើយ[669]។

[669] ឯកសារ D322/8.1.11 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៨ ខែសីហា ឆ្នាំ១៩៧៥។ ឯកសារ D6.1.737 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខ ៨ ខែសីហា ឆ្នាំ១៩៧៥ ឯកសារ D6.1.1132 យុវជន និងយុវនារីបដិវត្ត លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៥។ ឯកសារ D1.3.22.1 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ០១ ខែតុលា ឆ្នាំ១៩៧៥។ ឯកសារ D322/8.1.12 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៥។ ឯកសារ D6.1.746 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខពិសេស ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៥។ ឯកសារ D322/8.1.13 យុវជន និងយុវនារីបដិវត្ត លេខ ១២ ខែធ្នូ ឆ្នាំ១៩៧៥។ ឯកសារ D6.1.747 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ២ ខែកុម្ភៈ ឆ្នាំ១៩៧៦។ ឯកសារ D322/8.1.16 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៣ ខែមីនា ឆ្នាំ១៩៧៦។ ឯកសារ D6.1.749 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខ ២ និង ៣ ខែកុម្ភៈ ឆ្នាំ-ខែមីនា ឆ្នាំ១៩៧៦។ ឯកសារ D1.3.22.2 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខពិសេស ខែមេសា ឆ្នាំ១៩៧៦។ ឯកសារ D215/1.1.3 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា “កម្ពុជា” លេខ ៣ ខែមីនា ឆ្នាំ១៩៧៦។ ឯកសារ D215/1.1.6 ឯកសារ D215/1.1.4 ឯកសារ D61151 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា “កម្ពុជា” ខែមេសា ឆ្នាំ១៩៧៦។ ឯកសារ D6.1.750 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខ ៤ ខែមេសា ឆ្នាំ១៩៧៦ ឯកសារ D6.1.1133 យុវជន និងយុវនារីបដិវត្ត លេខ ៥ ខែឧសភា ឆ្នាំ១៩៧៦។ ឯកសារ D215/1.1.5 ឯកសារ D61152 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា “កម្ពុជា” ខែមិថុនា ឆ្នាំ១៩៧៦។ ឯកសារ D322/8.1.17, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៦ ខែមិថុនា ឆ្នាំ១៩៧៦។ ឯកសារ D6.1.751 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៦ ខែមិថុនា ឆ្នាំ១៩៧៦។ ឯកសារ D1.3.22.3, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៧ ខែកក្កដា ឆ្នាំ១៩៧៦។ ឯកសារ D6.1.100, “ទង់បដិវត្ត” លេខ ៧ ខែកក្កដា ឆ្នាំ១៩៧៦។ ឯកសារ D61153 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា “កម្ពុជា” ខែកក្កដា ឆ្នាំ១៩៧៦។ ឯកសារ D215/1.1.7 ឯកសារ D61154 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា “កម្ពុជា” ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ D322/8.1.19, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៨ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ D6.1.752, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខ ៨ ខែសីហា ឆ្នាំ១៩៧៦។ ឯកសារ D219/370.1.1, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ៩ ខែកញ្ញា ឆ្នាំ១៩៧៦។ ឯកសារ D6.1.748, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ១០ ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ D6.1.753, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខពិសេស ខែកញ្ញា-ខែតុលា ឆ្នាំ១៩៧៦។ ឯកសារ D322/8.1.20, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D6.1.754, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “ទង់បដិវត្ត” លេខ ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៦។ ឯកសារ D322/8.1.21, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ “យុវជន និងយុវនារីបដិវត្ត” លេខ ១២ ខែធ្នូ ឆ្នាំ១០៧៦។ ឯកសារ D6.1.755,

២២៦. ការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាអំពីភ័ស្តុតាងដោះបន្ទុក និងការប្រើប្រាស់ភ័ស្តុតាង នៅក្រៅវិសាលភាពនៃកិច្ចស៊ើបសួរ ដើម្បីសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់ការបង្កើត និងគ្រប់គ្រងសហការណ៍ និងការដ្ឋាន ដោយ "ត្រួតពិនិត្យ" ការដ្ឋាន

---

ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខពិសេស ខែធ្នូ ឆ្នាំ១៩៧៦-ខែមករា ឆ្នាំ១៩៧៧។ ឯកសារ D6.1.765 យុវជន និងយុវនារីបដិវត្ត លេខ ១-២ ខែមករា-ខែកុម្ភៈ ឆ្នាំ១៩៧៧។ ឯកសារ D322/8.1.22 យុវជន និងយុវនារីបដិវត្ត លេខ ៣ ខែមីនា ឆ្នាំ១៩៧៧។ ឯកសារ D215/1.1.8 ឯកសារ D61155 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា "កម្ពុជា" ការបោះពុម្ពពិសេស ខែមេសា ឆ្នាំ១៩៧៧។ ឯកសារ D322/8.1.23 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខពិសេស ខែមេសា ឆ្នាំ១៩៧៧។ ឯកសារ D322/8.1.24 យុវជន និងយុវនារីបដិវត្ត លេខ ៤ ខែមេសា ឆ្នាំ១៩៧៧។ ឯកសារ D215/1.1.9 ឯកសារ D61156 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា "កម្ពុជា" លេខ ១៤ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ D322/8.1.25 យុវជន និងយុវនារីបដិវត្ត លេខ ៥ ខែឧសភា ឆ្នាំ១៩៧៧។ ឯកសារ D1.3.6.1, ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខ ៦ ខែមិថុនា ឆ្នាំ១៩៧៧។ ឯកសារ D6.1.738 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត", លេខ ៧ ខែកក្កដា ឆ្នាំ១៩៧៧។ ឯកសារ D322/8.1.27 ទស្សនាវដ្ដីរូបភាពចេញផ្សាយរាល់ខែ លេខ ១៨ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ D6.1.766 យុវជន និងយុវនារីបដិវត្ត លេខ ៧-៨ ខែកក្កដា ឆ្នាំ-ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ D6.1.739 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧។ ឯកសារ D6.1.767 យុវជន និងយុវនារីបដិវត្ត លេខពិសេស ខែកញ្ញា ឆ្នាំ១៩៧៧។ ឯកសារ D6.1.740។ ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខពិសេស ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ឯកសារ D6.1.768 យុវជន និងយុវនារីបដិវត្ត លេខ ១០-១១ ខែតុលា-ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ឯកសារ D1.3.22.5 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខពិសេស ខែធ្នូ ឆ្នាំ១៩៧៧-ខែមករា ឆ្នាំ១៩៧៨។ ឯកសារ D215/1.1.10 ឯកសារ D61157 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា "កម្ពុជា" លេខ ២៤ ខែមករា ឆ្នាំ១៩៧៨។ ឯកសារ D6.1.1131 យុវជន និងយុវនារីបដិវត្ត លេខ ១-២ ខែមករា-ខែកុម្ភៈ ឆ្នាំ១៩៧៨។ ឯកសារ D6.1.741 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខ ២ ខែកុម្ភៈ ឆ្នាំ១៩៧៨។ ឯកសារ D215/1.1.11 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា "កម្ពុជា" លេខ ៣ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ D322/8.1.31 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខ ៣ ខែមីនា ឆ្នាំ១៩៧៨។ ឯកសារ D6.1.742 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខ ៤ ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ D6.1.769 យុវជន និងយុវនារីបដិវត្ត លេខ ៣-៤ ខែមីនា ឆ្នាំ-ខែមេសា ឆ្នាំ១៩៧៨។ ឯកសារ D1.3.22.6 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខពិសេស ខែឧសភា-ខែមិថុនា ឆ្នាំ១៩៧៨។ ឯកសារ D6.1.743 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខ ៧ ខែកក្កដា ឆ្នាំ១៩៧៨។ ឯកសារ D6.1.744 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត" លេខ ៨ ខែសីហា ឆ្នាំ១៩៧៧។ ឯកសារ D6.1.745 ទស្សនាវដ្ដីរបស់ ប.ក.ក មានចំណងជើងថា៖ "ទង់បដិវត្ត", លេខ ៩ ខែកញ្ញា ឆ្នាំ១៩៧៨។ ឯកសារ D219/370.1.1 យុវជន និងយុវនារីបដិវត្ត លេខ ១០ ខែតុលា ឆ្នាំ១៩៧៨។ ឯកសារ D322/8.1.35 យុវជន និងយុវនារីបដិវត្ត លេខ ១១ ខែវិច្ឆិកា ឆ្នាំ១៩៧៨។ ឯកសារ D215/1.1.12 ឯកសារ D61149 ទស្សនាវដ្ដីរបស់កម្ពុជាប្រជាធិបតេយ្យមានចំណងជើងថា "កម្ពុជា" លេខ ៣៩ ខែមេសា ឆ្នាំ១៩៧៩។

និងសហករណ៍ នៅក្នុងភូមិភាគពាយ័ព្យ មានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឱ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

*ក. ការចូលរួមចំណែក ក្នុងការបង្កើតនិងគ្រប់គ្រង សហករណ៍និងការដ្ឋាន - វត្តមាននៅកិច្ចប្រជុំ*

២២៧. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថាលោក យឹម ទិត្យ "ដឹកនាំការប្រជុំ និងវគ្គរៀនសូត្រនៅតាមការដ្ឋាននានា ថ្លែងសុន្ទរកថា និងការណែនាំ និងការបណ្តុះបណ្តាលដល់ កម្មាភិបាលថ្នាក់ក្រោមស្តីពី ការសាងសង់ និងការបង្កបង្កើនផល"[670] ចាប់ពីពាក់កណ្តាលឆ្នាំ ១៩៧៦ និង "ជំរុញការអនុវត្តគោលនយោបាយ សេដ្ឋកិច្ច ប.ក.ក"[671]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាអំពីភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុក របស់សាក្សីដែលគាត់បានដកស្រង់ ដើម្បីគាំទ្រការសន្និដ្ឋាននេះ៖

- លេខ ភីវ មិនដែលបានកំណត់អត្តសញ្ញាណលោក យឹម ទិត្យ ដោយត្រឹមត្រូវទេ។ គាត់មិនច្បាស់អំពីតួនាទីរបស់ 'តាទិត្យ'[672] ហើយគាត់មានវត្តមាននៅកិច្ចប្រជុំជាមួយ 'តាទិត្យ' ក្រោយរដូវវស្សា នាឆ្នាំ១៩៧៨[673]។

- ភ័ស្តុតាងរបស់ ដុស ដឿន ពាក់ព័ន្ធមនុស្សម្នាក់ឈ្មោះ 'តាទិត្យ' ដែលជាកម្មាភិបាលភូមិភាគពាយ័ព្យ ទទួលបន្ទុកឃុំកន្ទឺមួយ ក្នុងស្រុកបាណន់[674]។

- ជុច ពន្លក បានបញ្ជាក់ថា 'តាទិត្យ' ដែលគាត់ស្គាល់ "ធ្វើការដូចគេឯងដែរ" ធ្វើការជាមួយប្រជាជនសាមញ្ញ[675] ហើយ "មិនមែនជាមេដឹកនាំអ្វីទេ"[676]។

[670] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤០២-៤០៤។

[671] ដូចយោងខាងលើ កថាខណ្ឌ ៤០៥។

[672] ឯកសារ D219/236 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ឆ.១៨ ERN 01080844។

[673] ឯកសារ D219/210 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លេខ ភីវ ឆ.៥-ឆ.៦ ERN 01074048។ សម្រាប់ការវិភាគលម្អិត ទៅលើចម្លើយរបស់ លេខ ពីវ សូមមើល ចម្លើយតបរួមទៅនឹងដីកាសន្និដ្ឋានស្ថាពរ កថាខណ្ឌ ១២៦៤-១២៧៣។

[674] ឯកសារ D219/797 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុស ឌឿន ឆ.២០០-ឆ.២១៤ ERN 01305016-01305017 ។

[675] ឯកសារ D22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ERN 00699634-00699635។

- ទៀប ទិត្យ អះអាងថាបានចូលរួមការប្រជុំមួយដែល 'តាទិត្យ'មានវត្តមាន នៅមុនពេលដែលគាត់ត្រូវបានចាប់ខ្លួន[677] នៅក្នុងខែមករា ឬខែកុម្ភៈ ឆ្នាំ១៩៧៨[678] ហើយគាត់មិនបានកំណត់ អត្តសញ្ញាណលោក យឹម ទិត្យ ដោយត្រឹមត្រូវឡើយ[679]។ គាត់ក៏បានបញ្ជាក់ថា គាត់មិនប្រាកដថាតើ 'តាទិត្យ' មកពីនិរតី ឬអត់ទេ[680] ហើយថា ឡើងកាន់អំណាចក្រោយតាវ៉ាញត្រូវបានចាប់ខ្លួន[681]។ ដោយពិចារណាទៅលើភ័ស្តុតាងនេះ និងអង្គហេតុដែលថា តាប៉ែត ជំនួសតាវ៉ាញ ក្រោយពេលដែលគាត់ត្រូវបានចាប់ខ្លួន[682] សាក្សីនេះប្រហែលជាច្រឡំ 'តាទិត្យ' ជាមួយតាប៉ែត។

*ខ. ការចូលរួមចំណែកក្នុងការបង្កើត និងគ្រប់គ្រងសហការណ៍ និងការដ្ឋាន- ការអនុវត្តវិន័យតឹងតែ ទៅលើកម្មករ ជាពិសេសនៅទំនប់កង្ហត*

២២៨. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ "បានចូលរួមចំណែក ក្នុងការជំរុញការអនុវត្តវិន័យតឹងតែងសម្រាប់កម្មករ ជាពិសេសនៅទំនប់កង្ហត"[683]។ ក្នុងការសម្រេចបែបនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តែមួយរូបប៉ុណ្ណោះ គឺឈ្មោះ សោម វណ្ណា ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយ និងភ័ស្តុតាងដោះបន្ទុក របស់សាក្សីរូបនេះឡើយ។ សោម វណ្ណា បានបញ្ជាក់ថា គាត់ធ្វើការនៅទំនប់កង្ហត[684] ធ្លាប់បានឮឈ្មោះ 'តាទិត្យ'

---

[676] ឯកសារ D22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុច ពន្លក ERN 00699634-00699635។

[677] ឯកសារ D219/464 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.៣៤ ERN 01132055។

[678] ឯកសារ D219/464 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.៤២-ឆ.៤៣ ERN 01132056។

[679] គាត់បានកំណត់អត្តសញ្ញាណតាទិត្យថា មានមាឌធំ ខ្ពស់ និងសម្បុរខ្មៅ ឯកសារ D118/138 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.៣៥ ERN 00960693។ ឯកសារ D219/464 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.៣៣ ERN 01132055។

[680] ឯកសារ D219/464 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.៣៧ ERN 01132055។

[681] ឯកសារ D219/464 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទៀប ទិត្យ ឆ.៣៩-ឆ.៤០ ERN 01132056។

[682] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៥៣។

[683] ដូចយោងខាងលើ កថាខណ្ឌ ៤០៦។

[684] ឯកសារ D219/46 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.២៥ ERN 01032222។

ប៉ុន្តែមិនដែលធ្លាប់ឃើញគាត់[685] មិនដឹងអំពីតួនាទីរបស់គាត់ដែរ[686] និងមិនដែលឃើញ 'តាទិត្យ' ចូលរួមក្នុងកិច្ចប្រជុំនៅទំនប់កង្ហត[687] ហើយ 'តាទិត្យ' មិនដែលមកការដ្ឋានគាត់ឡើយ[688]។ មិនមានអត្ថិភាពភ័ស្តុតាងផ្សេងទៀតឡើយ នៅក្នុងសំណុំរឿង ដែលអះអាងពីការចូលរួមរបស់លោក យឹម ទិត្យ នៅក្នុងការអនុវត្តវិន័យចំពោះកម្មការ នៅការដ្ឋាននានា ក្នុងភូមិភាគពាយ័ព្យ។

២២៩. ផ្ទុយពីការសម្រេចរបស់គាត់អំពីការចោទប្រកាន់ពីការចូលរួមរបស់លោក យឹម ទិត្យ នៅក្នុងការបង្កើត និងគ្រប់គ្រងការដ្ឋាននិងសហករណ៍ នៅភូមិភាគពាយ័ព្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា លោក យឹម ទិត្យ មិនមានវត្តមាននៅសហករណ៍ធិបតី[689] រោងចក្រស្កុសកំពង់កុល[690] ឬនៅឃុំកំពង់ព្រីង និងរាំងកេសី[691] គឺនៅសហករណ៍និងការដ្ឋានបី ក្នុងចំណោមទីតាំងបួន ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានធ្វើការស៊ើបអង្កេត។ មិនមានភ័ស្តុតាងនៅក្នុងសំណុំរឿង ដែលអះអាងអំពីការចូលរួមចំណែករបស់លោក យឹម ទិត្យ នៅក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ធិបតី រោងចក្រស្កុសកំពង់កុល ឬនៅឃុំកំពង់ព្រីង និងរាំងកេសីឡើយ។

២៣០. លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភ័ស្តុតាង ឬពិចារណាអំពីធាតុផ្សំអត្តនោម័តរបស់លោក យឹម ទិត្យ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៃការដាក់ក្នុងមន្ទីរឃុំឃាំង ការដាក់ឲ្យទៅជាទាសករ និងអំពើអមនុស្សធម៌ដទៃទៀត[692]។

២៣១. ផ្អែកលើភ័ស្តុតាងនេះ មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់

---

[685] ឯកសារ D219/46 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៣៨-ឆ.៤០ ERN 01032223។

[686] ឯកសារ D219/46 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៤១ ERN 01032223។

[687] ឯកសារ D219/46 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៣១-ឆ.៣៧, ឆ.៤៧ ERN 01032222-01032224។

[688] ឯកសារ D219/46 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សោម វណ្ណា ឆ.៤២ ERN 01032223។

[689] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៦០២-៦១៦។

[690] ដូចយោងខាងលើ កថាខណ្ឌ ៧៤៦។

[691] ដូចយោងខាងលើ កថាខណ្ឌ ៩២០។

[692] ដូចយោងខាងលើ កថាខណ្ឌ ១១២។

ការសម្រេចថា លោក យឹម ទិត្យ បានចូលរួមយ៉ាងចម្បងនៅក្នុងការបង្កើត និងគ្រប់គ្រងសហករណ៍ និងការដ្ឋាន នៅក្នុងភូមិភាគពាយ័ព្យ[693] ចាប់ពី "ដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"[694]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឲ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

*គ. ការបោសសម្អាតភូមិភាគពាយ័ព្យ និងការកំណត់គោលដៅលើក្រុមជាក់លាក់*

២៣២. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា កម្មាភិបាលភូមិភាគនិរតី ត្រូវបានជ្រើសរើស និងបញ្ជូនទៅតាមបញ្ជារបស់ "តាម៉ុក និងយឹមទិត្យ" ចន្លោះពីឆ្នាំ១៩៧៦ ដល់ឆ្នាំ១៩៧៨[695] ដើម្បីត្រួតត្រាភូមិភាគពាយ័ព្យ និងបោសសម្អាតដែលរៀបចំឡើយដោយ "តាម៉ុក និង យឹម ទិត្យ" ក្នុងអំឡុងឆ្នាំ១៩៧៦ រហូតដល់ពេលដួលរលំកម្ពុជាប្រជាធិបតេយ្យ នៅក្នុងខែមករា ឆ្នាំ១៩៧៩[696]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថា ការសម្រេចរបស់គាត់មួយណាដែលទាក់ទងជាមួយនឹង តាម៉ុក និងមួយណាទាក់ទងជាមួយនឹងលោក យឹម ទិត្យ។

២៣៣. ភស្តុតាងជាឯកសារ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ដើម្បីគាំទ្រដល់ការសម្រេចនេះ មិនបានលើកឡើងអំពីលោក យឹម ទិត្យ ឡើយ[697]។

២៣៤. ក្នុងចំណោមសាក្សីទាំង ៤១ រូប ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ធ្វើជាមូលដ្ឋានភស្តុតាងសម្រាប់ការសម្រេចនេះ[698] សាក្សី ១៦ រូបបានបញ្ជាក់ថា គាត់មិនដែលឮឈ្មោះលោក យឹម ទិត្យ ឬ 'តាទិត្យ' ទេ[699] ហើយសាក្សី ២៦ រូបទៀត មិនបានផ្តល់ភស្តុតាង

---

[693] ដូចយោងខាងលើ កថាខណ្ឌ ៩៩៧, ១០២១។

[694] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(i)។

[695] ដូចយោងខាងលើ កថាខណ្ឌ ២៩៥-២៩៩។

[696] ដូចយោងខាងលើ កថាខណ្ឌ ៤១៣-៤២៦។

[697] ដូចយោងខាងលើ កថាខណ្ឌ ២៩៥។

[698] ដូចយោងខាងលើ កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៤៣, កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៨៤ និងកថាខណ្ឌ ៤១២ ជើងទំព័រ ១០៨៦។

[699] ឯកសារ D118/84 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គួច ភឿន ឆ.១៩ ERN 00945399។ ឯកសារ D118/221 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ផាន់ យឹម ឆ.១២៩ ERN 00982503។ ឯកសារ D219/140 កំណត់ហេតុនៃការ

## ទាក់ទងនឹងការចោទប្រកាន់ពីការចូលរួមរបស់លោក យឹម ទិត្យ នៅក្នុងការបោសសម្អាត[700]។

---

ស្តាប់ចម្លើយសាក្សី យក់ នាម ឆ.១៨៧ ERN 01056096។ ឯកសារ D118/170 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក សំអាត ហៅ រឹម ឆ.១៣២, ឆ.១៣៣, ឆ.១៣៧ ERN 00969598។ ឯកសារ D219/861 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក សំអាត ហៅ រឹម ឆ.២៨ ERN 01347266 ឆ.១១២, ឆ.១១៥, ឆ.១១៦, ឆ.១២៤ ERN 01347280-01347282។ ឯកសារ D219/869 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សេក សំអាត ហៅ យាយរឹម ឆ.៤៤, ឆ.៤៥, ឆ.៤៧, ឆ.៤៩ ERN 01348863-01348864។ ឯកសារ D219/138 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់ ឆ.៣៨ ERN 01056047។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៤៤៖ ឯកសារ D118/294 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡាយ អេង ឆ.១១-ឆ.១២ ERN 01023825។ ឯកសារ D219/50 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ុយ ចិន្តា ឆ.១៦៦-ឆ.១៦៧ ERN 01032630។ ឯកសារ D118/264 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខែម សុខ ឆ.៥៣ ERN 00997972។ ឯកសារ D219/57 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ រុន ឆ.៥០-ឆ.៥១ ERN 01034501។ ឯកសារ D119/94 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៊ូ ម៉ៅ ឆ.២៤ ERN 00976177។ ឯកសារ D219/125 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ស្រី សឿម ឆ.៧៨-ឆ.៧៩ ERN 01047389។ ឯកសារ D219/345 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី នឹម លន ឆ.៣៣ ERN 01102919។ ឯកសារ D219/300 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិម ប៊ុនឈឿន ឆ.១៦ ERN 01096524។ ឯកសារ D219/310 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី វ័ន្ត សាមុត ឆ.២៤ ERN 01097684។ ឯកសារ D134/3 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាត ឆាង ឆ.៤០ ERN 00947332។ ឯកសារ D119/109 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សួន ឡូវ ឆ.៧៨ ERN 00980138។ សូមមើល ឧបសម្ព័ន្ធ ក៖ សាក្សីដែលមិនធ្លាប់ឮពីឈ្មោះតាទិត្យ។

[700] ឯកសារ D119/124 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ឆ.២៩-ឆ.៣១ ERN 00987270។ ឯកសារ D219/66 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គង់ ឆោម ឆ.៤៣-ឆ.៤៨, ឆ.៥២-ឆ.៥៩ ERN 01037203-01037204។ ឯកសារ D118/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹក លី ឆ.១០-ឆ.១១ ERN 00945419។ ឯកសារ D6.1.132 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ិន សា ERN 00242225-00242226។ ឯកសារ D118/249 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ឆ.៧៣ ERN 00990867។ ឯកសារ D219/37 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សួន មុត ឆ.៧៦ ERN 01032110។ ឯកសារ D6.1.730 ឯកសារ D127/2.1.10 ឯកសារ D127/2.1.11 ឯកសារ D117/70 ឯកសារ D117/71 ឯកសារ D117/72 ឯកសារ D219/234.1.2 ឯកសារ D117/73 ឯកសារ D219/120 ឯកសារ D219/702.1.94 ឯកសារ D219/702.1.95 ឯកសារ D347/2.1.27 ឯកសារ D219/792.1.2 ឯកសារ D347/2.1.28 ឯកសារ D219/792.1.3 ឯកសារ D219/971 កំណត់ហេតុស្តាប់ចម្លើយ និងប្រតិចារឹក ប្រាក់ យុត។ ឯកសារ D219/847.1 កំណត់ហេតុស្តាប់ចម្លើយ អោ អាន។ ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.៣២-ឆ.៣៣ ERN 01037142។ ឯកសារ D118/259 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម ឆ.៤៧-ឆ.៥០, ឆ.៥៤-ឆ.៥៧ ERN 00997029-00997030 ឆ.១៤២, ឆ.១៤៨-ឆ.១៥០ ERN 00997042 ឆ.២៨០-ឆ.២៨២ ERN 00997059។ ឯកសារ D119/124 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម អេន ឆ.២៦-ឆ.២៧ ERN 00987269-

២៣៥. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ "ចាត់តាំងកម្មាភិបាលភូមិភាគនិរតីមួយចំនួនតូច ឲ្យទៅបំពេញការងារជាមួយកម្មាភិបាលភូមិភាគពាយ័ព្យ" នៅក្នុងឆ្នាំ១៩៧៦[701]។ សាក្សីទាំង ១៧ រូប ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់មក មិនបានគាំទ្រដល់ការសម្រេចនេះទេ[702]។ សាក្សីប្រាំមួយរូបមិនដែលឮលោក យឹម ទិត្យ ឬ

---

00987270។ ឯកសារ D118/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ជឿន ឆ.២៧ ERN 00945407។ ឯកសារ D118/150 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហែម មឿន ឆ.១០ ERN 00967996 ឆ.២៣-ឆ.២៥ ERN 00967998 ឆ.៧២-ឆ.៧៤ ERN 00967005។ ឯកសារ D219/900 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មូល អេង ឆ.៥៧-ឆ.៥៩ ERN 01379792។ ឯកសារ D219/19 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សាន់ ឡុន ឆ.៧៥៥, ឆ.៧៥៩ ERN 01029210 ឆ.៧៧៤ ERN 01029211។ ឯកសារ D118/96 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឡុច អេង ឆ.៤, ឆ.៦-ឆ.៩, ឆ.១១-ឆ.១៣, ឆ.១៧-ឆ.២០, ERN 00947288-00947290។ ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តុប សឿង ឆ.១៥, ឆ.២៤, ឆ.២៧, ឆ.៣២-ឆ.៣៤, ឆ.៣៦, ឆ.៣៩-ឆ.៤៣, ឆ.៥៤-ឆ.៥៧ ERN 01046461-01046465 ឆ.១៣១-ឆ.១៣២, ឆ.១៣៤ ERN 01046473។ ឯកសារ D6.1.1063 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN 00187667-00187668។ ឯកសារ D1.3.29.2 កំណត់ហេតុនៃការសួរចម្លើយ កាំង ហ្កេកអ៊ាវ ហៅ ឌុច ERN 00146678-00146679។ ឯកសារ D6.1.873 ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០០៩ ERN 00406936 បន្ទាត់ ១៩-២១។ ឯកសារ D219/85.1.3 ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២/០១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៦ EN 01319813-01319814។ ឯកសារ D6.1.866 ប្រតិចារឹកសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៩ ERN 00344070 បន្ទាត់ ៧-១៣។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៤៤៖ ឯកសារ D219/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.៣៤-ឆ.៣៥ ERN 01037176-01037177 ឆ.៦៤ ERN 01037180។ ឯកសារ D118/75 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហ៊ុយ ក្រឹម ឆ.៤១ ERN 00934371។ ឯកសារ D118/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ ភើយ ឆ.៣២-ឆ.៣៣ ERN 00882722-00882723។ ឯកសារ D219/175 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហង់ ហោន ឆ.១៩, ឆ.២៨ ERN 01065999-01066001។ ឯកសារ D219/689 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សុខ ជាតិ ឆ.១០៥-ឆ.១០៦ ERN 01205223-01205224។ ឯកសារ D219/586 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យុន ម៉ុន ឆ.៧៥-ឆ.៧៦ ERN 01167502។ ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត ឆ.២៥ ERN 01155824។ ឯកសារ D219/589 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចឹម ប៊ុនរ៉េត ឆ.១២០-ឆ.១២១ ERN 01167608។

[701] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ២៩៨។

[702] ដូចយោងខាងលើ កថាខណ្ឌ ២៩៨ ជើងទំព័រ ៧៥២។

'តាទិត្យ' [703] សាក្សីមួយរូបមិនបានលើកឡើងសោះអំពីឈ្មោះលោក យឹម ទិត្យ នៅក្នុងភ័ស្តុតាងរបស់គាត់[704] សាក្សីបួនរូបមិនបានលើកឡើងពីឈ្មោះលោក យឹម ទិត្យ នៅក្នុងបរិបទនៃហេតុការណ៍ ក្នុងឆ្នាំ១៩៧៦[705] ហើយភ័ស្តុតាងរបស់សាក្សីប្រាំមួយរូប ទាក់ទងជាមួយនឹងឆមាសទីពីរនៃឆ្នាំ១៩៧៨[706]។

២៣៦. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការសម្រេចថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ លោក យឹម ទិត្យ បានស្វាគមន៍កម្មាភិបាលភូមិភាគនិរតី នៅពេលដែលពួកគេមកដល់បាត់ដំបង ហើយចាត់តាំងពួកគេទៅជំនួសកម្មាភិបាល នៅតាមទីកន្លែងផ្សេងៗជាច្រើន នៅក្នុងភូមិភាគពាយ័ព្យ[707]។ មិនមានសាក្សីរូបណាដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានដកស្រង់ បានគាំ

---

[703] ឯកសារ D118/250 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី មុត វើក កំណត់សម្គាល់នៅ ERN 00992420។ ឯកសារ D219/36 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈួម សារ៉ើន ឆ.៣២ ERN 01032096។ ឯកសារ D118/107 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សែត ឌុន ឆ. ២៣ ERN 00951918។ ឯកសារ D219/20 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឈុំ វ៉ាន់នី ឆ.៦៧ ERN 01029498។ ឯកសារ D219/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជាម ញ៉ ឆ.២៧-ឆ.២៨ ERN 01025483។ ឯកសារ D219/142 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សារុន ឆ.៥៣ KH01056122។

[704] ឯកសារ D119/69 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ក្រូច ទឹម ឆ.២៨-ឆ.៣០, ឆ.៣៣-ឆ.៣៤, ឆ.៣៦ ERN 00969030-00969031។

[705] ឯកសារ D118/106 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ជឿម ឆ.១២ ERN 00951904 ឆ.៣៦, ឆ.៣៩ ERN 00951907-00951908។ ឯកសារ D118/87 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទេព សៀន ឆ.៤៩ ERN 00945432។ ឯកសារ D219/538 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សឿន ម៉ត ឆ.៣៦ ERN 01155826 ឆ.៤០ ERN 01155827 ឆ.៩៦ ERN 01155835។ ឯកសារ D119/65 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទុំ សឿន ឆ.៣០-ឆ.៣៣ ERN 00953023 ឆ.៤០-ឆ.៤១ ERN 00953024 ឆ.៤៧-ឆ.៤៨, ឆ.៥៣-ឆ.៥៤ ERN 00953025-00953026 ឆ.៦០, ឆ.៦២ ERN 00953027 ឆ.៦៥ ERN 00953028 ឆ.៧៨-ឆ.៧៩ ERN 00953030។

[706] ឯកសារ D118/85 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជា ជឿន ឆ.២៧, ឆ.៣០ ERN 00945407។ ឯកសារ D219/551 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហេង ឃ្លី ឆ.៦១-ឆ.៦២ ERN 01157597 ឆ.១៥៦-ឆ.១៦២ ERN 01157609-01157610។ ឯកសារ D118/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ិក លី ឆ.១៣ ERN 00945419 ឆ.២៣-ឆ.២៤ ERN 00945421។ ឯកសារ D219/430 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឿង ប៉ាន ឆ.៩៩ ERN 01122414 ឆ.១២៨ ERN 01122420។ ឯកសារ D219/117 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី គុប សឹង ឆ.៦៧-ឆ.៧២ ERN 01046466។ ឯកសារ D219/953 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឈឹង ឈឿត ឆ.៥៥-ឆ.៥៦ ERN 01425173។

[707] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ២៩៩។

ទ្រដល់ការសម្រេចនេះទេ[708]។

- យឹម គួញ មកដល់បាត់ដំបងនៅចុងឆ្នាំ១៩៧៨[709]។

- ព្រាប កប ដែលជាជនពិការភ្នែកនៅពេលនោះ[710] មិនដែលបានឃើញ ឬឮអំពី 'តាទិត្យ' ទេ[711] នៅមុនពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨ នៅពេលដែលប្រពន្ធរបស់គាត់បានប្រាប់គាត់ថា 'តាទិត្យ' ចូលរួមពិធីរៀបអាពាហ៍ពិពាហ៍ពួកគាត់[712]។

- ណុប ងឹម មកភូមិភាគពាយ័ព្យនៅក្នុងខែមិថុនា ឆ្នាំ១៩៧៨ ហើយបីខែក្រោយមក គាត់រៀបការជាមួយ ព្រាប កប នៅថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៨[713]។

- ពៅ គឿន គឺជាកងទ័ពភូមិភាគពាយ័ព្យ ដែលឈរជើងនៅអូរតាក្រី ពីឆ្នាំ១៩៧៥ ដល់ចុងឆ្នាំ១៩៧៧[714] ហើយគាត់រត់គេចទៅធ្វើការនៅ ចំការកប្បាសនៅភ្នំដីប៉ាង រហូតដល់វៀតណាមចូលមកដល់[715]។ គាត់មិនស្គាល់មេដឹកនាំណាមួយ ដែលគ្រប់គ្រងតំបន់និងភូមិភាគឡើយ[716] ហើយគាត់មិនដែលជួប 'តាទិត្យ' ទេគឺគ្រាន់តែឮឈ្មោះគាត់ [717] ហើយមិនដឹងថានរណាជា

---

[708] ដូចយោងខាងលើ កថាខណ្ឌ ២៩៩ ជើងទំព័រ ៥៧៨។

[709] ឯកសារ D219/904 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យឹម គួញ ឆ.៤៧ ERN 0138133។

[710] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.១៧ ERN 01037139។

[711] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.២៩-ឆ.៣០ ERN 01037141 ឆ.៧២ ERN 01037148។

[712] ឯកសារ D219/62 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ព្រាប កប ឆ.២៩ ERN 01037141 ឆ.៥០-ឆ.៥១ ERN 01037145។

[713] ឯកសារ D123/2/2.17a បទសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ណុប ងឹម ERN 00733829។ ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ងឹម ឆ.៦៨ ERN 01008708។

[714] ឯកសារ D219/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.៥១-ឆ.៥៣ ERN 01037179។ ឯកសារ D219/682 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.១១-ឆ.១៣ ERN 01203899។

[715] ឯកសារ D219/682 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.១៩ ERN 01203900 ឆ.៤៤-ឆ.៤៧ ERN 01203905-01203906។ ឯកសារ D219/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.៨-ឆ.១៣ ERN 01037173។

[716] ឯកសារ D219/682 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.១៧-ឆ.១៩ ERN 01203900។

[717] ឯកសារ D219/64 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.៣១ ERN 01037176។

មេដឹកនាំ ភូមិភាគពាយ័ព្យទេ នៅពេលដែលកម្មាភិបាលភូមិភាគនិរតីមកដល់[718]។

២៣៧. មិនមានសាក្សីណាម្នាក់បានបញ្ជាក់ថា លោក យឹម ទិត្យ ឬ 'តាទិត្យ' បានចាត់តាំងពួកគេឲ្យទៅជំនួស កម្មាភិបាលភូមិភាគពាយ័ព្យ។

២៣៨. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេច ដោយផ្អែកលើភ័ស្តុតាងរបស់សាក្សីតែមួយរូប ដែលថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ លោក យឹម ទិត្យ បានចូលរួមក្នុងការចាប់ខ្លួនប្រធានកងវរសេនាតូចពីររូប ដែលគ្មានអាវុធក្នុងដៃ ហើយដែលគ្រប់គ្រងលើរោងចក្រស្កសកំពង់កុល[719]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងរបស់ឈ្មោះ ហួន ជឿម ដែលពាក់ព័ន្ធនឹងការសម្រេចនេះ ហើយដែលផ្ទុយនឹងភ័ស្តុតាង ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែក។ ហួន ជឿម មិនដែលធ្លាប់ធ្វើការនៅរោងចក្រស្កសកំពង់កុល មិនធ្លាប់ឃើញ 'តាទិត្យ' ដោយផ្ទាល់[720] និងមិនដែលឮពីហេតុការណ៍ណាទាក់ទងនឹង 'តាទិត្យ'[721] ទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិក៏មិនបានពិចារណាថា សាក្សីនេះបានផ្តល់ចម្លើយចំនួន ៩០ ទំព័រ ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៦ ដែលក្នុងចម្លើយទាំងនោះ គាត់មិនបានលើកឡើងពី 'តាទិត្យ' ទេ ប៉ុន្តែនៅប្រាំបីឆ្នាំក្រោយ គឺនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ ២០១៣ ក្រោយពេលដែលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ត្រូវបានបញ្ចេញជាសាធារណៈ ដោយខុសច្បាប់នោះ ហួន ជឿម ដែលនៅ ៣៥ឆ្នាំ បន្ទាប់ពីបញ្ចប់របបកម្ពុជាប្រជាធិបតេយ្យ បែបជាចងចាំភ្លាមៗថា គាត់ធ្លាប់ឮអំពី 'តាទិត្យ'។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាអំពីការមិនមានភ័ស្តុតាងគួរឲ្យជឿទុកចិត្តបានដែលថា លោក យឹម ទិត្យ ធ្លាប់ទៅពិនិត្យរោងចក្រស្កស ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់នៅចំណុចផ្សេងក្នុងដីកាដំណោះស្រាយ[722] ហើយដែលថា ភ័ស្តុតាងរបស់សាក្សីរូបនេះគឺជាពាក្យចចាមអារាមគ្មានការគាំទ្រ និងអនាមិក។

---

[718] ឯកសារ D219/682 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ គឿន ឆ.១៧ ERN 01203900។

[719] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤១៨។

[720] ឯកសារ D118/106 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ជឿម ឆ.១២ ERN 00951904។

[721] ឯកសារ D118/106 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហួន ជឿម ឆ.១៩ ERN 00951905។

[722] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៧៤៦។

២៣៩. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញភ័ស្តុតាង និងមិនពិចារណាអំពីធាតុផ្សំអត្តនោម័តរបស់លោក យឹម ទិត្យ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃការដាក់ក្នុងមន្ទីរឃុំឃាំង អំពើមនុស្សឃាត ការសម្លាប់រង្គាល និងអំពើអមនុស្សធម៌ដទៃទៀត[723]។

២៤០. មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា ដោយផ្អែកលើភ័ស្តុតាងនេះ លោក យឹម ទិត្យ បានគាំទ្រ និងបានចូលរួមចំណែកដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា លើការអប់រំរៀនសូត្រ "សមាសធាតុមិនល្អ" និងការសម្លាប់ខ្មាំង និង "សមាសធាតុមិនល្អ" ទាំងក្នុង និងក្រៅជួរបក្សកុម្មុយនីស្តកម្ពុជា[724] ចាប់ពី "ដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩"[725]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឱ្យមានការរំលោភបំពាន ទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

*ឃ. ការគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍*

២៤១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេច ដោយផ្អែកលើភ័ស្តុតាងរបស់សាក្សីពីររូប[726] ដែលថា ក្នុងនាមជាផ្នែកមួយនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ ជាលេខាតំបន់១ និងតំបន់៤ និងដោយសារ "វត្តមាន" របស់គាត់ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍មួយ[727]ដែលធ្វើឡើងនៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨[728] លោក យឹម ទិត្យ បានគាំទ្រ[729] និងចូលរួមចំណែកដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការគ្រប់គ្រងទៅលើ ការរៀបអាពាហ៍ពិពាហ៍[730] ចាប់

---

[723] ដូចយោងខាងលើ កថាខណ្ឌ ១១២។

[724] ដូចយោងខាងលើ កថាខណ្ឌ ៩៩៧, ១០២២។

[725] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(i)។

[726] ណុប ធីម និង ព្រាប កប។

[727] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១៤។

[728] ឯកសារ D118/285 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ឆ.៦៨, ឆ.៧៣ ERN 01009708។ ឯកសារ D219/835 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ណុប ធីម ឆ.១៤៩ ERN 01329405។

[729] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣១៤។

[730] ដូចយោងខាងលើ កថាខណ្ឌ ៤២៧។

ពី “ដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩”[731]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបង្ហាញភ័ស្តុតាង និងមិនបានពិចារណាទៅលើធាតុផ្សំអត្តនោម័តិរបស់លោក យឹម ទិត្យ ក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មប្រឆាំងមនុស្ស នៃការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍[732] ហើយភ័ស្តុតាងបែបនេះ មិនមាននៅក្នុងសំណុំរឿងទេ។

២៤២. បើទោះបីជាសន្មត ដើម្បីតែជាការលើកទឡ្ហីករណ៍ក្តី (*arguendo*) ថា លោក យឹម ទិត្យ គឺជាផ្នែកមួយនៃគណៈកម្មាធិការភូមិភាគពាយ័ព្យ និងជាលេខាតំបន់១ និងតំបន់៤ នៅក្នុងឆមាសទីពីរឆ្នាំ១៩៧៨[733] ដែលគាត់មិនមែននោះ[734] ក្តី ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើត្រឹមតែវត្តមានរបស់លោក យឹម ទិត្យ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍តែមួយ នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ អាចកំណត់ថាជា “ការចូលរួមចំណែកយ៉ាងចម្បង” ចំពោះគោលនយោបាយគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍ ដែលតម្រូវដោយច្បាប់ស្តីពីសហឧក្រិដ្ឋកម្ម[735]។

២៤៣. មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា ដោយផ្អែកលើភ័ស្តុតាងនេះ លោក យឹម ទិត្យ បានគាំទ្រ និងបានចូលរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍[736] ចាប់ពី “ដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩”[737]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឲ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

### (ii) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម ខ

[731] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(i)។

[732] ដូចយោងខាងលើ កថាខណ្ឌ ១១២។

[733] ដូចយោងខាងលើ កថាខណ្ឌ ៣៨០-៣៨២, ៩៩៤, ៣៦០-៣៧១, ៩៩៣, ៣៧៧។

[734] ខាងលើ កថាខណ្ឌ ១៦៤-១៨៨, ១៩៨-២១៥។

[735] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១១០។

[736] ដូចយោងខាងលើ កថាខណ្ឌ ៩៩៨, ១០២៤។

[737] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(i)។

២៨៤. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្លាប់រង្គាលខ្មែរក្រោម "មិនក្រោយពេលដែលគាត់បានចូលកាន់តំណែងជាច្រើន នៅក្នុងគណៈតំបន់ ១៣ ក្នុងពេលណាមួយក្នុងឆ្នាំ១៩៧៦" រហូតដល់ពេលបញ្ចប់របប[738]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនត្រឹមត្រូវទេ។

២៨៥. ដូចដែលបានលើកឡើងពីខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញពីការរៀបរាប់អង្គហេតុសំខាន់ និងការកំណត់ប្រភេទនៃបទល្មើស ដែលជាមូលដ្ឋាននៃការសម្រេចថា លោក យឹម ទិត្យ ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍[739]។

២៨៦. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើ ការចោទប្រកាន់ដូចខាងក្រោម[740] បើទោះបីជាមានភ័ស្តុតាងបង្ហាញថាពិតជាបានកើតឡើងក្តី (ដែលមិនបានកើតឡើងនោះទេ) អាចបង្កើតបានជា "ការចូលរួមចំណែកយ៉ាងសំខាន់" ដោយរបៀបណា ចំពោះការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម៖

- "សេចក្តីថ្លែងថ្កោលទោស" របស់លោក យឹម ទិត្យ[741]។
- ការចោទប្រកាន់ពី "ការស្អប់ខ្ពើមខ្លាំងក្លាចំពោះប្រជាជនវៀតណាម" របស់លោក យឹម ទិត្យ[742]។
- ការព្រមានរបស់គាត់ (មិនមែនការគំរាមកំហែង) ចំពោះនរណាដែល "វត់ចូលយួន"[743]។
- ការចោទពី *វត្តមាន* របស់គាត់នៅក្នុងការប្រជុំដែលអ្នកមានទំនាក់ទំនងជាមួយវៀតណាម

---

[738] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(ii), ១០១៧(ii), ១០១៨, ១០២២។

[739] ខាងលើ កថាខណ្ឌ ៦៣-៧៩។

[740] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៨៧-៣៨៦។

[741] ដូចយោងខាងលើ កថាខណ្ឌ ៣៨៨។

[742] ដូចយោងខាងលើ កថាខណ្ឌ ៣៨៧។

[743] ដូចយោងខាងលើ កថាខណ្ឌ ៣៨៨។

ត្រូវបានរៀបរាប់ថាជាខ្មាំង[744]។

- ការចោទប្រកាន់ថា គាត់ថ្លែងមិនច្បាស់អំពី "យួនខ្មែរ [...] ស្ថានភាពសន្តិសុខផ្ទៃក្នុង"[745]។

- ការចោទប្រកាន់ថា លោក យឹម ទិត្យ "តែងតែនិយាយអំពីយួន"[746]។

- ចម្លើយដែលឆ្លើយដាក់លោក យឹម ទិត្យ អំពីតម្រូវការក្នុងការវាយ "យួន" ដែលបង្កជាការគំរាមកំហែង និងភាពចាំបាច់ដែលត្រូវធ្វើការជាមួយបក្សកុម្មុយនីស្តកម្ពុជា ជាជាងចូលជាមួយ "យួន"[747]។

២៤៧. ប្រយោគទាំងអស់នេះមិនមានខ្លឹមសារ បរិបទ និងកាលបរិច្ឆេទច្បាស់លាស់ទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើ សុន្ទរកថា ការព្រមាន និងមតិមិនផ្លូវការ ដែលមានវោហាសាស្ត្រប្រឆាំងនឹងវៀតណាមទាំងនេះ អាចបង្កើតបានជា "ការចូលរួមយ៉ាងសំខាន់" ដោយរបៀបណាចំពោះការសម្លាប់រង្គាលបែបប្រល័យពូជសាសន៍ទៅលើខ្មែរក្រោម ជាពិសេសនៅក្នុងបរិបទដែលលោក យឹម ទិត្យ ត្រូវបានចោទថាកំពុងបំពេញការងារ នៅក្រោមរបបមួយដែលកំពុងមានសង្គ្រាមជាមួយវៀតណាមនោះ។

២៤៨. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថា ការសម្រេចណាមួយរបស់គាត់ ទាក់ទងនឹងការចូលរួមចំណែករបស់លោក យឹម ទិត្យ និងការសម្រេចមួយណា ទាក់ទងនឹងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានយោងជារួមទៅរក "បក្សកុម្មុយនីស្តកម្ពុជា យឹម ទិត្យ និងអ្នកដែលគាត់បានសហការជាមួយ"[748] ព្រមទាំង "យឹម ទិត្យ និងអ្នកដែលគាត់បានសហការជាមួយ នៅគ្រប់កម្រិតនៃឋានានុក្រមរបស់បក្សកុម្មុយនីស្តកម្ពុជា"[749]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះខ្មែរក្រោម មានឫសគល់ច្រើនពីការស្អប់ខ្ពើមជនជាតិវៀតណាម ដោយសារតែ "អំពើ

[744] ដូចយោងខាងលើ កថាខណ្ឌ ៣៨៩។

[745] ដូចយោងខាងលើ កថាខណ្ឌ ៣៩០។

[746] ដូចយោងខាងលើ កថាខណ្ឌ ៣៩៣។

[747] ដូចយោងខាងលើ កថាខណ្ឌ ៣៩៤-៣៩៧។

[748] ដូចយោងខាងលើ កថាខណ្ឌ ១០១១។

[749] ដូចយោងខាងលើ កថាខណ្ឌ ១០៤០។

ឈ្លានពានវាតទីនិយម” និងការភ័យខ្លាចជាបន្តបន្ទាប់ដែលថា វៀតណាមមានមហិច្ឆិតាចង់បានទឹកដីរបស់កម្ពុជាប្រជាធិបតេយ្យ” ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានញែកឱ្យដាច់រវាងការចូលរួមចំណែករបស់លោក យឹម ទិត្យ និងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[750]។ ការសម្រេចទាំងអស់នេះមិនមែនអំពីការចូលរួមចំណែកជាបុគ្គលរបស់លោក យឹម ទិត្យ ឡើយ ហើយ “សហឧក្រិដ្ឋកម្មរួមមិនមែនជា ទស្សនៈបើកចំហរដែលអនុញ្ញាតឱ្យមានការផ្តន្ទាទោសផ្អែកលើពិរុទ្ធភាពដោយសារការមានទំនាក់ទំនងជាមួយឡើយ”[751]។

២៤៩. សហចៅក្រមស៊ើបអង្កេតអន្តរជាតិផ្តល់សំអាងហេតុដោយមិនត្រឹមត្រូវថា លោក យឹម ទិត្យ មានការចូលរួមចំណែកយ៉ាងសំខាន់ ដោយសារតែ “សេចក្តីថ្លែងការណ៍ [...] ស្របគ្នាទាំងពេលវេលា និងភូមិសាស្ត្រទៅនឹងការសម្លាប់ជាទ្រង់ទ្រាយធំចំពោះប្រជាជនខ្មែរក្រោមរាប់រយនាក់យ៉ាងតិច”[752]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើ “ស្របគ្នា” នៃពាក្យពេចន៍ចោទប្រកាន់របស់គាត់ ជាមួយការសម្លាប់ទាំងអស់នេះ អាចបង្ហាញដោយរបៀបណាថា លោក យឹម ទិត្យ បានចូលរួមយ៉ាងសំខាន់ដល់អំពើប្រល័យពូជសាសន៍។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពន្យល់ថាតើ សេចក្តីថ្លែងការណ៍ណាមួយ ដែលអាចដាក់បន្ទុកចំពោះលោក យឹម ទិត្យ នៅជិតទាំងពេលវេលា និងភូមិសាស្ត្រ ឬថាតើសេចក្តីថ្លែងការណ៍ទាំងនោះ ជំរុញឱ្យមានការសម្លាប់រង្គាលដោយរបៀបណា[753]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាំបាច់ត្រូវពិនិត្យដោយប្រុងប្រយ័ត្ន ដោយផ្អែកលើការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានធ្វើការសម្រេចជាក់លាក់ជាប្រព័ន្ធ អំពីពេលវេលានៃតួនាទី*តាមនិតិន័យ*របស់លោក យឹម ទិត្យ និងសិទ្ធិអំណាចជាក់ស្តែងរបស់លោក យឹម ទិត្យ[754] ការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានកម្រិតកំណត់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ តាមដែនកំណត់ពេលវេលានៃការស៊ើបអង្កេត[755] និងការដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានភាពជាក់លាក់អំពី ការទទួលខុសត្រូវរបស់លោក យឹម ទិត្យ នៅដំណាក់កាលផ្សេងៗគ្នា ក្នុងអំឡុងពេលដែលគាត់ត្រូវបាន

---

[750] ដូចយោងខាងលើ កថាខណ្ឌ ១៩៧។

[751] រឿងក្តី Brdanin អង្គជំនុំជម្រះតុលាការកំពូល កថាខណ្ឌ ៤២៨។

[752] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៣៩១។

[753] ដូចយោងខាងលើ កថាខណ្ឌ ៣៨៦-៣៩១។

[754] ខាងលើ កថាខណ្ឌ ១២៤-២១៥, ២១៧។

[755] ខាងលើ កថាខណ្ឌ ៩៥-១០៣។

ចោទប្រកាន់នៅក្នុងភូមិភាគនិរតី ចាប់ពីប្រហែលខែកញ្ញា ឆ្នាំ១៩៧៥[756] រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[757]និងនៅក្នុងភូមិភាគពាយ័ព្យចាប់ពី "ដើមឆ្នាំ១៩៧៧ រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩"[758]។

២៥០. មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា ដោយផ្អែកលើភស្តុតាងនេះ លោក យឹម ទិត្យ បានចូលរួមចំណែកយ៉ាងសំខាន់ដល់គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការសម្លាប់វង្កាលខ្មែរក្រោម ភ្លាមៗបន្ទាប់ពីពេលដែលគាត់បានចូលកាន់តំណែងជាច្រើន នៅក្នុងគណៈតំបន់ ១៣ ក្នុងពេលណាមួយក្នុងឆ្នាំ ១៩៧៦ រហូតដល់ពេលបញ្ចប់របប[759]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឲ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

**(iii) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកដល់សហឧក្រិដ្ឋកម្មរួម គ**

២៥១. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម គ ក្នុងការជំរុញឲ្យមានប្រព័ន្ធនៃការធ្វើបាបនៅមន្ទីរសន្តិសុខវត្តព្រះធាតុ ចាប់ពីខែតុលា ឆ្នាំ១៩៧៥ រហូតដល់ចុងបញ្ចប់នៃរបប ដែលជាធាតុផ្សំនៃការទទួលខុសត្រូវ សហឧក្រិដ្ឋកម្មរួម ១ ឬសហឧក្រិដ្ឋកម្មរួម ២[760]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា លោក យឹម ទិត្យ "ទៅពិនិត្យទៀងទាត់" នៅមន្ទីរសន្តិសុខវត្តព្រះធាតុ បានបញ្ជាឲ្យមានឧក្រិដ្ឋកម្មនៅវត្តព្រះធាតុ និងបានចូលរួមដោយផ្ទាល់ក្នុងឧក្រិដ្ឋកម្មនៅវត្តព្រះធាតុ[761] ជាពិសេស "អំឡុងពេលចុះពិនិត្យទាំងនោះ គាត់បានសួរនាំអ្នកទោស កំណត់អត្តសញ្ញាណអ្នកទោសថាជាខ្មាំង និងបានបញ្ជា និងបានបញ្ជូនបញ្ជាបន្ត ឬយ៉ាងហោចណាស់យល់

[756] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ១០១៦(iii) និង ១០១៧(iii)។

[757] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(ii) និង (iii) និង ១០១៨។

[758] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(i), ១០១៧(i), ១០២០។

[759] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(ii), ១០១៧(ii), ១០១៨, ១០២២។

[760] ដូចយោងខាងលើ កថាខណ្ឌ ១០១៦(iii), ១០១៧(iii), ១០១៨។

[761] ដូចយោងខាងលើ កថាខណ្ឌ ៤៣៣-៤៦៩។.

ព្រមឲ្យសួរចម្លើយ និងសម្លាប់អ្នកទោស"[762]។ ការសម្រេចទាំងនេះមិនត្រឹមត្រូវទេ។

*ក. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ ទៅពិនិត្យទៀតទាត់នៅវត្តព្រះធាតុ*

២៥២. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា លោក យឹម ទិត្យ ទៅពិនិត្យ "ទៀងទាត់" នៅមន្ទីរសន្តិសុខវត្តព្រះធាតុ[763]។ សំអាងហេតុដែលខុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺថា ដោយសារតែ "គណៈកម្មាធិការស្រុកគិរីវង់បានគ្រប់គ្រងផ្ទាល់ទៅលើមន្ទីរសន្តិសុខវត្តព្រះធាតុ" គឺថា លោក យឹម ទិត្យ បានទៅពិនិត្យទីតាំងនោះជាទៀងទាត់[764]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានដោយមិនត្រឹមត្រូវ អំពីការចូលរួមចំណែករបស់លោក យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម ដោយសារតែការចោទអំពីសមាជិកភាពរបស់លោក យឹម ទិត្យ នៅក្នុងគណៈកម្មាធិការស្រុក[765]។

២៥៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងទាំងស្រុងរបស់សាក្សី ដុក ចាន់, យូ ភ្នំ, ទន់ ស៊ួន, អោក ចន និង ហោ យ៉ន[766]។

- ដុក ចាន់ ដែលនៅវត្តព្រះធាតុចាប់ពីឆ្នាំ១៩៧៣ រហូតដល់ប្រហែលខែមិថុនា ឆ្នាំ១៩៧៥[767]

---

[762] ដូចយោងខាងលើ កថាខណ្ឌ ៤៦៣។

[763] ដូចយោងខាងលើ កថាខណ្ឌ ៤៣៩។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា លោក យឹម ទិត្យ បានចុះមកធ្វើទស្សនកិច្ចចំនួនបីលើក នៅក្នុងរយៈពេលជាងមួយឆ្នាំ។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៣។

[764] ដូចយោងខាងលើ កថាខណ្ឌ ៤៣៩, ៤៥៩, ៤៦៣-៤៦៩។

[765] ដូចយោងខាងលើ។

[766] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៣៩, ៤៥៩, ៤៦៣-៤៦៩។

[767] ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុក ចាន់ ឆ.៣ ERN 01040103-01040104 ("តើនៅពេលណាដែលលោកចាប់ផ្តើមចូលធ្វើការឲ្យមន្ទីរសន្តិសុខប្រធាតុ? ឆ.៣៖ ប្រហែលជានៅក្នុងឆ្នាំ១៩៧៣ នៅក្នុងពេលនោះ មន្ទីរសន្តិសុខនេះស្ថិតនៅក្នុងភូមិគោកព្រិច ឃុំគោកព្រិច ហើយនៅដើមឆ្នាំ១៩៧៥ យើងបានរើមន្ទីរនោះពីគោកព្រិចយកមកដាក់នៅក្នុងវត្តប្រធាតុ មួយរយៈពេលខ្លីមុនបែកភ្នំពេញក្នុងឆ្នាំ១៩៧៥។ នៅក្នុងពេលនោះ បុគ្គលិកមន្ទីរសន្តិសុខទាំងអស់ ហើយនិងអ្នកទោសត្រូវបានរើមកដាក់វត្តប្រធាតុ ប៉ុន្តែ អ្នកទោសមានតែ ៤-៥ នាក់ប៉ុណ្ណោះទេ")។ សូមមើលផងដែរ ចម្លើយរបស់ ដុក ចាន់ ថា "រឿងទាំងនេះ ប្រហែលជាចាប់ផ្តើមពីឆ្នាំ១៩៧៤" ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុក ចាន់ ឆ.៧ ERN 01040104។

ហើយលែងត្រឡប់មកវត្តព្រះធាតុទៀតនោះ បានបញ្ជាក់ថា ទោះបីជាឈ្មោះគាត់នៅជាបុគ្គលិកចាប់ពីអំឡុងខែមិថុនា ឆ្នាំ១៩៧៥ រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៧ តែគាត់លែងនៅស្រុកគិរីវង់ហើយ ក្នុងអំឡុងពេលនោះ[768]។ បន្ទាប់ពីចាកចេញពីស្រុកគិរីវង់ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៥ គាត់ទៅនៅទីរួមខេត្តតាកែវ រហូតដល់ប្រហែលពាក់កណ្តាលឆ្នាំ១៩៧៧[769]។ គាត់ត្រឡប់មកស្រុកគិរីវង់វិញ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ដើម្បីធ្វើការនៅក្នុងកងផលិត ហើយក្នុងពេលនោះគាត់មិនបានឃើញ មេដឹកនាំស្រុកណាម្នាក់ចុះមកពិនិត្យវត្តព្រះធាតុឡើយ[770]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើភ័ស្តុតាង ដែលមិនមានភាពទាក់ទងតាមពេលវេលារបស់ឌុក ចាន់ ដើម្បីសម្រេចថា លោក យឹម ទិត្យ បានទៅពិនិត្យវត្តព្រះធាតុ ហើយមិនបានពិចារណាអំពីសក្ខីកម្មដែលផ្ទុយគ្នារបស់ ឌុក ចាន់ ឡើយ[771]។

- ហោ យ៉ន បានផ្តល់ភ័ស្តុតាងផ្ទុយគ្នា អំពីចំនួនដងដែលគាត់បានឃើញ "ទិត" នៅវត្តព្រះធាតុ[772]។ ភាពអាចជឿជាក់បាននៃការបានឃើញ "ទិត" ច្បាស់លាស់របស់គាត់ បានថយចុះជាបន្តបន្ទាប់ ដោយសារតែគាត់មិនអាចកំណត់អត្តសញ្ញាណលោក យឹម ទិត្យ បានត្រឹមត្រូវ នៅពេលដែលបង្ហាញរូបថត ហើយគាត់ច្រឡំលោក យឹម ទិត្យ ជាមួយតាណាំ[773]។ រូបថតមិនត្រូវបានកំណត់អត្តសញ្ញាណ ដោយលេខយោង ហើយក៏មិនត្រូវបានផ្ទៀងផ្ទាត់ជាផ្លូវការ ថាជាអត្តសញ្ញាណលោក យឹម ទិត្យ[774]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់សំអាងហេតុ សម្រាប់ការពឹងផ្អែកទៅលើចម្លើយរបស់ ហោ

[768] ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុក ចាន់ ឆ.២ ERN 01040103។

[769] ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុក ចាន់ ឆ.២ ERN 01040103។

[770] ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌុក ចាន់ ឆ.១១-ឆ.១២ ERN 01040105-01040106។

[771] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៣, ៤៦៥។

[772] ឯកសារ D1.3.11.18 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន EN 00217607។ ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២២ ERN 00788831។ ឯកសារ D219/55 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១០ ERN 01034062។ ឯកសារ D219/55 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២០ ERN 01034064។

[773] ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២០ ERN 00788830៖ (ស.៖ តើរូបនេះមើលទៅស្រដៀង តាទិត ដែរឬទេ? ឆ.២០៖ មិនដូចទេ ដូចតាណាំច្រើនជាង [...]")។

[774] ដូចយោងខាងលើ។

យ៉ន នៅពេលដែលមានភាពមិនច្បាស់លាស់ថាតើ ក្នុងនាមជាអ្នកទោសម្នាក់ តើ ហោយ៉ន អាចដឹងដោយរបៀបណាថា លោក យឹម ទិត្យ គឺជានរណា ឬតើគាត់មានតួនាទីអ្វីក្នុងការគ្រប់គ្រងវត្តព្រះធាតុ។

- យូ ភ្នំ ដែលមិនប៉ានទៅជិតមន្ទីរសន្តិសុខ[775] បានបញ្ជាក់ថា វត្តព្រះធាតុត្រូវបានផ្លាស់ប្តូរនៅក្នុងឆ្នាំ ១៩៧៥ មុនពេលដែលត្រូវបានរួមបញ្ចូលជាមួយ "គុកក្រោមដី" មួយទៀតនៅក្នុងឆ្នាំ១៩៧៦ ហើយបានបញ្ឈប់ដំណើរការទាំងស្រុង នៅក្នុងឆ្នាំ១៩៧៧ ដែលចំណុចនេះនាំឲ្យមានចំណោទសួរថា តើ យូ ភ្នំ ទៅទីនោះនៅពេលណាឲ្យប្រាកដ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ១៩៧៧ បើគាត់ពិតជាបានទៅមែន[776]។ អោក ចន បាននិយាយថា ខ្មែរក្រហមលែងប្រើប្រាស់វត្តព្រះធាតុ ធ្វើជាមន្ទីរឃុំឃាំងនៅក្នុងឆ្នាំ១៩៧៧[777]។

- ទន់ ស៊ួន នៅវត្តព្រះធាតុក្នុងរយៈពេលខ្លីត្រឹមបួនថ្ងៃប៉ុណ្ណោះ នៅ "ចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ ១៩៧៦"[778]។ គាត់មិនអាចផ្តល់យោបល់អំពីការទៅពិនិត្យវត្តព្រះធាតុរបស់លោក យឹម ទិត្យ ដែលត្រូវបានចោទថាទៅជាញឹកញាប់ នៅក្នុងអំឡុងរបបខ្មែរក្រហមឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបំប៉ោងដោយមិនត្រឹមត្រូវពីការអះអាងអំពី "ការពិនិត្យទៀងទាត់" របស់លោក យឹម ទិត្យ នៅវត្តព្រះធាតុ ផ្អែកលើរយៈពេលត្រឹមតែបួនថ្ងៃ[779]។

- ព័ត៌មានរបស់ អោក ចន មិនមានកាលបរិច្ឆេទច្បាស់លាស់ ហើយយោងត្រឹមតែជាទូទៅទៅអំឡុងពេល "ឆ្នាំ៧៥ដល់៧៩"[780]។ អោក ចន យល់ច្រឡំអំពីពេលវេលា ដែលគាត់គិតថា គាត់បានឃើញ 'តាទិត្យ' នៅវត្តព្រះធាតុ។ គាត់គិតថា គាត់បានឃើញ 'តាទិត្យ' ម្តង

---

[775] ឯកសារ D219/109 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ ភ្នំ ឆ.៩ ERN 01045255។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៣, ៤៦៥។

[776] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៥២ ERN 01110210។

[777] ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.២០ ERN 00968089។

[778] ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៤៨-ឆ.៤៩, ឆ.៦០ ERN 01102937-01102938។

[779] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៣, ៤៦៥។

[780] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៣ ERN 01110206។

នៅពេលគាត់ជាប់ឃុំនៅវត្តព្រះធាតុ ក្នុងខែមេសា ឆ្នាំ១៩៧៧[781]។ គាត់និយាយថា គាត់មិនដែលឃើញ 'តាទិត្យ' ទេ ក្រោយឆ្នាំ១៩៧៦[782] ប៉ុន្តែ គាត់បាននិយាយថា 'តាទិត្យ' មកគុករៀងរាល់សប្តាហ៍[783] ឬពីរសប្តាហ៍ម្តង និងថា គាត់បានឃើញ 'តាទិត្យ' ពីរដងក្នុងអំឡុងពេលគាត់ជាប់ឃុំឃាំងបីខែ[784]។

- អោក ចន ជាប់ខ្នោះនៅក្នុងវត្តព្រះធាតុ នៅក្នុងបន្ទប់មួយ ដែលមិនមានបង្អួច ហើយមានភាពមិនច្បាស់លាស់ថាតើ គាត់អាចដឹងដោយរបៀបណាថា 'តាទិត្យ' មកពិនិត្យគុក[785]។ អោក ចន បាននិយាយថា គាត់ "មិនដឹងថា គាត់មកញឹកញាប់ ឬអត់ទេ ព្រោះខ្ញុំនៅជាប់ក្នុងគុក"[786]។ ពីដំបូង អោក ចន បានបញ្ជាក់ថា មានគុកក្រោយដីមួយនៅវត្តស្លែង ដែលកសាងឡើងក្នុងឆ្នាំ១៩៧៥ ហើយត្រូវបានរើទៅវត្តព្រះធាតុវិញ នៅក្នុងឆ្នាំ១៩៧៦[787]។ គាត់មិនបានដឹងថា ពេលណាដែលគុកត្រូវបានរើពីវត្តស្លែង ទៅវត្តព្រះធាតុទេ ព្រោះគុកនេះស្ថិតនៅក្នុងឃុំផ្សេង[788] ហើយគាត់ក៏មិនដឹងថា "ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងថា

---

[781] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៨០ ERN 01110212។

[782] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.២១, ឆ.២២ ERN 01110207-011102108៖ "ស.៖ តើលោកជួបតាទិត្យ ចុងក្រោយនៅឆ្នាំណា? ឆ.២១៖ ខ្ញុំជួបគាត់ដំបូង នៅឆ្នាំ១៩៧៤ ហើយបានជួបគាត់ចុងក្រោយ ១៩៧៦។ ស.៖ តើក្រោយពីឆ្នាំ១៩៧៦ តើលោកធ្លាប់បានឮឈ្មោះតាទិត្យ និងតាគុំ ទៀតដែរឬទេ? ឆ.២២៖ អត់ទេ")។

[783] ឯកសារ D1.3.11.2 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ អោក ចន EN 00219254។

[784] ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៧៥ ERN 00968096។

[785] ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៧៦ ERN 00968096៖ (ស.៖ នៅពេលដែលលោកឃើញតាទិត ចូលទៅក្នុងបន្ទប់ឃុំឃាំងអ្នកទោស ហើយលោកនិយាយថា បន្ទប់ឃុំឃាំងអ្នកទោសគ្មានបង្អួចទេ។ ហេតុអ្វីបានជាលោកដឹងថាអ្នកដែលចូលទៅមើលអ្នកទោសនោះជាតាទិត? ឆ.៧៦៖ ពេលខ្ញុំនៅកន្លែងផលិតស្រុក គឺខ្ញុំស្គាល់គាត់ហើយ។ នៅក្នុងបន្ទប់ឃុំឃាំងពេលថ្ងៃ មិនងងឹតនោះទេ គឺងងឹតតែយប់ប៉ុណ្ណោះ")។

[786] ឯកសារ D105/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៩៨ ERN 00788851។

[787] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៥២ ERN 01110210៖ (ស.៖ តើនៅឆ្នាំណាដែលគេរៀបចំគុកនៅក្នុងដីនោះ? ឆ.៥២៖ នៅឆ្នាំ១៩៧៥ ប៉ុន្តែនៅឆ្នាំ១៩៧៦ គេប្តូរទៅកន្លែងផ្សេងហើយ")។

[788] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៦៥ ERN 01110211៖ (ស.៖ តើគេរើគុកពីវត្តស្លែងទៅនៅវត្តប្រធាតុនៅឆ្នាំណា? ឆ.៦៥៖ ខ្ញុំមិនដឹងទេ ព្រោះនៅឃុំខុសគ្នា")។

មានគុកប៉ុណ្ណោះ”[789]។

- អោក ចន មិនអាចកំណត់អត្តសញ្ញាណលោក យឹម ទិត្យ បានទេ នៅពេលបង្ហាញរូបថតមនុស្សម្នាក់ ដែលគាត់គិតថាជា ខៀវ សំផន។ ទោះជាបែបណាក្តី រូបថតនេះមិនត្រូវបានបង្ហាញជាផ្លូវការ នៅក្នុងភ័ស្តុតាងថា ជារូបពិតប្រាកដរបស់លោក យឹម ទិត្យ[790]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា “នៅពេលពិចារណាពេលវេលា នៅចន្លោះរបបកម្ពុជាប្រជាធិបតេយ្យ និងកាលបរិច្ឆេទរូបថត ហើយអង្គហេតុដែលសាក្សីបានស្គាល់ យឹម ទិត្យ នៅក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យ ការខកខានរបស់សាក្សី ក្នុងការកំណត់អត្តសញ្ញាណ យឹម ទិត្យ នៅក្នុងរូបថត ពុំប៉ះពាល់ជាក់ស្តែងលើ ភាពអាចទុកចិត្តបាននៃសាក្សីនោះឡើយ”[791]។ បញ្ហានៃភ័ស្តុតាងបែបនេះ គួរតែផ្តល់សំអាងហេតុចំពោះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការមានមន្ទិលសង្ស័យអំពីភាពអាចជឿជាក់បាននៃការចងចាំរបស់ អោក ចន ហើយមិនត្រូវព្យាយាមផ្តល់យុត្តិកម្មឡើយ។

- ហោ យ៉ន បានរំឭកថា លោក យឹម ទិត្យ បានទៅពិនិត្យវត្តព្រះធាតុ “ទំនងយ៉ាងយូរបំផុតនៅចុងឆ្នាំ១៩៧៧ ឬដើមឆ្នាំ១៩៧៨”[792] ប៉ុន្តែ ហោ យ៉ន នៅវត្តព្រះធាតុនៅក្នុងឆ្នាំ១៩៧៣[793]។ នៅពេលត្រូវបានសួរបញ្ជាក់អំពីពេលវេលានៃការឃុំឃាំង គាត់បានឆ្លើយថា “ខ្ញុំជាប់គុកនៅឆ្នាំ១៩៧៣ មិនមែនឆ្នាំ១៩៧៨ទេ ប្រហែលជាមានការច្រឡំគ្នាហើយ រវាង៧៣ និង៧៨”[794]។ ហោ យ៉ន បានបញ្ជាក់បំភ្លឺនាពេលបន្ទាប់ម្តងទៀតថា កាលបរិច្ឆេទ

---

[789] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៦៧ ERN 01110211៖ (ស.៖ តើលោកមានដឹងថាអ្នកណាគេឃុំឃាំងនៅគុកក្រោមដីនៅវត្តស្លែងទេ? ឆ.៦៧៖ ខ្ញុំមិនដឹងទេ ខ្ញុំគ្រាន់តែដឹងថា មានគុកប៉ុណ្ណោះ”)។ អោក ចន ក៏បានឆ្លើយដែរថា ខ្លួនគាត់ផ្ទាល់ គាត់ “មិនសូវដឹងទេ” ពីមន្ទីរសន្តិសុខស្រុកគិរីវង់ ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៥៧ ERN 00968093។

[790] ឯកសារ D105/5 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.១០៤ ERN 00788852។

[791] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៩។

[792] ដូចយោងខាងលើ កថាខណ្ឌ ៤៦៩។

[793] ឯកសារ D118/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១០ ERN 00968069។

[794] ដូចយោងខាងលើ នេះជាកំហុសដែលងាយនឹងមាន ជាពិសេស ដោយហេតុថា នៅក្នុងភាសាខ្មែរ ពាក្យសម្រាប់លេខ “បី” និងលេខ “ប្រាំបី” អាចនឹងងាយស្តាប់ច្រឡំ។

ដែលគាត់ជាប់ឃុំឃាំង រយៈពេលប្រាំបីខែ គឺ នៅក្នុងឆ្នាំ១៩៧៣[795]។

- ហោ យ៉ន បាននិយាយយោងដោយទូទៅទៅរក "សមាជិកគណៈស្រុក" ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាអំពី ភ័ស្តុតាងមិនគ្រប់គ្រាន់ ដែល ហោ យ៉ន បាននិយាយយោងទៅរកលោក យឹម ទិត្យ។ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ថា "ដោយសារពេលវេលាកន្លងផុតរវាងហេតុការណ៍ និងកាលបរិច្ឆេទនៃរូបថត ពុំឲ្យអាចឲ្យសាក្សីសម្គាល់ យឹម ទិត្យ។ ដូច្នេះ ភ័ស្តុតាងរបស់សាក្សីនេះមានភាពអាចទុកចិត្តបានគ្រប់គ្រាន់"[796] ប៉ុន្តែ បញ្ហានេះគួរជាសំអាងហេតុក្នុងការមានមន្ទិលសង្ស័យ ចំពោះការចងចាំរបស់ ហោ យ៉ន មិនមែនត្រូវធ្វើយុត្តិកម្មទេ។

២៥៤. មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា ដោយផ្អែកលើភ័ស្តុតាងនេះ លោក យឹម ទិត្យ បានពិនិត្យទៀងទាត់នៅមន្ទីរសន្តិសុខវត្តព្រះធាតុឡើយ[797]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានភាពអយុត្តិធម៍ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឲ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

*ខ. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមដោយផ្ទាល់ក្នុងការសួរចម្លើយនៅមន្ទីរសន្តិសុខវត្តព្រះធាតុ*

២៥៥. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមដោយផ្ទាល់ក្នុងការសួរចម្លើយនៅវត្តព្រះធាតុ ចំនួនពីរដង នៅពេលវេលាមិនជាក់លាក់ ដោយផ្អែក

---

795 ឯកសារ D118/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១២ ERN 00968069៖ ("ស.៖ ក្រោយពេលដែលគេដោះលែងលោកចេញពីគុក តើមានរយៈពេលប៉ុន្មានទើបរបបខ្មែរក្រហមដួលរលំ? ឆ.១២៖ ខ្ញុំជាប់គុកនៅឆ្នាំ១៩៧៣ គឺប្រហែលជា ៨ ខែ ដែលខ្ញុំនៅក្នុងគុក")។

796 ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៩។

797 ដូចយោងខាងលើ កថាខណ្ឌ ៤៣៩។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា លោក យឹម ទិត្យ បានចុះមកធ្វើទស្សនកិច្ចចំនួនបីលើក នៅក្នុងរយៈពេលជាងមួយឆ្នាំ។ ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៣។

លើចម្លើយតែមួយរបស់ ទន់ ស៊ូន ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤[798]។

- សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាទៅលើភ័ស្តុតាងផ្ទុយរបស់ ទន់ ស៊ូន និងការដែល ទន់ ស៊ូន មិនបានលើកឡើងពីលោក យឹម ទិត្យ សួរចម្លើយអ្នកទោសនៅវត្តព្រះធាតុ នៅក្នុងការស្តាប់ចម្លើយ ឬការទំនាក់ទំនងកន្លងមកជាមួយ សហព្រះរាជអាជ្ញាអន្តរជាតិ ក.ស.ច.ស និងយ៉ាងហោចណាស់ជាមួយអង្គការមិនមែនរដ្ឋាភិបាលចំនួនពីរផ្សេងគ្នា។

- ការស្តាប់ចម្លើយរបស់ ទន់ ស៊ូន ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ កាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨ មិនបានលើកឡើងពី លោក យឹម ទិត្យ ថា មានទំនាក់ទំនងជាមួយវត្តព្រះធាតុទេ[799]។ គាត់ស្ថិតនៅក្នុងគុក ២០៤ ចំនួនបួនខែ[800] ប៉ុន្តែ មិនបានដឹងឮផ្ទាល់អំពីវត្តព្រះធាតុទេ[801] ហើយគាត់បាននិយាយថាវាជា "តំបន់ហាមឃាត់" ហើយ "គេមិនឲ្យទៅក្បែទីនោះទេ"[802] និងថា មានការហាមឃាត់មិនឲ្យចូលវត្តព្រះធាតុ ហើយអ្នកណាដែលហ៊ានចូល អាចត្រូវគេចាប់ខ្លួន[803]។

- ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ ទន់ ស៊ូន ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០០៩ មិនបានលើកឡើងពីលោក យឹម ទិត្យ ទេ។ គាត់បានបញ្ជាក់ថា ការដឹងឮរបស់គាត់អំពីវត្តព្រះធាតុ គឺបានដោយសារពាក្យចចាមអារាមអនាមិក "អ្នកទោសបានប្រាប់ខ្ញុំពីរឿងនេះដោយសារខ្ញុំទទួលចង់ដឹងពី ស្ថានភាពអ្នកទោសនៅក្នុងគុកនោះ"[804]។

- ការស្តាប់ចម្លើយរបស់ ទន់ ស៊ូន ជាមួយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រម

---

[798] ដូចយោងខាងលើ កថាខណ្ឌ ៤៦៣, ៤៦៧ ជើងទំព័រ ១២៦៤-១២៦៦ ដកស្រង់ ឯកសារ D219/110 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ូន ឆ.៣, ឆ.៤, ឆ.៦ ERN 01045262-01045264។

[799] ឯកសារ D1.3.11.56 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ ទន់ ស៊ូន។

[800] ឯកសារ D1.3.11.56 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ ទន់ ស៊ូន EN 00219281។

[801] ឯកសារ D1.3.11.56 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ ទន់ ស៊ូន EN 00219281។

[802] ឯកសារ D1.3.11.56 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ ទន់ ស៊ូន EN 00219281។

[803] ឯកសារ D1.3.11.56 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ ទន់ ស៊ូន EN 00219281។

[804] ឯកសារ D5/122 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ូន ERN 00491808។

Blunk កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១០ មិនបានលើកឡើងពីលោក យឹម ទិត្យ ទេ ទាក់ទងនឹងវត្តព្រះធាតុ។ គាត់មិនបាននិយាយថា គាត់ជាប់ឃុំឃាំងនៅទីនោះឡើយ បើទោះបីជាត្រូវបានផ្តល់ភ័ស្តុតាងបន្ថែមអំពីវត្តព្រះធាតុ[805] និងសួរឲ្យបញ្ជាក់ពីភ័ស្តុតាងកន្លងមករបស់កាត់ ទាក់ទងវត្តព្រះធាតុក្តី[806]។

- នៅក្នុងការស្តាប់ចម្លើយរបស់ ទន់ ស៊ួន ជាមួយអតីតសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចៅក្រម Blunk កាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១១[807] នៅពេលប្រឈមនឹងការសួរដេញដោល គាត់នៅតែអះអាងថា គាត់ "មិនដឹងទេ"[808]។ បន្ទាប់មកគាត់បានប្តូរចម្លើយដោយនិយាយថា គាត់បានទៅវត្តព្រះធាតុ "ទៅរៀនសូត្រ" នៅពេលមួយមិនច្បាស់។ នៅពេលសួរអំពីលោក យឹម ទិត្យ គាត់មិនបានផ្តល់ចម្លើយអ្វីអំពីការដែលលោក យឹម ទិត្យ បានសួរចម្លើយអ្នកទោស នៅវត្តព្រះធាតុឡើយ៖ "ស៖ តើលោកមានបានដឹង ព័ត៌មានផ្សេងទៀតទេអំពីតាទិត" ឆ៖ ខ្ញុំមិនដឹងអ្វីផ្សេងទៀតទេអំពីគាត់ទេ"[809]។

- នៅក្នុងការស្តាប់ចម្លើយរបស់ ទន់ ស៊ួន ជាមួយ ក.ស.ច.ស នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០១៣ គាត់បាននិយាយថា គាត់ត្រូវបានអប់រំរៀនសូត្រនៅវត្តព្រះធាតុ រយៈពេលពីរទៅបីថ្ងៃ[810]។ គេមិនឲ្យគាត់ចូលទៅក្នុងទីតាំងឃុំឃាំងសម្រាប់អ្នកទោសឡើយ[811] ហើយ

---

[805] ឯកសារ D3/8 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ឆ.៣ ERN 00619851។ ទន់ ស៊ួន សំដៅដល់ទីតាំងដែលត្រូវគេកំណត់នៅវត្តប្រធាតុដែលមានទំហំប្រហែល ១០០ ម៉ែត្រការ៉េ។

[806] ឯកសារ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ឆ.៣ ERN 00619851។

[807] ឯកសារ D13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន។

[808] ឯកសារ D13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ERN 00687004 ("ស.៖ តើលោកដឹងទេថាតើនៅក្នុងគណៈស្រុកនេះ ជាពិសេសនៅមន្ទីរសន្តិសុខព្រះធាតុ នរណាគេមានសិទ្ធិសម្រេចចាប់ និងសម្លាប់អ្នកទោស? ឆ.៖ ខ្ញុំមិនដឹងទេ ព្រោះនៅសម័យនោះ គេមិនឲ្យយើងដឹងទេ។ ចំណែកនៅមន្ទីរសន្តិសុខវត្តព្រះធាតុ ខ្ញុំមិនដឹងទេ ខ្ញុំត្រូវបានគេបញ្ជូនទៅរៀនសូត្រ ៣ឬ៤ ថ្ងៃប៉ុណ្ណោះ។ ខ្ញុំត្រូវបានគេបញ្ជូនទៅគុក ២០៤ ហៅគុកត្រពាំងគង ហើយជាប់នៅទីនោះអស់រយៈពេល៤ខែ។ នៅពេលគេចាប់មនុស្ស ខ្ញុំឃើញតែយាយបូ ជាអ្នកទទួលមនុស្ស និងចាប់មនុស្សទៅ និងការបាញ់មនុស្សផ្ទាល់នៅគោកព្រេច គឺយាយបូ ជាអ្នកបញ្ជាទាំងអស់")។

[809] ឯកសារ D13 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ERN 00687003-00687004។

[810] ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ឆ.១២ ERN 00891154។

"តាទិត ឬតាតុម ឬយាយបូ ជាទូទៅមកត្រួតពិនិត្យមើលអ្នកទោស"[812]។ ការតាំងសំណួរនេះមិនបានកំណត់ថា តើ ទន់ ស៊ូន បានដឹងបញ្ហានេះ ពីបទពិសោធន៍ផ្ទាល់របស់គាត់ នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ឬគាត់បានដឹងរឿងនេះ នៅក្រោយឆ្នាំ១៩៧៩ បន្ទាប់ពីគាត់បានទំនាក់ទំនងជាមួយអ្នកស៊ើបអង្កេត ការពិភាក្សាជាសាធារណៈ និងអង្គការមិនមែនរដ្ឋាភិបាល ឬថាតើចាប់តាំងពីពេលដែលគាត់ បានផ្តល់ចម្លើយចុងក្រោយនៅថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១១ គាត់បានទទួលឥទ្ធិពលពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលត្រូវបានបញ្ចេញជាសាធារណៈ ដោយខុសច្បាប់ ហើយអាចស្វែងរកបានដោយទូលំទូលាយ ចាប់ពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ នោះទេ[813]។

- ទន់ ស៊ូន ត្រូវបានអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានស្តាប់ចម្លើយក្រៅផ្លូវការ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៤ ហើយត្រូវបាន "ស្តាប់ចម្លើយ ហើយដោយយល់ថា គាត់ដឹងព័ត៌មានដែលមានប្រយោជន៍"[814]។

២៥៦. ចម្លើយរបស់ ទន់ ស៊ូន ជាមួយ ក.ស.ច.ស នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៤ បានបញ្ជាក់ជាលើកដំបូងថា 'តាទិត្យ' សួរចម្លើយអ្នកទោសនៅវត្តព្រះធាតុ ចំនួនពីរដងនៅចុងឆ្នាំ១៩៧៦[815]។ បន្ទាប់មក ទន់ ស៊ូន បានផ្តល់ព័ត៌មានអំពី 'តាទិត្យ' និង "ប្រធាន" ផ្សេងៗទៀតនៅស្រុកគិរីវង់ គឺតាតុម និង

---

[811] ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ឆ.១៥ ERN 00891155 ("ស.៖ តើអ្នកទោសត្រូវគេធ្វើបាបដែរឬទេ? ឆ.១៥៖ គេមិនឱ្យខ្ញុំឃើញទេ ព្រោះគេមិនឱ្យចូលទៅកន្លែងឃុំអ្នកទោសទេ ខ្ញុំបានតែចូលដល់ក្នុងបរិវេណវត្ត")។

[812] ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ូន ឆ.១៦-ឆ.១៨ ERN 00891155។

[813] នៅត្រឹមថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលោកទីបីរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងឯកសារនានាពាក់ព័ន្ធនឹងការខ្វែងយោបល់របស់សហព្រះរាជអាជ្ញាជាតិ ត្រូវបានលេចចេញដោយខុសច្បាប់ទៅដល់សារព័ត៌មាន ហើយលោក យឹម ទិត្យ ត្រូវបានស្គាល់ឈ្មោះជាសាធារណៈថាជាជនសង្ស័យម្នាក់ក្នុងចំណោមជនសង្ស័យទាំងបីនាក់។ សូមមើល ឯកសារ D72/1.1.11 កំណត់ហេតុនៃកិច្ចស៊ើបសួរ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១១។

[814] ឯកសារ D219/122 កំណត់ហេតុនៃកិច្ចស៊ើបសួរ ERN 01363998។

[815] ឯកសារ D219/110 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ូន ឆ.១, ឆ.៣-ឆ.៤, ឆ.៨ ERN 01045262-01045264។

យាយបូ ដែលបានសួរចម្លើយអ្នកទោស នៅវត្តព្រះធាតុ[816]។ ទន់ ស៊ួន មិនត្រូវបានអនុញ្ញាតឲ្យចូលតំបន់ឃុំឃាំងអ្នកទោស នៅវត្តព្រះធាតុទេ (គាត់ត្រូវបានឃុំខ្លួននៅក្នុងកុដិ ឬរោងអារឈើ ហើយគាត់អាចចូលបានត្រឹម បរិវេណវត្តប៉ុណ្ណោះ)[817] ប៉ុន្តែ គាត់បានអះអាងថា បានឮពាក្យពេចន៍ជាក់លាក់នៃសំណួរដែល 'តាទិត្យ'បានសួរអ្នកទោស ក្នុងពេលសួរចម្លើយ "ថាតើគ្នាឯងប៉ុន្មាននាក់ មកពីណា"[818]។ លើសពីនេះទៀត ទន់ ស៊ួន មិនច្បាស់ថាតើគាត់បានឃើញ 'តាទិត្យ' កំពុងនិយាយជាមួយអ្នកទោស ឬបុគ្គលិករបស់គុកទេ[819]។

២៥៧. កាលបរិច្ឆេទនៃការជាប់ឃុំឃាំងរបស់ ទន់ ស៊ួន មិនច្បាស់លាស់។ គាត់ត្រូវបានចាប់ខ្លួន នៅចុងឆ្នាំ ១៩៧៦ ហើយត្រូវបានបញ្ជូនទៅគុក ២០៤[820]។ ដូចដែលបានបង្ហាញពីខាងលើ គាត់បាននិយាយនៅក្នុងការស្តាប់ចម្លើយពេលបន្ទាប់ថា គាត់ត្រូវបានបញ្ជូនទៅរៀនសូត្រ នៅវត្តព្រះធាតុប្រហែលពីរទៅបីថ្ងៃ[821] ឬបួនថ្ងៃ "អំឡុងពេល១៩៧៥ ដល់១៩៧៩"[822] ឬប្រហែលជា "នៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦"[823] ដែលក្នុងអំឡុងពេលនោះ គាត់បានអះអាងថាបានឃើញ 'តាទិត្យ' ពីរដង

[816] ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.២៦, ឆ.៤៧-ឆ.៤៩, ឆ.៥៤-ឆ.៥៦, ឆ.៦២ ERN 01102934-01102938។

[817] ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.១០ ERN 01102933។ សូមមើលផងដែរ៖ ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ឆ.១៥ ERN 00891155។ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៥៣ ERN 01102937។

[818] ឯកសារ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៥៦ ERN 01102937។

[819] ឯកសារ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៤៦, ឆ.៥២ ERN 01102936-01102937។

[820] ឯកសារ D5/122 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ERN 00491807។

[821] ឯកសារ ឯកសារ D118/22 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ទន់ ស៊ួន ឆ.១២ ERN 00891154។

[822] ឯកសារ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៣-ឆ.១២ ERN 01102933 ឆ.៤៨ ERN 01102937។

[823] ឯកសារ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៦០ ERN 01102938។

ហើយម្តងៗ បានឃើញប្រហែល១០នាទី[824]។ គាត់បាននិយាយថា អួន គឺជាប្រធានវត្តព្រះធាតុនៅពេលនោះ[825]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានទទួលស្គាល់ថា "ភាពខុសគ្នាអំពីពេលវេលា" មានន័យថា ភ័ស្តុតាងរបស់ ទន់ ស៊ួន មិនអាចពឹងផ្អែកបានឡើយ[826]។

២៥៨. មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា ដោយផ្អែកលើភ័ស្តុតាងនេះ លោក យឹម ទិត្យ បានចូលរួមដោយផ្ទាល់ក្នុងការសួរចម្លើយអ្នកទោស[827]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឱ្យមានការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

*គ. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមដោយផ្ទាល់ក្នុងការសម្លាប់មនុស្សនៅវត្តព្រះធាតុ*

២៥៩. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា លោក យឹម ទិត្យ បានចេញបញ្ជាឱ្យ "វះពោះ" អ្នកទោសនៅវត្តព្រះធាតុ[828]។ ចំណុចនេះជាការមិនត្រឹមត្រូវទេ។

២៦០. សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចបែបនេះដោយផ្អែកលើ ត្រឹមតែភ័ស្តុតាងរបស់ ហោ យ៉ន ដែលសូម្បីតែការវិភាគផ្ទាល់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់នូវភ័ស្តុតាងអំពី ភាពមិនស្របគ្នាទាល់តែសោះ ដែលគួរតែធ្វើឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិច្រានចោលសក្ខីកម្មរបស់គាត់ទាំងស្រុង[829]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាថា ហោ យ៉ន ស្ថិតនៅក្នុងគុកនៅឆ្នាំ១៩៧៣[830] ហើយមិនបានផ្តល់ស្ថានទម្ងន់សមស្របចំពោះ

---

[824] ឯកសារ ឯកសារ D219/346 កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ទន់ ស៊ួន ឆ.៥០ ERN 01102937។

[825] ឯកសារ ឯកសារ D1.3.11.56 បទសម្ភាសន៍របស់សហព្រះរាជអាជ្ញាអន្តរជាតិជាមួយ ទន់ ស៊ួន EN 00219281។

[826] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៦៧។

[827] ដូចយោងខាងលើ កថាខណ្ឌ ៤៦៣។

[828] ដូចយោងខាងលើ កថាខណ្ឌ ៤៥៦-៤៥៧។

[829] ដូចយោងខាងលើ។

[830] ខាងលើ កថាខណ្ឌ ២៥៣។ ឯកសារ ឯកសារ D118/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១០ ERN 00968069។

ភ័ស្តុតាងរបស់គាត់ដែលថា "ខ្ញុំមិនបានឃើញមានរឿងអ្វី កើតឡើងនោះទេ"[831] ហើយដែលផ្ទុយពីភ័ស្តុតាងរបស់គាត់អំពីការចោទប្រកាន់ចំពោះហេតុការណ៍មួយនេះ[832]។ គាត់មិនស្គាល់អត្តសញ្ញាណរបស់ កម្មាភិបាលខ្មែរក្រហម អំពីបញ្ហាដែលពួកគេបានចេញ ឬមុខងាររបស់មន្ទីរសន្តិសុខឡើយ ហើយបាននិយាយថា គាត់ "មិនដឹង" ថា "ទិត" មានតួនាទីអ្វីទេ នៅក្នុងស្រុកគិរីវង់[833]។ ប្រភពនៃភ័ស្តុតាងរបស់គាត់ដែលថា "ទិត តុម បូ នៅពីលើវត្តព្រះធាតុ" មិនច្បាស់លាស់ ហើយមិនបានឆ្លើយតប ជាមួយពេលវេលាដែលគាត់ នៅក្នុងគុកនៅឆ្នាំ១៩៧៣ ទេ[834]។

២៦១. ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីបញ្ហា "វះពោះ" អ្នកទោស ផ្អែកលើការវិភាគរបស់គាត់ទៅលើភ័ស្តុតាងរបស់ ដុក ចាន់ ដែលថា លោក យឹម ទិត្យ បានចូលរួមកិច្ចប្រជុំថ្នាក់ស្រុក ជាមួយតាព្រីងប្រធានវត្តព្រះធាតុ[835]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាថា ដុក ចាន់ មិនបានផ្តល់ភ័ស្តុតាងអំពីតួនាទីរបស់លោក យឹម ទិត្យ អំពីខ្លឹមសារនៃរបាយការណ៍របស់ តាព្រីង អំពីពេលវេលា និងភាពញឹកញាប់ ថាតើរបាយការណ៍ជាទម្រង់លាយលក្ខណ៍អក្សរឬយ៉ាងណា ឬអំពីបញ្ហាអ្វីដែលតាព្រីង ត្រូវបានតម្រូវឱ្យរាយការណ៍ទៅ

---

[831] ឯកសារ ឯកសារ D219/55 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ERN 01034061-01034063 ឆ.៧-ឆ.១១។

[832] ឯកសារ ឯកសារ D1.3.11.18 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន EN 00217607 ("គេវះយកប្រម៉ាត់ពីអ្នកដែលត្រូវបានគេសម្លាប់។ [តាតុំ] និងបូ មកយកប្រម៉ាត់ រាប់រយប្រម៉ាត់។ ទិត្យ មកយូរៗម្តងតែប៉ុណ្ណោះ")។ ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២២ ERN 00788831៖ ("ស.៖ តើលោកបានឃើញតាទិត មកគុកនេះប៉ុន្មានដងដែរ? ឆ.២២៖ ខ្ញុំបានឃើញមកទីនេះប្រហែលជាជាង ១០ ដង ព្រោះជាដំណាក់កាលសម្លាប់ច្រើន")។ ឯកសារ ឯកសារ D219/55 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១០ ERN 01034062៖ ("ក្នុងពេលលោកជាប់ឃុំនៅក្នុងគុកវត្តព្រះធាតុ តើលោកឃើញតាទិត្យ នៅទីនោះ ប៉ុន្មានដង ពេលដែលគេយកអ្នកទោសទៅសម្លាប់យកប្រម៉ាត់? ឆ.១០៖ តាទិត្យមកតែម្តងទេ គឺនៅពេលដែលអ្នកទោស ៣០ នាក់ ត្រូវបានគេវះពោះយកប្រម៉ាត់")។ ឯកសារ ឯកសារ D219/55 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.២០ ERN 01034064៖ ("ក្នុងសំណួរទី៤៨ គេសួរលោកថា "តើលោកបានជួបតាទិត្យប៉ុន្មានដង កាលលោកនៅគុកវត្តព្រះធាតុ" ហើយលោកឆ្លើយថា "ខ្ញុំបានជួបគាត់ពីរដង។ តាទិត្យ មកគុកព្រះធាតុប្រហែល ៣ ឬ ៤ ខែ ហើយឆ្នាំក្រោយមកម្តងទៀត"។ តើលោកអាចបញ្ជាក់ប្រាប់យើងអំពីរឿងនេះបន្ថែមទៀតបានទេ? ឆ.២០៖ ខ្ញុំចង់បញ្ជាក់ប្រាប់ថា តាទិត្យ មកយកប្រម៉ាត់ពីគុកតែម្តងទេ ហើយម្តងទៀតដែលខ្ញុំបានជួបគាត់ គឺនៅក្នុងភូមិក្បាលដំរីដែលស្ថិតនៅជិតវត្តព្រះធាតុនោះដែរ")។

[833] ឯកសារ ឯកសារ D105/6 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១២ ERN 00788829៖ ("លោកចាំទេថាតើ តាទិត មានតួនាទីអ្វីនៅក្នុងស្រុកគិរីវង្សនេះដែរឬទេ? ឆ.១២៖ ខ្ញុំមិនដឹងទេ ព្រោះខ្ញុំមិនបានចូលរួមជាមួយគេទេ [...]")។

[834] ឯកសារ D1.3.11.18 កំណត់ហេតុស្តាប់ចម្លើយ ហោ យ៉ន EN 00217606-7។

[835] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៣៩, ៤៥៩, ៤៦៣-៤៦៩។

គណៈកម្មាធិការស្រុកគិរីវង់[836]។ មិនមានភស្តុតាងលម្អិតអំពីថាតើ ដុក ចាន់ អាចដឹងបានដោយរបៀបណាអំពីរចនាសម្ព័ន្ធរាយការណ៍លម្អិត នៅវត្តព្រះធាតុ នៅក្នុងបរិបទនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈសម្ងាត់។

២៦២. ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការចោទប្រកាន់ពីបញ្ហា "វះពោះ" អ្នកទោស ក៏ផ្អែកផងដែរទៅលើ ការសម្រេចរបស់គាត់អំពីឋានានុក្រមបញ្ជាការ នៅស្រុកគិរីវង់ទៅលើវត្តព្រះធាតុ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា "ប្រធានគុកជាអ្នករាយការណ៍ អំពីចម្លើយដែលត្រូវបានកត់ត្រា ក្នុងពេលសួរចម្លើយ ទៅគណៈកម្មាធិការស្រុក ហើយរបាយការណ៍ទាំងនោះ គឺជាមូលដ្ឋានសម្រាប់ធ្វើការសម្រេចដោះលែង"[837]។ មូលដ្ឋាននៃការសម្រេចត្រឹមតែសក្ខីកម្មពីរបីជួររបស់ ហុក ចន និងកាលបរិច្ឆេទ នៃការជាប់ឃុំឃាំងរបស់ ហោ យ៉ន ដែលមិនច្បាស់លាស់នោះ[838]។ ដោយប្រឈមមុខជាមួយការមិនមានភស្តុតាងគ្រប់គ្រាន់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់សំអាងហេតុថា "នៅពេលដែល យឹម ទិត្យ បានទៅពិនិត្យមើលមន្ទីរសន្តិសុខនោះ សាក្សី ហោ យ៉ន ទំនងជាជាប់ឃុំនៅវត្តព្រះធាតុ ក្នុងឆ្នាំ១៩៧៧ ឬ ឆ្នាំ១៩៧៨"[839]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាថា ការសម្រេចរបស់គាត់អំពីការចុះពិនិត្យរបស់លោក យឹម ទិត្យ ដោយផ្ទាល់ ផ្អែកលើការបកស្រាយដោយមិនត្រឹមត្រូវចំពោះភស្តុតាងរបស់ ហោ យ៉ន ដែលធ្វើឲ្យការនេះទៅជា មូលហេតុវិលទៅវិលមក និងប្រឆាំងខ្លួនឯង សម្រាប់ការសម្រេចដែលមិនត្រឹមត្រូវថា លោក យឹម ទិត្យ ចុះ "ពិនិត្យយ៉ាងទៀងទាត់"[840]។

២៦៣. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាថា អោក ចន មិនដែលបានឃើញថា លោក យឹម ទិត្យ ចេញបញ្ជាទៅប្រធានគុក ហើយគាត់បាននិយាយថា កម្រិតស្រុកមិនអាចចេញបញ្ជា

[836] ឯកសារ D219/86 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដុក ចាន់ ឆ.៧ ERN 01040104។

[837] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៥១។

[838] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៥ ERN 01110213-01110214 ឆ.៩៤-ឆ.៩៧។

[839] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៥៥។

[840] ហោ យ៉ន ជាប់គុកនៅឆ្នាំ១៩៧៣។ ខាងលើ កថាខណ្ឌ ២៥៣។ឯកសារ D118/155 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ហោ យ៉ន ឆ.១០ ERN 00968069។

ឲ្យសម្លាប់អ្នកទោសបានទេ[841]។ ផ្ទុយទៅវិញ គាត់បាននិយាយថា 'តាទិត្យ' មិនបានចេញបញ្ជា[842] ឡើយ។ អោក ចន បានបញ្ជាក់ថា មិនមែន 'តាទិត្យ' ទេដែលស្ថិតក្នុងតួនាទីជាន់ខ្ពស់ អ្នកដែលមាន តួនាទីធំ គឺ តាតុម[843]។ លើសពីនេះទៀត គាត់បាននិយាយថា គាត់ត្រូវជាប់ខ្នោះនៅក្នុងវត្តព្រះធាតុ នៅក្នុងបន្ទប់មួយដែលគ្មានបង្អួច ហើយមិនច្បាស់ថាតើគាត់ អាចដឹងបានដោយរបៀបណា ថា 'តាទិត្យ' ដើរមើលគុក ឬចេញបញ្ជានោះ[844]។

២៦៤. មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចថា ដោយផ្អែកលើភ័ស្តុតាងរបស់ ហោ យ៉ន លោក យឹម ទិត្យ បានចេញបញ្ជា "វះពោះ" អ្នកទោសនៅវត្តព្រះធាតុ[845] ហើយបានបញ្ជា និងបានបញ្ជូនបញ្ជាបន្ត ឬយ៉ាងហោចណាស់យល់ព្រម ឲ្យសួរចម្លើយ និងសម្លាប់អ្នកទោសនោះ[846]។ ការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលនាំឲ្យមានការរំលោភបំពាន ទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

## ឃ. ការសន្និដ្ឋាន

២៦៥. សម្រាប់សំអាងហេតុដូចបានលើកឡើងខាងលើ ការវាយតម្លៃទៅលើយុត្តាធិការបុគ្គលរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានសុវត្ថិភាពទេ ដោយសារតែកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនផ្សេងគ្នា (១) សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពិចារណាដោយមិនត្រឹមត្រូវថា

---

[841] ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៥៩ ERN 00968094។

[842] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.១១០ ERN 01110215៖ (ស.៖ តើក្រៅពីបញ្ជាឲ្យដោះលែងលោក គាត់មានចេញបញ្ជាអ្វីទៀតទេ? ឆ.១១០៖ អត់ទេ")។

[843] ឯកសារ D219/369 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.១៧ ERN 01110207។ សូមមើលផងដែរ៖ ភ័ស្តុតាងរបស់ លឹម ងេន ដែលនាំឲ្យមានការភ័ន្តច្រឡំចំពោះអត្តសញ្ញាណរបស់លោក យឹម ទិត្យ និងតាតុំ៖ "ប្រជាជនតែងតែហៅបុរសទាំងពីរនាក់ជាគូ" ឯកសារ D219/121 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម ងេន ឆ.១៣ ERN 01047179។

[844] ឯកសារ D118/156 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អោក ចន ឆ.៧៦ ERN 00968096៖ (ស.៖ នៅពេលដែលលោកឃើញតាទិត ចូលទៅក្នុងបន្ទប់ឃុំឃាំងអ្នកទោស ហើយលោកនិយាយថា បន្ទប់ឃុំឃាំងអ្នកទោសគ្មានបង្អួចទេ។ ហេតុអ្វីបានជាលោកដឹងថាអ្នកដែលចូលទៅមើលអ្នកទោសនោះជាតាទិត? ឆ.៧៦៖ ពេលខ្ញុំនៅកន្លែងផលិតស្រុក គឺខ្ញុំស្គាល់គាត់ហើយ។ នៅក្នុងបន្ទប់ឃុំឃាំងពេលថ្ងៃ មិនងងឹតនោះទេ គឺងងឹតតែយប់ប៉ុណ្ណោះ")។

[845] ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កថាខណ្ឌ ៤៥៦-៤៥៧។

[846] ដូចយោងខាងលើ កថាខណ្ឌ ៤៦៣។

ចំណងសាច់ញាតិជាមួយកម្មាភិបាលខ្មែរក្រហមជាន់ខ្ពស់ គឺ តាម៉ុក មានន័យថា លោក យឹម ទិត្យ គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" (២) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសបន្តបន្ទាប់ ក្នុងការសម្រេចរបស់គាត់អំពីតួនាទីផ្លូវការដែលបានចោទរបស់លោក យឹម ទិត្យ ឬសិទ្ធិអំណាចជាក់ស្តែង នៅក្នុងភូមិភាគនិរតី និងភូមិភាគពាយ័ព្យ និងការចោទប្រកាន់ពីសមាជិកភាពរបស់លោក យឹម ទិត្យ នៅក្នុងសហឧក្រិដ្ឋកម្មរួម និង (៣) សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការសម្រេចថា លោក យឹម ទិត្យ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងសហឧក្រិដ្ឋកម្មរួម ក, ខ និង គ។ ដោយផ្អែកលើភ័ស្តុតាង ដែលមាននៅក្នុងសំណុំរឿង មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសម្រេចលើអង្គហេតុថា លោក យឹម ទិត្យ គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ដូច្នេះហើយត្រូវស្ថិតក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ។

## សេចក្តីសន្និដ្ឋាន

២៦៦. សម្រាប់សំអាងហេតុដូចបានលើកឡើងខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសអង្គហេតុ និងអង្គច្បាប់យ៉ាងធ្ងន់ធ្ងរ តាមរយៈការសម្រេចថា លោក យឹម ទិត្យ ជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ កំហុសឆ្គងនេះបើតែមួយមានលក្ខណៈស្លាប់រស់ ហើយបើជារួម បណ្តាលឲ្យមានវិមតិសង្ស័យធ្ងន់ធ្ងរទៅលើការបំពេញកិច្ច ស៊ើបអង្កេតតាមផ្លូវតុលាការទាំងស្រុង។ ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនគួរអាចឈានដល់ដំណាក់កាលនីតិវិធីនៃការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ដោយសារតែកាលៈទេសៈនៃសំណុំរឿង០០៤ បានធ្វើឲ្យលុបលទ្ធភាពណាមួយនៃការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ទីពី ទោះបីជាបែបនេះក្តី នៅពេលដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅតែសម្រេចបញ្ជូនលោក យឹម ទិត្យ ទៅជំនុំជម្រះ គាត់បញ្ជូនរឿងទៅជំនុំជម្រះ ដោយប្រើប្រាស់ឯកសារ ដែលមិនអាចបំពេញបាន សូម្បីតាមលក្ខណៈផ្លូវការមូលដ្ឋានបំផុតសម្រាប់ដីកាបញ្ជូនរឿងទៅជំនុំជម្រះស្របតាមវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ហើយទីបី បទចោទនៅក្នុងឯកសារនោះ មិនបានគោរពទៅតាមវិសាលភាពអង្គហេតុនៃកិច្ចស៊ើបសួរឡើយ។ ទីបួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកដោយមិនត្រឹមត្រូវសម្រាប់ការសម្រេចរបស់គាត់អំពីយុត្តាធិការបុគ្គល ដោយការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួម ដោយចាត់ទុក លោក យឹម ទិត្យ ក្នុងលក្ខណៈខុសប្លែកមិនអាចពន្យល់បានពីជនត្រូវចោទដទៃទៀតរបស់ អ.វ.ត.ក។ ជាចុងក្រោយ ដីកាដំណោះស្រាយរបស់

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទោះជាក្នុងករណីណាក៏ដោយ មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ច្រើន នៅគ្រប់ការសម្រេចនានា ដែលជាមូលដ្ឋាននៃការសន្និដ្ឋានរបស់គាត់ដែលថា លោក យឹម ទិត្យ គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ដោយជាប្រព័ន្ធ មិនបានពិចារណាទៅលើភ័ស្តុតាង និងសក្ខីកម្ម ដោះបន្ទុក ដែលផ្ទុយពីចម្លើយរបស់សាក្សី ដែលគាត់ពឹងផ្អែកទៅលើ ហើយជាប្រព័ន្ធ គាត់មិនបានអនុវត្តគោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ក្នុងករណីដែលភ័ស្តុតាងមិនច្បាស់លាស់ ឬបង្កឲ្យមានការសង្ស័យ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់សំអាងហេតុណាមួយសម្រាប់ការមិនពិចារណាទៅលើភ័ស្តុតាងសំខាន់ៗ ជាច្រើនលើសលប់ក្នុងសំណុំរឿង រួមទាំងសាក្សីពាក់ព័ន្ធ ដែលមិនធ្លាប់ឮអំពីលោក យឹម ទិត្យ ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានព្យាយាមផ្តល់យុត្តិកម្មសម្រាប់ការសម្រេចរបស់គាត់ ដោយយោងទៅ បទដ្ឋាន "ភវនីយភាព" ដែលនៅជាធរមានទេ។

២៦៧. ដោយផ្អែកលើមូលដ្ឋាននៃភ័ស្តុតាង ដែលមាននៅក្នុងសំណុំរឿង មិនមានអ្នកវិនិច្ឆ័យអង្គហេតុ ដែលមានហេតុផលណាម្នាក់ អាចឈានដល់ការសន្និដ្ឋាន ដូចសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា លោក យឹម ទិត្យ គឺជាអ្នក "ទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មនៃរបបកម្ពុជាប្រជាធិបតេយ្យ។ តាមពិតទៅ ការសម្រេចនេះមានភាពអយុត្តិធម៌ និងមិនសមហេតុផលទាល់តែសោះ ដែលបង្កើតជាការរំលោភបំពានទៅលើឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហើយតម្រូវឲ្យអង្គបុរេជំនុំជម្រះបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីជៀសវាងបញ្ហាអយុត្តិធម៌។

២៦៨. ចំពោះសំណូមពរដែលបានស្នើសុំ នៅក្នុង*បណ្តឹងឧទ្ធរណ៍ ប្រឆាំងការចេញដីកាដំណោះស្រាយពីរ* ប្រសិនបើអង្គបុរេជំនុំជម្រះបដិសេធលើសំណើសុំច្រានចោលដីកាដំណោះស្រាយទាំងពីរ សំណើសុំបច្ចុប្បន្នដែលស្នើសុំការបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដោយមានវត្តមាននៃដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចាំបាច់ត្រូវតែធ្វើឲ្យមានការលើកលែងការចោទប្រកាន់ភ្លាមៗប្រឆាំងលោក យឹម ទិត្យ។

## **ដំណោះស្រាយ**

**អាស្រ័យហេតុនេះ** ផ្អែកលើសំអាងហេតុដែលបានលើកឡើងមក មេធាវីការពារក្តីស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះឲ្យប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងដើម្បីជាប្រយោជន៍យុត្តិធម៌៖

(១) សម្រេចថា បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន និង

(២) សម្រេចថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គហេតុ និងកំហុសអង្គច្បាប់ ក្នុងការចោទប្រកាន់បញ្ជូនលោក យឹម ទិត្យ ទៅជំនុំជម្រះ និងសម្រេចច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះទាំងស្រុង និង

(៣) លើកលែងបទចោទប្រកាន់ទាំងអស់ក្នុងសំណុំរឿងប្រឆាំងលោក យឹម ទិត្យ។

សូមលោកចៅក្រម ទទួលយកបណ្តឹងឧទ្ធរណ៍នេះដោយក្តីគោរព។

________________ ____________________

សូ មូស្សេទ្ធី Suzana TOMANOVIĆ

**សហមេធាវីការពារក្តីលោក យឹម ទិត្យ**

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩